UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# លំនាំនៃបញ្ហានិទណ្ឌភាពដែលកំពុងកើតមានជាបន្ត

# នៅក្នុងប្រទេសកម្ពុជា

ខែ តុលា ឆ្នាំ ២០០៥

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១០ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧

# លំនាំនៃបញ្ហានិទណ្ឌភាពដែលកំពុងកើតមានជាបន្ត នៅក្នុងប្រទេសកម្ពុជា
## ខែ តុលា ឆ្នាំ ២០០៥

មាតិកា

អារម្ភកថា


I: សេចក្តីផ្តើម ........ ៤

II: ក្របខ័ណ្ឌអន្តរជាតិ ........ ៩

III: បញ្ហានិទណ្ឌភាពក្នុងឆ្នាំ១៩៩៤........ ១៥

IV: សេចក្តីត្រូវការ ដើម្បីកសាងឡើងវិញនូវមូលដ្ឋានគ្រឹះ ........ ២៥

V: ទំរង់នៃបញ្ហានិទណ្ឌភាពរវាងឆ្នាំ១៩៩៥-២០០៥ ........ ២៨

VI: កត្តាផ្សេងៗ ដែលនាំឱ្យកើតមានបញ្ហានិទណ្ឌភាព ........ ៤២

VII: កំលាំងដែលធ្វើការប្រឆាំងនឹងបញ្ហានិទណ្ឌភាព ........ ៦០

VIII: សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ ៦៨

ឧបសម្ព័ន្ធ ក : កំណត់សំគាល់អំពីប្រភពផ្សេងៗ ........ ៧៥

ឧបសម្ព័ន្ធ ខ : ករណីដោយឡែកផ្សេងៗចំពោះបុគ្គល ........ ៧៩

ឧបសម្ព័ន្ធ គ : សេចក្តីផ្តល់មតិទូទៅលេខ៣១ របស់គណៈកម្មាធិការសិទ្ធិមនុស្ស ........ ៩៩

## អារម្ភកថា

ការជំនះឱ្យបាននូវបញ្ហានិទណ្ឌភាពប្រហែលជាភារកិច្ចដ៏សំខាន់បំផុតតែមួយគត់ ដែលប្រទេសកម្ពុជាកំពុងប្រឈមមុខនាពេលបច្ចុប្បន្ននេះ ។

របាយការណ៍នេះ សរសេរពីទំរង់ និងគំរូផ្សេងៗនៃនិទណ្ឌភាព ដែលលោកតំណាងពិសេសគ្រប់រូបរបស់លោកអគ្គលេខាធិការអ.ស.ប.ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងអ្នកជំនាញការដទៃទៀតដែលធ្វើការក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ បានធ្វើការកត់ត្រានៅក្នុងរបាយការណ៍សាធារណៈនានា នៅក្នុងអំឡុងពេលជាងមួយទសវត្សកន្លងមកនេះ ។ អនុសាសន៍ទាំងឡាយដែលលោកតំណាងពិសេសទាំងនោះ និងអ្នកជំនាញការដទៃទៀត បានធ្វើឡើងមានការពាក់ព័ន្ធទៅនឹងវិធានការនានាដែលអាច និងគួរត្រូវបានថ្លែងឡើង ដើម្បីធ្វើការដោះស្រាយ និងបញ្ចប់បញ្ហានិទណ្ឌភាពទាំងនោះ គឺនៅតែត្រូវបន្តចាត់ការតទៅទៀត ។

ការជំនះឱ្យបាននូវបញ្ហានិទណ្ឌភាព គឺទាមទារឱ្យមានការប្តេជ្ញាចិត្តផ្នែកនយោបាយ និងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ពីនាយករដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការប្តេជ្ញាចិត្តពីសំណាក់ទីភ្នាក់ងារជាទ្វេភាគីក្តី និងពហុភាគីក្តី ដែលកំពុងជួយដល់ប្រទេសកម្ពុជា និងប្រជាពលរដ្ឋកម្ពុជា ក្នុងការកសាងស្ថាប័ននានា អោយមានការទទួលខុសត្រូវ និងការកសាងសង្គមប្រជាធិបតេយ្យ និងយុត្តិធម៌មួយ ដែលគ្រប់គ្រងដោយនីតិរដ្ឋ ។

ព័ត៌មានភាគច្រើន ដែលបានបង្ហាញនៅក្នុងឯកសារនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈរួចទៅហើយ ។ យើងមានគោលបំណងរៀបចំរបាយការណ៍មួយ ដែលអាចឱ្យអ្នកអានទូទៅប្រើប្រាស់បាន ។ យើងសង្ឃឹមថារបាយការណ៍នេះ នឹងនាំឱ្យមានការពិគ្រោះនិងពិភាក្សាគ្នានៅក្នុងប្រទេសកម្ពុជាអំពីចរិតលក្ខណៈ និងផលប៉ះពាល់នៃបញ្ហានិទណ្ឌភាព និងរិះរកវិធីដើម្បីបញ្ចប់បញ្ហាទាំងនេះ ។

របាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយច្បិចយកចេញពីរបាយការណ៍ដែលដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស និងមហាសន្និបាតរបស់អង្គការសហប្រជាជាតិជាហូរហែរមក ដែលរបាយការណ៍ទាំងនោះ

ធ្វើឡើងដោយលោកម៉ៃឃើល ឃើប៊ី និង លោកថូម៉ាស់ ហាំម៉ាប៊ើក អតីតតំណាងពិសេស ។ លោកអតីតតំណាងពិសេសបានអានរបាយការណ៍នេះ ហើយយល់ឃើញថា របាយការណ៍នេះពាក់ព័ន្ធដល់ការស៊ើបអង្កេត ការស្វះស្វែងរក និងអនុសាសន៍ដែលលោកទាំងពីរបានធ្វើក្នុងអាណត្តិរបស់លោក ហើយលោកបានយល់ស្របទាំងស្រុងលើឯកសារនេះ។

លោក ភិធើរ លយប្រែកត៍ តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

## *ផ្នែកទី I : សេចក្តីផ្តើម*

កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ លោកនាយករដ្ឋមន្ត្រី ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង លោក ហ៊ុន សែន បានផ្ញើលិខិតមួយច្បាប់ទៅលោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្នើសុំឱ្យលោកជួយក្នុងការនាំខ្លួនមកជំនុំជំរះ ជនទាំងឡាយដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅក្នុងអំឡុងនៃរបបគ្រប់គ្រងរបស់ខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧៥-១៩៧៩។[១] ការស្នើសុំនេះ នាំឱ្យមានកិច្ចដំណើរការផ្នែកនយោបាយ និងច្បាប់ដែលបានធ្វើចប់សព្វគ្រប់នៅក្នុងខែមេសា ឆ្នាំ២00៥ តាមរយៈកិច្ចព្រមព្រៀងមួយ ដែលធ្វើឡើងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីកាត់សេចក្តីនៅចំពោះមុខតុលាការកម្ពុជា។[២] នេះគឺជាជំហានទីមួយ ដែលឈានទៅដល់ការបញ្ចប់បញ្ហានិទណ្ឌភាព ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្រោមរបបគ្រប់គ្រងរបស់ខ្មែរក្រហម ដែលត្រូវបានគេចាត់ទុកថាជាបញ្ហាមួយដែល " វាមិនត្រឹមតែជាកាតព្វកិច្ចខាងសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែវាមានសារៈសំខាន់បំផុតខាងផ្នែកនយោបាយ និងសង្គម ចំពោះប្រជាពលរដ្ឋកម្ពុជាគ្រប់រូប"។

> "តាមរយៈការកំណត់អត្តសញ្ញាណ និងការផ្តន្ទាទោសជនទាំងឡាយដែលបានប្រព្រឹត្តអំពើបំពានផ្សេងៗនោះ ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបនឹងបានយល់ដឹងកាន់តែច្បាស់ថែមទៀត អំពីអតីតកាលរបស់ខ្លួន ហើយនៅទីបញ្ចប់បានដាក់រយៈពេលដ៏ខ្លោចផ្សាបំផុតនេះ និងជនទាំងឡាយដែលទទួលខុសត្រូវចំពោះទង្វើទាំងនេះ ឱ្យនៅពីខាងក្រោយហេតុការណ៍នេះ ហើយរួមគ្នាកសាងអនាគតមួយដែលល្អប្រពៃ និង មានសុខសន្តិភាព។ ការទទួលខុសត្រូវអាចដើរតួនាទីដ៏សំខាន់ក្នុងការទប់ស្កាត់បញ្ហានិទណ្ឌភាពនៅប្រទេសកម្ពុជា ដើម្បីបង្ហាញប្រាប់ជនទាំងឡាយដែលប្រព្រឹត្តល្មើសថា យ៉ាងហោចណាស់ក៏ការផ្តន្ទាទោសមួយអាចធ្វើទៅកើតដែរ និងដើម្បីលើកកំពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអត្ថន័យនៃយុត្តិធម៌ និង នីតិរដ្ឋ។[៣]

---

[១] នាយករដ្ឋមន្ត្រីទាំងពីរ បានធ្វើការស្នើសុំការជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ និងពីសហគមន៍អន្តរជាតិ ក្នុងការនាំខ្លួនមកជំនុំជំរះជនទាំងឡាយដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និង/ឬ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ។

[២] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[៣] *របាយការណ៍របស់ក្រុមអ្នកជំនាញការសំរាប់ប្រទេសកម្ពុជា* A/53/850, ខែកុម្ភៈ ឆ្នាំ១៩៩៩។

របាយការណ៍នេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងបង្ហាញឱ្យឃើញពីលំនាំផ្សេងៗ និងថ្មីៗបំផុត នៃបញ្ហានិទណ្ឌភាពផ្សេងទៀត ដែលលោកតំណាងពិសេសអង្គការសហប្រជាជាតិ និងអ្នកជំនាញការនានា បានកត់ត្រាទុក នៅក្នុងអំឡុងពេលជាងមួយទសវត្សរកន្លងមកនេះ ។ របាយការណ៍នេះ ផ្អែកជាសំខាន់លើរបាយការណ៍នានារបស់លោកតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដាក់ជូនមហាសន្និបាតអ.ស.ប. និងគណៈកម្មការសិទ្ធិមនុស្ស ធ្វើជាមូលដ្ឋានសំរាប់ការពន្យល់ខ្លីៗ អំពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ចាប់ពីពេលដែលរដ្ឋាភិបាលអាណត្តិទីមួយ ត្រូវបានជ្រើសតាំងឡើង តាមរយៈការបោះឆ្នោត តាមបែបប្រជាធិបតេយ្យចូលកាន់ដំណែងនៅក្នុងឆ្នាំ១៩៩៣ លំនាំផ្សេងៗនៃបញ្ហានិទណ្ឌភាព ចាប់ផ្តើមកកើតឡើងតាំងពីពេលនោះមក ហើយនិងកត្តាមួយចំនួនទៀត ដែលជំរុញឱ្យមានបញ្ហានិទណ្ឌភាពនេះ ។[៤] របាយការណ៍នេះ បរិយាយតែអំពីហេតុការណ៍ ដែលបានកើតមានក្នុងរយៈពេលប៉ុន្មានឆ្នាំ ចាប់ពីមានកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ឆ្នាំ១៩៩១ មក ។

និយាយជាសាមញ្ញទៅ បើមានបញ្ហានិទណ្ឌភាពហើយ នោះគឺមិនមានការការពារសិទ្ធិមនុស្សឡើយ ។ បញ្ហានេះកើតមាននៅពេលដែលរដ្ឋមួយខកខានមិនបានបំពេញភារកិច្ចរបស់ខ្លួន ក្នុងការចាប់ជនទាំងឡាយ ដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិ ដែលពួកគេបានប្រព្រឹត្ត ។ របាយការណ៍នេះផ្តោតជាសំខាន់លើបញ្ហានិទណ្ឌភាព ។ ចំពោះការរំលោភសិទ្ធិជាមូលដ្ឋាននានា ក៏ជាបទល្មើស ដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌផងដែរ-ឃាតកម្ម និងការសំលាប់ក្រៅច្បាប់ ដែលជាការរំលោភលើសិទ្ធិរស់រានមានជីវិត គឺជាឧទាហរណ៍យ៉ាងច្បាស់ - ហើយអាជ្ញាធររដ្ឋគួរតែធ្វើការស៊ើបអង្កេត និងដាក់ទណ្ឌកម្ម តាមរយៈការអនុវត្តច្បាប់ព្រហ្មទណ្ឌ ដោយតុលាការឯករាជ្យ ។ ប៉ុន្តែនិទណ្ឌភាពក៏អាចកើតមានផងដែរ ឧទាហរណ៍ ប្រជាពលរដ្ឋក្រីក្រត្រូវបានបណ្តេញតាមទំនើងចិត្ត ចេញពីដី ឬលំនៅដ្ឋានរបស់ពួកគេ ដោយមិនគោរពសិទ្ធិរបស់ពួកគេ ឬដោយមិនបានធ្វើការជួសជុលសំណងការខូចខាត និងដោយមិនមានការដាក់ទណ្ឌកម្ម ចំពោះជនដែលធ្វើការបណ្តេញប្រជាពលរដ្ឋទាំងនោះ ។

និទណ្ឌភាពមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់បុគ្គល ដែលត្រូវគេបដិសេធសិទ្ធិប៉ុណ្ណោះទេ ។ ករណីដែលសកម្មជននយោបាយត្រូវបានគេសំលាប់ នៅមុនពេលបោះឆ្នោត បញ្ហានេះមានផលប៉ះពាល់ដល់សេរីភាពនៃកិច្ចដំណើរការតាមបែបប្រជាធិបតេយ្យ ។ ករណីដែលអ្នកសារព័ត៌មាន ឬអ្នកនិពន្ធកាសែតមួយរូបត្រូវ

---

[៤] សូមមេត្តាមើលកំណត់សំគាល់ស្តីពីប្រភពផ្សេងៗនៅក្នុងឧបសម្ព័ន្ធ ក ។

គេសំលាប់ ឬការិយាល័យសារព័ត៌មានមួយចំនួនត្រូវទទួលរងការវាយប្រហារ នេះគឺជាការក៏រិតដល់សេរីភាពខាងសារព័ត៌មាន និងសេរីភាពខាងការសំដែងមតិ ។ ករណីដែលជនណាម្នាក់ត្រូវបានគេចោទប្រកាន់ពីបទព្រហ្មទណ្ឌដោយអំពើជួញដូរមនុស្ស បានធ្វើការសូកប៉ាន់ព្រះរាជអាជ្ញា ឬចៅក្រមមួយរូប ឱ្យលើកលែងការចោទប្រកាន់ គឺតុលាការពាក់ព័ន្ធបណ្តោយឱ្យមានទង្វើបែបនេះ ។ ករណីដែលនគរបាលធ្វើការញុះញង់ ឬសំរួលឱ្យមានការសំលាប់ដោយហ្វូងមនុស្ស ហើយមិនមានការដាក់ទណ្ឌកម្មណាមួយនោះនគរបាលទាំងនោះ ក្លាយជាអ្នកចូលដៃគ្នាប្រព្រឹត្តបទល្មើស ។ ករណីដែលប្រធានសហជីពមួយរូបត្រូវគេសំលាប់ ហើយជនដែលទទួលខុសត្រូវបានគេចខ្លួន បញ្ហានេះគំរាមកំហែងយ៉ាងខ្លាំងដល់សិទ្ធិខាងការងារ និងសេរីភាពក្នុងការបង្កើតសមាគម ។ មិនតែប៉ុណ្ណោះ វាថែមទាំងបង្កឱ្យមានបរិយាកាសភ័យខ្លាច និងការគាបសង្កត់ដល់សំលេងអ្នកចោទសួរពីគោលនយោបាយ និងការអនុវត្តន៍បច្ចុប្បន្ន ។

ចាប់តាំងពីឆ្នាំ១៩៩៣មក មានតំណាងពិសេសចំនួនបីរូប របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា គឺលោកម៉ៃឃើល ឃើប៊ី ជនជាតិអូស្ត្រាលី លោកថូម៉ាស់ ហាំម៉ាប៊ឺក ជនជាតិស៊ុយអែត និងលោកភីធឺរ ល័យប្រែកត៍ ជនជាតិអូទ្រីស ។ លោកតំណាងពិសេសទាំងបីរូបនេះបានដាក់របាយការណ៍ច្រើនជាង២០ ជូនគណៈកម្មការសិទ្ធិមនុស្ស និងមហាសន្និបាត រួមទាំងរបាយការណ៍មួយចំនួនទៀតទាក់ទងទៅនឹងវិស័យផ្សេងៗទៀត ។ របាយការណ៍នីមួយៗ មានភ្ជាប់ជាមួយនូវអនុសាសន៍ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីដាក់ចេញនូវវិធានការការពារសិទ្ធិមនុស្ស និងលុបបំបាត់បញ្ហានិទណ្ឌភាព ។ កន្លងមក រដ្ឋាភិបាលបានអនុវត្តតាមអនុសាសន៍ទាំងនេះ បានចំនួនតិចតួចបំផុត ។

ក្នុងរបាយការណ៍ ដែលបានសរសេរនៅក្នុងឆ្នាំ១៩៩៩ លោកថូម៉ាស់ ហាំម៉ាប៊ឺក បានកត់សំគាល់ថា "បាតុភូតនៃនិទណ្ឌភាព និង លក្ខណៈជាស្ថាប័នរបស់វា គឺជាឧបសគ្គដ៏ធំបំផុតមួយ ចំពោះកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើតឱ្យមាននីតិរដ្ឋនៅប្រទេសកម្ពុជា ។ ជាអាទិ៍ គឺខ្វះការឆ្លើយតបចំពោះអំពើហឹង្សានយោបាយ ប៉ុន្តែវាបានឆ្លុះបញ្ចាំងឱ្យឃើញផងដែរ នៅក្នុងរបាយការណ៍ស្ទើររាល់ថ្ងៃស្តីពីការរំលោភដោយមន្ត្រីយោធា និងនគរបាលលើប្រជាពលរដ្ឋសាមញ្ញ ក្នុងនោះរួមមានការសំលាប់មនុស្ស អំពើរំលោភសេពសន្ថវៈ ការចាប់ខ្លួនដោយខុសច្បាប់ ឬការចាប់ជំរិតយកប្រាក់ ក៏ដូចជាការវាយដំ និងអំពើហឹង្សាដទៃទៀត ។ ដោយតុលាការខ្វះធនធានមនុស្ស និង ធនធានដទៃទៀត បុគ្គលនានានៅក្នុងកងកំលាំងសន្តិសុខត្រូវបានបំពាក់អាវុធ មានអំណាច និងទទួលបានការការពារ ។ ប្រជាពលរដ្ឋដែលទទួលរងនូវការរំលោភ

សិទ្ធិពីសំណាក់យោធិន ពុំអាចរកយុត្តិធម៌ប្រកបដោយប្រសិទ្ធិភាពបានទេ។ បញ្ហានេះបានធ្វើឱ្យប៉ះពាល់ដល់ខ្លឹមសារនៃយុត្តិធម៌។[៥]

រយៈពេលប្រាំមួយឆ្នាំក្រោយមក លោក ភីថឺរ លយប្រែកតឺ បានរាយការណ៍ថា" បញ្ហានិទណ្ឌភាព គឺជាបុព្វហេតុ និងជាលទ្ធផលដ៏សំខាន់មួយ នៃបញ្ហាសិទ្ធិមនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជា។ នៅក្នុងករិតដ៏សាមញ្ញបំផុតរបស់វា វាឆ្លុះបញ្ចាំងឱ្យឃើញពីភាពដែលគ្មាន ឬមានការពង្រឹងការអនុវត្តន៍ច្បាប់មិនមានប្រសិទ្ធិភាព និងពីភាពដែលគ្មាន ឬមានតុលាការដែលមិនមានប្រសិទ្ធិភាព។ ប៉ុន្តែវាក៏ជាបញ្ហានយោបាយផងដែរ ក្នុងន័យថាកំណែទម្រង់លិទ្ធិប្រជាធិបតេយ្យដែលជំរុញឱ្យមានការទទួលខុសត្រូវនោះ ក៏មានសក្កានុពលអាចនឹងគំរាមកំហែងដល់ការឆ្លៀតឱកាសរកប្រយោជន៍ និងការបង្កើតសណ្តាប់ធ្នាប់ ដែលមានអ្នកធំការពារនៅពីក្រោយខាងសេដ្ឋកិច្ច និងខាងនយោបាយផងដែរ។ ហេតុដូច្នេះហើយ ប្រសិនបើទុកឱ្យបញ្ហានិទណ្ឌភាពនៅកាន់តែយូរកាលណា វាកាន់តែលំបាកក្នុងការបញ្ចប់វាកាលនោះ។ បញ្ហានេះមានជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងអំពើពុករលួយដែលធ្វើឱ្យបាត់បង់ជំនឿទុកចិត្តបន្តិចម្តងៗនៅក្នុងសង្គម។[៦]

ប្រទេសអ្នកផ្តល់ជំនួយ និងទីភ្នាក់ងារអភិវឌ្ឍន៍ជាច្រើនទទួលស្គាល់ថា នីតិរដ្ឋគឺជាបញ្ហាស្នូលសំរាប់ពង្រឹងអភិបាលកិច្ចល្អ ហើយវាគឺជាកត្តាដ៏សំខាន់មួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។[៧] និទណ្ឌភាពគឺជាប្រតិនិក្ខេបបទនៃនីតិរដ្ឋ។ វិធានការក្នុងការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព ដូចបានផ្តល់ជាអនុសាសន៍នៅក្នុងរបាយការណ៍នេះ គឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសុខមាលភាពសេដ្ឋកិច្ចនាថ្ងៃអនាគតរបស់ប្រទេសកម្ពុជា ក៏ដូចជាសំរាប់ការការពារសិទ្ធិមនុស្សផងដែរ។

*ករណីពីរជាការបំភ្លឺ*

*កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០១ មានយុវជនពីរនាក់ ឈ្មោះ ស៊ុង វាសនា និង ឌី ហូរ ត្រូវបាននគរបាលចាប់ខ្លួន ដោយសង្ស័យថាបានប្រព្រឹត្តអំពើប្លន់។ វាសនា ត្រូវបានគេចាប់បញ្ជូនទៅ*

---

[៥] របាយការណ៍លេខ E/CN.4/1999/101, វាក្យខ័ណ្ឌទី៤៥

[៦] របាយការណ៍លេខ E/CN.4/2004/105, វាក្យខ័ណ្ឌទី២៦

[៧] " សារៈសំខាន់នៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គឺជាតឹកតាងបញ្ជាក់ពីការពង្រឹងអភិបាលកិច្ចល្អ ជំរុញការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ " ។ សន្ទរកថាបូកសរុប ដោយសហប្រធាន សម័យប្រជុំក្រុមពិគ្រោះយោបល់លើកទី៧ សំរាប់ប្រទេសកម្ពុជា ខែធ្នូ ឆ្នាំ២០០៤។

*អធិការដ្ឋាននគរបាលខ័ណ្ឌ ៧ មករា ដើម្បីធ្វើការសាកសួរ ។ បន្ទាប់មកនគរបាលបាននាំខ្លួនគាត់ទៅកាន់កន្លែងចាប់ខ្លួន ហើយប្រគល់ឱ្យហ្វូងមនុស្ស ។ គាត់ត្រូវគេវាយរហូតដល់ស្លាប់ ហើយសាកសពរបស់គាត់ត្រូវបានគេយកទៅដុតចោល ។ រូបថតបង្ហាញពីអំពើហិង្សា ដែលគាត់ត្រូវគេសំលាប់ ការដុតបំផ្លាញសាកសពរបស់គាត់ និង ការចូលរួមយ៉ាងសកម្មពីសំណាក់នគរបាលមួយរូបស្លៀកពាក់ឯកសណ្ឋាន ។ ឌី ហួរ ត្រូវបានគេបំបែកចេញ បន្ទាប់មកត្រូវនគរបាលបាញ់សំលាប់ចោល ។ នគរបាលនោះបានអះអាងថា ឌី ហួរ បានព្យាយាមរត់គេចខ្លួន ។ បើតាមលោកតំណាងពិសេសដឹង មិនមានការដាក់ទណ្ឌកម្ម ឬចំណាត់ការណាមួយទៅលើនគរបាលពាក់ព័ន្ធក្នុងករណីនេះឡើយ ។*

*លោក ជួរ ជេត្តារិទ្ធិ៍ គឺជាអ្នកសារព័ត៌មានមួយរូប ។ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៣ គាត់ត្រូវគេបាញ់ត្រូវត្រង់កញ្ចឹងកផ្នែកខាងក្រោយបណ្តាលឱ្យស្លាប់ នៅពេលដែលគាត់ធ្វើដំណើរមកដល់កន្លែងធ្វើការនៅស្ថានីយវិទ្យុតាព្រហ្ម នៅទីក្រុងភ្នំពេញ ។ ស្ថានីយវិទ្យុនេះជាប់ពាក់ព័ន្ធនឹងគណៈបក្សហ៊្វុនស៊ិនប៉ិច ហើយត្រូវបានលោកនាយករដ្ឋមន្ត្រីធ្វើការស្តីបន្ទោស នៅក្នុងអំឡុងពេលមួយសប្តាហ៍មុនពេលកើតហេតុនេះ ។ ខ្មាន់កាំភ្លើងនោះត្រូវគេឌុបគេចខ្លួន ដោយម៉ូតូមួយគ្រឿង ដែលមានគេឃើញជននោះជិះទៅជិះមក១លើផ្លូវនោះជាច្រើនដងនៅព្រឹកថ្ងៃនោះ ។ មនុស្សជាច្រើនជឿថា មន្ត្រីយោធាពីររូប ដែលជាអ្នកទទួលខុសត្រូវចំពោះការសំលាប់នោះ ។ បើតាមលោកតំណាងពិសេសដឹង គឺមិនមានការចាប់ខ្លួនជនល្មើសទេ ។*[៨]

---

[៨] ក្រសួងមហាផ្ទៃបានអះអាងថា ករណីយនេះកំពុងស្ថិតក្នុងការស៊ើបអង្កេត ។ ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ ការឆ្លើយតបទៅនឹងលិខិតលេខ COHCHR/022/ 04.

## *ផ្នែកទីII : ក្របខ័ណ្ឌអន្តរជាតិ*

ការការពារសិទ្ធិមនុស្សនៅកម្ពុជា និងការបញ្ចប់បញ្ហានិទណ្ឌភាព ចំពោះការរំលោភសិទ្ធិមនុស្ស ដែលជាភារៈកិច្ចស្នូលសំរាប់ការការពារនោះ បានក្លាយជាការព្រួយបារម្ភដ៏ធំ នៃសហគមន៍អន្តរជាតិ ចាប់តាំងពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ មក។

នៅក្នុងកិច្ចព្រមព្រៀងទាំងនេះ អាជ្ញាធរកម្ពុជាមានភារៈកិច្ចការពារសិទ្ធិមនុស្ស រួមទាំងសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការការពារសិទ្ធិរបស់ខ្លួន និងដើម្បីធានាមិនឱ្យមានការវិលត្រឡប់មកវិញនូវ "គោល-នយោបាយ និងការអនុវត្តន៍ទាំងឡាយដែលមានពីអតីតកាល"។[៩] ដោយសំគាល់ឃើញថា "ប្រវត្តិដ៏ជូរចត់នាពេលថ្មីៗនេះ ទាមទារឱ្យមានវិធានការពិសេស ដើម្បីធានាការពារសិទ្ធិមនុស្ស" កិច្ចព្រមព្រៀងទាំងនេះបានចែងលំអិតពីបញ្ញត្តិស្តីពីសិទ្ធិមនុស្ស ហើយត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញថ្មី។[១០] គួរដាក់បញ្ចូលផងដែរនូវសេចក្តីប្រកាសស្តីពីសិទ្ធិជាមូលដ្ឋាន។ សិទ្ធិទាំងនេះគួរពង្រឹងការអនុវត្តន៍ដោយតុលាការឯករាជ្យ ហើយ "ជនរងគ្រោះ" គួរតែអាចពង្រឹងសិទ្ធិរបស់ខ្លួន នៅចំពោះមុខតុលាការ។

នៅក្នុងសម័យអន្តរកាលមុនការបោះឆ្នោតឆ្នាំ១៩៩៣ ការជួយឧបត្ថម្ភដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្ស ត្រូវបានផ្តល់ឱ្យដោយអង្គការសហប្រជាជាតិ តាមរយៈអ៊ុនតាក់។[១១] បន្ទាប់ពីការបោះឆ្នោត លោកអគ្គលេខាធិការអ.ស.ប បានតែងតាំងតំណាងពិសេសមួយរូបទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាហើយក៏បានបង្កើតការិយាល័យសិទ្ធិមនុស្សអ.ស.ប មួយប្រចាំនៅកម្ពុជា។ ការិយាល័យនេះមានភារៈកិច្ចតាមឃ្លាំ

---

[៩] កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយដ៏ទូលំទូលាយផ្នែកនយោបាយ នៃជំលោះរបស់ប្រទេសកម្ពុជា មាត្រា១៥។

[១០] ដោយហេតុនេះហើយ ទើបរដ្ឋធម្មនុញ្ញទទួលស្គាល់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិជាមូលដ្ឋាន ក្នុងនោះរួមមាន សិទ្ធិរស់រានមានជីវិត សេរីភាពបុគ្គល សន្តិសុខ សេរីភាពក្នុងការដើរហើរ សេរីភាពខាងសាសនា សេរីភាពក្នុងការប្រជុំ និង សេរីភាពក្នុងការបង្កើតសមាគម រួមទាំងគណៈបក្សនយោបាយ និងសហជីព នីតិវិធីត្រឹមត្រូវ និងសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ការការពារមិនឱ្យមានការដកហូតទ្រព្យតាមទំនើងចិត្ត ដោយគ្មានការទូទាត់សងត្រឹមត្រូវ សេរីភាពរួចផុតពីការរើសអើងពូជសាសន៍ ជាតិពន្ធុ សាសនា ឬភេទ ។ល។ សេចក្តីប្រកាសត្រូវតែស្របជាមួយបទបញ្ញត្តិនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធដទៃទៀត។ ជនរងគ្រោះមានសិទ្ធិស្មើសុំឱ្យតុលាការវិនិច្ឆ័យ និងពង្រឹងការអនុវត្តន៍សិទ្ធិទាំងនេះ "ឧបសម្ព័ន្ធទី៥" គោលការណ៍របស់រដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជា" កថាខ័ណ្ឌទី២ និងទី៥។

[១១] អាជ្ញាធរបណ្តោះអាសន្នអ.ស.ប នៅកម្ពុជា (អ៊ុនតាក់)។ អ៊ុនតាក់ មានភារៈកិច្ច "លើកស្ទួយបរិស្ថាន" ដែលក្នុងនោះមានការធានាដល់ការគោរពសិទ្ធិមនុស្សផងដែរ។

មើលការពារ និងមានមុខងារធ្វើសេចក្តីរាយការណ៍ជាសាធារណៈ ជាមួយនឹងកម្មវិធីជំនួយបច្ចេកទេស និងសេវាប្រឹក្សាយោបល់ ។ [១២]

ក្នុងឆ្នាំ១៩៩២ ប្រទេសកម្ពុជាបានបោះជំហានជាផ្លូវការមួយឆ្ពោះទៅរកការអនុវត្តន៍ភារៈកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅពេលដែលប្រទេសនេះបានចូលជាសមាជិកនៃសន្ធិសញ្ញាអន្តរជាតិសំខាន់ៗចំនួនប្រាំមួយ ដែលបានផ្តល់អំណាចតាមផ្លូវច្បាប់ដល់សិទ្ធិទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។ [១៣] ការធ្វើដូច្នេះ ប្រទេសកម្ពុជាមានកាតព្វកិច្ច ចំពោះប្រជាពលរដ្ឋរបស់ខ្លួន និង ចំពោះរដ្ឋភាគីដទៃទៀតផងដែរ ក្នុងការគោរព និងការពារសិទ្ធិជនគ្រប់រូបនៅក្នុងប្រទេស ។

ក្នុងនាមជារដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ ប្រទេសកម្ពុជាក៏ស្ថិតនៅក្រោមកាតព្វកិច្ចទូទៅ ក្នុងការអនុវត្តន៍សេចក្តីសំរេចចិត្តរបស់មហាសន្និបាត និង សេចក្តីសំរេចចិត្តរបស់គណៈកម្មការសិទ្ធិមនុស្សទាក់ទងនឹងឯកសារសិទ្ធិមនុស្ស ក៏ដូចជាក្នុងការគោរពក្រមសីលធម៌ជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតបទដ្ឋានដទៃទៀត ។ [១៤]

វិបាកមួយនៃបណ្តុំទំនាក់ទំនងអន្តរជាតិដ៏ស្មុគស្មាញនេះគឺច្បាប់ គោលនយោបាយ និងការអនុវត្តន៍នានារបស់កម្ពុជា មានការខកខានក្នុងការគោរពសិទ្ធិមនុស្ស ការខកខាននេះ គឺជាកង្វល់ស្របច្បាប់របស់

---

[១២] អាណត្តិរបស់ការិយាល័យប្រចាំកម្ពុជា និងអាណត្តិរបស់តំណាងពិសេស របស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ត្រូវបានកំណត់នៅក្នុងសេចក្តីសំរេចចិត្តរបស់គណៈកម្មការសិទ្ធិមនុស្សអ.ស.ប ឆ្នាំ១៩៩៣/៦ ។ បច្ចុប្បន្ន ការិយាល័យនេះស្ថិតក្រោមការដឹកនាំរបស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ។

[១៣] សន្ធិសញ្ញាទាំងនោះ រួមមាន : កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌, អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោឃៅអមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស , អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍,អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ, អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។

[១៤] ឯកសារទាំងនោះ រួមមាន បញ្ញត្តិជាបទដ្ឋានអប្បបរិមាសំរាប់គ្រប់គ្រងអ្នកទោស, បទវិន័យចំពោះភ្នាក់ងារទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់, គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ, គោលការណ៍គ្រឹះសំរាប់ការការពារជនគ្រប់រូប ស្ថិតក្រោមទំរង់គ្រប់បែបយ៉ាងនៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ, គោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង ឬអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ ។

សហគមន៍អន្តរជាតិ និងរដ្ឋជាសមាជិករបស់អ.ស.ប ដទៃទៀត។

ច្បាប់ គោលនយោបាយ និងការអនុវត្តន៍ទាំងនេះ ត្រូវបានតាមឃ្លាំមើល ម្យ៉ាងដោយលោកតំណាងពិសេស ដែលបានរាយការណ៍ទៅមហាសន្និបាត និងគណៈកម្មការសិទ្ធិមនុស្ស ហើយម្យ៉ាងទៀតដោយស្ថាប័នជំនាញខាងសិទ្ធិសញ្ញា ដែលត្រួតពិនិត្យមើលការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សរបស់រដ្ឋភាគី។ ក៏ដូចជាការឃ្លាំមើលវិធានការទាំងឡាយ ដែលចាត់ឡើងដោយប្រទេសកម្ពុជា ហើយជារឿយៗ តែងមានការខកខានក្នុងការចាត់វិធានការ ដើម្បីការពារសិទ្ធិមនុស្ស គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម និង ស្ថាប័នសន្ធិសញ្ញាដទៃទៀត ធ្វើអនុសាសន៍ជាច្រើន ដើម្បីឱ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការ។[១៥] ទីភ្នាក់ងារអ្នកផ្តល់ជំនួយ និងរដ្ឋាភិបាលដែលផ្តល់ជំនួយបច្ចេកទេស សំរាប់ការកសាងសមត្ថភាពក្នុងវិស័យច្បាប់ និងប្រព័ន្ធយុត្តិធម៌ ទទួលស្គាល់ពីទំនាក់ទំនងយ៉ាងជិតស្និទ្ធវាងនីតិរដ្ឋ និងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងធ្វើការពិនិត្យទៅលើការអនុវត្តន៍ក្នុងវិស័យនេះ។[១៦]

វិបាកមួយទៀតដែលកើតមានក្រោមច្បាប់អន្តរជាតិនោះ គឺប្រទេសកម្ពុជាមិនមានសេរីភាពពេញទីក្នុងការសំរេចអំពីច្បាប់ គោលនយោបាយ និងការអនុវត្តន៍ដែលខ្លួនអនុម័តនោះទេ ដោយបញ្ហាទាំងនេះទំនងជាមានផលប៉ះពាល់ជាអវិជ្ជមាន លើការទទួលបានសិទ្ធិមនុស្ស ឬជំរុញឱ្យមានបញ្ហានិទណ្ឌភាព។

តាមរយៈការចូលជាសមាជិកនៃសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើន ប្រទេសកម្ពុជាមានភារៈកិច្ច "គោរព និង ធានា" សិទ្ធិមនុស្សគ្រប់រូបដែលរស់នៅលើទឹកដីរបស់ខ្លួន-បុរស ស្ត្រី និង កុមារដើម្បីធានាថាសិទ្ធិរបស់ ពួកគេត្រូវបានការពារនៅក្នុងច្បាប់ និងគោលនយោបាយជាតិ។ នេះមានន័យថា ប្រទេសកម្ពុជាត្រូវចាត់វិធានការចាំបាច់ដើម្បីធ្វើឱ្យច្បាប់ និងការអនុវត្តន៍ក្នុងស្រុកស្របទៅនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ កតិកា សញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តំរូវឱ្យចាប់ជនរំលោភសិទ្ធិមនុស្ស

---

[១៥] សូមមើលឧទាហរណ៍ CCPR/C/79/Add.108.

[១៦] ធាតុផ្សំផ្សេងៗនៃនីតិរដ្ឋ ឧទាហរណ៍ ដែលធនាគារពិភពលោកបានសំគាល់ឃើញមាន: (ក)រដ្ឋាភិបាលខ្លួនឯងផ្ទាល់មានភារកិច្ចត្រូវអនុវត្តច្បាប់ (ខ)ជនគ្រប់រូបនៅក្នុងសង្គមមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ (គ)សេចក្តីថ្លៃថ្នូរជាមនុស្សរបស់ជនគ្រប់រូបត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់ និង (ឃ)យុត្តិធម៌ត្រូវតែមាននៅក្នុង*រាល់គំនិតផ្តួចផ្តើមទាំងអស់ ក្នុងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌* ដោយធនាគារពិភពលោក ឆ្នាំ២០០៤ ទំព័រទី២។

ឱ្យទទួលខុសត្រូវ ចំពោះទង្វើរបស់ខ្លួន ឧទាហរណ៍ នៅចំពោះមុខតុលាការឯករាជ្យ និងមិនលំអៀង ហើយដើម្បីធានាថាជន រងគ្រោះទទួលបានសំណងការខូចខាតដ៏សមរម្យ ។ កាតព្វកិច្ចខាងផ្លូវច្បាប់ទាំងនេះ អនុវត្តចំពោះគ្រប់ ស្ថាប័នទាំងអស់របស់រដ្ឋាភិបាល ដូចជា ស្ថាប័ននីតិប្រតិបត្តិ នីតិបញ្ញត្តិ និង តុលាការ ។ គេតម្រូវឱ្យរដ្ឋ នីមួយៗ ធានាការពារជនគ្រប់រូប ពីអំពើរំលោភផ្សេងៗដែលប្រព្រឹត្តឡើងមិនត្រឹមតែដោយមន្ត្រីយោធា និងនគរបាលប៉ុណ្ណោះទេ តែថែមទាំងដោយវិស័យឯកជន សាជីវកម្ម ពាណិជ្ជកម្ម និងអ្នកជួញដូរមនុស្សក៏ដូចជាបុគ្គលិករដ្ឋនានា កាលបើពួកគេបានចូលរួម ឧទាហរណ៍ ក្នុងការសំលាប់ដោយហ្វូងមនុស្ស ។

និទណ្ឌភាពផ្ទុយគ្នាទៅនឹងការទទួលខុសត្រូវ ។ និទណ្ឌភាពកើតមាននៅពេលដែលជនទាំងឡាយដែលប្រព្រឹត្តអំពើរំលោភរួចផុតពីការផ្តន្ទាទោសហើយមិនត្រូវបានចាប់ឱ្យទទួលខុសត្រូវនៅក្នុងចំណាត់ការណាមួយ ទោះជាការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ស៊ីវិល រដ្ឋបាល ឬខាងវិន័យ ឬចាប់ឱ្យទទួលទណ្ឌកម្មណាមួយ ហើយមិនមានការជួសជុលសំណងការខូចខាតដល់ជនរងគ្រោះក៏ទេដែរ ។[១៧]

សិទ្ធិមនុស្សជាមូលដ្ឋានដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមមានៈ សិទ្ធិរស់រានមានជីវិត សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម ឬជាកម្មវត្ថុនៃការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប សិទ្ធិសេរីភាព និងសន្តិសុខបុគ្គល សេរីភាពរួចផុតពីការចាប់ខ្លួន និងឃុំខ្លួនតាមទំនើងចិត្ត សិទ្ធិសេរីភាពខាងគំនិត មនសិកា សាសនា និងមតិយោបល់ និងសិទ្ធិចូលរួមក្នុងសវនាការត្រឹមត្រូវ និងសាធារណៈ ធ្វើឡើងដោយសាលាជំរះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង បង្កើតឡើងដោយច្បាប់ ដែលធានានូវនីតិវិធីត្រឹមត្រូវ ។ ការធានានីតិវិធីត្រឹមត្រូវនេះទាមទារ យ៉ាងហោចណាស់ ក៏ត្រូវជូនដំណឹងដល់សាមីជនបានដឹងឱ្យបានយ៉ាងឆាប់រហ័ស

---

[១៧] និទណ្ឌភាពត្រូវបានគេកំណត់ថាជា " ការមិនអាចធ្វើទៅបាន តាមព្រឹត្តន័យ ឬតាមនីតិន័យ ក្នុងការចាប់ជនប្រព្រឹត្តល្មើសឱ្យទទួលខុសត្រូវ - ទោះជានៅក្នុងចំណាត់ការខាងព្រហ្មទណ្ឌ ស៊ីវិល រដ្ឋបាល ឬខាងវិន័យក្តី - ដោយហេតុថាពួកគេមិនមែនជាកម្មវត្ថុនៃការសាកសួរ ដែលអាចឈានទៅដល់ការចោទប្រកាន់ ការចាប់ខ្លួន ការជំនុំជំរះ ហើយប្រសិនបើគេរកឃើញថាមានពិរុទ្ធភាពពិតមែននោះ គឺត្រូវផ្តន្ទាទោសទៅតាមទោសបញ្ញត្តិសមស្រប និងដើម្បីធ្វើការជួសជុលសំណងការខូចខាតទៅជនរងគ្រោះ E/CN.4/2005/102/Add.1 របាយការណ៍របស់លោក Diane Orentlicher អ្នកជំនាញការឯករាជ្យ ក្នុងការធ្វើបច្ចុប្បន្នភាពសំណុំគោលការណ៍ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហានិទណ្ឌភាព - *សំណុំគោលការណ៍នានាដែលបានធ្វើបច្ចុប្បន្នភាព សំរាប់ការការពារ និងការលើកស្ទួយសិទ្ធិមនុស្សតាមរយៈសកម្មភាពប្រយុទ្ធប្រឆាំងនឹងបញ្ហានិទណ្ឌភាព ។*

បំផុតពីបទចោទប្រកាន់មកលើខ្លួន អនុញ្ញាតឱ្យជននោះ រកអ្នកតំណាងតាមការជ្រើសរើសរបស់ខ្លួន ការជំនុំជំរះមិនត្រូវអូសបន្លាយពេលវេលាដែលមិនចាំបាច់ ជំនួយផ្នែកច្បាប់ អាចពិនិត្យសាក្សី មានសិទ្ធិប្តឹងឧទ្ធរណ៍សេចក្តីសំរេចកាត់ទោស ឬផ្តន្ទាទោសទៅតុលាការជាន់ខ្ពស់ ។

ច្បាប់សិទ្ធិមនុស្សអន្តរជាតិបានកំណត់ពីវិធានការនានា ដែលរដ្ឋភាគីត្រូវចាត់ឡើង តាមរយៈនគរបាល មន្ត្រីអនុវត្តច្បាប់ដទៃទៀត និងតុលាការរបស់ខ្លួន ដើម្បីការពារសិទ្ធិ និងធ្វើការទប់ស្កាត់បញ្ហានិទណ្ឌភាព ។ មានកាតព្វកិច្ចមួយក្នុងការស៊ើបអង្កេតនូវឧប្បត្តិហេតុទាំងឡាយ ដែលអាចពាក់ព័ន្ធដល់ការរំលោភសិទ្ធិជាមូលដ្ឋាន ។ ប្រសិនបើការស៊ើបអង្កេតនោះបង្ហាញថា មានអំពើរំលោភកើតឡើង រដ្ឋាភិបាលត្រូវធានាថា ត្រូវនាំខ្លួនជនដែលទទួលខុសត្រូវទៅតុលាការ ។ ការខកខានមិនបានធ្វើការស៊ើបអង្កេត និងការខកខានមិនបានចាប់ជនល្មើសឱ្យទទួលខុសត្រូវ អាចនាំឱ្យកើតមានការរំលោភមួយផ្សេងទៀត នៅក្នុងរដ្ឋ និងដោយរដ្ឋខ្លួនឯងផ្ទាល់ ទៅនឹងកតិកាសញ្ញា ។

ការនិយាយដូច្នេះមិនមានន័យថា បណ្តាប្រទេសក្រីក្រ ដែលមានច្បាប់ និងប្រព័ន្ធ[១៨] តុលាការនៅទន់ខ្សោយត្រូវតែឆ្លើយតបទៅនឹងការរំលោភសិទ្ធិ តាមរយៈនីតិវិធីច្បាប់មួយដ៏ស្មុគស្មាញនោះទេ ប៉ុន្តែត្រូវតែធ្វើការស៊ើបអង្កេត និងដាក់ទណ្ឌកម្ម ព្រមទាំងចាត់វិធានការខ្លះ ដើម្បីទប់ស្កាត់មិនឱ្យអំពើរំលោភទាំងនោះកើតមានឡើង ។

សិទ្ធិ និងភារកិច្ចទាំងនេះ មានលក្ខណៈសាមញ្ញ និងងាយស្រួលយល់បំផុត ចំពោះការរំលោភសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលតាមធម្មតា គេចាត់ទុកវាថាជា បទល្មើសព្រហ្មទណ្ឌក្រោមច្បាប់ជាតិ ហើយវាក៏ជាការរំលោភសិទ្ធិមនុស្ស ក្រោមច្បាប់អន្តរជាតិផងដែរ ។ ឧទាហរណ៍ជាក់ស្តែងបំផុតនោះគឺ ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបការបាត់ខ្លួនដោយបង្ខំ និងការសំលាប់ភ្លាមៗ ព្រមទាំងការសំលាប់ក្រៅច្បាប់ ដែលរំលោភលើសិទ្ធិរស់រានមានជីវិត ។ វាកើតឡើងនៅពេលដែលមន្ត្រីសាធារណៈ ឬភ្នាក់ងាររដ្ឋបានប្រព្រឹត្តរំលោភលើសិទ្ធិទាំងនេះ ច្បាប់អន្តរជាតិមិនអនុញ្ញាត -ហាមឃាត់ដាច់ខាត- អាជ្ញាធរជួយសំរាលជនល្មើសពីការទទួលខុសត្រូវផ្ទាល់ខ្លួនឡើយ ។ ម្យ៉ាងវិញទៀត ដោយសារតែពួកគេជាមន្ត្រី ឧទាហរណ៍ ជានគរបាល ឬនាយទាហានមិនអាច

---

[១៨] សូមមេត្តាមើល អនុផ្នែកទី៤-៦ នៃផ្នែកទី៦ ។

ធ្វើការដោះសារពីនិទណ្ឌភាពរបស់ខ្លួន ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់បានឡើយ ។[១៩] ប៉ុន្តែវាមានបញ្ហានិទណ្ឌភាពដដែល ឧទាហរណ៍ អំពើពុករលួយមិនអាចគ្រប់គ្រងបាន និង/ឬ កម្រមានឱសថសំរាប់ព្យាបាល ដែលអាចធ្វើការបង្វែរពីសេចក្តីត្រូវការបំផុត ដោយគ្មានការត្រួតពិនិត្យ និងការទទួលខុសត្រូវ ឬដីដែលទទួលបានដោយការរំលោភបំពានច្បាប់ ហើយដែលបណ្តាលឱ្យមានការដកហូតកម្មសិទ្ធិពីប្រជាពលរដ្ឋនៅជនបទ និងការបាត់បង់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ។

មិនមានវិធានការណាមួយ ដែលបានចែងបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីបញ្ចប់បញ្ហានិទណ្ឌភាព ចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងអំពើរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដែលបានប្រព្រឹត្តដោយមេដឹកនាំខ្មែរក្រហម នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ ។ នៅក្នុងគំនិតផ្តួចផ្តើមមួយដាច់ដោយឡែក ប៉ុន្តែស្របគ្នា នៅក្នុងឆ្នាំ១៩៩៧ អាស្រ័យហេតុនេះ លោកតំណាងពិសេសបានជំរុញលើកទឹកចិត្តដល់ប្រទេសកម្ពុជា ស្នើសុំជំនួយអន្តរជាតិ ដើម្បីបញ្ចប់បញ្ហានិទណ្ឌភាព ចំពោះបុគ្គលដែលជាមេដឹកនាំខ្មែរក្រហម ។

---

[១៩] សូមមើលគណៈកម្មាធិការសិទ្ធិមនុស្សទាំងមូល សេចក្តីផ្តល់មតិទូទៅលេខ៣១ *ចរិតលក្ខណៈនៃការទទួលខុសត្រូវតាមផ្លូវច្បាប់ដែលដាក់ឱ្យរដ្ឋភាគីអនុវត្តកតិកាសញ្ញា HRI/GEN/1/Rev.7. សូមជូនភ្ជាប់សេចក្តីផ្តល់មតិនេះ នៅក្នុងឧបសម្ព័ន្ធ គ ។.*

## *ផ្នែកទីIII : : បញ្ហានិទណ្ឌភាពក្នុងឆ្នាំ១៩៩៤*

ក្នុងឆ្នាំ២០០៥ លោក ភីថឺរ លយប្រែកតឹ បានធ្វើសេចក្តីរាយការណ៍ទៅគណៈកម្មការសិទ្ធិមនុស្សស្តីអំពីនិទណ្ឌភាពដែលជាបញ្ហា "ចេះតែមានជាបន្ត" និង "ជាប្រព័ន្ធ" នៅក្នុងប្រទេសកម្ពុជា។ លោកបានអំពាវនាវសុំឱ្យធ្វើការវិភាគពីការរីកចំរើន ចាប់តាំងពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ហើយបានគូសបញ្ជាក់ពីសេចក្តីត្រូវការឱ្យដកស្រង់យកមេរៀនក្នុងអតីតកាលសំរាប់ថ្ងៃអនាគត។ [២០]

មានកត្តាជាច្រើននៃបញ្ហានិទណ្ឌភាព ដែលបានសំគាល់ឃើញ នៅក្នុងរបាយការណ៍ឆ្នាំ២០០៥ ដែលបានរាយការណ៍ដោយអ៊ុនតាក់ នៅក្នុងឆ្នាំ១៩៩៣ នៅពេលអង្គការនេះបានចាកចេញពីប្រទេសកម្ពុជា បន្ទាប់ពីការត្រួតពិនិត្យមើលក្នុងសម័យអន្តរកាលឆ្ពោះទៅកាន់ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ [២១] ហើយជាថ្មីម្តងទៀត ដោយលោក ម៉ៃឃើល ឃីប៊ី នៅក្នុងឆ្នាំ១៩៩៤ នៅក្នុងរបាយការណ៍ដំបូងរបស់គាត់ដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស។ [២២] ដូច្នេះ របាយការណ៍ទាំងនេះ គឺជាចំណុចចាប់ផ្តើមសំរាប់ការវិភាគមួយ។ ទោះបីជារយៈពេលជាងមួយទសវត្សបានកន្លងផុតទៅហើយក្តី របាយការណ៍ទាំងនេះ នៅតែមានសារៈសំខាន់សំរាប់ពិពណ៌នាអំពីសភាពការណ៍ ដែលរដ្ឋាភិបាលកម្ពុជាទើបជាប់ឆ្នោតថ្មីក្នុងឆ្នាំ១៩៩៣ បានប្រឈមមុខ ហើយគេចាត់ទុកជាមូលដ្ឋានគ្រឹះមិនរឹងមាំ ដែលរដ្ឋាភិបាលទំនងជាកសាងឡើងដើម្បីការការពារសិទ្ធិមនុស្ស មូលដ្ឋានគ្រឹះមិនរឹងមាំនេះ ត្រូវតែធ្វើការរុះរើយកចេញទាំងស្រុង ហើយកសាងផែនគ្រឹះមួយថ្មីដែលរឹងមាំ។

អ៊ុនតាក់បានរាយការណ៍ថា ខ្លួនបានឃើញសង្គមមួយខ្វះស្ថាប័នជាមូលដ្ឋាន និងកិច្ចដំណើរការដែលផ្អែកលើការគោរពសិទ្ធិមនុស្ស។ ទាំងនេះរួមមានតុលាការឯករាជ្យ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមួយដែលឯក

---

[២០] សូមមេត្តាអានរបាយការណ៍លេខ E/CN.4/2005/116, ទំព័រទី២ និងកថាខ័ណ្ឌទី៧៧ ។.

[២១] សូមមេត្តាអានទាំងស្រុងនូវរបាយការណ៍ចុងក្រោយរបស់ការិយាល័យផ្នែកសិទ្ធិមនុស្ស ខែកញ្ញា ឆ្នាំ១៩៩៣។ អាណត្តិសិទ្ធិមនុស្សអ៊ុនតាក់ រួមមានកម្មវិធីអប់រំផ្នែកសិទ្ធិមនុស្ស ការតាមឃ្លាំមើលស្ថានការណ៍ទូទៅផ្នែកសិទ្ធិមនុស្ស ការស៊ើបអង្កេតពាក្យបណ្តឹងនានាអំពីការរំលោភសិទ្ធិមនុស្ស និងការចាត់វិធានការសមស្របដើម្បីធ្វើការកែតម្រូវ។ កិច្ចការទាំងនេះ ផ្សារភ្ជាប់ទៅនឹងភារកិច្ចដ៏ចំបងរបស់អ៊ុនតាក់ ក្នុងការរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងការត្រួតពិនិត្យនៅក្នុងសម័យអន្តរកាលឈានដល់ការរៀបចំឱ្យមានរដ្ឋាភិបាលប្រជាធិបតេយ្យ ដូច្នេះពួកគេបានជួបប្រទះនូវអំពើហឹង្សានយោបាយទាក់ទងនឹងការបោះឆ្នោត និងការរិតត្បិតទៅលើសេរីភាពខាងនយោបាយ។

[២២] សូមមេត្តាអានរបាយការណ៍លេខ E/CN.4/1994/73.

រាជ្យ ស្ថាប័នរដ្ឋដែលមានចិរភាព ក៏រិតអប់រំវិជ្ជាជីវៈមួយដែលមានលក្ខណៈទូលំទូលាយ អង្គការក្រៅរដ្ឋាភិបាលជាតិក្នុងស្រុក អាច និងមានបំណងលើកស្ទួយផលប្រយោជន៍របស់សង្គមស៊ីវិល ។ ស្ថាប័នដែលមានស្រាប់ កំពុងរៀបចំបំរុងឈានទៅរកការគ្រប់គ្រងផ្នែកនយោបាយមួយរឹងមាំដោយរដ្ឋដែលប្រើអំណាចផ្តាច់ការដែលគាំទ្រដោយកំលាំងយោធាសកម្ម ហើយមិនមានចេតនាផ្តល់ប្រភពអំណាចដល់អាជ្ញាធរផ្សេងទៀតឡើយ ។ នៅក្នុងវិស័យទាំងឡាយដែលគ្រប់គ្រងដោយរដ្ឋកម្ពុជា គណៈបក្សប្រជាជនកម្ពុជា និង រដ្ឋមានការពាក់ព័ន្ធដោយមានទំនាក់ទំនងក្រៅផ្លូវការតាមរបៀបជាអតិថិជន និងថៅកែ បន្ថែមពីលើការគ្រប់គ្រងគណៈបក្សដែលផ្តើមចេញពីថ្នាក់មជ្ឈឹមរហូតដល់ថ្នាក់មូលដ្ឋានភូមិ ឃុំ ។

តាមប្រវត្តិសាស្ត្រ ប្រព័ន្ធច្បាប់កម្ពុជាផ្អែកលើប្រព័ន្ធច្បាប់បារាំង ប៉ុន្តែបន្ទាប់ពីឆ្នាំ១៩៧៥មក ច្បាប់ និងស្ថាប័ននានា ដូចជាតុលាការ ត្រូវបានលុបបំបាត់ចោល ហើយបញ្ញវន្តជាច្រើនត្រូវបាត់បង់ជីវិត ក្លាយជាពលករនៅតាមជនបទ ឬត្រូវរត់ចោលស្រុក ។ ក្នុងឆ្នាំ១៩៧៩ នៅក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាកាន់អំណាច មានមនុស្សតិចតួចបំផុត ប្រសិនជាមាន ដែលមានការបណ្តុះបណ្តាលខាងច្បាប់ ហើយមិនមានមន្ត្រីអនុវត្តច្បាប់ ដែលបានទទួលការបណ្តុះបណ្តាលអំពីប្រពៃណីនៃនីតិរដ្ឋទេ ។ ការរៀបចំឡើងវិញនូវអត្ថបទច្បាប់មិនត្រូវបានព្យាយាមធ្វើ ម្យ៉ាងដោយសារ "បន្ទាត់ " របបនយោបាយ ហើយម្យ៉ាងទៀតដោយការខ្ចិចខ្ចាំបន្ទាប់ពីរបបគ្រប់គ្រងខ្មែរក្រហម ដែលក្នុងនោះ "ក្រមច្បាប់លំអិតមិនមានសារៈប្រយោជន៍ទេ គឺវាគ្រាន់តែជាមគ្គុទ្ទេសន៍សំរាប់អប់រំផ្នែកសីលធមិតែប៉ុណ្ណោះ ។" [២៣]

នៅក្នុងទសវត្សឆ្នាំ១៩៨០ តុលាការប្រជាជនបដិវត្តន៍ ត្រូវបានបង្កើតឡើងនៅគ្រប់ខេត្តទាំងអស់ ។ ក្រោមរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ តុលាការខេត្តទាំងនេះ មានសមាសភាពចៅក្រមជំនុំជំរះម្នាក់ និងក្រុមប្រឹក្សាប្រជាជនពីររូប ដែលត្រូវបានចាត់តាំងដោយមន្ត្រីបក្សមូលដ្ឋាន ។ ក្រុមប្រឹក្សាប្រជាជនមានសិទ្ធិ និងការទទួលខុសត្រូវស្មើគ្នានឹងចៅក្រម ហើយសេចក្តីសំរេចទាំងអស់ធ្វើឡើងដោយសំលេងភាគច្រើន ។ តុលាការខេត្តត្រូវស្ថិតក្រោមការដឹកនាំ មិនត្រឹមតែដោយតុលាការកំពូលនោះទេ ប៉ុន្តែថែមទាំងស្ថិតនៅក្រោមស្ថាប័នអយ្យការ រដ្ឋសភា និងក្រុមប្រឹក្សារដ្ឋមន្ត្រី ។ នៅមុនពេលសំរេចលើករណីនីមួយៗ គេតម្រូវឱ្យចៅក្រម សុំយោបល់ពីតុលាការកំពូល និង/ឬ ក្រសួងយុត្តិធម៌ ។ មិនមាននីតិវិធីសំរាប់បើកសវនាការបណ្តឹងឧទ្ធរណ៍ជាសាធារណៈ

---

[២៣] របាយការណ៍លេខ E/CN.4/1994/73, ទំព័រទី៧០ កថាខ័ណ្ឌទី២២

ទេ ហើយក៏មិនមានការតម្រូវឱ្យតុលាការកំពូលបញ្ជាក់ហេតុផលអំពីការសំរេចផ្ទុយពីតុលាការខេត្តនោះក៏ទេដែរ ។ "ប្រពៃណីនៃការដាក់ឱ្យតុលាការស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌" នេះ[២៤] បានបង្កើតឱ្យមានលំនាំអកប្បកិរិយា ដែលជាឧបសគ្គសំរាប់អ៊ុនតាក់ ហើយបានបង្ហាញឱ្យឃើញពីការលំបាកធ្វើការកែប្រែសំរាប់រយៈពេលវែង ។

រចនាសម្ព័ន្ធច្បាប់ និងស្ថាប័ន ដែលមានក្នុងឆ្នាំ១៩៩២ គឺជារចនាសម្ព័ន្ធច្បាប់ និងស្ថាប័ន ដែលបានបង្កើតឡើងជាងមួយទសវត្សរកន្លងមកហើយ ។ មិនមានអត្ថបទច្បាប់គ្រប់គ្រាន់ ឬគ្មានទាល់តែសោះ ទាំងច្បាប់រដ្ឋប្បវេណី កិច្ចសន្យា និងទ្រព្យសម្បត្តិ ទាំងច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ វិធានរបស់តុលាការ វិធានភស្តុតាង ឬច្បាប់ការងារ ។ ស្ថាប័នដទៃទៀត ដូចជា នគរបាល និងតុលាការមិនទាន់រៀបចំបានពេញលេញ ឬដំណើរការបានត្រឹមត្រូវនៅឡើយ ។

អ៊ុនតាក់បានវាយតំលៃបញ្ហាយុត្តិធម៌មិនជាមូលដ្ឋាន ថាជាការខូចខាតទាំងស្រុងនៅក្នុងប្រព័ន្ធច្បាប់ ហើយបានចាត់ទុកតុលាការព្រហ្មទណ្ឌ ថាជាចំណុចដែលមានការព្រួយបារម្ភបំផុត ។ អ៊ុនតាក់បានធ្វើសេចក្តីព្រាងច្បាប់ព្រហ្មទណ្ឌអន្តរកាល ជាវិធានការមួយសំរាប់បិទភ្ជិតចន្លោះប្រហោងហើយរំពឹងថានៅពេលដ៏ខ្លីខាងមុខច្បាប់នេះនឹងត្រូវដាក់ជំនួសដោយច្បាប់មួយទៀត ដែលមានលក្ខណៈអចិន្រ្តៃយ៍ជាង ។ តាមរយៈច្បាប់ព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់បានបញ្ចូលសញ្ញាណឯករាជ្យភាព ទៅក្នុងប្រព័ន្ធច្បាប់ ។ មាត្រា១ ចែងថា" ក្រុមចៅក្រមមិនត្រូវនៅក្រោមចំណុះអំណាចនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិ ឬក្រោមភាគីនយោបាយណាឡើយ" ។[២៥]

---

[២៤] លោក ម៉ៃឃើល ឃីប៊ី និយាយសំដៅដល់ការបញ្ជូនរបាយការណ៍របស់តុលាការកំពូលឆ្នាំ១៩៨៩ ទៅរដ្ឋសភា ដែលនៅក្នុងរបាយ-ការណ៍នោះ តុលាការបានផ្តល់មតិថា ខ្លួនគ្មាន " សមត្ថកិច្ចដោះស្រាយ " បណ្តឹងដោយខ្លួនឯងនោះទេ " ហើយថា គេមានសមត្ថកិច្ចត្រឹមតែពិនិត្យលើពាក្យបណ្តឹងប៉ុណ្ណោះ " ដូច្នេះហើយ គេអាចបង្វិលសំណុំរឿងទាំងនោះ ទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីធ្វើការដោះស្រាយ ។ នេះក៏ពីព្រោះតែ យើងយល់ថា ការងារទទួល និងដោះស្រាយពាក្យបណ្តឹង គឺជាបញ្ហាមនោគមវិជ្ជា" ។ របាយការណ៍លេខ E/CN.4/1994/73, ទំព័រទី១៩ ។

[២៥] ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ មាត្រា១ (១) ចែងថា " ឯករាជ្យភាពនៃក្រុមចៅក្រមត្រូវធានាឱ្យមានលក្ខណៈស្របនឹង *គោលការណ៍ជាមូលដ្ឋានស្តីអំពីឯករាជ្យភាពនៃក្រុមចៅក្រម ....* ។ ចៅក្រមទាំងឡាយត្រូវកាត់សេចក្តីតាមភាពមិនលំអៀង ផ្អែកលើហេតុការណ៍ ដែលមាននៅចំពោះមុខ ហើយក្នុងការគោរពច្បាប់ ដោយមិនព្រមទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ដោយចំពោះ ឬមិនចំពោះ អំពីភាគីណាមួយក្នុងរឿងកាត់ក្តី ឬអំពីអ្នកឯទៀតណាក៏ដោយ ។

ប៉ុន្តែ បើតាមការកត់សំគាល់របស់អ៊ុនតាក់ នៅពេលក្រោយមកថា" ការងារអនុម័តច្បាប់តែមួយនេះ មិនអាចធានាឱ្យតុលាការឯករាជ្យបានទេ ។ ទោះបីជាមានក្របខ័ណ្ឌ ដែលច្បាប់បានបង្កើតហើយក្តី ក៏មិនមានការខិតខំប្រឹងប្រែងពិតប្រាកដ ដើម្បីធ្វើឱ្យតុលាការមានការស្របគ្នាទៅនឹងក្របខ័ណ្ឌនោះឡើយ ។ ដូច្នេះ កាលបើតុលាការឯករាជ្យតែខាងបច្ចេកទេសពីស្ថាប័ននីតិប្រតិបត្តិរបស់រដ្ឋាភិបាល តុលាការនៅតែស្ថិតក្រោមបញ្ជាពីនីតិប្រតិបត្តិទាំងស្រុងជាដដែល ។[២៦] រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនបានពន្យល់ប្រាប់អ៊ុនតាក់ថា ចៅក្រមណាដែលមិនគោរពតាមសេចក្តីណែនាំរបស់គាត់ ហើយ "មិនគោរពច្បាប់" ត្រូវទទួលទណ្ឌកម្ម ។ តុលាការក៏បានដំណើរការក្រោមការគាបសង្កត់ពីសំណាក់នគរបាល និងក្រសួងសន្តិសុខជាតិ ។ ឧទាហរណ៍ គេមិនតម្រូវឱ្យនគរបាលចូលរួមក្នុងសវនាការកាត់សេចក្តីអ្នកទោសដែលនគរបាលរូបនោះជាអ្នកចាប់ខ្លួនពួកគេនោះទេ នៅខណៈដែលតុលាការ បានទទួលយកដោយគ្មានការចោទសួរយកព័ត៌មានដែលបានបង្ហាញនៅក្នុងរបាយការណ៍នគរបាល ។ មិនតែប៉ុណ្ណោះ នគរបាលមិនអាចធ្វើការតវ៉ាអំពីភស្តុតាងនេះ ដោយពួកគេមិនមានវត្តមាននៅក្នុងតុលាការ និងមិនអាចសួរដេញដោលសាក្សីបានឡើយ ។

នៅក្នុងអាណត្តិរយៈពេលខ្លីរបស់ខ្លួន អ៊ុនតាក់បានធ្វើការស៊ើបអង្កេតពាក្យបណ្តឹងពីការរំលោភសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយច្រើនជាង១៣០០ករណី ការសំលាប់ពាក់ព័ន្ធនឹងរឿងនយោបាយ និងជាតិពន្ធុ ការចាប់ខ្លួន ការចាប់ពង្រត់ ក៏ដូចជាគំរូផ្សេងៗនៃអំពើរំលោភ ដូចជាការយាយី និងការបំភិតបំភ័យទៅលើគណៈបក្សនយោបាយនានា ដោយនគរបាលមូលដ្ឋាន យោធា ឬអាជ្ញាធររដ្ឋបាល ។ ករណីខ្លះកើតមាននៅក្នុងប្រទេស ក្រោមការត្រួតត្រារបស់រដ្ឋាភិបាលនៃរដ្ឋកម្ពុជា ខណៈដែលករណីខ្លះទៀត កើតមាននៅតំបន់ផ្សេងទៀត នៅខាងក្រៅការត្រួតត្រារបស់រដ្ឋាភិបាល និងគ្រប់គ្រងដោយ ឧទាហរណ៍ កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យជាដើម ។

---

(២) ក្រុមចៅក្រមមិនត្រូវនៅក្រោមចំណុះអំណាចនីតិប្រតិបត្តិ ឬនីតិប្បញ្ញត្តិ ឬក្រោមភាគីនយោបាយណាឡើយ ។ ជនដែលត្រូវជ្រើសរើសអោយបំពេញមុខងារក្នុងតុលាការ ត្រូវតែជាអ្នកសុចរិត និងមានសមត្ថភាពផង ។

(៣) គោលការណ៍ឯករាជ្យភាពនៃក្រុមចៅក្រមប្រគល់សិទ្ធិ និងករណីយកិច្ចជូនចៅក្រម ដើម្បីធានាឱ្យការកាត់ក្តីប្រព្រឹត្តទៅ ក្នុងភាពសុចរិតនិងក្នុងការគោរពដល់សិទ្ធិនៃភាគីដែលត្រូវកាត់ក្តីទាំងអស់ ។ចៅក្រមត្រូវមានលទ្ធភាពបំពេញមុខងារខ្លួនតាមស្ថានភាពសំភារៈសមរម្យ និងគ្រប់គ្រាន់ ។ ចៅក្រម ត្រូវទទួលការហ្វឹកហ្វឺនត្រឹមត្រូវមានប្រាក់បៀវត្សគ្រប់គ្រាន់ ដើម្បីធានានូវភាពឥតល្អៀង និងឯករាជ្យភាពរបស់ពួកគេ ។

[២៦] របាយការណ៍ចុងក្រោយរបស់ផ្នែកសិទ្ធិមនុស្សអ៊ុនតាក់ ខែកញ្ញា ឆ្នាំ១៩៩៣ ទំព័រទី១៦ ។

ដើមឡើយ អ៊ុនតាក់ បានបញ្ចុះបញ្ចូលអាជ្ញាធរកម្ពុជា ឱ្យធ្វើការស៊ើបអង្កេតពាក្យបណ្តឹង និងធ្វើការចោទប្រកាន់ជនទាំងឡាយដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិធ្ងន់ធ្ងរនៅក្នុងតុលាការ ។ ក្នុងខណៈដែលមានប្រសិទ្ធិភាពនៅក្នុងករណីតូចតាចមួយចំនួន អ៊ុនតាក់សង្កេតឃើញមាន "ភាពអល់អែក" ក្នុងការចាត់វិធានការទៅលើមន្ត្រីជាន់ខ្ពស់ ហើយជាពិសេសការចាត់វិធានការលើករណីពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សផ្សេងៗ ។ នៅក្នុងករណីទាំងនេះ អាជ្ញាធររដ្ឋបាលបានធ្វើការបដិសេធមិនព្រមធ្វើការស៊ើបអង្កេត ហើយមន្ត្រីជាន់ខ្ពស់បានសំដែងមតិថា ពួកគេមិនមានសមត្ថកិច្ចទាំងក្នុងការស៊ើបអង្កេត ទាំងក្នុងការចោទប្រកាន់លើបញ្ហាទាំងនេះទេ ។ ខណៈដែលច្បាប់ព្រហ្មទណ្ឌអន្តរកាលបានចែងអំពីក្របខ័ណ្ឌផ្លូវការមួយក្នុងការដោះស្រាយបញ្ហានេះតាមរយៈច្បាប់ព្រហ្មទណ្ឌដែលវាបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ក្នុងការអនុវត្តន៍ជាក់ស្តែងបទល្មើសទាំងនេះមិនអាចធ្វើការចោទប្រកាន់ដោយរដ្ឋអាជ្ញា ដែលបានប្រឈមមុខមិនត្រឹមតែចំពោះការគំរាមកំហែងដោយការជ្រៀតជ្រែកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំឱ្យគ្រោះថ្នាក់ដល់រូបកាយ កាលបើពួកគេតាំងខ្លួនជាដើមបណ្តឹងអាជ្ញា ផ្ទុយទៅនឹងឆន្ទៈរបស់អាជ្ញាធរនយោបាយនានានោះ ។

ផ្ទុយទៅនឹងការរៀបរាប់ពីខាងដើម  ការិយាល័យរដ្ឋអាជ្ញាពិសេសមួយ ត្រូវបានបង្កើតឡើង នៅក្នុងខែមករា ឆ្នាំ១៩៩៣ ។ ដំបូងឡើយ អ៊ុនតាក់សង្ឃឹមថាប្រសិនជាការិយាល័យនេះដំណើរការនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ដោយសារចរិតសាធារណៈនៃការចោទប្រកាន់ វាអាចដើរតួនាទីធ្វើការកែប្រែ " វប្បធម៌ " ច្បាប់ និងមន្ត្រីតុលាការ ។  ការិយាល័យនេះមានអំណាច រួមមាន ធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងមន្ត្រីរាជការ នគរបាល ឬមន្ត្រីយោធានានា នៅក្នុងតុលាការកម្ពុជា ។ ប៉ុន្តែវាបានបង្ហាញពីការដែលមិនអាចធ្វើទៅបាន នៅពេលដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានធ្វើសេចក្តីណែនាំដល់ប្រធានតុលាការក្រុងភ្នំពេញថា គាត់នឹងត្រូវបានផ្តន្ទាទោស ពីការរំលោភច្បាប់ ប្រសិនបើគាត់ជំនុំជំរះករណីរឿងទាំងឡាយណាដែលរដ្ឋអាជ្ញាពិសេសបានបញ្ជូនមកឱ្យខ្លួន ។ ដូច្នេះហើយអ៊ុនតាក់ ត្រូវបង្ខំចិត្តទទួលស្គាល់ថា ខ្លួនមិនអាចចាត់ការករណីទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ នៅក្នុងតុលាការកម្ពុជាបានឡើយ ។

អ៊ុនតាក់បានសំគាល់ឃើញមានឧបសគ្គជាច្រើនទៀត ចំពោះឯករាជ្យភាពរបស់តុលាការ ។ អាជ្ញាធរបានជំទាស់ចំពោះការកំណត់ដែនអំណាចរបស់ខ្លួន ដែលចាំបាច់ត្រូវបង្កើតឱ្យមានតុលាការមួយឯករាជ្យ ហើយមិនមានបំណង ដើម្បីសហការក្នុងការស៊ើបអង្កេត ការចាប់ខ្លួន និងការចោទប្រកាន់ជនទាំងឡាយ ដែលប្រព្រឹត្តរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ។ សមាសភាពរបស់រដ្ឋបាលកម្ពុជា ជាពិសេស កងកំលាំងសន្តិសុខ មាន

ការជាប់ពាក់ព័ន្ធនៅក្នុងអំពើហឹង្សានយោបាយ ។ សមាសភាពទាំងពីរនេះ មានន័យថា តុលាការមិនត្រូវបានគេអនុញ្ញាតឱ្យដំណើរការដោយឯករាជ្យ និងមិនលំអៀងនោះទេ ។ ច្បាប់ និងតុលាការ ជាពិសេស នៅតែត្រូវគេចាត់ទុកជាឧបករណ៍របស់គណៈបក្សនយោបាយកំពុងកាន់អំណាច - ដែលបានពោលអះអាងតែមាត់ នៅក្នុងឱកាសមួយ ប៉ុន្តែលុះក្រោយមក ធ្វើជាមិនដឹងមិនឮ នៅពេលដែលជួបប្រទះការលំបាក ។ លើសពីនេះទៅទៀត នៅក្នុងអំឡុងពេលបោះឆ្នោត ចៅក្រមនៅតាមបណ្តាខេត្តជាច្រើន ត្រូវគេបង្ខំឱ្យឃោសនារកសំលេងឆ្នោតឱ្យគណៈបក្សប្រជាជនកម្ពុជា នៅក្នុងម៉ោងធ្វើការទៀតផង ។

នៅក្នុងរបាយការណ៍ចុងក្រោយរបស់ខ្លួន អ៊ុនតាក់បានធ្វើការសន្និដ្ឋានថា ការដែលអាជ្ញាធររដ្ឋស្របច្បាប់ គ្មានលទ្ធភាពក្នុងការទប់ស្កាត់អំពើហឹង្សាដែលកំពុងនឹងបន្តកើតមាន រួមមានការសំលាប់ក្រៅច្បាប់ និងវប្បធម៌ដែលទាក់ទងនឹងការរីករាលដាលនៃភាពគ្មានច្បាប់ ស្ថិតនៅជាកង្វល់ដ៏ធំជាងដែលខាងសិទ្ធិមនុស្ស ។ ការការពារ និងការលើកស្ទួយសិទ្ធិដទៃទៀត គឺពឹងផ្អែកលើការបង្កើតឡើងវិញនូវរដ្ឋបាលស៊ីវិល និងសណ្តាប់ធ្នាប់សាធារណៈនៅទូទាំងប្រទេស ។ គេជឿថា "អំពើហឹង្សាជាច្រើន ត្រូវបានប្រព្រឹត្តដោយសមាសភាពនគរបាល និងយោធា ការខ្វះការទទួលខុសត្រូវបច្ចុប្បន្នរបស់ពួកគេ និងការបង្កើតឱ្យមានស្វ័យតភាពហើយប្រសិនបើមិនធ្វើការត្រួតពិនិត្យទេនោះ វានឹងបំផ្លាញធ្ងន់ធ្ងរដល់ការរីកចំរើននៃវិស័យដទៃទៀត ។"[២៧]

នៅពេលដែលអ៊ុនតាក់បានបញ្ចប់អាណត្តិ វិធានការចំនួនពីរ ដើម្បីការពារសិទ្ធិមនុស្សត្រូវបានរៀបចំឡើងដោយប្រទេសកម្ពុជា ដែលវិធានការទាំងពីរនេះមានចែងនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស គឺការចូលជាសមាជិកនៃសន្ធិសញ្ញាសិទ្ធិមនុស្សចំនួនប្រាំមួយ និងការអនុម័តរដ្ឋធម្មនុញ្ញថ្មី នៅក្នុងខែកញ្ញា ឆ្នាំ១៩៩៣ ។

រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ធ្វើការខ័ណ្ឌចែកអតីតកាល ដោយការដាក់បញ្ចូលសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀត ។ រដ្ឋធម្មនុញ្ញការពារសិទ្ធិរស់រានមានជីវិត សិទ្ធិធ្វើកូដកម្ម សិទ្ធិចូលរួមធ្វើបាតុកម្មអហឹង្សា សេរីភាពខាងជំនឿសាសនា សេរីភាពក្នុងការសំដែងមតិ និងការបង្កើតសមាគម និងការបង្កើតគណៈបក្សនយោបាយ ។ រដ្ឋធម្មនុញ្ញមិនបានហាមឃាត់ការធ្វើទារុណកម្មប៉ុន្តែបានចែងធានាមិនឱ្យមានការរំលោភលើរាងកាយជាទូទៅ និងការប្រព្រឹត្តឃោរឃៅអមនុស្សធម៌នៅក្នុងពន្ធនាគារ និងនៅ

[២៧] ក្នុងសៀវភៅដដែលទំព័រទី៧០ ។

ក្នុងមន្ទីរឃុំឃាំង ហើយរដ្ឋធម្មនុញ្ញក៏បានចែងផងដែរថា ចំលើយសារភាពដែលបានមកពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពនៅក្នុងតុលាការទេ។ ការរើសអើងត្រូវហាមឃាត់។ មានបញ្ញត្តិដែលចែងអំពីការបែងចែកអំណាច និងឯករាជ្យភាពនៃតុលាការដែលត្រូវ "ការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ"។ ចៅក្រមមិនអាចត្រូវដកពីមុខងារបានទេ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រម ឬព្រះរាជអាជ្ញា ដែលបានប្រព្រឹត្តខុសទាំងនោះបាន។

របាយការណ៍លើកទី១ របស់លោក ម៉ៃឃើល ឃីប៊ី ដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស បានពិពណ៌នាអំពីសភាពការណ៍ដែលលោកបានរកឃើញ។[២៨] នៅពេលដែលលោកបានបញ្ជាក់លើការវិភាគរបស់អ៊ុនតាក់ អំពីការលំបាកផ្សេងៗ នៅក្នុងវិធីការពារសិទ្ធិមនុស្ស[២៩] លោកក៏បានសំគាល់ឃើញថា មានការរីកចំរើនប្រៀបធៀបទៅនឹងរយៈពេលដ៏ខ្លី ចាប់តាំងពីឆ្នាំ១៩៩១មក ទៅនឹងប្រវត្តិសាស្រ្តកន្លងមកថ្មីៗនេះនៃ "ការទទួលរងការឈឺចាប់បំផុតនៃប្រជាពលរដ្ឋរបស់ខ្លួន និងការដកហូតសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ"។ ឧទាហរណ៍ នៃការរីកចំរើននេះ រួមមានរដ្ឋធម្មនុញ្ញថ្មី ការកែលំអការងាររបស់តុលាការមួយចំនួន ការបណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញា និងនគរបាល និងការបង្កើត "ចំនួនកាន់តែកើនឡើងនៃ" អង្គការក្រៅរដ្ឋាភិបាល។ លោកបានផ្តល់មតិអំពី "បំណងប្រាថ្នា និងឆន្ទៈចង់ឱ្យមានការផ្លាស់ប្តូរ" បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ ហើយជាពិសេសគឺ "ការរីកលូតលាស់" នៃសេរីភាពខាងសារព័ត៌មាន "ក្នុងការជឿជាក់ជាថ្មីរបស់ប្រជាជនកម្ពុជាដែលតាមធម្មតាគឺប្រជាពលរដ្ឋនៅតំបន់ជនបទដាច់ស្រយាល ដែលបានធ្វើដំណើរមករាជធានី ដើម្បីសំដែងមតិ ទាមទារសិទ្ធិរបស់ខ្លួន "ហើយជារឿយៗ" មានពាក្យបណ្តឹងជាច្រើនទាក់ទងនឹងការរំលោភដោយមន្រ្តីនានា ដែលគណៈកម្មការសិទ្ធិមនុស្សរដ្ឋសភាបានទទួលរាល់ថ្ងៃ។"

ប៉ុន្តែនៅពេលដែលលោកធ្វើការពិនិត្យឡើងវិញអំពីសភាពការណ៍ទូទៅ លោក ឃីប៊ី បានកត់សំគាល់ឃើញមានបញ្ហាមួយចំនួនទាក់ទងនឹងសន្តិសុខ ដោយសារសង្រ្គាមស៊ីវិលដែលកើតមានជាហូរហែររហូតមក ការបន្សល់ទុកនូវចំការមីន គ្រាប់បែក និងអាវុធជាតិផ្ទុះផ្សេងទៀត ដែលដាក់លក់នៅលើទីផ្សារ ការរំលោភអំណាចដោយយោធា និងនគរបាលមួយចំនួន និងការខ្វះមធ្យោបាយប្រកបដោយប្រសិទ្ធិភាព និងយុត្តិធម៌ក្នុងការដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋ។ បញ្ហាទាំងនេះ គួរតែត្រូវបានគេឃើញនៅក្នុងបរិបទនៃការបំ

[២៨] របាយការណ៍លេខ E/CN.4/1994/73 & A/49/635

[២៩] ដូចរៀបរាប់ខាងលើ។

ផ្ដិចបំផ្លាញស្ទើរតែទាំងស្រុងនូវប្រព័ន្ធយុត្តិធម៌ និងហេដ្ឋារចនាសម្ព័ន្ធនានានៃសង្គមស៊ីវិលដែលចាំបាច់ ដើម្បីទទួលបានសិទ្ធិមនុស្ស និងដើម្បីការពារសិទ្ធិមនុស្ស ។

លោកបានសង្កេតឃើញថា ការពង្រឹងនីតិរដ្ឋ គឺជាមធ្យោបាយមួយនៃការប្រយុទ្ធប្រឆាំងទៅនឹងបញ្ហានិទណ្ឌភាពនៃកងកំលាំងប្រដាប់អាវុធកម្ពុជា ដែលបានបន្តប្រើប្រាស់អំណាចដោយគ្មានការហាមឃាត់យ៉ាងទូលំទូលាយ និងមានប្រសិទ្ធិភាព ក្នុងការចាប់ខ្លួន ឃុំខ្លួន និងការប្រហារជីវិត ដោយមិនគោរពច្បាប់ជាធរមាន រួមទាំងបទបញ្ជាផ្ទៃក្នុងកងទ័ព ក៏ដូចជាច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌ ។ នៅក្នុងផ្នែកជាច្រើននៃផ្ទៃប្រទេស សហគមន៍មូលដ្ឋាននានាដែលត្រូវបានគេដកហូតសិទ្ធិ ដែលត្រូវទទួលបានការការពារតាមរបៀបស៊ីវិលណាមួយនោះ មានបទពិសោធជាប្រចាំថ្ងៃនោះគឺ "ច្បាប់កាំភ្លើង" ។ ជារឿយៗ នគរបាល អាជ្ញាធរស៊ីវិល តុលាការ និងចៅក្រមមានការ "ភ័យខ្លាច និងមិនអាចចាត់វិធានការដ៏មានប្រសិទ្ធិភាព ដើម្បីបង្ក្រាបការអនុវត្តន៍ដោយបំពាន និងតាមទំនើងចិត្តពីសំណាក់យោធា និងនាំខ្លួនពួកគេទៅតាមវិន័យនៃច្បាប់ឡើយ ។"

ទាំងអ៊ុនតាក់ ទាំងលោកឃីប៊ី បានគូសបញ្ជាក់ពីផលប៉ះពាល់នៃបញ្ហានិទណ្ឌភាព តាមរយៈការរាយការណ៍អំពីករណីនីមួយៗ ។

*១- កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ១៩៩៣ នៅស្រុករមាសហែក ខេត្តស្វាយរៀង សមាជិកគណៈបក្សហ៊្វុនស៊ីនប៉ិចមួយរូបឈ្មោះ សឿន សួរ កំពុងសំរាកនៅផ្ទះជាមួយប្រពន្ធគាត់ឈ្មោះ ហុង សួរ និងកូនរបស់ខ្លួន ។ នៅម៉ោងប្រមាណជា ១១:៣០ នាទី មាននគរបាលមូលដ្ឋានម្នាក់ឈ្មោះ នឹម ចាន់ណារិទ្ធិ និងសេនាជនចំនួនពីរនាក់ឈ្មោះ កៅ ឆុង និង ស វីរ បានដើរចូលផ្ទះគាត់ ។ នឹម ចាន់ណារិទ្ធិ ប្រដាប់ដោយអាវុធធុនអាកា ៤៧ ។ ពួកគេបានគំរាមទារយកមាសពីគ្រួសារនេះ ហើយបានវាយ សឿន សួរ នៅចំពោះមុខប្រពន្ធគាត់ ។ សេនាជនម្នាក់បានយកពូថៅកាប់គាត់ ។ បន្ទាប់មកពួកគេបានដាក់ខ្នោះដៃគាត់ទៅក្រោយខ្នង ហើយបានយកកាំភ្លើងបាញ់ជើងគាត់ ។ ក្នុងផ្ទះនោះមានភាពងងឹត ប៉ុន្តែសេនាជនពីរនាក់នោះកាន់ពិល ហើយមានសាក្សីជាច្រើននាក់អាចស្គាល់ពួកគេ ព្រោះអ្នកទាំងនោះរស់នៅក្នុងភូមិជាមួយគ្នា ។ បន្ទាប់ពីបាញ់ សឿន សួរ ហើយ សេនាជនបានវាយក្បាល ហុង សួរ ដោយស្នៀយកាំភ្លើង ។ បុរសទាំងនោះបានធ្វើការឆែកឆេរលើខ្លួននាងរកមាស ។ ប៉ុន្តែពួកគេរកមិនឃើញមាសទេ*

*ពួកគេបានធ្វើការឆែកឆេរ និងបានលួចយកក្រវិលមួយចំហៀង មាន់មួយ និងសំលៀកបំពាក់មួយចំនួនទៀត ។ នៅពេលដែលពួកគេចាកចេញពីផ្ទះនោះ  នឹម ចាន់ណារិទ្ធិ ងាកទៅរក សឿន សួរ ដែលកំពុងដេកដួលលើដីស្រែកឱ្យគេជួយ ហើយបានបាញ់គាត់មួយគ្រាប់ចំក្បាល បណ្តាលឱ្យស្លាប់ភ្លាមមួយរំពេច ។ អ្នកស៊ើបអង្កេតរបស់អ៊ុនតាក់ បានស្នើឱ្យតុលាការចេញដីកាចាប់ខ្លួន នឹម ចាន់ណារិទ្ធិ កៅ ឆុង និង ស វ័រ ហើយបានធ្វើការសន្និដ្ឋានថា ការសំលាប់នេះពាក់ព័ន្ធនឹងរឿងនយោបាយ ។ អ៊ុនតាក់បានសំគាល់ឃើញថា មិនមានការចេញដីកាចាប់ខ្លួនជនល្មើសទាំងនេះឡើយ ។*

*២- កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៩៤ មានមន្ត្រីយោធាមួយរូបឈ្មោះ សុខ ថា ដែលឪពុកម្តាយគាត់ត្រូវគេរកឃើញថាមានពិរុទ្ធដោយការប្រព្រឹត្តបទល្មើស ប៉ុន្តែមិនទាន់ត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារនៅឡើយទេ ។ ឈ្មោះ សុខ ថា នេះបានសំរុកចូលក្នុងអាគារតុលាការ (ក្រុងកំពង់សោម) អមដំណើរដោយយោធិនម្នាក់ទៀត ដែលប្រដាប់ដោយអាវុធ ។ ចៅក្រម និងព្រះរាជអាជ្ញា បានបង្ខំចិត្តរត់គេចខ្លួន ដោយភ័យខ្លាចមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ខ្លួន ។ ព្រះរាជអាជ្ញាយោធា មិនបានចាត់វិធានការណាមួយដើម្បីធ្វើការចោទប្រកាន់ទាហានទាំងនោះនៅចំពោះមុខតុលាការយោធាទេ ហើយក៏មិនបានចាត់ការនៅក្នុងតុលាការស៊ីវិលដែរ ។ ឪពុកម្តាយ សុខ ថា នៅមានសេរីភាពនៅឡើយ ។ មានរបាយការណ៍ជាច្រើន (ដែលមានការជជែកគ្នា) អំពីការដែល សុខ ថា ត្រូវបានបញ្ចុះសក្តិ ហើយត្រូវបានផ្លាស់ចេញ ។ លោកតំណាងពិសេស បានផ្តល់មតិ " សូមឱ្យចាត់វិធានការ ដើម្បីធ្វើការឆ្លើយតបទៅនឹងការវាយប្រហារនេះ ហើយថាការចាត់វិធានការនេះ មិនទាន់សមល្មមទៅនឹងទម្ងន់ទោសនោះទេ " ។*[៣០]

*៣- កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៤ មានជនប្រដាប់អាវុធមួយក្រុម ដែលគេស្គាល់ថាជាយោធិនមកពីយោធភូមិភាគទី៤ បានធ្វើការអុកឡុកក្នុងពន្ធនាគារខេត្តបាត់ដំបង ធ្វើការគំរាមដល់អាយុជីវិតអ្នកយាម និងអ្នកទោសដទៃទៀត ហើយបង្ខំឱ្យធ្វើការដោះលែងអ្នកទោសម្នាក់ឈ្មោះ តែ សុគន្ធា ដែលត្រូវបានផ្តន្ទាទោសពីបទជួញដូរវត្ថុបូរាណពីប្រទេសកម្ពុជា*

---

[៣០] ក្រសួងមហាផ្ទៃបានទទួលស្គាល់ថា សុខ ថា បានធ្វើការគំរាមកំហែងព្រះរាជអាជ្ញា ប៉ុន្តែបានបដិសេធថាមានការជ្រៀតជ្រែកនៅក្នុងកិច្ចដំណើរការជំនុំជំរះក្តីរបស់តុលាការ ។ នៅក្នុងសៀវភៅដដែលនេះ កំណត់សំគាល់លេខ៨ និងកំណត់សំគាល់បន្តបន្ទាប់មកទៀត បង្ហាញឱ្យឃើញថា សុខ ថា ត្រូវបានបណ្តេញចេញពីការងារ ដោយសារ ប្រធានតុលាការបានប្តឹងទៅមេបញ្ជាការរបស់គាត់ ។

*ទៅប្រទេសថៃ ។ តែ សុគន្ធា កំពុងស្ថិតក្នុងការគេចខ្លួននៅឡើយ ។ លោកតំណាងពិសេសបាន ផ្តល់អនុសាសន៍ថា "ការជ្រៀតជ្រែកនៅក្នុងការផ្តន្ទាទោសតាមផ្លូវច្បាប់ណាមួយដែលកំណត់ ដោយតុលាការ គឺជាការប្រមាថមើលងាយដល់សមត្ថកិច្ចតុលាការ" ។*[៣១]

[៣១] ក្នុងការឆ្លើយតប ក្រសួងមហាផ្ទៃបានបញ្ជាក់ថា តុលាការបានចេញដីកាចាប់ខ្លួន ហើយកំពុងស្វែងរកចាប់ខ្លួន តែ សុគន្ធា។ ប៉ុន្តែមិនបាននិយាយអំពីទណ្ឌកម្មទៅលើជនល្មើសនោះឡើយ ។ ក្នុងសៀវភៅដដែល កំណត់សំគាល់លេខ ៨។

## *ផ្នែកទី IV  :  សេចក្តីត្រូវការ ដើម្បីកសាងឡើងវិញនូវមូលដ្ឋានគ្រឹះ*

នៅក្នុងរបាយការណ៍[៣២] លើកទី១របស់លោក លោកឃីប៊ីបានកំណត់អំពីរបៀបវារៈសំរាប់ការផ្លាស់ប្តូរ ហើយបានកំណត់នូវវិស័យមួយចំនួន ដែលតម្រូវឱ្យរដ្ឋាភិបាលដែលទើបជាប់ឆ្នោតថ្មីៗ ចាត់វិធានការជាបន្ទាន់បំផុត ហើយវិធានការទាំងនោះរួមមាន : ការបង្កើតស្ថាប័នថ្មី ដូចដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ និងការអនុម័តច្បាប់ថ្មី ដើម្បីឱ្យការធានាទាំងឡាយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញអនុវត្តប្រកបដោយប្រសិទ្ធិភាព ។

លោកបានស្នើយ៉ាងទទូច ឱ្យបង្កើតយ៉ាងឆាប់រហ័សនូវស្ថាប័នចំនួនពីរដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលជាស្នូលនៃនីតិរដ្ឋរួមមានៈ ក្រុមប្រឹក្សាធម្មនុញ្ញ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ការបកស្រាយរដ្ឋធម្មនុញ្ញ និងការពិនិត្យធម្មនុញ្ញភាព លើសេចក្តីព្រាងច្បាប់ទាំងអស់ ដែលបានដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានអំណាចក្នុងការកំណត់ពីបញ្ញត្តិដែលអធម្មនុញ្ញភាព រួមទាំងការរំលោភលើសិទ្ធិជាមូលដ្ឋាន នៅក្នុងច្បាប់ដែលរដ្ឋសភាបានអនុម័ត ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានអំណាចលើកស្នើទៅព្រះមហាក្សត្រពីការតែងតាំងចៅក្រម ហើយវាគឺជាស្ថាប័នតែមួយគត់ ដែលមានអំណាចត្រួតពិនិត្យ និងដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ។

គេតម្រូវឱ្យមានច្បាប់ផងដែរ នៅក្នុងវិស័យសំខាន់ៗជាច្រើន ។ ត្រូវមានច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដើម្បីបង្កើតនិងធ្វើនិយតកម្មប្រព័ន្ធស្តីពីរយៈពេលបំរើការងាររបស់ចៅក្រមថ្មី ក្នុងនោះរួមមាននីតិវិធីក្នុងការតែងតាំង លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍ប្រាក់បៀវត្ស ប្រាក់សោធននិវត្តន៍ ក្រមសីលធម៌ និងនីតិវិធីដាក់ទណ្ឌកម្មខាងវិន័យ ។ ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីវិធានភស្តុតាង និងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី  ត្រូវបានពិនិត្យឡើងវិញ ដើម្បីឱ្យស្របទៅនឹងរដ្ឋធម្មនុញ្ញថ្មី គឺជាការចាំបាច់ក្នុងការបង្កើតមូលដ្ឋានច្បាប់មួយ ដែលមានលក្ខណៈទូលំទូលាយសំរាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ការងាររបស់នគរបាល កិច្ចដំណើរការរបស់តុលាការ និង ការរៀបចំប្រព័ន្ធតុលាការឡើងវិញ គឺជាសេចក្តីត្រូវការក្នុងការបង្កើត និង បញ្ជាក់ឱ្យច្បាស់ពីយុត្តាធិការរបស់តុលាការគ្រប់ជាន់ថ្នាក់ ។

---

[៣២] របាយការណ៍លេខ E/CN.4/1994/73.

លោក ឃីប៊ី ក៏បានគូសបញ្ជាក់ផងដែរថា សិទ្ធិទាំងឡាយដែលបច្ចុប្បន្ននេះ ត្រូវបានការពារជាផ្លូវការនៅក្នុងរដ្ឋធម្មនុញ្ញថ្មី នឹងមិនមានការគ្រប់គ្រងវាទេ ប្រសិនបើគ្មានការអនុម័តច្បាប់សំរាប់អនុវត្តសិទ្ធិទាំងនោះ ។ គាត់បានទាញចំណាប់អារម្មណ៏ចំពោះសភាពការណ៏នៃច្បាប់កម្ពុជាដែលមានស្រាប់ ហើយដែលមិនស្របទៅនឹងគោលការណ៏សិទ្ធិមនុស្សអន្តរជាតិ ដែលបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ ហើយដែលត្រូវតែធ្វើវិសោធនកម្ម ។

- រដ្ឋធម្មនុញ្ញបានធានាសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីព សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនមានច្បាប់ ឬបទបញ្ជាណាមួយគ្រប់គ្រងសមាសភាពសំខាន់ៗ នៃរបបទាក់ទងនឹងឧស្សាហកម្ម ដូចជាប្រាក់ឈ្នួលអប្បបរិមា ពេលម៉ោងធ្វើការ សុខភាព និង សុវត្ថិភាព ។
- រដ្ឋធម្មនុញ្ញបានទទួលស្គាល់សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខបុគ្គល ហើយច្បាប់ព្រហ្មទណ្ឌកម្ពុជា តម្រូវឱ្យធ្វើការផ្តន្ទាទោសចំពោះអំពើល្មើស ។[៣៣] ប៉ុន្តែ ដើម្បីពង្រឹងការអនុវត្តន៏ច្បាប់ ត្រូវមានវិធាន និងនីតិវិធីលំអិត ដើម្បីធានាដល់ការស៊ើបអង្កេត ជាអាទិ៏ដូចជា ក្នុងករណីពាក់ព័ន្ធដល់ការសំលាប់ និងការដកហូតជីវិតមនុស្សតាមទំនើងចិត្ត ។
- រដ្ឋធម្មនុញ្ញបានទទួលស្គាល់សិទ្ធិប្រជាពលរដ្ឋ ក្នុងការចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សដោយមន្ត្រីនានា ប៉ុន្តែតាមការអនុវត្តន៏ជាក់ស្តែង វិធានការបែបនេះមិនអាចចាត់ការបានទេ ពីព្រោះច្បាប់កម្ពុជាមិនមានបញ្ញត្តិគ្រប់គ្រាន់សំរាប់ការជួសជុលសំណងខូចខាតផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណីនៅឡើយ ឧទាហរណ៏ ជនដែលត្រូវគេចាប់ខ្លួនមិនអាចធ្វើចំណាត់ការតាមផ្លូវច្បាប់ ដើម្បីតវ៉ាពីភាពស្របច្បាប់នៃការឃុំខ្លួនរបស់គេបានឡើយ ។
- ការជំនុំជំរះ ក្រោមច្បាប់កម្ពុជា មិនគោរពតាមនីតិវិធីត្រឹមត្រូវដែលបានធានាឡើយ ។ ទោះបីជារដ្ឋធម្មនុញ្ញបានទទួលស្គាល់ការសន្មត់ទុកជាមុនថាគ្មានទោស ហើយបានចែងថាការទទួលយកចំលើយសារភាពដែលកើតឡើងពី "ការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី " មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។ លោកឃីប៊ី បានរាយការណ៏ថា ការរៀបចំ

[៣៣] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៧ និងមាត្រា១០ ។

> សវនាការធ្វើឡើងតាមរបៀបដែលបង្ខំឱ្យជនជាប់ចោទបង្ហាញថាខ្លួនជាជនស្លូតត្រង់ហើយ មិនមែនផ្ទុយពីនេះទេ។ តាមការអនុវត្តន៍ជាក់ស្តែង តុលាការផ្អែកតែលើចំលើយសារភាព ធ្វើជាភស្តុតាងសំខាន់នៃពិរុទ្ធភាព ទោះបីជាចុងចោទបានអះអាងថា ចំលើយសារភាពនោះ បានមកពីការធ្វើទារុណកម្មក្តី ។ វិធានច្បាប់នីតិវិធីព្រហ្មទណ្ឌ បានចាត់ទុករបាយការណ៍ របស់នគរបាលថាជាការសន្មត់ពីការពិត ហើយចុងចោទមិនមានសិទ្ធិ ពិនិត្យលើសាក្សីដាក់ បន្ទុកឡើយ ដូច្នេះហើយសវនាការភាគច្រើនធ្វើឡើងដោយគ្មានការត្រួតពិនិត្យលើសាក្សី។

លោកឃីប៊ី បានធ្វើការសន្និដ្ឋានថា ប្រទេសកម្ពុជាមិនអាចបំពេញតាមសេចក្តីតម្រូវឱ្យ " គោរព និងធានា " សិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ " បុគ្គលគ្រប់រូបនៅក្នុងទឹកដីរបស់ខ្លួន " បានឡើយ លុះត្រាតែរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ និង បទបញ្ញាទាក់ទងនឹងវិស័យផ្សេងគ្នាទាំងនោះសិន ។ គេអាចនិយាយម្យ៉ាងទៀតថា ប្រសិនបើ សិទ្ធិជា មូលដ្ឋាននៅក្នុងរដ្ឋធម្មនុញ្ញត្រូវបានគោរពនោះប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើឱ្យច្បាប់របស់ខ្លួនភាគច្រើន មានភាពស្អាតស្អំ និងមានប្រសិទ្ធិភាពចំពោះច្បាប់ដែលមានស្រាប់ និងចំពោះការអនុវត្តន៍ដែលនាំឱ្យ មានបញ្ហានិទណ្ឌភាពកើតឡើង។

## *ផ្នែកទី V: ទំរង់នៃបញ្ហានិទណ្ឌភាពរវាងឆ្នាំ១៩៩៥-២០០៥*

ចាប់តាំងពីឆ្នាំ១៩៩៥ លោក ថូម៉ាស់ ហាំម៉ាប៊ឺក និងលោក ភីថឺរ លយប្រែកតឺ តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.បបានទាក់ទាញចំណាប់អារម្មណ៍ជាច្រើនលើកច្រើនសារអំពីករណីដែលកើតឡើងចំពោះបុគ្គល បណ្តឹង និងសភាពការណ៍នីមួយៗដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិជាមូលដ្ឋានដោយមន្ត្រីរដ្ឋាភិបាល ឬដោយការសមគំនិតរបស់ខ្លួន ដែលក្នុងនោះមិនមានវិធានការមានប្រសិទ្ធិភាពណាមួយត្រូវបានធ្វើឡើងដើម្បីការស៊ើបអង្កេត និងធ្វើការចោទប្រកាន់ជនដែលទទួលខុសត្រូវឡើយ ។

ទំហំ និងភាពធ្ងន់ធ្ងរនៃករណីទាំងនេះបង្ហាញឱ្យឃើញច្បាស់ តាមរយៈឧទាហរណ៍ ពន្យល់ដោយលោក ថូម៉ាស់ ហាំម៉ាប៊ឺក នៅក្នុងរបាយការណ៍របស់លោក ដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស ក្នុងឆ្នាំ២០០០ នៅពេលដែលលោកស្នើសុំឱ្យមានការស៊ើបអង្កេតលើករណីរឿងថ្មីៗនេះ ដោយអតីតរដ្ឋាភិបាលទើបជាប់ឆ្នោត ។ ករណីទាំងនោះរួមមាន : ករណីឃាដកម្មលើអ្នកកាសែតបួនរូប ការវាយប្រហារដោយគ្រាប់បែកដៃទៅលើសមាជគណៈបក្សប្រជាធិបតេយ្យសេរី និងព្រះពុទ្ធសាសនា នៅក្នុងខែកញ្ញា ឆ្នាំ១៩៩៥ ឃាដកម្មលើលោកកូវ សាមុត ប្រធាននាយកដ្ឋានព្រហ្មទណ្ឌសេដ្ឋកិច្ចក្រសួងមហាផ្ទៃ នៅចុងឆ្នាំ១៩៩៦ ការវាយប្រហារដោយគ្រាប់បែកទៅលើបាតុកម្មស្របច្បាប់ និងដោយសន្តិវិធី កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ ដែលបានសំលាប់មនុស្សច្រើនជាង១៨នាក់ និងរបួស១៤២នាក់ ការវាយប្រហារដោយគ្រាប់រ៉ុកកែតទៅលើស្ថានីយ៍ទូរទស្សន៍មួយកន្លែងនៅក្រុងព្រះសីហនុ កាលពីថ្ងៃទី៤ ឧសភា ឆ្នាំ១៩៩៧ ការវាយប្រហារទៅលើការិយាល័យសារព័ត៌មានប្រចាំថ្ងៃមួយកន្លែង ហៅថា*កោះសន្តិភាព* កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៧ និងការព្យាយាមជាបន្តបន្ទាប់ទៅលើអាយុជីវិតអ្នកនិពន្ធមួយរូប ការសំលាប់ និងការបាត់ខ្លួនរបស់សមាជិកយោធា និងស៊ីវិលនៃគណៈបក្សនយោបាយប្រឆាំងនានា នៅក្នុងខែកក្កដា ឆ្នាំ១៩៩៧ នៅក្នុងព្រឹត្តការណ៍រដ្ឋប្រហារ និងក្នុងរយៈពេលជាច្រើនខែក្រោយមក ការសំលាប់ដែលត្រូវបានរាយការណ៍កើតមាននៅមុនពេលបោះឆ្នោតឆ្នាំ១៩៩៨ ហើយនិងការស្លាប់ទាក់ទងនឹងបាតុកម្មក្រោយថ្ងៃបោះឆ្នោត ។[៣៤] លោកហាំម៉ាប៊ឺក បានលើកឡើងពីករណីទាំងនេះ និងករណីដទៃទៀត នៅក្នុងអនុសាសន៍ ដែលលោកបានដាក់ជូនរដ្ឋាភិបាល ។

---

[៣៤] របាយការណ៍លេខ E/CN.4/2000/109 កថាខ័ណ្ឌទី២២

បន្ទាប់មកករណីទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីតំណាងមួយដែលមាន១៧៨ករណី ហើយបានដាក់ជូនរដ្ឋាភិបាល កាលពីខែកុម្ភៈ ឆ្នាំ២០០៤។ ករណីទាំងនេះ ត្រូវបានដាក់ជូនរដ្ឋាភិបាលជ្រាបក្នុងអំឡុងពេល១២ឆ្នាំ ដោយអ៊ុនតាក់ និងលោកតំណាងពិសេស។ លោកបានស្នើឱ្យរដ្ឋាភិបាលជួយពិនិត្យបញ្ជីនេះឡើងវិញ ហើយបានក្រើនរំលឹកអំពីស្ថានការណ៍ ឬលទ្ធផលបច្ចុប្បន្ននៃការស៊ើបអង្កេត ឬកិច្ចដំណើរការរបស់តុលាការ និងអំពីចំណាត់ការផ្នែករដ្ឋបាលដែលត្រូវធ្វើឡើង ប្រសិនបើមាន។ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានផ្តល់ចំលើយជាលាយលក្ខណ៍អក្សរ ផ្ញើជូនលោកតំណាងពិសេស កាលពីខែវិច្ឆិកា ឆ្នាំ២០០៤។[៣៥]

គេអាចរកឃើញករណីភាគច្រើននៅក្នុងរបាយការណ៍របស់លោកតំណាងពិសេស ដែលពាក់ព័ន្ធដល់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុត ប៉ុន្តែមិនមានការស៊ើបអង្កេតប្រកបដោយប្រសិទ្ធិភាពណាមួយ ដើម្បីចាប់ជនល្មើសឱ្យទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌ ឬចំណាត់ការដទៃផ្សេងទៀតឡើយ។

*ក- ការសំលាប់សមាជិកយោធា និងស៊ីវិលនៃគណៈបក្សប្រឆាំង។* នៅក្នុងអនុសាសន៍មួយ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ លោក ហាំម៉ាប៊ឺក បានបង្ហាញព័ត៌មានជាច្រើន ក្នុងនោះមានព័ត៌មានទាក់ទងនឹងការសំលាប់ដោយហេតុផលនយោបាយ ដែលកើតមាន បន្ទាប់ពីរដ្ឋប្រហារយោធា កាលពីខែកក្កដាឆ្នាំ១៩៩៧។[៣៦] ក្នុងនោះមានករណីមួយ គឺករណីលោក ហូ សុខ។

*លោកហូ សុខគឺជារដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាសមាជិកជាន់ខ្ពស់នៃគណៈបក្សហ៊្វុនស៊ិនប៉ិច។ កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៧ លោកត្រូវបានចាប់ខ្លួននៅវេលាម៉ោង៤:០០ល្ងាច នៅលើដងវិថីមួយក្នុងក្រុងភ្នំពេញដោយមនុស្ស៤នាក់ ស្លៀកពាក់ស៊ីវិល មកពីនាយកដ្ឋានព្រហ្មទណ្ឌកំរិតធ្ងន់នៃនគរបាលជាតិដឹកនាំ*

---

[៣៥] ក្រសួងមហាផ្ទៃបានឆ្លើយតបយ៉ាងពីស្តារពីស្ថានភាពនៃករណីនេះ។ ក្នុងករណី៦៤ ក្រសួងបានបង្ហាញថា ក្រសួងកំពុងស៊ើបអង្កេតលើករណីទាំងនោះ តែពុំមានជនណាម្នាក់ត្រូវបានចាប់ខ្លួនឡើយ។ ២៥ករណីបានកើតឡើងពាក់ព័ន្ធក្នុងព្រឹត្តិការណ៍ខែកក្កដាឆ្នាំ១៩៩៧ ក៏ពុំមានធ្វើការស៊ើបអង្កេតដែរ មាន៤ករណីយដែលកើតឡើងក្នុងតំបន់ដែលកាន់កាប់ដោយខ្មែរក្រហមក៏ពុំត្រូវបានស៊ើបអង្កេតដែរ។ ការស៊ើបអង្កេតត្រូវបានគេធ្វើហើយត្រូវបានធ្វើរួចរាល់ទៅលើ ករណីដែលនៅសេសសល់ ក្នុងនោះមានពីរករណីក្នុងព្រឹត្តិការណ៍ពុំបានកើតឡើងឡើយ។ ដើម្បីបានពីស្តារ សូមមើលឧបសម្ព័ន្ធ ខ។

[៣៦] អនុសាសន៍ : *ភស្តុតាងនៃការសំលាប់ក្រៅច្បាប់ ការធ្វើទារុណកម្ម និងការបាត់ខ្លួនមនុស្ស ចាប់តាំងពីថ្ងៃទី២-៧ ខែកក្កដា ឆ្នាំ១៩៩៧។*

*ដោយលោកវរៈសេនីយ៍ឯក ម៉ៅ ចាន់ដារ៉ា និងវរៈសេនីយ៍ឯក តែន បូរ៉ានី ។ លោកត្រូវបានគេនាំខ្លួនទៅក្រសួងមហាផ្ទៃ ហើយគាត់ត្រូវគេសំលាប់នៅទីនោះ នៅវេលាម៉ោង៥:០០ល្ងាច ។ នៅថ្ងៃទី៨ ខែកក្កដា វេលាម៉ោង៣:០០ព្រឹក គេបានឃើញសាកសពលោកហូ សុខដែលមានស្នាមរបួសដោយគ្រាប់កាំភ្លើងចំនួនពីរកន្លែង សាកសពរបស់គាត់ត្រូវបានជនប្រដាប់អាវុធមួយក្រុម ស្ថិតក្នុងសំលៀកបំពាក់ឯកសណ្ឋានប្រយុទ្ធ បាននាំយកទៅកាន់វត្តលង្កា ។ ពួកគេបានបញ្ជាឱ្យយកសាកសពគាត់ទៅដុតចោលជាបន្ទាន់ ដោយគ្មានការសាកសួរ និងដោយគ្មានលិខិតអនុញ្ញាតបូជាសពទេ ទោះបីការអនុវត្តន៍ជាទំលាប់ និងតាមផ្លូវច្បាប់ ការបូជាសពមិនអាចប្រព្រឹត្តទៅដោយគ្មានលិខិតអនុញ្ញាតត្រឹមត្រូវបានឡើយ ។ លុះដល់ព្រឹកថ្ងៃបន្ទាប់មក ក្រោយពីបានបូជាសពរួច មានលិខិតមួយច្បាប់មានឈ្មោះលោកហូ សុខ បានបញ្ជាក់ថា គាត់ស្លាប់ "ដោយគ្រាប់កាំភ្លើង" ដែលចេញដោយនាយកដ្ឋានសុខាភិបាលរាជធានីភ្នំពេញ ។*[៣៧]

ករណីមួយទៀត ពាក់ព័ន្ធនឹងការសំលាប់ទាហានហ៊ុនស៊ីនប៉ិច :

*កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៧ ការិយាល័យប្រចាំនៅកម្ពុជា បានរកឃើញកន្លែងដុតសាកសពចោលជាច្រើនកន្លែងនៅតាមបណ្តោយផ្លូវជាតិលេខ៤នៅជ្រោះពេជ្រនិល ហើយបានរកឃើញឆ្អឹងមនុស្សដែលឆេះរោល និងខ្មោះជើងចំនួនពីរគូ ។ សេចក្តីបរិយាយជាបន្តបន្ទាប់បានបញ្ជាក់ថា ទាំងនេះគឺជាសាកសពរបស់ទាហានហ៊ុនស៊ីនប៉ិចបួនរូប ដែលសាកសពរបស់គេត្រូវបានទាហានកងពលលេខ៤៤ យកមកបោះចោលនៅទីនោះ កាលពីថ្ងៃទី១០ ខែកក្កដា វេលាម៉ោង ៩:៣០យប់ ហើយត្រូវបានដុតចោលនៅ ថ្ងៃទី១១ ខែកក្កដា ។ លុះក្រោយមក គេបានរកឃើញរណ្តៅសពកប់រាក់ៗមួយ មានសាកសពមនុស្សប្រុសពីរនាក់ ដែលមានចងក្រណាត់បិទមុខ ដៃចងស្លាបសេកទៅក្រោយ និងមានស្នាមគ្រាប់កាំភ្លើងមួយគ្រាប់នៅត្រង់ក្បាល ។ គេឃើញខ្សែក្រវ៉ាត់មួយធ្វើពីស្បែកនៅជិតរណ្តៅសព ។ សេចក្តីបរិយាយបន្ថែមបញ្ជាក់ថា នៅថ្ងៃទី៩ ខែកក្កដា មានទាហានហ៊ុនស៊ីនប៉ិចជាច្រើននាក់ ពី១៥ ទៅ ២២នាក់ ត្រូវបានយោធានៃយោធភូមិភាគទី៣ ដែលមានមូល-ដ្ឋាននៅខេត្តកំពង់ស្ពឺ ដឹកដោយរថយន្តកងទ័ព សំលាប់ ហើយកប់ចោលនៅតំបន់ជ្រោះពេជ្រនិល ។ ជនរងគ្រោះត្រូវបានគេពិពណ៌នាថាជា "បងធំ" ដែលមានភក្តីភាពនឹងទ្រង់រណឬទ្ធិ ហើយរួមទាំងនាយទាហានហ៊ុនស៊ីនប៉ិចជាច្រើនរូបទៀត ។ ជ្រោះនោះស្ថិតក្រោមការគ្រប់គ្រងផ្តាច់មុខរបស់កងពលលេខ៤៤ ដែលមានមូលដ្ឋាននៅស្រែថ្លុង ។*

[៣៧] ការស៊ើបអង្កេតជាផ្លូវការលើករណីមរណៈភាពរបស់លោក ហូ សុខ ត្រូវបានពិចារណានៅក្នុងផ្នែកទី៦ ។

នៅក្នុងអនុសាសន៍បន្ទាប់មកទៀត ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨ លោកហាំម៉ាប៊ឹក បានកត់ត្រាករណីជាច្រើន ដែលក្នុងចំណោមនោះ មានករណីសំលាប់ក្រៅច្បាប់ចំនួន ២៨ករណីបន្ថែមទៀត និងករណីឃាដកម្មពាក់ព័ន្ធនឹងសមាជិកគណៈបក្សនយោបាយប្រឆាំង ។[៣៨] លោកបាននិយាយថា លោកជឿថាមិនមានការស៊ើបអង្កេតត្រឹមត្រូវលើករណីទាំងនេះឡើយ ។ នគរបាល និងអាជ្ញាធររដ្ឋាភិបាល បានធ្វើការសន្និដ្ឋានថាករណីភាគច្រើន ជាករណី "ប្លន់ " " ទំនាស់បុគ្គល" ឬ ជាអំពើសងសឹក ។ លោកបានផ្តល់អនុសាសន៍ថា មានករណីជាច្រើន អាចមានធាតុផ្សំតាមការអះអាងទាំងនេះ តែហេតុផលផ្សេងៗទៀត អាចនៅលាយឡំចំរុះគ្នាហើយវាអាចជារឿងឃាតកម្មនយោបាយ ក៏ប៉ុន្តែត្រូវបានរៀបចំអោយទៅជាមានមូលហេតុផ្សេងពីនេះទៅវិញ ។ ដូច្នេះ លោកបានស្នើថា "មានតែការស៊ើបអង្កេតឱ្យបានល្អិតល្អន់បំផុតប៉ុណ្ណោះទេ ទើបអាចកំណត់ពីមូលហេតុពិតប្រាកដរបស់វាបាន" ។ លោកក៏បានកត់សំគាល់ផងដែរថា ការខកខានមិនបានធ្វើការផ្តន្ទាទោសដល់បទឧក្រិដ្ឋទាំងឡាយដែលបានចុះផ្សាយជាសាធារណៈហើយនោះ វានឹងជំរុញលើកទឹកចិត្តដល់សមាជិកនៃកងកំលាំងប្រដាប់អាវុធ និងនគរបាលឱ្យជឿជាក់ថា ពួកគេរួចផុតពីការផ្តន្ទាទោស ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលពួកគេបានប្រព្រឹត្ត ។

ក្នុងនោះ មានករណីលោក អ៊ីន ភួង និងកូនស្រីរបស់គាត់ម្នាក់ឈ្មោះ ចាន់ សូរិយា ។[៣៩]

> *កាលពីល្ងាចថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៨ លោក អ៊ីន ភួង ប្រពន្ធ និងកូនស្រីពីរនាក់របស់គាត់កំពុងសំរាកនៅផ្ទះ ។ នៅវេលាម៉ោង ៩:១៥ ល្ងាច មានបុរសបីនាក់ ម្នាក់ប្រដាប់ដោយអាវុធអាកា ៤៧ មួយដើម បានចូលទៅក្នុងផ្ទះ ។ លោកអ៊ីន ភួង កំពុងយោលកូនស្រីពៅរបស់គាត់ឈ្មោះចាន់ សូរិយា ដែលកំពុងដេកក្នុងអង្រឹង ។ ប្រពន្ធគាត់នៅក្រៅផ្ទះកំពុងឱ្យចំណីជ្រូក ។ លោក អ៊ីន ភួង ត្រូវគេបាញ់ចំនួនបួនគ្រាប់បណ្តាលឱ្យគាត់ និងកូនស្រីគាត់ត្រូវរងរបួស ។ គេបានយកក្រមាចងគាត់ ហើយទារយកលុយពីគាត់ ។ ពួកគេបានយក វ៉ាលីសគាត់ចំនួនពីរ ដែលមានដាក់សំលៀកបំពាក់ សៀវភៅ និងសំភារៈសំរាប់បង្រៀន និងឯកសារនយោបាយ ព្រមទាំងប័ណ្ណសមាជិកគណៈបក្សហ៊្វុនស៊ិនប៉ិច និងរូបថតលោក សម រង្ស៊ី ចំនួនមួយសន្លឹក ប៉ុន្តែរកមិនឃើញប័ណ្ណសមាជិកគណៈបក្សជាតិខ្មែរ (KNP) របស់លោក អ៊ីន ភួង ទេ ។ ពួកគេក៏បានយកគោមួយក្បាលរបស់គ្រួសារនោះទៅ ។ ក្រៅតែ*

---

[៣៨] អនុសាសន៍ដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨ ផ្នែកទីIII និងផ្នែកទី IV

[៣៩] នៅភូមិកងនាង ស្រុកព្រះស្តេច ខេត្តព្រៃវែង ។

*ពីគោមួយក្បាលនោះ សំភារៈដទៃទៀតក្រោយមកត្រូវគេគ្រវែងចោល ។ លោកអ៊ិន ភួង និងកូនស្រីរបស់គាត់ទាំងពីរនាក់នេះបានស្លាប់ បន្ទាប់ពីពួកគេត្រូវរងរបួស ។ លោកអ៊ិន ភួង គឺជាគ្រូបង្រៀនសាលាបឋមសិក្សា និងជាសមាជិកគណៈកម្មការវត្តក្នុងភូមិគាត់ ។ គេដឹងថា លោកមិនដែលមានទំនាស់ជាមួយអ្នកណាម្នាក់នៅក្នុងភូមិទេ ហើយលោកគឺជាអ្នកចាស់ទុំដែលគេគោរពរាប់អាននៅក្នុងសហគមន៍ ។ គាត់គឺជាសមាជិកមួយរូប នៃគណៈបក្សហ្វ៊ុនស៊ិនប៉ិច ហើយនៅក្នុងឆ្នាំ១៩៩៥ លោកបានចូលរួមក្នុងគណៈបក្សជាតិខ្មែរ ហើយកំពុងត្រៀមខ្លួនទទួលការតែងតាំងពីគណៈបក្សនេះ(KNP) ជាសមាជិកគណៈបក្ស នៅពេលដែលលោកត្រូវគេសំលាប់ ។*[៤០]

តាមពិតទៅករណីទាំងនេះ មិនមានការស៊ើបអង្កេតពេញលេញ ក្នុងរយៈពេលមួយដែលសមហេតុផលទេ បាននាំឱ្យគណៈកម្មាធិការសិទ្ធិមនុស្សសំដែងនូវ " ការភ្ញាក់ផ្អើល " ជាខ្លាំង ហើយអំពាវនាវសុំឱ្យរដ្ឋាភិបាលចាត់វិធានការជាបន្ទាន់ ដើម្បីបង្ការកុំឱ្យបញ្ហានេះកើតមានជាថ្មីទៀត ដើម្បីធ្វើការស៊ើបអង្កេតលើពាក្យបណ្តឹងទាំងអស់ និងដើម្បីនាំខ្លួនជនជាប់ចោទដែលបានរំលោភសិទ្ធិក្នុងកតិកាសញ្ញា ទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ ។[៤១]

---

[៤០] ក្រសួងមហាផ្ទៃបានរាយការណ៍ថា ក្រោយមកជនសង្ស័យពីរនាក់ត្រូវបានចាប់ខ្លួន ឈ្មោះសន សាន និង សន សាន់ ប៉ុន្តែក្រោយមកបានរត់គេចខ្លួននៅថ្ងៃបន្ទាប់ ។ នគរបាលក៏កំពុងធ្វើការស្វែងរកចាប់ខ្លួនជនសង្ស័យពីរនាក់ផ្សេងទៀត ឈ្មោះខ្វាន់ កុយ និងគង់ ដុក ដែលមានដីកាចាប់ខ្លួនហើយ ប៉ុន្តែពួកគេបានរត់គេចខ្លួនដែរ ។ *សៀវភៅដដែល កំណត់សំគាល់លេខ៨* ។ ចំពោះការវិវត្តន៍មួយគួរឱ្យស្វាគមន៍ នៅគ្រាចុងក្រោយគឺ គង់ ដុក ត្រូវបានចាប់ខ្លួនក្នុងដើមឆ្នាំ២០០៥ ។ បន្ទាប់មកតុលាការខេត្តព្រៃវែងបានជូនដំណឹងមកការិ-យាល័យយើងខ្ញុំថា តុលាការបានបើកសវនាការជំនុំជំរះលើករណីនេះកាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៥ហើយសន សាន. សន សាន់ និងខ្វាន់ កុយ ត្រូវបានតុលាការកាត់ទោសកំបាំងមុខ និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល៧ឆ្នាំ ។ គង់ ដុក ដែលត្រូវបានចាប់ខ្លួនត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល១០ឆ្នាំ ។ សាលក្រមក៏បានបញ្ជាឱ្យធ្វើការចោទប្រកាន់មនុស្សម្នាក់ទៀតដែលមានឈ្មោះហៅក្រៅថា " ចាន់ថា " នៅស្រុកកំពង់ត្របែក ។ ប៉ុន្តែ នគរបាលបានរាយការណ៍ថា គេរកមិនឃើញមានឈ្មោះជននោះទេ ។

[៤១] គណៈកម្មាធិការមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះរបាយការណ៍នានា ស្តីពីកំលាំងសន្តិសុខ បានសម្លាប់មនុស្ស ការបាត់ខ្លួននិងស្លាប់ផ្សេងទៀតនៅក្នុងកន្លែងឃុំឃាំង និងចំពោះការខកខានរបស់រដ្ឋភាគី ក្នុងការស៊ើបអង្កេតយ៉ាងពេញលេញលើការចោទប្រកាន់ទាំងនេះ និងការនាំខ្លួនជនល្មើសទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ ។ គណៈកម្មាធិការមានការព្រួយបារម្ភ ជាពិសេស អំពីការមិនចាត់វិធានការចំពោះការបាត់ខ្លួន និងការស្លាប់ជាច្រើនដែលបានកើតមាននៅឆ្នាំ១៩៩៧ និងនៅក្នុងអំឡុងពេលនៃការបោះឆ្នោតឆ្នាំ១៩៩៨ និងចំពោះការពន្យាពេលស៊ើបអង្កេត ដើម្បីបញ្ចប់ករណីនៃការបោកគ្រាប់បែកដៃទៅលើហ្វូងបាតុករ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ ។ គួរចាត់វិធានការ ដោយមិនត្រូវពន្យាពេល ដើម្បីទប់ស្កាត់កុំឱ្យកើតមានតទៅទៀត នូវឧប្បត្តិហេតុទាំងនេះ ដើម្បីធ្វើការស៊ើបអង្កេតរាល់ការចោទប្រកាន់ ហើយនាំខ្លួនជនទាំងឡាយដែលត្រូវបានចោទប្រកាន់ថាបានរំលោភបំពានលើសិទ្ធិទាំង

*ខ- ករណីឃាដកម្មទាក់ទងនឹងរឿងនយោបាយ និងអំពើហឹង្សានៅក្នុងអំឡុងពេលបោះឆ្នោត* ត្រូវបានកត់ត្រានៅក្នុងការបោះឆ្នោតនីមួយៗហើយត្រូវបានចងក្រងជាឯកសារដោយលំអិតជាពិសេសនៅក្នុងពេលបោះឆ្នោតថ្នាក់ជាតិ ឆ្នាំ១៩៩៨។[៤២] ជាអាទិ៍គឺ ករណីរបស់ឈ្មោះ ឯម អៀម :

*កាលពីព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៨ លោកឯម អៀម បានជិះកង់ចេញពីផ្ទះគាត់ឆ្ពោះទៅកាន់ទីស្នាក់ការស្រុកនៃគណៈបក្សហ៊្វុនស៊ិនប៉ិច ដែលគាត់ធ្វើការនៅទីនោះ ។ គេបានឃើញគាត់ត្រូវមនុស្សប្រាំមួយនាក់ចាប់ខ្លួនគាត់ ដែលក្នុងនោះមាន ប្រធានភូមិម្នាក់ នគរបាលឃុំ និងប្រធានកងសេនាជន ។ ពួកគេបានធ្វើការឆែកឆេរលើខ្លួនគាត់ ហើយបានដកហូតយកឯកសារគណៈបក្ស ។  បន្ទាប់មកគាត់ត្រូវបានគេដាក់ខ្នោះដៃ យកក្រណាត់ចងបិទមុខគាត់ ហើយនាំសំដៅទៅចំការកៅស៊ូដែលនៅជិតនោះ លុះក្រោយមកគេឃើញសាកសពគាត់នៅទីនោះ ។ នៅថ្ងៃទី១៩ ខែមិថុនា គេបានស្គាល់ថាពិតជាសាកសពគាត់ ។ គេឃើញក្បាលគាត់ផ្នែកខាងឆ្វេង ដល់ផ្នែកខាងក្រោយខ្ទង និង ដៃស្តាំមានស្នាមរបួស ។ បាក់ធ្មេញជាច្រើនកន្លែង បាក់ឆ្អឹងថ្គាមស្តាំ ហើយច្រមុះគាត់ត្រូវបែកខ្ទេច ។ សាក្សីជាច្រើនបាននិយាយថា កាលពីថ្ងៃទី៩ខែមិថុនាប្រធានភូមិបានអញ្ជើញប្រជាពលរដ្ឋមកផ្ទះគាត់ ហើយបាននិយាយថាបើអ្នកណាចូលគណៈបក្សនយោបាយក្រៅពីគណៈបក្សប្រជាជនកម្ពុជា(CPP) នឹងត្រូវសំលាប់ចោល ។ គាត់បាននិយាយសំដីនេះដដែលៗជាច្រើនថ្ងៃ បន្ទាប់ពីមានអំពើឃាដកម្មនេះ ដោយបញ្ជាក់ថា សមាជិកគណៈបក្ស សម រង្ស៊ី នឹងត្រូវសំលាប់ម្តងមួយៗ ។*[៤៣]

មានករណីឃាដកម្មជាច្រើន ដែលគេសង្ស័យថាជារឿងនយោបាយ ក៏ត្រូវបានកត់ត្រាទុកផងដែរ នៅក្នុងបរិបទនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ កាលពីខែកុម្ភៈ ឆ្នាំ២០០២ និងការបោះឆ្នោតជ្រើសតាំង

---

ឡាយ ដែលមានចែងក្នុងកតិកាសញ្ញានេះ ទៅតុលាការ ដើម្បីផ្តន្ទាទោសទៅតាមច្បាប់ ។ របាយការណ៍លេខ CCPR/C/79/Add. 108, កថាខ័ណ្ឌទី១១ ។

[៤២] សូមមេត្តាមើលឧទាហរណ៍ របាយការណ៍របស់លោកតំណាងពិសេស *ការឃ្លាំមើលអំពើហឹង្សា និងការបំភិតបំភ័យទាក់ទងនឹងការបោះឆ្នោត* ខែមិថុនា ដល់ ខែតុលា ឆ្នាំ១៩៩៨ ។

[៤៣] *ការឃ្លាំមើលដោយលោកតំណាងពិសេស ចំពោះអំពើហឹង្សា និងការបំភិតបំភ័យខាងនយោបាយ* ចាប់ពីថ្ងៃទី២៨ មិថុនា ដល់ ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ១៩៩៨ ។ ក្រសួងមហាផ្ទៃបាននិយាយថា ការស៊ើបអង្កេតបានចប់សព្វគ្រប់ហើយ ករណីនេះត្រូវបានបញ្ជូនទៅតុលាការកាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៨ ហើយបានរកឃើញជនសង្ស័យជាច្រើននាក់ទៀត ។ ប៉ុន្តែមិនទាន់មានការចាត់វិធានការតទៅទៀតនៅឡើយទេ ។ *ក្នុងសៀវភៅដដែល* កំណត់សំគាល់លេខ៨ ។

តំណាងរាស្ត្រ ខែកក្កដា ឆ្នាំ២០០៣ ។ លោក ភីថឺរ លយប្រែកតឺ បានរាយការណ៍ នៅក្នុងឆ្នាំ២០០៥ ថា ការិ- យាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានចងក្រងឯកសារពាក់ព័ន្ធនឹងករណីឃាដកម្ម ដូចនេះចំនួន ៤៣ករណី ដែលកើតមាននៅក្នុងអំឡុងពេលបោះឆ្នោត ហើយថាភាគច្រើននៃករណីទាំងនេះ មិនមានជនល្មើសណាម្នាក់ត្រូវបានផ្តន្ទាទោស និងដាក់ពន្ធនាគារឡើយ ។[៤៤]

ករណីខ្លះមានចរិតលក្ខណៈជា "ការស៊ីឈ្នួល" សំលាប់ដែលអ្នកស៊ីឈ្នួលសំលាប់-តាមធម្មតាជិះម៉ូតូ បាញ់ជនរងគ្រោះនៅទីសាធារណៈ និងនៅកណ្តាលថ្ងៃតែម្តង ។ ជនរងគ្រោះទាំងនោះរួមមានឥស្សរជនសាធា រណៈ និងប្រធានសហជីព ។ ចៅក្រម សុខ សេដ្ឋាមុនី ត្រូវគេសំលាប់កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ :

*លោក សុខ សេដ្ឋាមុន្នី គឺជាចៅក្រមមួយរូប នៃតុលាការក្រុងភ្នំពេញ ។ លោកត្រូវបានបាញ់ស្លាប់ នៅទីក្រុងភ្នំពេញ ដោយខ្មាន់កាំភ្លើងពីរនាក់ ដែលជិះម៉ូតូមួយគ្រឿង ដែលបានឈប់នៅអែបរថយន្តរបស់គាត់ នៅលើផ្លូវបំបែកដែលមានភ្លើងស្តុប ហើយបានបាញ់រះលើរូបលោក ។ លុះក្រោយមក មានជនសង្ស័យបីនាក់ ត្រូវបានចាប់ខ្លួន ដោយកងរាជអាវុធហត្ថក្រុង ។ ជនសង្ស័យម្នាក់ត្រូវបានដោះលែង នៅពេលដែលគេរក ឃើញថា គាត់កំពុងស្ថិតនៅក្នុងគុក នៅពេលកើតមានអំពើឃាតកម្ម ។ ជនសង្ស័យពីរនាក់ទៀតត្រូវបានដោះ លែងឱ្យមានសេរីភាពវិញ បន្ទាប់ពីចៅក្រមស៊ើបអង្កេតរកមិនឃើញមានភស្តុតាងដាក់បន្ទុកលើពួកគេ ។ នៅ ពេលធ្វើការសាកសួរអំពីស្ថានការណ៍នៃការស៊ើបអង្កេត ស្នងការនគរបាលបានអះអាងថា កងរាជអាវុធហត្ថ ក្រុង បានធ្វើការចាប់ខ្លួនជំហានដំបូង ហើយនគរបាលមិនបន្តធ្វើការស៊ើបអង្កេតករណីនេះតទៅទៀតទេ ។ លោក ភីថឺរ លយប្រែកតឺ បានចេញសេចក្តីថ្លែងការណ៍មួយ កាលពីថ្ងៃទី១៦ ខែឧសភា លើកឡើងពីការ ព្រួយបារម្ភអំពីការសំលាប់ និងឧប្បត្តិហេតុដទៃទៀត ដែលធ្វើឱ្យអន្តរាយដល់ឯករាជ្យភាពតុលាការ ហើយ បានធ្វើការអំពាវនាវ សុំឱ្យធ្វើការស៊ើបអង្កេតទាំងស្រុង និងមិនលំអៀង ។[៤៥]*

---

[៤៤] របាយការណ៍លេខ E/CN.4/2005/116 កថាខ័ណ្ឌទី១៣ ។ ទោះបីជាក្នុងចំណោម៤៣ករណី មាន១៨ករណី ដែលជនល្មើស ត្រូវ បានផ្តន្ទាទោស នៅក្នុងករណីភាគច្រើន នៅតែមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីភាពអាចទុកចិត្តបាននៃការផ្តន្ទាទោស អំពីគុណភាព ការស៊ើបអង្កេត និងការចោទប្រកាន់ ក៏ដូចជាការមិនបំពេញបានតាមបទដ្ឋានអប្បបរមាស្តីពីការជំនុំជំរះប្រកបដោយភាពត្រឹមត្រូវ ។

[៤៥] កាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៣ លោក ឈុន ចិត្រា ត្រូវបានចាប់ខ្លួនពីបទឃាដកម្មលើចៅក្រម ហើយជនសង្ស័យម្នាក់ទៀត ឈ្មោះ មុល មិត្ត អាយុ៤១ឆ្នាំ ត្រូវបានចាប់ខ្លួននៅថ្ងៃបន្ទាប់មកទៀត ។ ជនសង្ស័យទាំងពីរនាក់នេះ គឺជាអតីតសមាជិកនៃកងទ័ព សេរីកម្ពុជា (CFF) ដែលបានជាប់ពន្ធនាគារ ដោយសារខ្លួនមានតួនាទីនៅក្នុង CFF ដែលធ្វើការវាយប្រហារនៅក្នុងខែវិច្ឆិកាឆ្នាំ២០០០ ។

ករណីដទៃទៀត ពាក់ព័ន្ធនឹងការ "ស៊ីឈ្នួល" សំលាប់មនុស្ស ដែលបានធ្វើឡើងនៅទីក្រុងភ្នំពេញ ចាប់ពីខែកុម្ភៈ ឆ្នាំ២០០៣ ដល់ខែឧសភា ឆ្នាំ២០០៤ រួមមានមន្ត្រីសង្ឃព្រះនាម សម ប៊ុនធឿន, ទីប្រឹក្សាគណៈបក្សហ្វ៊ុនស៊ិនប៉ិច លោកឱម រដ្ឋសាឌី , លោក ជូរ ជេដ្ឋារិទ្ធី អ្នកយកព័ត៌មានវិទ្យុ, លោក ជា វិជ្ជា និង លោក រស់ សុវណ្ណារ៉េត ប្រធានសហជីព និងអ្នកស្រី គីម ស៊ីនួន ត្រូវបានគេបាញ់សំលាប់ដែរ ដែលគាត់ត្រូវជាម្តាយកញ្ញា ទូចស្រីនិច អ្នកចម្រៀងដ៏មានប្រជាប្រិយភាព ដែលត្រូវបានគេបាញ់បណ្តាលឱ្យពិការផងដែរ ។[៨៦]

*គ- ការជំនុំជំរះមិនត្រឹមត្រូវ និងការមិនគោរពតាមនីតិវិធីត្រឹមត្រូវរបស់តុលាការ ។* នៅក្នុងករណីទាំងឡាយ អំពើឃាដកម្មទំនងជាដោយហេតុផលនយោបាយ ត្រូវបានធ្វើការស៊ើបអង្កេត ហើយជនសង្ស័យត្រូវបានចាប់ខ្លួន និងចោទប្រកាន់ ចំណាត់ការរបស់តុលាការជារឿយៗ ត្រូវបានគេសំគាល់ឃើញថា មានការខ្វះខាតធ្ងន់ធ្ងរនៃនីតិវិធីត្រឹមត្រូវ ។ បញ្ហាទាំងនេះរួមមានការផ្តន្ទាទោសដោយផ្អែកតែទៅលើចំលើយសារភាពដែលគេរាយការណ៍ថា ធ្វើឡើងដោយការបង្ខិតបង្ខំ ឬការជំនុំជំរះដែលគេមិនអនុញ្ញាតឱ្យហៅសាក្សី មកឆ្លើយការពារ ឬការសួរដេញដោលដល់នគរបាល និងសាក្សីដាក់បន្ទុកដទៃទៀត ហើយចៅក្រមបានបង្ហាញភស្តុតាងលំអៀងនៅក្នុងចំណាត់ការនីតិវិធីរបស់ខ្លួន ហើយជនស៊ីវិលត្រូវបានជំនុំជំរះដោយតុលាការយោធា ។ ទាំងនេះគឺជាការខ្វះចន្លោះធ្ងន់ធ្ងរផ្អែកច្បាប់ និងនីតិវិធីដែលធ្វើឱ្យមានការមន្ទិលសង្ស័យទៅលើពិរុទ្ធភាពពិតប្រាកដរបស់ទណ្ឌិតទាំងនោះ ។ ឧទាហរណ៍ពីរ គឺការជំនុំជំរះករណីលោក ជាម ច័ន្ទនី និងករណីបុរសពីរនាក់ទៀត ឈ្មោះប៊ន សំណាង និងសុខ សំអឿន ជាជនជាប់ចោទពីបទឃាដកម្មលើលោក ជា វិជ្ជា ។

*១- លោកជាម ច័ន្ទនី តំណាងរាស្ត្រមួយរូប នៃគណៈបក្សប្រឆាំងសម រង្ស៊ី ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៥ ក្នុងរយៈប៉ុន្មានម៉ោងបន្ទាប់ពីរដ្ឋសភាបានបោះឆ្នោតដកអភ័យឯកសិទ្ធិរបស់គាត់ ។ កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥ តុលាការយោធាបានកាត់ទោសគាត់ឱ្យជាប់ពន្ធនាគាររយៈពេលប្រាំពីរឆ្នាំ ។ គាត់មានពិរុទ្ធភាពពីបទប្រព្រឹត្តអំពើល្មើសដែលត្រូវផ្តន្ទាទោសតាមមាត្រា៣៦ "ក្រុមជនប្រដាប់អាវុធ" ដោយសារគាត់បានរៀបចំកងទ័ពខុសច្បាប់ និងមាត្រា៤៥ "អំពើឆបោក"*

---

កាលពីថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៤ ចៅក្រមស៊ើបអង្កេតបានចេញដីកាដោះលែងជនសង្ស័យ ដោយគ្មានភស្តុតាងគ្រប់គ្រាន់ ហើយជនសង្ស័យទាំងពីរនាក់នេះ ត្រូវបានដោះលែង នៅថ្ងៃទី១០ ខែមេសា ។

[៨៦] សូមមេត្តាមើលឧបសម្ព័ន្ធ "គ" ដើម្បីបានយល់ដឹងលំអិតថែមទៀត ។

នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលឆ្នាំ១៩៩២ (ច្បាប់អ៊ុនតាក់) ហើយទាក់ទងនឹងមាត្រា៦(៣) និងមាត្រា៤២នៃច្បាប់ស្តីពីគណៈបក្សនយោបាយ ។ ក្រោមច្បាប់កម្ពុជា តុលាការយោធាមានយុត្តាធិការតែទៅលើបទល្មើសយោធា ដែលប្រព្រឹត្តដោយយោធិនតែប៉ុណ្ណោះ ។ អាស្រ័យហេតុនេះ អយ្យការយោធា និងតុលាការយោធាមិនមានសមត្ថកិច្ចចេញដីកាចាប់ខ្លួនលោកជាម ច័ន្ទនីដែលគាត់ជាជនស៊ីវិលឡើយ ។ ការបើកសវនាការ បាននាំឱ្យមានការមន្ទិលសង្ស័យយ៉ាងខ្លាំង អំពីភាពលំអៀង និងសមត្ថភាពរបស់ តុលាការ ក្នុងការអនុវត្តន៏គោលការណ៍ "សន្មត់ជាមុនថាគ្មានទោស" ។ មេធាវីការពារក្តីត្រូវបានតុលាការរារាំងមិនឱ្យសាកសួរសាក្សីដាក់បន្ទុក ។ គេមិនអនុញ្ញាតឱ្យមេធាវីទាំងនោះអញ្ជើញសាក្សី របស់ខ្លួនមកឆ្លើយបំភ្លឺ និងការសាកសួរចុងចោទរបស់គេទៀតសោធ ក៏ត្រូវបានតុលាការបញ្ឈប់ ដោយគ្មានហេតុផលដែរ ។ ចៅក្រមបានរំខានហើយរំខានទៀត នៅពេលដែលសាក្សីផ្តល់សក្ខីកម្មបំភ្លឺ ដែលអាចជាឧបសគ្គដល់ការចោទប្រកាន់របស់ព្រះរាជអាជ្ញា ។ អយ្យការមិនបានផ្តល់ភស្តុតាងដើម្បីគាំទ្រដល់ការចោទប្រកាន់ថា ចុងចោទបានរៀបចំបង្កើតកងកំលាំងប្រដាប់អាវុធខុសច្បាប់ទេ ។ លោក លយប្រែកត៏ បានហៅការជំនុំជំរះនេះថាជាការដែលមិនអាចជឿទុកចិត្តបាន ។

២- លោកជា វិជ្ជា ជាប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ។ លោកត្រូវបានគេបាញ់ស្លាប់ កាលពីថ្ងៃទី២២ ខែមករាឆ្នាំ២០០៤ ដោយខ្មាន់កាំភ្លើងជិះម៉ូតូមួយគ្រឿង នៅខណៈពេលដែលគាត់កំពុងស្ថិតនៅឯមុខស្តង់លក់កាសែតមួយកន្លែង ក្នុងរាជធានីភ្នំពេញ ។ ជនសង្ស័យពីរនាក់ត្រូវបានចាប់ខ្លួន ប៉ុន្តែលុះក្រោយមក នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤ ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងភ្នំពេញបានចេញដីកាដោះលែងជនសង្ស័យទាំងពីរនាក់នេះ ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់ ។ ព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ ។ កាលពីថ្ងៃទី២២ ខែមីនា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានដាក់ទណ្ឌកម្មខាងវិន័យដល់ចៅក្រមស៊ើបអង្កេត ដោយសំអាងលើមូលហេតុផ្សេង ហើយបានផ្លាស់ចៅក្រមនោះចេញ ។ សាលាឧទ្ធរណ៍បានបើកសវនាការលើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ហើយបានបញ្ជូនករណីនេះ ត្រឡប់មកតុលាការក្រុងភ្នំពេញវិញ ដើម្បីធ្វើការស៊ើបអង្កេតបន្ថែម ។ កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០០៥ ជនជាប់ចោទពីរនាក់នេះត្រូវបានតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល២០ឆ្នាំ ។ ការជំនុំជំរះនេះ ត្រូវបានមជ្ឈដ្ឋានជាច្រើនរិះគន់ : ចៅក្រមផ្អែកលើចំលើយសារភាពដែលចៅក្រមស៊ើបអង្កេតមុនបានបដិសេធថាមាន "ភាពមិនប្រក្រតី" សាក្សីដាក់

*បន្ទុកមិនបានចូលមកបង្ហាញខ្លួននៅក្នុងតុលាការ ហើយតុលាការមិនអាចពិនិត្យលើភស្តុតាងរបស់គេ មិនមានការធ្វើកោសល្យវិច្ច័យ ឬភស្តុតាងសាក្សីផ្ទាល់ភ្នែកត្រូវបានប្រឌិតឡើងដោយអយ្យការ ហើយចំលើយការពារថាខ្លួននៅកន្លែងផ្សេងនៅពេលកើតហេតុ (alibis) មិនត្រូវបានចៅក្រមយកមកពិចារណាឡើយ ។ លោកភីថឺរ លយប្រែកតឺបានអះអាងថា អយ្យការមិនបានបង្ហាញភស្តុតាងណាមួយដែលភ្ជាប់ទំនាក់ទំនងរវាងចុងចោទទៅនឹងអំពើល្មើសនោះទេ ហើយមិនបានគោរពតាមគោលការណ៍ជាមូលដ្ឋានស្តីពីការជំនុំជំរះប្រកបដោយភាពត្រឹមត្រូវ ដូចជាគោលការណ៍សន្មត់ជាមុនថាគ្មានទោស និងភាពមិនលំអៀងរបស់តុលាការជាដើម ។*[៤៧]

*ឃ- ការសំលាប់ដោយហ្វូងមនុស្ស ។* ក្នុងឆ្នាំ២០០២ លោក ភីថឺរ លយប្រែកតឺ បានទាញចំណាប់អារម្មណ៍លើការកើនឡើងនៃករណីសំលាប់ដោយហ្វូងមនុស្ស ។[៤៨]

*នៅក្នុងករណីមួយ កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ មន្ត្រីជាន់ខ្ពស់នគរបាលមួយរូប ក្នុងខ័ណ្ឌចំការមន រាជធានីភ្នំពេញ បាននាំជនសង្ស័យម្នាក់ចេញពីអធិការដ្ឋាននគរបាលរួចចាក់សោរដោះខ្នោះដៃចេញ ហើយបានប្រគល់ជននោះទៅឱ្យហ្វូងមនុស្សដែលកំពុងតែឈររង់ចាំ ។ ជនសង្ស័យត្រូវស្លាប់ ក្នុងពេលប៉ុន្មាននាទីក្រោយមក ។ ឈ្មោះជននោះ និងសេចក្តីរៀបរាប់លំអិតដទៃទៀត ពីហេតុការណ៍ដែលកើតមាន មិនត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុនគរបាលទេហើយក៏គ្មានការចាត់វិធានការផ្នែកព្រហ្មទណ្ឌ ឬផ្នែកវិន័យ នៅក្នុងករណីនេះដែរ ។*

*នៅក្នុងករណីមួយទៀត ដែលករណីនេះកើតឡើងនៅរាជធានីភ្នំពេញផងដែរ កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៩ នគរបាលក្រុង បានចាប់ដាក់ខ្នោះដៃជនសង្ស័យម្នាក់ពីអំពើលួច ជននោះឈ្មោះ ប៊ិច ភឿន ។ ប្រមាណជា ២ម៉ោងបន្ទាប់ពីការឃុំគ្រងរបស់នគរបាល នគរបាលបានដោះលែង*

---

[៤៧] ប៊ិន សំណាង និង សុខ សំអឿន បានប្តឹងឧទ្ធរណ៍ ។ ករណីរបស់លោក ជា វិជ្ជា ត្រូវបានរៀបចំចងក្រងជាឯកសារ ហើយបច្ចុប្បន្នករណីនេះកំពុងស្ថិតនៅចំពោះមុខគណៈកម្មាធិការផ្នែកសេរីភាពខាងសមាគមនៃអង្គការពលកម្មអន្តរជាតិ (ILO) ។ សូមមេត្តាមើលរបាយការណ៍បណ្តោះអាសន្នរបស់គណៈកម្មាធិការ ILO ករណីលេខ : ២៣១៨ ដែលប្តឹងរដ្ឋាភិបាលកម្ពុជា តំណាងដោយសហព័ន្ធសហជីពសេរីអន្តរជាតិ ឆ្នាំ២០០៥ ។

[៤៨] គំនុំសងសឹកនៅលើដងវិថីក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៥ ។

*ជននោះ ហើយនគរបាលបានឈរមើលមនុស្សមួយក្រុម កំពុងវាយសំពងលើជននោះដោយដំបង ។ ក្រោយពីរងរបួសជាដំណំមក បិច គឿនបានរត់គេចចេញពីការវាយដំនេះ ។ នៅខណៈពេលដែលគាត់កំពុងរត់ គាត់ត្រូវបានក្រុមនគរបាល "ខ្លាបោះ" ធ្វើការពួនស្ទាក់ ហើយបាញ់ឱ្យស្លាប់ភ្លាម ។*[៤៩]

លោក លយប្រែកតឺ បានកត់សំគាល់ថា ជួនកាល សារព័ត៌មានបានចាត់ទុកឧប្បត្តិហេតុប្រភេទនេះថាជាតុលាការ "ប្រជាជន" ហើយថាសមាជិកនគរបាល មិនសូវជាជួយធ្វើអន្តរាគមន៍ក្នុងរឿងនេះឡើយ ។[៥០] ការវាយប្រហារដោយហ្វូងមនុស្ស បានកើតមានយ៉ាងឆាប់រហ័ស ដែលជនរងគ្រោះស្ទើរតែមិនអាចបង្ហាញពីភាពស្លូតត្រង់របស់ខ្លួនបានឡើយ ។ ការចោទប្រកាន់ធម្មតាហាក់ដូចជាគ្រប់គ្រាន់ហើយ ឧទាហរណ៍ ការស្រែកឡើងថា "ចាប់ចោរ ចាប់ចោរ" ។ ខណៈដែលនគរបាលខ្លះបានបង្ហាញនូវឆន្ទៈក្នុងការធ្វើអន្តរាគមន៍ មានករណី "ជាច្រើន" ដែលនគរបាល និងអ្នកដទៃទៀតដែលមានអំណាច បានបដិសេធមិនព្រមជួយដល់ជនដែលត្រូវគេកំពុងសំលាប់ ឬមិនតែប៉ុណ្ណោះ ថែមទាំងបានចូលរួមយ៉ាងសកម្មនៅក្នុងការញុះញង់ឱ្យមានអំពើហឹង្សាដោយហ្វូងមនុស្សទៀតផង ។ គេមិនបានដឹងច្បាស់ថាតើនគរបាលបានរាយការណ៍អំពីករណីនៃការវាយប្រហារដោយហ្វូងមនុស្សឬអត់ វាហាក់ដូចជាមន្ត្រីតុលាការមិនបានទទួលសំណុំរឿងពីនគរបាល ហើយតុលាការបានទទួលរឿងដែលបានដឹងចំនួនតែពីរករណីប៉ុណ្ណោះ ហើយនៅក្នុងករណីទាំងពីរនេះ មិនមានអ្នកណាម្នាក់ត្រូវបានដាក់ពន្ធនាគារឡើយ ។

នៅឆ្នាំ២០០៤ លោកភីថឺរ លយប្រែកតឺ បានរាយការណ៍ថា នៅក្នុងអំឡុងពេលជាងប្រាំឆ្នាំកន្លងទៅនេះ មានមនុស្សប្រមាណជាង១០០នាក់ត្រូវបាត់បង់ជីវិតនៅក្នុងព្រឹត្តិការណ៍សំលាប់ដោយហ្វូងមនុស្ស ហើយមានមនុស្សជាច្រើនទៀតត្រូវរងរបួសធ្ងន់ ។ នៅក្នុងករណីជាច្រើន មន្ត្រីអនុវត្តច្បាប់បានធ្វើការញុះញង់ហ្វូងមនុស្សឱ្យធ្វើការវាយប្រហារជនសង្ស័យថាជាចោរលួច ឬចោរប្លន់ ។[៥១] លោកបានផ្តល់ជាអនុសាសន៍ឱ្យបង្កើតគណៈកម្មាធិការស៊ើបអង្កេតឯករាជ្យមួយ ដែលមានសមាសភាពតំណាង ដែលមានការទទួលខុសត្រូវមកពីគណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងអង្គការខាងសាសនានានា ដើម្បីពិនិត្យលើរាល់អំពើហឹង្សាដោយហ្វូងមនុស្ស ថាតើហេតុអ្វីបានជាកើតមានការវាយប្រហារទាំងនេះ និងដើម្បីរកវិធីទប់ស្កាត់កុំឱ្យហេតុ

---

[៤៩] ក្រសួងមហាផ្ទៃបានអះអាងថា ករណីនេះកំពុងស្ថិតក្នុងការស៊ើបអង្កេត ។ *សៀវភៅដដែល* កំណត់សំគាល់លេខ ៨ ។

[៥០] សូមមើលខាងលើ ។

[៥១] សូមមើលរបាយការណ៍លេខ E/CN.4/2005/116 កថាខ័ណ្ឌទី១៨ ។

ការណ៍នេះកើតមានតទៅទៀត និងដើម្បីពិនិត្យពិច័យសីលធម៌របស់នគរបាល និងព្រះរាជអាជ្ញា នៅក្នុងការវាយប្រហារទាំងនេះ ។ ការស៊ើបអង្កេតបែបនេះ មិនទាន់បានបង្កើតឱ្យមាននៅឡើយទេ ។

*ង-ការធ្វើទារុណកម្ម នៅក្នុងពេលនគរបាលសួរចំលើយ ។* របាយការណ៍ស្តីពីករណីនេះលើកទីមួយរបស់លោក ហាំម៉ាប៊ឺក ដាក់ជូនរដ្ឋាភិបាល ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៧ បានសរសេរលំអិតអំពីករណីធ្វើទារុណកម្ម ចំនួន៣២ករណី នៅក្នុងខេត្តបាត់ដំបង ។[៥២] លោកបានលើកជាឧទាហរណ៍អំពីករណីនៃអធិការដ្ឋាននគរបាល ស្រុកស្វាយប៉ោ ដែលជនជាប់ចោទស្ទើរតែទាំងអស់ ដែលមិនព្រមទទួលកំហុស ត្រូវគេធ្វើទារុណកម្មឱ្យចុះ ហត្ថលេខាលើចំលើយសារភាព ដោយរួមទាំងជនជាប់ចោទពីបទព្រហ្មទណ្ឌ និងជនជាប់ចោទពីបទធ្វើសកម្ម ភាពខ្មែរក្រហម ។ មិនមានភស្តុតាងណាមួយបង្ហាញថា អ្នកដែលទទួលខុសត្រូវ ត្រូវបានផ្តន្ទាទោស ឬដាក់ វិន័យឡើយ ។ លោកបានផ្តល់ជាអនុសាសន៍ថា ការដែលអាជ្ញាធរខេត្តមិនបានចាត់វិធានការ បានធ្វើឱ្យមាន ការសង្ស័យថា មន្ត្រីដែលជាចៅហ្វាយនាយ កំពុងធ្វើការការពារមន្ត្រីក្រោមឱវាទរបស់ខ្លួន ដែលជាអ្នកធ្វើ ទារុណកម្ម ហើយការគាំពារបែបនេះបានជំរុញឱ្យមានការធ្វើទារុណកម្មដោយអ្នកដែលទទួលខុសត្រូវក្នុងការ ពង្រឹងច្បាប់ ។[៥៣]

គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្មបានសំដែងនូវការព្រួយបារម្ភ "ដោយសារមានបណ្តឹងជា ច្រើនចេះតែបន្តកើតមានឥតឈប់ឈរ ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯ ទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលបានប្រព្រឹត្តឡើងដោយមន្ត្រីអនុវត្តច្បាប់ នៅក្នុង អធិការដ្ឋាននគរបាល និងនៅក្នុងពន្ធនាគារ" ។[៥៤] គណៈកម្មាធិការនេះបានផ្តល់ជាអនុសាសន៍ថា អាជ្ញាធរគួរ ធានាឱ្យមាន" ការស៊ើបអង្កេតទាំងស្រុង ភ្លាម១ និងមិនលំអៀង ហើយធ្វើការផ្តន្ទាទោសជនល្មើសទាំងនោះ ដើម្បីបញ្ចប់បញ្ហានិទណ្ឌភាព ចំពោះមន្ត្រីអនុវត្តច្បាប់ និងសមាជិកនៃកងកំលាំងប្រដាប់អាវុធ ។ អាជ្ញាធរគួរ

---

[៥២] សូមមើលផ្នែកទីVI ខាងក្រោម ។

[៥៣] ករណីដែលថ្មីបំផុតនោះគឺ ករណីរបស់ អៀត អឿន ជាកសិករម្នាក់មកពីខេត្តព្រៃវែង ដែលគាត់ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ ដោយជាប់សង្ស័យថាបានលួចក្របីជាច្រើនក្បាល ហើយត្រូវស្លាប់រយៈពេលបីថ្ងៃក្រោយមក ។ សូមមេត្តាមើល ឧបសម្ព័ន្ធ គ ។

[៥៤] សេចក្តីសន្និដ្ឋាន និង អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្មលេខ CAT/C/CR/31/7 ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៤ ។

ធានាផងដែរថា ភស្តុតាងដែលបានតាមរយៈការធ្វើទារុណកម្ម មិនត្រូវបានប្រើនៅក្នុងតុលាការឡើយ ។ គួរបង្កើតស្ថាប័នឯករាជ្យមួយ ដើម្បីដោះស្រាយពាក្យបណ្តឹងផ្សេងៗ ។ កន្លងមក មិនទាន់មានការចាត់វិធានការណាមួយ ដើម្បីបង្កើតស្ថាប័ននេះទេ ។

នៅក្នុងឆ្នាំ២០០៤ លោកលយប៉្រេកតី បានរាយការណ៍ថា ទារុណកម្មនៅតែជាបញ្ហាមួយធ្ងន់ធ្ងរដដែល នៅក្នុងមន្ទីរឃុំឃាំងរបស់នគរបាល ។ លោកជឿថា បញ្ហានេះមានការថយចុះនៅក្នុងពន្ធនាគារនានា ។

*ច-ការប្រើប្រាស់កំលាំងហួសប្រមាណដោយនគរបាលៈ* បើតាមសេចក្តីរាយការណ៍បានឱ្យដឹងថា អាវុធស្វ័យប្រវត្តិសំរាប់សំលាប់មនុស្សត្រូវបានគេបើកឱ្យនគរបាលជាតិប្រើប្រាស់ ។ បញ្ហានេះជាការរួមចំណែកនាំឱ្យនគរបាលប្រើប្រាស់កំលាំងហួសប្រមាណ ជួនកាលបណ្តាលឱ្យមានមនុស្សស្លាប់ និងការសំលាប់មនុស្សភ្លាមៗ គួរឱ្យរន្ធត់ និងឧប្បត្តិហេតុនៃការស្លាប់មានកំរិតខ្ពស់ នៅក្នុងការចាប់ខ្លួន និងក្នុងពេលឃុំខ្លួនដោយគ្មានការ ទទួលខុសត្រូវ ។ ប្រសិនបើមានមនុស្សស្លាប់នៅក្នុងមន្ទីរឃុំឃាំង ការស៊ើបអង្កេតមានការលំបាកច្រើនដោយ គ្មានការធ្វើកោសល្យវិច័យលើសាកសព នៅមុនពេលបូជាសពនោះទេ ។

*ឆ-ការវាយប្រហារលើអាគារតុលាការ ។* ក្នុងឆ្នាំ២០០៥ លោកតំណាងពិសេស បានលើកឡើងពីការវាយប្រហារដែលមានចំនួនសរុបទាំងអស់ ១៨លើក ទៅលើអាគារតុលាការ នៅក្នុងរយៈពេលមួយទសវត្សកន្លងទៅនេះ នៅក្នុងករណីភាគច្រើនទាំងនេះ គេបានកត់ត្រាថា មាននគរបាល ឬយោធាចូលរួមពាក់ព័ន្ធ ។[៥៥]

នៅក្នុងឆ្នាំ១៩៩៧ លោកហាំម៉ាប៊ឹក បានកត់ត្រាអំពី "ការខកចិត្ត" នៃតុលាការខេត្តបាត់ដំបង ចំពោះការលំបាកធ្វើការចោទប្រកាន់ជនល្មើសជាយោធា ឬនគរបាល ទោះបីជាមានភស្តុតាងបង្ហាញថា ពួកគេជាអ្នកទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សភាគច្រើននៅក្នុងខេត្តនានា និងចំពោះបទល្មើសព្រហ្មទណ្ឌដែលតុលាការត្រូវដោះស្រាយ ។[៥៦] បុគ្គលិកតុលាការត្រូវទទួលរងការគំរាមកំហែង រួមមាន ការគំរាមកំហែងដល់អាយុជីវិត និងការបំភិតបំភ័យដោយយោធា និងនគរបាល ។ តុលាការបានបើកសវនាការកំបាំងមុខចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងមន្ត្រីយោធា និងនគរបាល នៅក្នុងអំឡុងពេលពីរឆ្នាំកន្លងមក

---

[៥៥] សូមមើលរបាយការណ៍លេខ E/CN.4/2005/116, កថាខ័ណ្ឌទី១៦ ។

[៥៦] សូមមើលរបាយការណ៍លេខ A/52/489 កថាខ័ណ្ឌទី៦០ ។

នេះ ប៉ុន្តែមិនមានសាលក្រមណាមួយត្រូវបានអនុវត្តនៅឡើយទេ ហើយក៏មិនមានការសហការពីនគរបាល និងកងរាជអាវុធហត្ថជាមួយតុលាការនៅពេលអនុវត្តសាលក្រមដែរ ។

*នៅខេត្តបន្ទាយមានជ័យ នាយនគរបាលយុត្តិធម៌ម្នាក់បានចូលអុកឡុកពន្ធនាគារ រួមដំណើរដោយមន្ត្រីនគរបាលចំនួន៣០រូប ប្រដាប់ដោយអាវុធគ្រប់ដៃ និងរថពាសដែកមួយគ្រឿងដើម្បីរំដោះមន្ត្រីនគរបាលមួយរូបដែលត្រូវបានចាប់ខ្លួនដោយសារគាត់វាយ និងគំរាមសំលាប់ប្រពន្ធគាត់ ។ បន្ទាប់មកគាត់បានគំរាមដល់អាយុជីវិតព្រះរាជអាជ្ញា ដែលបានចេញដីកាចាប់ខ្លួនគាត់ ។ ចាប់ពីពេលនោះមក នាយនគរបាលរូបនោះនៅតែមិនអើពើគោរពតាមដីការបស់តុលាការ ហើយបានគំរាមប្រើអំពើហិង្សាប្រសិនបើមានការចាត់វិធានការតាមផ្លូវច្បាប់ទៅលើមន្ត្រីនគរបាលរបស់គាត់ណាម្នាក់ ។ តុលាការបានរាយការណ៍ពីហេតុការណ៍នេះទៅក្រសួងយុត្តិធម៌ ប៉ុន្តែបើតាមលោកតំណាងពិសេសដឹង មិនមានការចាត់វិធានការតាមផ្លូវច្បាប់ ឬខាងវិន័យណាមួយឡើយ ។*[៥៧]

*ជ- "ពិធីធ្វើសមាហរណកម្ម"* នៅថ្នាក់ខេត្ត ឬថ្នាក់មូលដ្ឋាន មានការលើកលែងតាមព្រឹត្តិន័យ ពីការចោទប្រកាន់ចំពោះអំពើឧក្រិដ្ឋធ្ងន់ធ្ងរមួយចំនួន ។ លោកហាំម៉ាប៊ើក បានរាយការណ៍អំពីពិធី "ធ្វើសមាហរណកម្ម" ចំនួនពីរដាច់ដោយឡែកពីគ្នានៅក្នុងឆ្នាំ២០០០ ។[៥៨] ពិធីទាំងនេះត្រូវបានរៀបចំឡើងដោយអាជ្ញាធរខេត្ត ដោយមានការចូលរួមពីសំណាក់មន្ត្រីរដ្ឋាភិបាល និងសមាជិករដ្ឋសភាមួយរូប ។ មានការអនុញ្ញាតឱ្យរួចផុតពីការចោទប្រកាន់មនុស្សចំនួន១៥នាក់ពីបទប្លន់ប្រដាប់អាវុធ ។ ក្នុងចំណោមចោរប្លន់ប្រដាប់អាវុធទាំង១៥នាក់ ដែលបានធ្វើសមាហរណកម្ម មាន ៧នាក់ តុលាការបានចេញដីកាចាប់ខ្លួនរួចហើយ ក្នុងនោះ អ្នកខ្លះជាប់ចោទពីបទឃាដកម្ម ។ លោកបានកត់សំគាល់ថាពិធីទាំងនេះបានធ្វើឱ្យអន្តរាយដល់កិច្ចដំណើរការរបស់តុលាការ ។

---

[៥៧] ក្រសួងមហាផ្ទៃបានទទួលស្គាល់ថា ឧប្បត្តិហេតុនេះពិតជាកើតមានប្រាកដមែន ។ ប៉ុន្តែ ក្រសួងបានកត់សំគាល់ថា ការដោះលែងមន្ត្រីនគរបាល កើតឡើងនៅទីបញ្ជាការកងរាជអាវុធហត្ថ មិនមែននៅក្នុងពន្ធនាគារទេ ។ *សៀវភៅដដែល* កំណត់សំគាល់ទី៨ ។

[៥៨] សូមមើលរបាយការណ៍លេខ E/CN.4/2000/109 កថាខ័ណ្ឌទី៤៩ ។

## *ផ្នែកទី VI: កត្តាផ្សេងៗដែលនាំឱ្យកើតមានបញ្ហានិទណ្ឌភាព*

ជាតួយ៉ាង បញ្ហានិទណ្ឌភាពកើតមាននៅក្នុងស្ថានភាពមួយចំនួននៅពេលដែលមិនទាន់មានក្របខ័ណ្ឌច្បាប់ត្រឹមត្រូវ ការអនុវត្តន៍ច្បាប់នៅមិនទាន់មានភាពរឹងមាំ និងត្រឹមត្រូវនៅឡើយ ក្នុងខណៈដែលមិនទាន់មានប្រព័ន្ធសំរាប់ចាប់ជនល្មើសឱ្យទទួលខុសត្រូវ មានការភ័ន្តច្រឡំពីខ្សែរយៈនៃអំណាច និងអំពីដែនសមត្ថកិច្ចរបស់ស្ថាប័នផ្សេងៗ ជាពិសេស មិនមានការរាយការណ៍ ការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មចំពោះអំពើរំលោភសិទ្ធិមនុស្ស ។ បញ្ហានេះគួបផ្សំនឹងអំពើពុករលួយ ដែលជាឧបសគ្គដល់ការអនុវត្តន៍ច្បាប់របស់នគរបាល និងព្រះរាជអាជ្ញា ហើយនិងការអនុវត្តន៍ច្បាប់ដោយតុលាការឯករាជ្យ ។

រដ្ឋាភិបាលកម្ពុជា មិនទទួលស្គាល់ថាមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរឡើយ ។ រដ្ឋាភិបាលធ្វើការពន្យល់អំពីការខកខានក្នុងការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មចំពោះការរំលោភទាំងនេះ គឺដោយសារមន្ត្រីនានាខ្វះការបណ្តុះបណ្តាល និងបទពិសោធន៍ ហើយប្រទេសជាតិជួបប្រទះនូវភាពក្រីក្រ និងខ្វះធនធាន ។ ក្នុងខណៈនេះដែរ លោកតំណាងពិសេសបានទទួលស្គាល់យ៉ាងច្បាស់ពីសេចក្តីត្រូវការឱ្យមានការបណ្តុះបណ្តាលនិងធនធានច្រើនថែមទៀត ។ លោកបានគូសបញ្ជាក់ថា ដំណោះស្រាយចំពោះបញ្ហានេះ គឺទាមទារមិនត្រឹមតែឱ្យមាន ជាឧទាហរណ៍ ច្បាប់ថ្មី និងនគរបាលដែលមានការបណ្តុះបណ្តាលល្អប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានការប្តេជ្ញាចិត្តផ្នែកនយោបាយ ដើម្បីធានាថា មិនមានជនណាម្នាក់ស្ថិតនៅពីលើច្បាប់ឡើយ ហើយរដ្ឋាភិបាលគួរធ្វើការណែនាំដល់ស្ថាប័នទាំងអស់ឱ្យបានដឹងអំពីគោលការណ៍ទាំងនេះ ។[៥៩] តុលាការគួរតែមានអំណាចពិតប្រាកដក្នុងការចោទប្រកាន់ជនល្មើស ដោយមិនគិតពីឋានៈ ឬបុណ្យសក្តិរបស់ពួកគេឡើយ ហើយត្រូវទុកឱ្យតុលាការបំពេញភារៈកិច្ចរបស់ខ្លួនដោយឯករាជ្យ ។

វិស័យចំនួនបួន ដែលអាចលើកយកមកពិចារណាបាន ដែលជារឿយៗតែងមានភាពសាំញ៉ាំរវាងកត្តាធំៗមួយចំនួន ដែលបង្កឱ្យមានបញ្ហានិទណ្ឌភាពដូចជា: ការខ្វះខាតធនធាន និងសមត្ថភាព ភាពទន់ខ្សោយនៃវិស័យច្បាប់ និងតុលាការ និងភាពគ្មានឆន្ទៈរបស់ថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់ ក្នុងការដាក់ទណ្ឌកម្មមន្ត្រីទាំងឡាយដែលទទួលខុសត្រូវក្នុងការរំលោភសិទ្ធិមនុស្ស ។ ក្នុងនោះ មានការធ្វើទារុណកម្ម ការកាត់ទោសប្រហារ

---

[៥៩] លោក ថូម៉ាស់ ហាំម៉ាប៊ឺក បានរាយការណ៍ ក្នុងឆ្នាំ១៩៩៧ អំពីការរីកលូតលាស់ និងការរីកចំរើនឡើង នៃបណ្តាញបក្សពួក និងអ្នកមានអំណាច ។

ជីវិតភ្លាមៗ វិស័យពន្ធនាគារ ព្រមទាំងប្រព័ន្ធច្បាប់ និងយុត្តិធម៌ ។ កត្តាមួយទៀតដែលមានជាក់ស្តែងនៅក្នុងសេចក្តីថ្លែងការណ៍ជាផ្លូវការ និងនៅក្នុងរបាយការណ៍របស់លោកតំណាងពិសេស គឺការភ័យខ្លាចទូទៅដែលរារាំងជនរងគ្រោះភាគច្រើនមិនឱ្យប្តឹងទាមទារសំណងជំងឺចិត្ត និងសំណងការខូចខាត ។ ការភ័យខ្លាច គឺមិនអាចជៀសផុតទេចំពោះបញ្ហានិទណ្ឌភាពដែលកើតមានរហូតមក ។ នេះមានន័យថា អំពើរំលោភមានសភាពធ្ងន់ធ្ងរបំផុត បើតាមសេចក្តីរាយការណ៍ ហើយជារឿយៗសាក្សីភ័យខ្លាចមិនហ៊ានផ្តល់សក្ខីកម្មបំភ្លឺឡើយ ។

*i. ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប*

នៅក្នុងរបាយការណ៍របស់ខ្លួនដាក់ជូនគណៈកម្មាធិការប្រឆាំងទារុណកម្ម ក្នុងខែមករា ឆ្នាំ២០០៣ រដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា មានការធ្វើទារុណកម្ម ធ្វើឡើងដោយនគរបាល ដើម្បីទាញយកចំលើយសារភាព ដែលគេចាត់ទុកថាជា "ចំលើយសារភាពដោយបង្ខំ " ដើម្បីធ្វើជាទំរង់ភស្តុតាងមួយដ៏សំខាន់ ។ ដូច្នេះគេបានបង្ខិតបង្ខំជនជាប់ចោទឱ្យសារភាព ដោយមិនផ្អែកលើបច្ចេកទេសសួរចំលើយ និងបច្ចេកទេសស៊ើបអង្កេតឡើយ ។ រដ្ឋាភិបាលអះអាងថា ការបណ្តុះបណ្តាលបន្ថែមទៀតនឹងអាចកាត់បន្ថយការជឿទុកចិត្តលើភស្តុតាងដែលបានមកពីចំលើយសារភាព ។[៦០]

នៅក្នុងរបាយការណ៍របស់លោក លោកតំណាងពិសេសបានធ្វើការវិភាគលំអិតអំពីកត្តាផ្សេងៗគាំទ្រនៅក្នុងសភាពការណ៍នេះ និងអំពីច្បាប់ និងគោលនយោបាយនានា ដែលនាំឱ្យមានការរីករាលដាលនៃការប្រើអំពើទារុណកម្ម។  នៅក្នុងឆ្នាំ១៩៩៧ លោកបានរាយការណ៍ថា :

"ទារុណកម្មត្រូវបានហាមឃាត់យ៉ាងច្បាស់នៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែ ការខ្វះខាតនូវបទបញ្ញត្តិលំអិតស្តីពី ការផ្តន្ទាទោសចំពោះអំពើទារុណកម្ម ការខ្វះខាតនូវច្បាប់ស្តីពីភស្តុតាង ភាពទន់ខ្សោយរបស់តុលាការ ការខ្សត់ខ្សោយខាងធនធានសម្ភារៈ និងធនធានមនុស្សសំរាប់តុលាការ ការភ័យខ្លាចដែលចេះតែរីកធំទៅៗក្នុង ការចោទប្រកាន់ជនល្មើសដែលមានអំណាច ឬដែលត្រូវបានគេការពារ ការខ្វះខាតយន្តការក្នុងកងកម្លាំងនគរបាល សំរាប់ឱ្យមន្ត្រីជាន់ខ្ពស់នគរបាលត្រួតពិនិត្យលើសកម្មភាពរបស់អ្នកដែលស្ថិតក្រោមឱវាទរបស់ខ្លួន ការប្រើអំណាចដោយរំលោភក្នុងការចាប់ និងសួរចម្លើយ ព្រមទាំងការខ្វះសមត្ថភាពរបស់តុលាការ

[៦០] សូមមើលរបាយការណ៍ CAT/C/21/Add.5 កថាខ័ណ្ឌទី ១៧៣-១៨២ ។

ក្នុងការចោទប្រកាន់ ដោយសារតែមានប្រព័ន្ធនិទណ្ឌភាពស្របច្បាប់មួយការពារដោយមាត្រា៥១[៦១] ទាំងអស់នេះបានរួមចំណែកនាំឱ្យមានស្ថានភាពមួយ ដែលធ្វើឱ្យច្បាប់ទៅជាគ្មានប្រសិទ្ធភាព ។ ការបំបាត់ទារុណកម្មទាមទារឱ្យ មានគោលជំហរយ៉ាងច្បាស់ និងប្រកបដោយការប្តេជ្ញាមួយនៃអ្នកដឹកនាំនយោបាយរបស់ប្រទេសជាតិ ។"[៦២]

លោកបានពិពណ៌នាអំពីសភាពការណ៍នេះថា នៅពេលដែលជនទាំងឡាយត្រូវបាននគរបាល ឬកងរាជអាវុធហត្ថចាប់ខ្លួន ជនទាំងនោះត្រូវគេធ្វើទារុណកម្មឱ្យឆ្លើយសារភាពថាបានប្រព្រឹត្តបទល្មើស ដែលក្រោយមក ចំលើយសារភាពនេះត្រូវបានគេប្រើប្រាស់សំរាប់ធ្វើជាភស្តុតាងសំខាន់ក្នុងការកាត់ទោស ។ ក្រសួងយុត្តិធមិបានទទួលស្គាល់បញ្ហានេះ ដែលបានជំរុញព្រះរាជអាជ្ញា និងចៅក្រមនានា ឱ្យបដិសេធរាល់ភស្តុតាងរបស់នគរបាលដែលបានមកពីការធ្វើទារុណកម្ម ហើយធ្វើការចោទប្រកាន់អ្នកសួរចំលើយដែលបានធ្វើទារុណកម្មអ្នកជាប់ឃុំឃាំង និងដើម្បីស្វែងរកកិច្ចសហការពីនគរបាល កងរាជអាវុធហត្ថជាតិ និងក្រសួងមហាផ្ទៃ ដើម្បីនាំខ្លួនជនទាំងឡាយដែលទទួលខុសត្រូវ ក្នុងការធ្វើទារុណកម្មទៅតុលាការ ដើម្បីផ្តន្ទាទោសទៅតាមច្បាប់ ។ ក៏ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងទាំងនេះ មានប្រសិទ្ធិភាពនៅមានកំរិតនៅឡើយ ពីព្រោះតែមានការរារែកពីសំណាក់នគរបាល និងកងរាជអាវុធហត្ថជាតិតាមឋានានុក្រម ក្នុងការសហការជាមួយតុលាការនៅក្នុងករណីទាំងឡាយ ដែលមន្ត្រីក្រោមឱវាទរបស់ខ្លួនជាអ្នកទទួលខុសត្រូវ ចំពោះអំពើទារុណកម្មទាំងនោះ ។

ដោយកត់សំគាល់ឃើញថា ជំហានទី១នៃការការពារ ត្រូវបានធ្វើឡើង ដើម្បីស៊ើបអង្កេតឱ្យបានឆាប់រហ័សនូវរបាយការណ៍នានាដែលអាចជឿទុកចិត្តបាន ចំពោះករណីទាំងឡាយដែលពាក់ព័ន្ធដល់ការធ្វើទារុណកម្មដូចលោកតំណាងពិសេសបានបង្ហាញខាងលើ ។ របាយការណ៍មួយដែលបានដាក់ជូនរដ្ឋាភិបាលក្នុងខែមិថុនា ឆ្នាំ១៩៩៧ បានចងក្រងចំនួន៣២ករណីនៃជនជាប់ចោទ ដែលត្រូវគេរាយការណ៍ថាទទួលរងនូវការធ្វើទារុណកម្មនៅក្នុងមន្ទីរឃុំឃាំងរបស់នគរបាលក្នុងខេត្តបាត់ដំបង ។ គេមិនឃើញមានការឆ្លើយតបភ្លាម១នោះទេ ។

ពីរឆ្នាំក្រោយមក នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ លោកហាំម៉ាប៊ឹក បានជួបជាមួយអគ្គនាយកនគរបាលជាតិ ដែលលោកមានប្រសាសន៍ថា លោកបានចាប់ផ្តើមធ្វើការស៊ើបអង្កេតលើករណីទាំងនោះហើយ ហើយលោកបានប្រកាសថា មន្ត្រីនគរបាលណាម្នាក់ដែលគេរកឃើញថាទទួលខុសត្រូវចំពោះការធ្វើទារុណកម្ម

---

[៦១] នេះយោងលើមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលបានធ្វើវិសោធនកម្ម ក្នុងឆ្នាំ១៩៩៩ ។

[៦២] របាយការណ៍របស់លោកអគ្គលេខាធិការអ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា A/52/489 កថាខ័ណ្ឌទី៩៤ ។

ក្នុងករណីនេះត្រូវប្រឈមមុខនឹងការដាក់ទណ្ឌកម្ម ។ សេចក្តីណែនាំនេះត្រូវបានផ្ញើទៅនគរបាលទូទាំងប្រទេស ដើម្បីបញ្ឈប់សកម្មភាពបំពានច្បាប់ និងរំលោភសិទ្ធិប្រជាពលរដ្ឋ និងដើម្បីក្រើនរំលឹកថាមន្ត្រីនគរបាលណា ដែលមិនអនុវត្តតាមសេចក្តីណែនាំនេះ នឹងត្រូវទទួលទណ្ឌកម្ម ។

គំនិតផ្តួចផ្តើមនេះ ធ្វើឡើងស្របពេលគ្នាជាមួយនឹងដំណើរទស្សនកិច្ចរបស់អ្នកជំនាញការច្បាប់ព្រហ្មទណ្ឌអ.ស.ប ចំនួនពីររូប ។ អ្នកជំនាញការទាំងនេះ ត្រូវបាននគរបាលជំរាបប្រាប់តាមត្រង់ថា ការផ្តន្ទាទោសភាគច្រើនធ្វើឡើងតាមរយៈចំលើយសារភាព ប៉ុន្តែការរំលោភសិទ្ធិមនុស្សគឺបណ្តាលមកពីការខ្វះការបណ្តុះបណ្តាល ។ នៅពេលដែលទទួលស្គាល់ពីសេចក្តីត្រូវការឱ្យមានការបណ្តុះបណ្តាល អ្នកជំនាញការបានស្នើសុំឱ្យមន្ត្រីជាន់ខ្ពស់នានាបន្ថយការពឹងផ្អែកលើចំលើយសារភាព ។[៦៣]

នៅក្នុងខែកញ្ញា ឆ្នាំ១៩៩៩ នគរបាលជាតិបានចេញរបាយការណ៍របស់ខ្លួនពាក់ព័ន្ធនឹងការស៊ើបអង្កេតនៅក្នុងខេត្តបាត់ដំបង ។ របាយការណ៍បានធ្វើការឆ្លើយតបជាលំអិត ចំពោះករណីភាគច្រើន ផ្អែកលើមូលដ្ឋាននៃការសំភាសន៍ជាមួយនគរបាលសួរចំលើយ និងជនរងគ្រោះដោយការធ្វើទារុណកម្ម ។ របាយការណ៍បានដាក់បញ្ចូលនូវចំលើយរបស់ជនរងគ្រោះ ដែលចោទប្រកាន់ថាមានការធ្វើទារុណកម្ម ស្របជាមួយនឹងការបដិសេធរបស់នគរបាលថាមានការធ្វើទារុណកម្មនេះ ។ វាបានបង្ហាញពីសេចក្តីត្រូវការពង្រឹងវិស័យនានាផ្នែកបច្ចេក-ទេស និងបានផ្តល់អនុសាសន៍ដល់នគរបាលទទួលខុសត្រូវការពារអ្នកជាប់ឃុំឃាំងមិនឱ្យមានការធ្វើទុក្ខទោស ហើយត្រូវផ្តល់ការបណ្តុះបណ្តាលដល់នាយនគរបាលអំពីបច្ចេកទេសស៊ើបអង្កេត សួរចំលើយនិងប្រមូលភស្តុ-តាង ។ របាយការណ៍បានដាក់ចេញជាអនុសាសន៍សុំឱ្យបង្កើតក្រុមនីតិវិធីព្រហ្មទណ្ឌមួយ ដើម្បីពង្រឹងការស៊ើបអង្កេត ការគ្រប់គ្រង និងការចងក្រងឯកសារពាក់ព័ន្ធទៅនឹងករណីព្រហ្មទណ្ឌផ្សេងៗ ។

ទោះជាការស៊ើបអង្កេតនេះដែលភាគច្រើនគឺជាការស៊ើបអង្កេតទាំងស្រុង ព្រមជាមួយនិងអនុសាសន៍មានប្រយោជន៍ផ្សេងទៀតក៏ដោយ ក៏ការស៊ើបអង្កេតរបស់នគរបាលមិនបានរកឃើញថាមានការធ្វើទារុណ-កម្មនៅក្នុងករណីណាមួយឡើយ ។ របាយការណ៍បានបញ្ជាក់ថា "ការវាយដំ និងការប្រើពាក្យសំដីឃោរឃៅ "

---

[៦៣] *សូមមេត្តាអានរបាយការណ៍របស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ស្តីពីបេសកកម្មដើម្បីវាយតំលៃសភាពការណ៍បច្ចុប្បន្ននៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅប្រទេសកម្ពុជា*ចាប់ពីថ្ងៃទី១០-២២ ខែឧសភា ឆ្នាំ១៩៩៩ ដោយលោក Arun Bhagat អតីតនាយកការិយាល័យស៊ើបអង្កេតឥណ្ឌា និងលោក Eduardo Vetere មកពីផ្នែកការពារឧក្រិដ្ឋកម្ម និងត្រួតពិនិត្យគ្រឿងញៀនរបស់អ.ស.ប ប្រចាំនៅទីក្រុងវីយែន ។

អាចត្រូវគេប្រើប្រាស់ដើម្បីទាញយកចំលើយសារភាព នៅក្នុងករណីមួយចំនួន ប៉ុន្តែគេមិនចាត់ទុកបញ្ហានេះថាជារឿងធំដុំ សំរាប់ធ្វើការចោទប្រកាន់ ពីការធ្វើទារុណកម្មនោះទេ។ របាយការណ៍បានដាក់ចេញជាអនុ-សាសន៍ សូមកុំឱ្យដាក់ទណ្ឌកម្មខាងវិន័យទៅលើនគរបាលសួរចំលើយ ហើយដោយកថាហេតុមិនត្រូវធ្វើការចោទប្រកាន់ ឬដាក់ទណ្ឌកម្មខាងវិន័យចំពោះសកម្មភាព នៃការធ្វើទារុណកម្មណាមួយដែលបានរាយការណ៍នៅក្នុងអនុសាសន៍ឡើយ។

ដោយមានរបាយការណ៍ជាច្រើនផ្ទុយគ្នាបែបនេះ ទើបការិយាល័យប្រចាំនៅកម្ពុជាបានបន្តទទួលរបាយការណ៍ស្តីពីការធ្វើទារុណកម្ម និងការធ្វើទុក្ខទោសផ្សេងៗទៀត។

*ii. ការសំលាប់ភ្លាមៗគួរឱ្យរន្ធត់*

ទិសដៅស៊ើបអង្កេតផ្សេងគ្នាមួយបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ នៅក្នុងការឆ្លើយតបរបស់នគរ-បាលទៅនឹងអនុសាសន៍លើកទីពីរ របស់លោកហាំម៉ាប៊ឺក ដែលមានចំនួន ៤០ករណី នៃការសំលាប់ក្រៅច្បាប់ដោយហេតុផលនយោបាយដែលបានកើតមានបន្ទាប់ពីមានរដ្ឋប្រហារយោធាក្នុងខែកក្កដា ឆ្នាំ១៩៩៧។ លោកហាំម៉ាប៊ឺក បានដាក់ករណីទាំងនេះជូនរដ្ឋាភិបាល កាលពីខែសីហា ឆ្នាំ១៩៩៧។[៦៤] បន្ទាប់ពីលោកហ៊ុន សែនអតីតនាយករដ្ឋមន្ត្រីទី២ បានធ្វើការអំពាវនាវដល់អង្គការសិទ្ធិមនុស្សនានា សូមឱ្យផ្តល់ព័ត៌មានទៅរដ្ឋាភិបាលបន្ទាប់ពីព្រឹត្តិការណ៍រដ្ឋប្រហារ ខែកក្កដា ឆ្នាំ១៩៩៧ ដើម្បីអាចធ្វើការទប់ស្កាត់អំពើរំលោភច្បាប់"។

ការមិនបានធ្វើការស៊ើបអង្កេតដ៏មានប្រសិទ្ធិភាពទៅលើករណីទាំងឡាយដែលកើតមាននេះ បង្ហាញឱ្យឃើញច្បាស់នៅក្នុងរបាយការណ៍របស់អ្នកជំនាញនគរបាលពីររូបរបស់អ.ស.ប ដែលបានមកធ្វើទស្សនកិច្ចនៅកម្ពុជា ក្នុងខែឧសភា ឆ្នាំ១៩៩៨។ មន្ត្រីទាំងនេះមានអាណត្តិ ដើម្បីបញ្ជាក់អំពីការរីកចំរើន ដែលនគរបាលកម្ពុជាធ្វើការស៊ើបអង្កេតករណីទាំងនេះ ហើយនៅក្នុងការស៊ើបអង្កេតលើការវាយប្រហារដោយគ្រាប់បែកដៃ

[៦៤] សូមមេត្តាមើលអត្ថបទខាងលើ ទំព័រទី១៤ និងទី១៥។

នៅពេលកន្លងមកនេះ ទៅលើហ្វូងបាតុករ កាលពីខែមីនា ឆ្នាំ១៩៩៧ ដែលបានសំលាប់មនុស្សជាង១៤ នាក់ និង ១៤២ នាក់ទៀតត្រូវរងរបួស ។[៦៥]

ដំបូងអ្នកជំនាញការអ.ស.ប បានពិចារណាអំពីរបៀបស៊ើបអង្កេតរបស់នគរបាល លើករណីវាយប្រ-ហារដោយគ្រាប់បែកដៃ និងអំពីគោលដៅផ្សេងៗទៀត ដែលត្រូវបានអនុវត្ត ឧទាហរណ៍ ការកំណត់អត្ត-សញ្ញាណរបស់សាក្សីផ្ទាល់ភ្នែកដែលមានវត្តមាននៅពេលនោះ និងការប្រមូលភស្តុតាងក្បាលគ្រាប់ ។ អ្នកជំនាញទាំងនោះបានធ្វើសេចក្តីសន្និដ្ឋានថា ការខ្វះធនធានមិនមែនជាហេតុផលចំបងសំរាប់ភាពមិនពេញលេញក្នុងការស៊ើបអង្កេតនោះទេ ដោយបានបញ្ជាក់ថា "ទោះបីជាខ្វះការបណ្តុះបណ្តាលផ្នែកកោសល្យវិច័យ និងបទពិសោធន៍ក្នុងការស៊ើបអង្កេតក៏ដោយ....គោលដៅដ៏ទូលំទូលាយ និងមាំមួនជាងនេះ គួរតែអាចទទួលបានលទ្ធផលហើយ បើគិតមកទល់ពេលនេះ" ។

បន្ទាប់មក អ្នកជំនាញការទាំងនោះបានពិភាក្សាជាមួយមន្ត្រីជាន់ខ្ពស់នគរបាល អំពីមរណភាពរបស់លោក ហូ សុខ[៦៦] ដែលករណីរបស់គាត់ត្រូវបានរៀបរាប់ពីខាងដើមរួចមកហើយ គឺជាមនុស្សដែលមានក្នុងបញ្ជីអនុសាសន៍របស់លោកហាំម៉ាប៊ឺក ។ លោកហូ សុខ គឺជារដ្ឋលេខាធិការក្រសួងមហាផ្ទៃហើយក៏ជាទីប្រឹក្សាជាន់ខ្ពស់មួយរូបផងដែររបស់គណៈបក្សហ៊្វុនស៊ីនប៉ិច ។

អ្នកជំនាញការទាំងនេះ បានជួបជាមួយមន្ត្រីជាន់ខ្ពស់មួយរូប ដែលបានចាប់ខ្លួនលោក ហូ សុខ ។ លោកវរៈសេនីយ៍ឯក ដារ៉ា បានប្រាប់អ្នកជំនាញការថា បន្ទាប់ពីការចាប់ខ្លួនមក លោកបានទាក់ទងជាមួយមន្ត្រីជាន់ខ្ពស់ដែលបានធ្វើការណែនាំគាត់ឱ្យទៅចាប់ខ្លួន ។ លោកបានសួរថា តើគួរចាត់វិធានការអ្វីតទៅទៀត ព្រោះដោយសារមិនមានករណីចោទប្រកាន់លើលោក ហូ សុខ ហើយគាត់ក៏មិនត្រូវបានចោទប្រកាន់ពីបទ

---

[៦៥] សូមមើលរបាយការណ៍របស់អ្នកជំនាញៈ *ការវាយប្រហារដោយគ្រាប់បែកនៅទីក្រុងភ្នំពេញ កាលថ្ងៃទី៣០ខែមីនា ឆ្នាំ១៩៩៧ និងការសំលាប់ក្រៅច្បាប់ថ្ងៃទី២-៧ ខែកក្កដា ឆ្នាំ១៩៩៧: ការវាយតំលៃលើការស៊ើបអង្កេត*ខែឧសភា ឆ្នាំ១៩៩៨ ។ អ្នកជំនាញការទាំងនោះមានៈ លោក Arun Bhagat អតីតនាយកការិយាល័យស៊ើបអង្កេតឥណ្ឌា និង លោកសាស្ត្រាចារ្យ Prof. Peter Burns QC សមាជិកកាណាដានៃគណៈកម្មាធិការUNCAT ។ អាណត្តិរបស់ពួកគេ បានស្នើឱ្យពួកគេ ជួយដល់រដ្ឋាភិបាលក្នុងការកំណត់នូវអ្វីដែលជាសេចក្តីត្រូវការសំរាប់ការពង្រឹងគុណភាពនៃការស៊ើបអង្កេត ។

[៦៦] សូមមើលខាងលើ ផ្នែកទី៥ ។

ល្មើសអ្វីមួយនោះក៏ទេដែរ ។ នៅក្នុងខណៈពេលដែលគេនាំលោក ហូ សុខ ទៅកាន់បន្ទប់មួយនៅនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នៅទីនោះមានវត្តមាននគរបាលពីរនាក់ស្លៀកពាក់ធម្មតា គ្មានអាវុធ ។ បន្ទាប់មកមានទាហានម្នាក់ ស្លៀកពាក់ឯកសណ្ឋានប៉ារ៉ា  ដែលមានឆ្នូតក្រហមមួយលើ កអាវ/ស្មា បានដើរចូលទៅក្នុងបន្ទប់ ហើយបានបាញ់លោកហូ សុខ ដោយកាំភ្លើងអាកា៤៧ ដោយស្រែកយ៉ាងខ្លាំងថា គាត់ទទួលខុសត្រូវចំ-ពោះការសំលាប់គ្រួសារទាហានម្នាក់ ។ ទោះបីជាមានទាហានពី៥០-៦០នាក់នៅខាងក្រៅអាគារនោះក្តី អ្នកបាញ់ប្រហារនៅតែអាចលោតផ្លោះជញ្ជាំងរបងបរិវេណ ហើយបានគេចខ្លួនបាត់ទៅ ។ នៅល្ងាចនោះ អ្នកធ្វើកោសល្យវិច័យមួយក្រុម បានមកពិនិត្យកន្លែងកើតហេតុ ហើយបានរកឃើញសំបកគ្រាប់ និងក្បាលគ្រាប់បាញ់ហើយ ចំនួនមួយគ្រាប់ ។ មន្ត្រីពេទ្យបានពិនិត្យសាកសព ប៉ុន្តែមិនបានធ្វើការវះកាត់សាកសពនោះទេ ។ នគរបាលពីរនាក់ ដែលនៅក្នុងបន្ទប់នៅពេលនោះ ត្រូវគេអះអាងថាមានការភ័យរន្ធត់ជាខ្លាំង មិនអាចធ្វើការរៀបរាប់ឱ្យបានសមស្របពីជនជាប់ចោទនោះទេ ។ លុះដល់ព្រឹកព្រលឹមថ្ងៃបន្ទាប់មក  គេបានយកសាកសពទៅបូជា ដោយគ្មានលិខិតអនុញ្ញាតបូជាសព ដែលតាមធម្មតា គេតម្រូវឱ្យមានលិខិតនេះមុននឹងបូជាសព ។

កាលពីថ្ងៃទី១៤ ខែកក្កដា គណៈកម្មការស៊ើបសួរមួយត្រូវបានបង្កើតឡើង ។ ទោះបីជាសមាជិកជាន់ខ្ពស់នៃនាយកដ្ឋានកណ្តាលនគរបាលព្រហ្មទណ្ឌ ត្រូវបានព្យួរពីការងារដោយសារការធ្វេសប្រហែសក្នុងការផ្តល់ការការពារដល់លោកហូ សុខ គេមិនឃើញមានការចាត់វិធានការណាមួយផ្សេងទៀតនោះទេ ។ លុះក្រោយមក មន្ត្រីម្នាក់ដែលគេព្យួរពីការងារ ត្រូវបានទទួលការតែងតាំងជាសមាជិកគណៈកម្មការមួយថ្មី ។

អ្នកជំនាញការបានកត់ត្រាយោបល់របស់ពួកគេថា មិនមានការស៊ើបអង្កេតនោះឡើយ "ដែលបើតាមផ្លូវច្បាប់ គឺត្រូវតែធ្វើការស៊ើបអង្កេត" ។ ពួកគេយល់ថា អ្នកស៊ើបអង្កេត គួរតែអាចកំណត់ពីអង្គភាពយោធា ដែលបានដាក់ពង្រាយកំលាំងនៅថ្ងៃនោះ នៅក្នុងក្រសួងមហាផ្ទៃ ។ វាទំនងជាអ្នកបាញ់ប្រហារនោះជាទាហាននៅក្នុងអង្គភាពនេះតែម្តង ។  កាលបើគេរកឃើញអង្គភាពនោះហើយ  ភស្តុតាងកោសល្យវិច័យអាចឈានទៅកំណត់ពីអាវុធ គេបានប្រើប្រាស់សំរាប់សំលាប់លោក ហូ សុខ ពីព្រោះគេបានរកឃើញសំបកគ្រាប់បាញ់ចេញចំនួនបីគ្រាប់ និងក្បាលគ្រាប់ចំនួនមួយ នៅកន្លែងកើតហេតុ ។ ការស៊ើបអង្កេតមិនបានឈានទៅដល់កាលៈទេសៈសង្ស័យអំពីការបូជាសពដោយទាហានជាច្រើននាក់ស្លៀកពាក់ឯកសណ្ឋាននៅវេលាម៉ោង៣:០០ ព្រឹកនោះទេ ។ បើតាមសេចក្តីរាយការណ៍ថា មានចេញលិខិតមរណៈភាព និងលិខិតបូជាសព ប៉ុន្តែមិនមានការស៊ើបអង្កេតធ្វើឡើងជាខ្សែសង្វាក់នោះទេ ទោះជាលិខិតមរណៈភាពត្រូវបានចេញក្នុងភាពមិនប្រក្រតី

បន្ទាប់ពីការបូជាសពក៏ដោយ ។ ការដែលនគរបាល និងទាហានខកខានមិនបានតាមចាប់ខ្លួនឃាតករ មិនមានការពន្យល់អំពីបញ្ហានេះទេ ថ្វីបើមាននគរបាលជាច្រើននាក់ស្ថិតនៅខាងក្រៅអាគារ និងហេតុដែលថា ជញ្ជាំងរបងបរិវេណអាគារស្ថិតនៅជិតបំផុត ចំងាយប្រមាណជា២០០-២៥០ម៉ ពីទីនោះ ។ នេះបានបង្ហាញយ៉ាងច្បាស់ថា ការខកខានមិនបានធ្វើការស៊ើបអង្កេតនេះ មិនទាក់ទងជាចំបងទៅនឹងការខ្វះធនធាននោះទេ ។

បន្ទាប់មកអ្នកជំនាញការបានពិភាក្សាអំពីករណីដទៃទៀត នៃការសំលាប់ក្រៅច្បាប់ដែលបានកត់ត្រានៅក្នុងអនុសាសន៍របស់លោកហាំម៉ាប៊ឺក ជាមួយមន្ត្រីនគរបាលជាន់ខ្ពស់ ក៏ដូចជា ជាមួយមន្ត្រីកងរាជអាវុធហត្ថជាតិ  អយ្យការស៊ីវិល  និងអយ្យការយោធា ។ អ្នកជំនាញការបានធ្វើការសន្និដ្ឋានថា គ្មានករណីណាមួយត្រូវបានស៊ើបអង្កេត ឬកំពុងត្រូវបានស៊ើបអង្កេតយ៉ាងហ្មត់ចត់នោះទេ ។ អ្នកជំនាញការបានរាយការណ៍ថា ពួកគេមិនអាចកំណត់ថា តើអយ្យការយោធា ឬអយ្យការស៊ីវិល ជាអ្នកមានសមត្ថកិច្ចលើយោធិនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ នៅពេលដែលស្ថាប័នទាំងពីរនេះបានអះអាងថា ខ្លួនមានសមត្ថកិច្ច ប៉ុន្តែគ្មានស្ថាប័នណាមួយនៃស្ថាប័នទាំងពីរនេះ បានធ្វើការស៊ើបអង្កេតលើករណីទាំងនេះទេ ។ អយ្យការយោធាបានបញ្ជាក់ថាស្ថាប័នរបស់ខ្លួនមានសមត្ថកិច្ច ក៏ប៉ុន្តែខ្លួនមិនអាចចាត់វិធានការណាមួយបាន ដោយគ្មានបញ្ជាពីអគ្គសេនាធិការបានឡើយ ហើយកន្លងមកគេមិនដែលបានទទួលបញ្ជាណាមួយពីអគ្គសេនាធិការទេ ។ អយ្យការស៊ីវិលយល់ច្បាស់ថា ខ្លួនមានសមត្ថកិច្ចលើករណីរឿងទាំងអស់ដែលពាក់ព័ន្ធនឹងយោធិន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ  ប៉ុន្តែមិនបានធ្វើការស៊ើបអង្កេតករណីណាមួយឡើយ ។

នៅក្នុងសន្ទរកថាបិទរបស់ខ្លួន អ្នកជំនាញការបានកត់សំគាល់ថា ការស៊ើបអង្កេតត្រូវបានព្យាយាមធ្វើនៅក្នុងករណីរឿងតែពីរគត់ នៅក្នុងអនុសាសន៍ ហើយក៏គ្មានការចាប់ខ្លួនអ្នកណាម្នាក់ដែរ ។ ពួកគេយល់ថា ការស៊ើបអង្កេតទាំងពីរនេះបានបង្ហាញពី "ការខ្វះភាពខ្លាំងក្លា និងការប្ដេជ្ញាចិត្ត" ។

គេបានប្រាប់ លោក ហាំម៉ាប៊ឺក ថា ការស៊ើបអង្កេតលើករណីមរណៈភាពរបស់លោក ហូ សុខ "ត្រូវបានបញ្ឈប់"ហើយ ហើយគេបានទទួលព័ត៌មានពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ថា  គាត់មិនបានទទួលការណែ

នាំពីគណៈរដ្ឋមន្ត្រី ដើម្បីបើកសម័យប្រជុំគណៈកម្មាធិការអន្តរក្រសួងមួយ ដើម្បីស៊ើបអង្កេតករណីទាំងនេះទេ។ ទាំងនេះបានបង្ហាញពី "ការខ្វះភាពមុតមាំ" ។[៦៧]

*iii. ពន្ធនាគារនានា*

នៅក្នុងរបាយការណ៍របស់ខ្លួន លោកតំណាងពិសេសទាំងអស់ បានទាញការចាប់អារម្មណ៍ជានិច្ចទៅលើវិស័យផ្សេងៗ ដែលអនុវត្តដោយខ្វះខាតធនធាន គ្មានបទបញ្ជាផ្ទៃក្នុងពន្ធនាគារ ឬមានតែនៅខ្សោយ និងសកម្មភាពរបស់មន្ត្រីនានា ក្នុងការកំណត់កំរិតនៃការគោរពសិទ្ធិមនុស្សនៅក្នុងពន្ធនាគារ ។

លោកបានទាញការចាប់អារម្មណ៍ចំពោះ ផលវិបាកដែលកើតមាន ដោយសារការផ្តល់ថវិកាមិនគ្រប់គ្រាន់ ដែលជារឿយៗនាំឱ្យអ្នកទោសទទួលទានអាហារមិនគ្រប់គ្រាន់ នាំអោយកើតមានបញ្ហាសុខភាព ហើយអនុរក្សពន្ធនាគារមិនបានទទួលប្រាក់បៀវត្សទាន់ពេលវេលា ហើយអ្នកខ្លះមិនមកធ្វើការ ។ ដោយសារតែមានអនុរក្សពន្ធនាគារមួយចំនួនតូចមកធ្វើការ ទើបមានអ្នកទោសដែលអត់ឃ្លាន និងអស់សង្ឃឹម បានខិតខំព្យាយាមរត់ចេញពីគុកជាច្រើនលើកច្រើនសារ ហើយមានអ្នកទោសជាច្រើននាក់ត្រូវបានបាញ់ឱ្យស្លាប់ ឬរងរបួស ។[៦៨] ការមិនបានផ្តល់ថវិកាគ្រាប់គ្រាន់សំរាប់ដឹកជញ្ជូន មានន័យថាអ្នកទោសត្រូវតែចេញចំណាយទៅលើមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន និងត្រូវចេញចំណាយសំរាប់នគរបាលដែលអមដំណើរពួកគេ ហើយពួកគេមិនអាចមានលទ្ធភាពចូលរួមក្នុងសវនាការរបស់ខ្លួនបានឡើយ ។[៦៩] ជាលទ្ធផល សវនាការត្រូវបានធ្វើឡើងដោយកំបាំងមុខ ។ ហេតុនេះហើយ អ្នកទោសត្រូវបានគេបដិសេធសិទ្ធិទាំងស្រុង ក្នុងការប្តឹងតវ៉ាពីទោសរបស់ខ្លួនទៅសាលាឧទ្ធរណ៍ ។[៧០]

---

[៦៧] ក្រសួងមហាផ្ទៃបានអះអាងថា ករណីនេះ បាននឹងកំពុងបន្តធ្វើការស៊ើបអង្កេតតទៅទៀត ។ *ក្នុងសៀវភៅដដែល* កំណត់សំគាល់ទី៨ ។

[៦៨] សូមមើលរបាយការណ៍លេខ A/53/489 កថាខ័ណ្ឌទី៩៧ ។

[៦៩] សូមមើលរបាយការណ៍លេខ E/CN.4/2004/114 កថាខ័ណ្ឌទី៣៥ ។

[៧០] នៅចន្លោះខែសីហា និង ខែវិច្ឆិកា ឆ្នាំ១៩៩៩ ក្នុងចំណោមអ្នកទោសទាំងអស់ ៣០ករណី មានតែអ្នកទោសចំនួន ៦ករណីប៉ុណ្ណោះដែលសាលាឧទ្ធរណ៍បានបើកសវនាការ ។

នៅក្នុងឆ្នាំ១៩៩៧ លោក ហាំម៉ាប៊ឹក បានទាញការយកចិត្តទុកដាក់ចំពោះហេតុដែលគ្មានបទបញ្ជាពន្ធនាគារនៅក្នុងប្រទេសកម្ពុជា។[៧១] នេះមានន័យថា ពន្ធនាគារនៅប្រទេសកម្ពុជាកំពុងដំណើរការដោយភាពគ្មានច្បាប់គ្រប់គ្រង។ មិនមានវិធាន និងនិយាមជាមូលដ្ឋានច្បាស់លាស់សំរាប់ការផ្តល់ម្ហូបអាហារ ការថែទាំសុខភាព វិន័យ និងការគ្រប់គ្រង។ ជាលទ្ធផល មានអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុត និងករណីនិទណ្ឌភាពមួយចំនួន បានកើតមាននៅក្នុងពន្ធនាគារនានា។

នៅក្នុងឆ្នាំ១៩៩៩ នីតិវិធីពន្ធនាគារថ្មីមួយ ត្រូវបានអនុម័ត។ ក្នុងឆ្នាំ២០០២ លោកភីធឺរ ល័យប្រេកតឺ បានដឹកនាំឱ្យមានការអនុវត្តន៍មួយ ដើម្បីត្រួតពិនិត្យពីស្ថានភាពពន្ធនាគារ ហើយធ្វើការប្រៀបធៀបស្ថានភាពនេះ ទៅនឹងស្ថានភាពពន្ធនាគារក្នុងឆ្នាំ១៩៩៤។ លោកបានសំគាល់ឃើញមានបញ្ហាធំៗ ដែលនៅតែមាននៅឡើយ ដូចជា: បញ្ហាសុខភាពនៅមានកំរិតទន់ខ្សោយ ខ្វះម្ហូបអាហារ ទឹក និងអនាម័យ ការឃុំខ្លួនបណ្តោះអាសន្នហួសរយៈពេលដែលច្បាប់កំណត់ សវនាការកំបាំងមុខនិងការកំរិតសិទ្ធិប្តឹងឧទ្ធរណ៍ព្រមទាំងការដាក់កំហិតយ៉ាងតឹងរឹងដល់មេធាវី ក្រុមគ្រួសារ និង អង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការចូលជួបអ្នកជាប់ ពន្ធនាគារ។[៧២]

លោកក៏បានទាក់ទាញការចាប់អារម្មណ៍នៅក្នុងរបាយការណ៍នេះ ចំពោះ " ករណីសាកល្បងមួយ "នៃនិទណ្ឌភាព : ការជំនុំជំរះអនុរក្សពន្ធនាគារប្រាំនាក់នៃពន្ធនាគារខេត្តកំពង់ចាម ពីបទបង្ករបួសស្នាមទៅលើអ្នកទោសប្រាំនាក់ ទង្វើទាំងនេះធ្វើឡើងនៅចំពោះមុខប្រធានពន្ធនាគារ។ ទោះបីជាមានភស្តុតាងដែលលោកលយប្រែកតឺ យល់ថាពិតជាគ្រប់គ្រាន់សំរាប់ធ្វើការចោទប្រកាន់ហើយក៏ដោយ ក៏ចុងចោទទាំងនេះត្រូវបានតុលាការលើកលែងការចោទប្រកាន់នៅក្នុងសវនាការរបស់ខ្លួននៅក្នុងឆ្នាំ២០០២។ ទោះបីជាតុលាការបានធ្វើការណែនាំឱ្យចាត់វិធានការខាងវិន័យក្តី មន្ត្រីបីនាក់ក្នុងចំណោមនោះបានបន្តធ្វើការនៅក្នុងពន្ធនាគារដដែល។ ក្នុងករណីនេះ ជនរងគ្រោះបានប្តឹងឧទ្ធរណ៍ពីសេចក្តីសំរេចរបស់តុលាការនេះ ទៅសាលាឧទ្ធរណ៍ហើយ។

---

[៧១] សូមមើលរបាយការណ៍លេខ A/53/498 កថាខ័ណ្ឌទី១០៩ ។

[៧២] *ស្ថានភាពពន្ធនាគារកម្ពុជា ឆ្នាំ១៩៩៤* : ឆ្ពោះទៅកាន់គោលនយោបាយពន្ធនាគារមួយ ដែលមានលក្ខណៈមនុស្សធម៌សំរាប់ប្រទេសកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០០២។

### *iv. ប្រព័ន្ធច្បាប់ : តុលាការ*

ការលំបាកដែលអាជ្ញាធរកម្ពុជាបានជួបប្រទះ នៅក្នុងអំឡុងពេលចាប់ពីឆ្នាំ១៩៩៣ គឺជាការធ្វើកំណែទម្រង់ប្រព័ន្ធតុលាការមួយដែលទន់ខ្សោយ មិនមានការបណ្តុះបណ្តាល និងវិចរិល ដែលមានប្រវត្តិនៃដំណើរការស្ថិតនៅក្រោមការដឹកនាំផ្នែកនយោបាយ ឱ្យទៅជាប្រព័ន្ធតុលាការមួយដែលឯករាជ្យ ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ និងតាមការតម្រូវដោយច្បាប់អន្តរជាតិ។

ការរីកចំរើនឆ្ពោះទៅសំរេចបាននូវគោលដៅនេះ ត្រូវបានធ្វើការវាយតំលៃនៅក្នុងឆ្នាំ១៩៩៩ នៅពេលដែលមានរបាយការណ៍មួយស្តីពីស្ថានភាពតុលាការកម្ពុជា និងប្រព័ន្ធច្បាប់ ត្រូវបានដាក់បង្ហាញជូនលោកអគ្គលេខាធិការអ.ស.ប ដោយអ្នកជំនាញការមួយក្រុម ដែលមានអាណត្តិស្វែងរកជំរើសច្បាប់ផ្សេងៗ ដើម្បីនាំខ្លួនមេដឹកនាំខ្មែរក្រហមទៅតុលាការ ដើម្បីកាត់ទោសទៅតាមផ្លូវច្បាប់។[៧៣] អ្នកជំនាញការទាំងនោះ បានពិចារណាថា តើគេ "អាច" រៀបចំធ្វើការជំនុំជំរះក្តីនៅក្នុងតុលាការកម្ពុជា ឬគេគួរតែបង្កើតតុលាការអន្តរជាតិមួយនៅខាងក្រៅប្រទេសកម្ពុជាវិញ។

ពួកគេបានធ្វើការសន្និដ្ឋានថា ការជំនុំជំរះក្តី មិនគួរធ្វើនៅប្រទេសកម្ពុជាទេ ពីព្រោះតុលាការកម្ពុជាស្ថិតក្នុងស្ថានភាពបច្ចុប្បន្នរបស់ខ្លួន មិនទំនងជាបំពេញបាននូវបទដ្ឋានអន្តរជាតិអប្បបរមានៃយុត្តិធម៌នោះទេ សូម្បីតែមានការជួយឧបត្ថម្ភពីមជ្ឈដ្ឋានខាងក្រៅក៏ដោយ។ អ្នកជំនាញការទាំងនោះបានធ្វើការពិពណ៌នាពីកិច្ចដំណើរការនៃប្រព័ន្ធតុលាការកម្ពុជាថា "មានភាពទន់ខ្សោយ នៅក្នុងវិស័យសំខាន់ៗជាច្រើន" ហើយបានធ្វើការកត់សំគាល់ថា រដ្ឋាភិបាលដែលកើតឡើងក្រោយឆ្នាំ១៩៩៣ មិនទាន់បានអនុម័តច្បាប់លំអិតជាច្រើន ស្តីពីការចាត់តាំងប្រព័ន្ធតុលាការទេ។ អ្នកជំនាញការបានទទួលស្គាល់ពីបច្ច័យនៃប្រវត្តិសាស្ត្រនិងភាពក្រីក្រដោយបានពិពណ៌នាអំពីហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធច្បាប់ថា មានភាពទន់ខ្សោយ "ជាប្រទេសមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយលើពិភពលោក តុលាការខ្វះខាតសៀវភៅច្បាប់ផ្សេងៗ ម៉ាស៊ីន អង្គុលីលេខ និងសំភារៈចាំបាច់ជាមូលដ្ឋានមួយចំនួនទៀត ជាពិសេស នៅតាមបណ្តាខេត្តនានា។ អាគារតុលាការ មានសភាពទ្រុឌទ្រោម។ ពន្ធនាគារនានា មានសភាពចាស់ខ្លាំងពេក"។

[៧៣] *កម្ពុជា : របាយការណ៍របស់ក្រុមអ្នកជំនាញការសំរាប់កម្ពុជា លេខ* A/53/850 ចុះខែកុម្ភៈ ឆ្នាំ១៩៩៩។

ប៉ុន្តែទន្ទឹងនឹងស្ថានភាពរិចរិលខ្លាំងនេះ ពួកគេក៏បានកត់សំគាល់ឃើញថា :

"ប្រទេសកម្ពុជា នៅខ្វះខាតនូវវប្បធម៌នៃការគោរពចំពោះប្រព័ន្ធតុលាការព្រហ្មទណ្ឌមួយ ដែលមិនលំអៀង ។ តុលាការព្រហ្មទណ្ឌ ទទួលបានតែមួយភាគ នៃមួយភាគរយនៃថវិកាជាតិប៉ុណ្ណោះ ហើយចៅក្រមទទួលប្រាក់បៀវត្សបន្តិចបន្តួចប្រមាណ ២០ដុល្លារ ក្នុងមួយខែប៉ុណ្ណោះ ។ ជាបច្ច័យ ទោះបីជាមានបុគ្គលមួយចំនួនមានលក្ខណៈសម្បត្តិល្អនៅក្នុងតុលាការក៏ដោយ ក៏ជាទូទៅគេជឿថាចៅក្រមខ្លះអាចត្រូវចុងចោទ ឬដើមចោទទិញបានយ៉ាងងាយដែរ ។ ចៅក្រមភាគច្រើនលើសលុប មានជាប់ពាក់ព័ន្ធជិតស្និទ្ធផងដែរ ជាមួយគណៈបក្សប្រជាជនកម្ពុជា ។ បុគ្គលមួយចំនួន ដែលមានអំណាចក្នុងជួររដ្ឋាភិបាល ដូចជាឥស្សរៈជននយោបាយសំខាន់ៗ ប្រព័ន្ធសន្តិសុខ និងក្រសួងយុត្តិធម៌ ត្រូវបានគេស្គាល់ជាទូទៅថាបានប្រើឥទ្ធិពលទៅលើសេចក្តីសំរេចនានារបស់ចៅក្រមស៊ើបអង្កេត និងសាលាជំរះក្តី ។ ទាំងនេះរួមមាន ការគំរាមកំហែងនិងការវាយប្រហារទៅលើរូបរាងកាយចៅក្រម ឬនៅក្នុងចំណោមចៅក្រមដទៃទៀត គេគ្រាន់តែដឹងថា រយៈពេលកាន់មុខតំណែង ហើយតាមធម្មតា ជីវភាពរស់នៅរបស់ពួកគេនៅថ្ងៃអនាគត គឺពឹងផ្អែកទាំងស្រុងទៅលើការយល់ព្រមពីសំណាក់ឥស្សរជននយោបាយនានា ។ ម្យ៉ាងទៀត មេធាវីការពារក្តីព្រហ្មទណ្ឌ ទោះបីជាពួកគេបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវហើយក៏ដោយ ក៏ត្រូវគេធ្វើឱ្យរាំងស្ទះការងាររបស់ខ្លួនដែរ ។ មេធាវីទាំងនោះ បាននិយាយថា ចៅក្រមនានាយកចិត្តទុកដាក់តិចតួចបំផុត ចំពោះអំណះអំណាងផ្អែកច្បាប់របស់ពួកគេ ទោះជានៅក្នុងករណីដដែលៗក្តី ។ តុលាការ និងនគរបាល ដាក់កំហិតដល់ការជួបប្រាស្រ័យទាក់ទងរបស់គេ ជាមួយកូនក្តីរបស់គេ សូម្បីតែនៅក្នុងពេលសវនាការក៏ដោយ ។ មេធាវីការពារក្តីក៏អាចប្រឈមមុខនឹងការគំរាមកំហែងពីសំណាក់គ្រួសារ និងមិត្តភក្តិជនរងគ្រោះផងដែរ ។ ការប្រព្រឹត្តទៅលើពិរុទ្ធជន ដែលរង់ចាំការកាត់សេចក្តី ឬអ្នកទោសនៅក្នុងពន្ធនាគារ នៅតែស្ថិតនៅឆ្ងាយក្រោមបទដ្ឋានអន្តរជាតិនៅឡើយ ។ សរុបសេចក្តីមក ប្រព័ន្ធតុលាការកម្ពុជាស្ថិតនៅឆ្ងាយពីបទដ្ឋានអន្តរជាតិ ស្តីពីយុត្តិធម៌ព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងនៅក្នុងឯកសារដទៃទៀត" ។[៧៤]

នៅពេលដែលគណៈកម្មការសិទ្ធិមនុស្សធ្វើការពិចារណាទៅលើវិធានការនានា ដែលប្រទេសកម្ពុជាបានធ្វើឡើងដើម្បីអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាទូទៅ បញ្ហានេះកើតមានស្របពេលគ្នាជាមួយនឹងការវាយតំលៃដ៏ខ្លាំងក្លានេះ ។ គណៈកម្មការបានកត់សំគាល់ផងដែរថា ឧត្តមក្រុម

---

[៧៤] សៀវភៅដដែល កថាខ័ណ្ឌទី១២៩ ។

ប្រឹក្សានៃអង្គចៅក្រម មិនមានភាពឯករាជ្យ ទទួលឥទ្ធិពលពីរដ្ឋាភិបាល ហើយមិនបានបង្ហាញថាខ្លួនអាចដោះស្រាយបណ្តឹងជាច្រើន អំពីអសមត្ថភាព និង អាកប្បកិរិយាអសីលធម៌របស់ចៅក្រមបានឡើយ ។[៧៥] លោកតំណាងពិសេស និងគណៈកម្មការសិទ្ធិមនុស្ស បានផ្តល់អនុសាសន៍ស្របគ្នា (ដែលកន្លងមកមិនបានទទួលលទ្ធផលអ្វីសោះ)ថា ការដែលចៅក្រមនានាមានសមាជិកភាពនៅក្នុងគណៈបក្សនយោបាយផ្សេងៗ គឺមានវិសមិតភាពជាមួយឯករាជ្យភាពរបស់តុលាការ ហើយការនេះគួរតែត្រូវបានហាមឃាត់ ។[៧៦]

ព្រះរាជអាជ្ញាកម្ពុជាបានជំរាបជូនអ្នកជំនាញការអ.ស.ប (នៅក្នុងឆ្នាំ១៩៩៩ ផងដែរ) ថា ខ្លួនមិនអាចចេញដីកាកោះ ឬធ្វើការចាប់ខ្លួនសមាជិកនៃកងកំលាំងប្រដាប់អាវុធដែលជាប់ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ និងករណីផ្សេងទៀត ដែលបានចោទប្រកាន់ទៅលើសមាជិកនៃកងកំលាំងប្រដាប់អាវុធដែលប្រព្រឹត្តបទល្មើសដោយគេចាត់ទុកទង្វើនេះថាជាការ"ធ្វេសប្រហែស" ។ នៅក្នុងឆ្នាំ២០០២ លោកភីធឺរ លយប្រែកតឺ បានជួបជាមួយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលគាត់បានរៀបរាប់ផងដែរអំពី "ភាពសោះកក្រោះនៃស្ថានភាពប្រព័ន្ធតុលាការថា ឯករាជ្យភាពរបស់តុលាការត្រូវបានគំរាមកំហែងជារឿយៗ ពីសំណាក់អំណាចនីតិប្រតិបត្តិ និងផ្នែកឯកជនដែលមានអំណាច" ។[៧៧]

គេត្រូវគត់សំគាល់ពីការផ្លាស់ប្តូរចំនួនពីរ លើកទីមួយគឺមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលជាកម្មវត្ថុនៃការទិទៀនឥតឈប់ឈរ ពីសំណាក់លោកតំណាងពិសេសនានា និងគណៈកម្មការសិទ្ធិមនុស្ស ។ ច្បាប់នេះ ត្រូវបានធ្វើវិសោធនកម្ម នៅក្នុងខែកញ្ញា ឆ្នាំ១៩៩៩ ។ បញ្ញត្តិច្បាប់នេះ ត្រូវបានរដ្ឋសភាអនុម័ត នៅក្នុងឆ្នាំ១៩៩៤ ទោះបីជាមានបទបញ្ញត្តិមួយចំនួន ស្តីពីសិទ្ធិជាមូលដ្ឋាន ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញក្តី ក៏វានាំឱ្យមានបញ្ហានិទណ្ឌភាពជាក់ស្តែងចំពោះការចោទប្រកាន់ មិនត្រឹមតែចំពោះមន្ត្រីរាជការ

---

[៧៥] សេចក្តីសង្កេតសន្និដ្ឋានលេខ CCPR/C/79/Add.១០៨ កថាខ័ណ្ឌទី៨ (ក) - នៅក្នុងរបាយការណ៍របស់ខ្លួនដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស ប្រទេសកម្ពុជាបានទទួលស្គាល់ថា តុលាការរបស់ខ្លួនមិនមាន " ឯករាជ្យភាពពេញលេញទេ " អាស្រ័យដោយមាន " ការជ្រៀតជ្រែក និងការគាបសង្កត់ " ពីស្ថាប័នដទៃទៀតរបស់រដ្ឋាភិបាល ហើយថាមានចៅក្រមមួយចំនួនបានទទួលប្រាក់សំណូក ក៏ព្រោះតែពួកគេ "មិនអាចអត់ទ្រាំបាន" ចំពោះជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ដែលលំបាកខ្លាំងពេក "ហើយបានចេញ" សេចក្តីសំរេចដោយលំអៀង ។ សូមមេត្តាមើលរបាយការណ៍ដំបូង ដាក់ជូនគណៈកម្មការសិទ្ធិមនុស្សលេខ CCPR/C/81/Add.១២ កថាខ័ណ្ឌទី២០៩ ។

[៧៦] តាមរយៈវិសោធនកម្ម មាត្រា១៥ នៃច្បាប់ស្តីពីគណៈបក្សនយោបាយ ។

[៧៧] សូមមេត្តាមើលរបាយការណ៍លេខ E/CN.4/2001/103 កថាខ័ណ្ឌទី៣៨ ។

ស៊ីវិលប៉ុណ្ណោះទេ តែថែមទាំងចំពោះនគរបាល ហើយបើតាមការអនុវត្តន៍ជាក់ស្តែង ចំពោះយោធិនផងដែរ ។ ច្បាប់បានធ្វើការរាំងខ្ទប់តុលាការ មិនឱ្យធ្វើការស៊ើបអង្កេត និងចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌណាមួយឡើយ កាលបើជនសង្ស័យស្ថិតនៅក្នុងអង្គភាពនគរបាលឬយោធាលុះត្រាតែមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នរបស់ជនសង្ស័យ ឬ ក្នុងករណីពាក់ព័ន្ធដល់មន្ត្រីជាន់ខ្ពស់ ត្រូវមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ។ ដូច្នេះ មាត្រា៥១ បានធ្វើឱ្យនិទណ្ឌភាពក្លាយជាស្របច្បាប់ ។ ការធ្វើវិសោធនកម្ម បានលុបចោលសេចក្តីតម្រូវឱ្យមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីធ្វើការចោទប្រកាន់ ។ មាត្រានេះចែងថា ព្រះរាជអាជ្ញាគ្រាន់តែជូនដំណឹងអំពីការចោទប្រកាន់នោះ ទៅប្រធានស្ថាប័នសាមីជាការស្រេច ។[៧៨] ទោះជាយ៉ាងណាក៏ដោយ មាត្រាដែលបានធ្វើវិសោធនកម្មនេះហាក់មិនបង្ហាញពីការផ្លាស់ប្តូរជាដុំកំភួនដល់ការចាប់មន្ត្រីរាជការស៊ីវិល ជាពិសេសនគរបាល និងយោធិន ឱ្យទទួលខុសត្រូវចំពោះអំពើល្មើសដែលខ្លួនបានប្រព្រឹត្តនោះឡើយ ។ ចៅក្រម និងព្រះរាជអាជ្ញាខ្លះ បានរាយការណ៍ផងដែរថា ភារកិច្ចជូនដំណឹងទៅប្រធានស្ថាប័នសាមី បានផ្តល់លទ្ធភាពឱ្យជនសង្ស័យគេចវេសពីការចាប់ខ្លួន ។ សារដែលថាមន្ត្រីរាជការស៊ីវិល រួមទាំងនគរបាល និងយោធាស្ថិតនៅពីលើច្បាប់ បានបង្ហាញឱ្យឃើញពីការលំបាកលុបបំបាត់ចោល ។

ការផ្លាស់ប្តូរលើកទីពីរ គឺនៅក្នុងឆ្នាំ២០០២ នៅពេលដែលរដ្ឋាភិបាលបានប្រកាសតំលើងប្រាក់ឧបត្ថម្ភដល់ចៅក្រមនិងព្រះរាជអាជ្ញា ។ ខណៈពេលដែលការតំលើងប្រាក់ឧបត្ថម្ភនេះត្រូវបានទទួលស្វាគមន៍ គេមិនឃើញមានការថយចុះនៃអំពើពុករលួយ តាមមធ្យោបាយដែលគួរអោយកត់សំគាល់ណាមួយទេ ។

លោកភីថឺរ លយប្រែកតី បានស្នើយ៉ាងទទូចជាច្រើនលើកច្រើនសារដល់រដ្ឋាភិបាលឱ្យធ្វើការប្តេជ្ញាចិត្តចំពោះការធ្វើកំណែទំរង់រចនាសម្ព័ន្ធនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនិងដើម្បីធានាឯករាជ្យភាពរបស់ខ្លួន ។ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ លោកតំណាងពិសេស បានសរសេរលិខិតមួយច្បាប់ផ្ញើជូនលោកនាយករដ្ឋមន្ត្រី ដែលក្នុងលិខិតនោះ លោកបានគូសបញ្ជាក់នូវកង្វល់មួយចំនួន អំពីវិធានការនានាដែលត្រូវធ្វើឡើងក្នុង

---

[៧៨] ច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចែងថា "ក្នុងករណីដែលមន្ត្រីរាជការណាម្នាក់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាសំរេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះ ទៅប្រធានស្ថាប័នសាមីក្នុងរយៈពេល ៧២ម៉ោងយ៉ាងយូរ ។ បើមានការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជាបណ្តោះអាសន្នលើមន្ត្រីរាជការណាមួយនោះ ព្រះរាជអាជ្ញា ឬចៅក្រមមានសមត្ថកិច្ចត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធានស្ថាប័នសាមី ។ ក្នុងករណីដែលបទល្មើសនោះកើតមានក្នុងក្របខ័ណ្ឌនៃការបំរើការងារសាធារណៈ រដ្ឋត្រូវការពារមន្ត្រីរាជការនោះតាមផ្លូវច្បាប់ " ។

ការឆ្លើយតបទៅនឹង "កាចោទប្រកាន់អំពីកំហុសឆ្គង និងអំពើពុករលួយ" ចំពោះចៅក្រមនិងព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញ ។ លោកបានដឹងពីភាពធ្ងន់ធ្ងរនៃការចោទប្រកាន់ ។ ទោះជាដូច្នោះក្តី លោកបានអះអាងថា ក្រសួងយុត្តិធមិបានប្រើប្រាស់អំណាចរបស់ខ្លួនជ្រុលដោយបានធ្វើការព្យួរព្រះរាជអាជ្ញារងពីររូបពីការងារ ហើយលោកបានទាញការចាប់អារម្មណ៍ចំពោះនីតិវិធី ដែលគួរតែយកមកអនុវត្តតាម នៅក្នុងការចាត់វិធានការខាងវិន័យធ្វើឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយគួរតែគិតអំពីគោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពនៃតុលាការ ។[៧៩] នៅក្នុងករណីទាំងនេះ លោកយល់ថា វាផ្ទុយទៅនឹងគោលការណ៍ជាមូលដ្ឋានដែលចៅក្រម និងព្រះរាជអាជ្ញាត្រូវបានគេកោះហៅមកការពារខ្លួនដែលបន្ទុកត្រូវធ្លាក់មកលើពួកគេ ជាអ្នកលើកយកភស្តុតាងមកបង្ហាញថា ខ្លួនមិនបានប្រព្រឹត្តកំហុសឆ្គង ឬថាការចេញសេចក្តីសំរេចរបស់ខ្លួន គឺមិនមែនមិនត្រូវនោះទេ ហើយថានឹងមិនមានការកោះហៅសាក្សីនៃភាគីណាមួយមកឆ្លើយបំភ្លឺនោះឡើយ ។

"ការចោទប្រកាន់ពីបទប្រព្រឹត្តអំពើពុករលួយ គួរតែត្រូវចាត់វិធានការដាក់វិន័យ... ។ ទោះជាយ៉ាងណាក៏ដោយ ចៅក្រម និងព្រះរាជអាជ្ញាមិនត្រូវទទួលទណ្ឌកម្ម ចំពោះការធ្វើសេចក្តីសំរេចខុស ឬត្រូវទទួលវិន័យដោយសារកំហុសអចេតនា នៅក្នុងការធ្វើសេចក្តីសំរេចរបស់ខ្លួន ឬចំពោះការមិនយល់ស្របតាមការបកស្រាយច្បាប់ណាមួយនោះឡើយ"[៨០] ។

### v. *ប្រព័ន្ធច្បាប់ : ក្របខ័ណ្ឌច្បាប់*

លោកតំណាងពិសេស បានទាញការចាប់អារម្មណ៍ជារឿយៗ អំពីភាពទន់ខ្សោយនៅក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា ដោយលោកបានកត់សំគាល់ឃើញពីភាពចន្លោះប្រហោងនៃច្បាប់ និងចរិតចំរុះនៃប្រព័ន្ធច្បាប់

---

[៧៩] *គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពនៃតុលាការ* មានចែងពីគោលការណ៍មួយចំនួន ដែលត្រូវគោរពតាម នៅក្នុងកិច្ចដំណើរការដាក់វិន័យ ព្យួរការងារ ឬការដកចៅក្រមចេញពីមុខតំណែង [ប្រការ៧-២០] ។ "បើមានការចោទប្រកាន់ ឬពាក្យបណ្តឹងតវ៉ាទៅលើចៅក្រមណាមួយ ក្នុងឋានៈខ្លួនជាអ្នកប្រកបវិជ្ជាជីវៈក្នុងកិច្ចការតុលាការ គេត្រូវយករឿងនេះទៅដោះស្រាយឱ្យបានរួសរាន់ និងដោយយុត្តិធមិតាមនីតិវិធីត្រឹមត្រូវ ។ចៅក្រមត្រូវមានសិទ្ធិទទួលបានការបើកសវនាការមួយដើម្បីជំនុំជំរះរឿងក្តីរបស់ខ្លួនប្រកបដោយយុត្តិធមិ " [ប្រការ៧] " រាល់កិច្ចដំណើរការក្នុងការសំរេចដាក់វិន័យ ការព្យួរ ឬការដកចៅក្រមចេញពីមុខដំណែង ត្រូវស្ថិតក្រោមការពិនិត្យមើលឡើងវិញដោយឯករាជ្យ [ប្រការ២០]" ។ គោលការណ៍ស្រដៀងគ្នានេះ មាននៅក្នុង *គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា* ប្រការ២១ និងប្រការ២២ ។

[៨០] លិខិតរបស់ការិយាល័យប្រចាំកម្ពុជា លេខយោង : COHCHR/022/05

ដែលបណ្តាលឱ្យកើតមាន "ការភ័ន្តច្រឡំមួយចំនួន" ក្នុងការអនុវត្តន៏ច្បាប់ និងនីតិវិធីពាក់ព័ន្ធមួយចំនួន។ ក្នុងពេលទន្ទឹមគ្នានេះដែរ រដ្ឋសភាបាន និងកំពុងធ្វើការបំពេញនូវចន្លោះប្រហោងមួយចំនួន នៅក្នុងការរៀបរយច្បាប់មួយចំនួននៃប្រទេសកម្ពុជា ដែលមិនទាន់ដោះស្រាយបាននៅឡើយ ចាប់ពីឆ្នាំ១៩៩៤ ឧទាហរណ៍ តាមរយៈច្បាប់ភូមិបាលឆ្នាំ២០០១។[៨១] មានច្បាប់មួយចំនួនតូច ធ្វើឡើងក្នុងវិស័យទាំងនេះដែលមានសារសំខាន់ចំពោះ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី សំរាប់ធ្វើការដោះស្រាយជំលោះផ្សេងៗ។ ក្នុងឆ្នាំ២០០២ ហើយម្តងទៀត ក្នុងឆ្នាំ២០០៤ ក្រុមពិគ្រោះយោបល់នៃប្រទេសអ្នកផ្តល់ជំនួយសំរាប់ប្រទេសកម្ពុជាបានធ្វើការអំពាវនាវសុំឱ្យរដ្ឋសភាអនុម័តឱ្យបានឆាប់នូវច្បាប់ចំនួនប្រាំបី ដែលចាំបាច់សំរាប់ការបង្កើតក្របខ័ណ្ឌច្បាប់។ ច្បាប់ទាំងនោះរួមមានៈក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់រៀបចំអង្គការស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ  ច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[៨២] ការងារនេះបានធ្វើជាថ្មីម្តងទៀត ទៅលើអនុសាសន៏ដែលបានធ្វើឡើងដោយលោកម៉ៃឃើលឃីប៊ី នៅក្នុងរបាយការណ៍លើកដំបូងរបស់លោកដាក់ជូនគណៈកម្មការសិទ្ធិមនុស្សក្នុងឆ្នាំ១៩៩៤។ ការខកខានមិនបានអនុម័តច្បាប់ទាំងនេះ មានន័យថា ស្ថានភាពស្ថិតនៅជាដដែល រួមទាំងច្បាប់ និងបទបញ្ជាមួយចំនួន ដែលមានកាលបរិច្ឆេទទន្ទឹមគ្នានឹងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ហើយរហូតមកដល់ទសវត្សឆ្នាំ១៩៨០ ទាំងច្បាប់ក្នុងសម័យអន្តរកាលដែលអនុម័តដោយអ៊ុនតាក់ នៅតែបន្តអនុវត្តរហូតមកទល់ពេលបច្ចុប្បន្ននេះ។

កាលបើការពិតដែលថា ការអនុម័តច្បាប់មួយចំនួនមិនបានធានាដល់ការអនុវត្តន៏របស់វា ការខ្វះច្បាប់ជាមូលដ្ឋានមានផលវិបាកជាក់ស្តែង និងធ្ងន់ធ្ងរ។ នៅក្នុងសភាពការណ៏ខ្លះ ដូចបានសំគាល់ឃើញមាននៅក្នុងផ្នែកទី IV សមិទ្ធិទាំងឡាយ ត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ប៉ុន្តែការអនុវត្តន៏សិទ្ធិទាំងនេះ ទាមទារឱ្យមានច្បាប់ថ្មីៗជាច្រើន ប្រសិនជាមិនមានច្បាប់ទាំងនេះទេ ប្រាកដជាគ្មានការគ្រប់គ្រងដោយច្បាប់ពិតប្រាកដនោះឡើយ។

---

[៨១] ច្បាប់ភូមិបាលនៅត្រូវការឱ្យមានការអនុម័តអនុក្រឹត្យសំខាន់ៗជាច្រើន ដើម្បីអនុវត្តច្បាប់នេះ។ បញ្ហាទាំងឡាយទាក់ទងនឹងការអនុវត្តន៏ច្បាប់ មានរៀបរាប់នៅក្នុងរបាយការណ៏របស់លោកតំណាងពិសេស ដែលមានចំណងជើងថា *"ដីសម្បទានគោលដៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា : ទស្សនៈវិស័យខាងសិទ្ធិមនុស្ស ឆ្នាំ២០០៤"* ។

[៨២] សូមមេត្តាមើលគេហទំព័រ នៃធនាគារពិភពលោក http://siteresources.worldbank.org/ INTCAMBODIA/ Resources/Monitoring-Indicators.pdf.

ផលវិបាកអវិជ្ជមាន ដែលប្រទេសកម្ពុជា ខកខានក្នុងការអនុម័តច្បាប់ភាគច្រើន បច្ចុប្បន្ននេះត្រូវបាន ប្រទេសអ្នកផ្តល់ជំនួយកំណត់ថា ជាបញ្ហាអាទិភាពដែលជាក់ស្តែងគឺករណីនៃវិស័យតុលាការ ។ ទោះបីជាច្បាប់ត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៤ ដើម្បីបង្កើតឧត្តមប្រឹក្សានៃអង្គចៅក្រមក្តី ភាពចំរូងចំរាស់អំពីសមាជិកភាពនៃក្រុមប្រឹក្សាបានពន្យាពេលក្នុងការបង្កើតស្ថាប័ននេះ ហើយចាប់ពីពេលនោះ ក្រុមប្រឹក្សានេះមិនបានដើរតួនាទីរបស់ខ្លួន ដូចដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញថាជាស្ថាប័នមួយឯករាជ្យ ទទួលខុសត្រូវក្នុងការតែងតាំង ផ្ទេរ និងដាក់វិន័យចៅក្រមទេ ។ ដោយសារគ្មានបទបញ្ញត្តិលំអិតពាក់ព័ន្ធនឹងនីតិវិធីតែងតាំង និងលក្ខខណ្ឌការងាររបស់ចៅក្រម ដែលចាំបាច់ត្រូវតែចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នីតិវិធីរដ្ឋបាលចាស់នៅតែបន្តអនុវត្ត ។ ដូច្នេះហើយ អំណាចនៅតែស្ថិតនៅក្រោមក្រសួងយុត្តិធម៌ដដែល ដែលអាចមានអំណាចច្រើនលើសលុប ដែលអំណាចទាំងនោះជារបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ផ្អែកតាមស្មារតីនៃរដ្ឋធម្មនុញ្ញ និងនៅតែមានឥទ្ធិពលទៅលើ ឧទាហរណ៍ សន្តិសុខ និងរយៈពេលបំរើការងាររបស់ចៅក្រម ។

ផលវិបាកដទៃទៀត អាចឃើញមាននៅក្នុងទំនាក់ទំនងជាមួយនគរបាល ។ អ្នកជំនាញការខាងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអ.ស.ប បានសំគាល់ពីផលវិបាកជាអវិជ្ជមានមួយចំនួន ដែលបណ្តាលមកពីការខ្វះច្បាប់ទូលំទូលាយជាមូលដ្ឋាន ដែលជាផែនគ្រឹះដ៏រឹងមាំនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។ ច្បាប់គ្រឹះទាំងនេះគួរតែរួមបញ្ចូលនូវក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីវិធាននៃភស្តុតាង និងក្រមព្រហ្មទណ្ឌ ។ នៅពេលទន្ទឹមគ្នានេះ ច្បាប់អ៊ុនតាក់ និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ ដែលច្បាប់ហួសសម័យទាំងពីរនេះ ការពារសិទ្ធិជាមូលដ្ឋានទាំងឡាយ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បាន និងកំពុងបន្តអនុវត្ត ។ នេះមានន័យថា នគរបាលជាតិដំណើរការក្រោមច្បាប់មួយដែលអនុវត្តជាទូទៅចំពោះមន្ត្រីរាជការស៊ីវិល ហើយមិនមានគោលការណ៍ច្បាប់ជាក់លាក់ និងច្បាស់លាស់សំរាប់សកម្មភាពនគរបាលរបស់ខ្លួន ។ លទ្ធផលមួយនេះ គឺការខ្វះភាពច្បាស់លាស់នៃដែនសមត្ថកិច្ចៈ មន្ត្រីនគរបាលបានប្រាប់អ្នកជំនាញការថា វាមិនមានភាពច្បាស់លាស់ចំពោះពួកដែលមានអំណាចបញ្ជាឱ្យធ្វើការស៊ើបអង្កេតលើបទល្មើសណាមួយ (នគរបាល ឬ ព្រះរាជអាជ្ញា) ។

### *vi. ប្រព័ន្ធច្បាប់ : វិជ្ជាជីវៈច្បាប់*

ជនជាប់ចោទជាច្រើនមិនបានបង្ហាញខ្លួននៅក្នុងតុលាការទេ ហើយមានករណីរឿងរដ្ឋប្បវេណីជាច្រើនត្រូវបានជំនុំជំរះដោយគ្មានមេធាវីការពារ ចំពោះជនដែលងាយរងគ្រោះបំផុត ។ ក្នុងឆ្នាំ២០០៣ លោក

ភីថឺរ លយប្រែកតឺ បានរាយការណ៍ថា មានមេធាវីតិចជាង២០០នាក់ ដែលប្រកបវិជ្ជាជីវៈច្បាប់ ហើយមានតែមេធាវីចំនួន២០នាក់ប៉ុណ្ណោះ ដែលប្រកបវិជ្ជាជីវៈមេធាវី នៅតាមបណ្ដាខេត្តនានា។ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០២ "ជាលើកដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រ នៃតុលាការខេត្តព្រះវិហារ" ដែលមានការការពារស្រប ច្បាប់នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ដែលផ្ដល់ដោយមេធាវីការពារជនក្រីក្រ ពីសំណាក់អង្គការក្រៅរដ្ឋាភិបាល គឺគំរោងអ្នកការពារក្ដីកម្ពុជា។[៨៣]

ជំហានវិជ្ជមានមួយ គឺការបើកមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី ដែលបាននទទួលនិស្សិតវ័យក្មេងមួយក្រុមចំនួន៦០នាក់លើកដំបូង ដែលបានបញ្ចប់ការសិក្សាផ្នែកច្បាប់ ឱ្យចូលសិក្សាក្នុងឆ្នាំ ២០០២។ លោក លយប្រែកតឺ បានស្នើយ៉ាងទទូចដល់រដ្ឋាភិបាល សូមឱ្យបង្កើតមូលនិធិជំនួយផ្នែកច្បាប់ ដើម្បីផ្ដល់សេវាកម្មច្បាប់ ដល់ប្រជាពលរដ្ឋក្រីក្រ ដែលរស់នៅតាមតំបន់ជនបទ។

ប៉ុន្តែការនេះបានកើតមានជាថ្មីម្ដងទៀតនូវចំណោទរវាងបញ្ហាសមត្ថភាព និងការប្រើប្រាស់"ឆន្ទៈ" នយោបាយ។ លោកលយប្រែកតឺ ក៏បានសំដែងនូវកង្វល់អំពីរបាយការណ៍ថាគណៈមេធាវីដែលគេស្គាល់ថា ជាស្ថាប័នមួយសំរាប់បង្កើតវិជ្ជាជីវៈច្បាប់ដែលខ្លាំង ហើយឯករាជ្យនិងការពារសិទ្ធិមនុស្សបានទទួលមូលនិធិ យ៉ាងច្រើនសន្ធឹកសន្ធាប់ ពីមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ហើយក្នុងខែកញ្ញា ឆ្នាំ២០០៤ ស្ថាប័ននេះបានទទួល នាយករដ្ឋមន្ត្រី និងឥស្សរជនថ្នាក់ដឹកនាំនយោបាយដទៃទៀតជាសមាជិករបស់ខ្លួនដោយបានផ្ដល់អាជ្ញាប័ណ្ណ ប្រកបវិជ្ជាជីវៈច្បាប់ បើទោះបីជាមានលក្ខណៈសម្បត្តិខាងវិជ្ជាជីវៈមិនគ្រប់គ្រាន់ក៏ដោយ។

---

[៨៣] សូមមេត្តាមើលរបាយការណ៍លេខ E/CN.4/2003/114 កថាខ័ណ្ឌទី២០។

## *VII. កំលាំងធ្វើការប្រឆាំងនឹងនិទណ្ឌភាព*

ដូចបានកត់សំគាល់នៅក្នុងផ្នែកទីIIIដូច្នោះដែរ អ៊ុនតាក់បានរាយការណ៍ថា គេបានឃើញសង្គមមួយដែលខ្វះស្ថាប័នគ្រឹះមួយចំនួន និងកិច្ចដំណើរការដែលផ្អែកលើការគោរពសិទ្ធិមនុស្ស ។ ស្ថាប័នទាំងនេះរួមមាន ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និង អង្គការក្រៅរដ្ឋាភិបាលជាតិនិងក្នុងស្រុកនានា អាច និងមានបំណងលើកស្ទួយផលប្រយោជន៍សង្គមស៊ីវិល ។

ចាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសមក ប្រទេសកម្ពុជាបានទទួលស្វាគមន៍ប្រជាពលរដ្ឋដែលបានព្យាយាមជំនះប្រវត្តិសាស្ត្រដ៏សែនជូរចត់នៃប្រទេសជាតិរបស់ខ្លួនតាមរយៈជាឧទាហរណ៍ ការងាររបស់ខ្លួននៅក្នុងអង្គការក្រៅរដ្ឋាភិបាលនានា ដែលគាំទ្រសិទ្ធិមនុស្ស សិទ្ធិនារី និងយុត្តិធម៌សង្គម ជាសកម្មជន បុគ្គលិក អ្នកកាសែត ប្រធានសហជីព អ្នកបរិស្ថាន ប្រធានសហគមន៍ គ្រូបង្រៀន និងនិស្សិត ។ ពួកគេបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហានិទណ្ឌភាព ហើយមានអ្នកខ្លះបានក្លាយជាជនរងគ្រោះដោយអំពើទាំងនេះផងដែរ ។

លោកតំណាងពិសេសទាំងអស់ បានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចពិភាក្សាផ្លាស់ប្តូរព័ត៌មាន និងក្នុងន័យស្ថាបនាជាមួយអង្គការក្រៅរដ្ឋាភិបាលនានា និងសមាជិកទាំងឡាយនៃសង្គមស៊ីវិលដទៃទៀត ។ លោក ភីធឺរ លយប្រែកតឺ បានទាញការចាប់អារម្មណ៍ជាពិសេស ចំពោះសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស[៨៤] ដែលបានដកស្រង់យកទាំងស្រុងនូវសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់ ។ សេចក្តីថ្លែងការណ៍ចែងថា ជនគ្រប់រូបមានសិទ្ធិ ជាឯកត្តជនម្នាក់ៗ និងជាមួយអ្នកដទៃ ក្នុងការលើកស្ទួយ និងការខិតខំប្រឹងប្រែងការពារ និងធ្វើឱ្យសម្រេចបាននូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ហើយដើម្បីទាញការចាប់អារម្មណ៍របស់សាធារណៈ ដល់ការគោរពសិទ្ធិមនុស្សទាំងនៅក្នុងអត្ថបទច្បាប់ ទាំងនៅក្នុងការអនុវត្តន៍ជាក់ស្តែង ។ សេចក្តីថ្លែងការណ៍នេះចែងជាពិសេសអំពីសេរីភាពក្នុងការបង្កើតសមាគម ការប្រជុំ និងការសំដែងមតិ ដែលសិទ្ធិសេរី

[៨៤] សេចក្តីថ្លែងការណ៍របស់អ.ស.បស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល ដែលមហាសន្និបាតបានអនុម័ត ក្នុងឆ្នាំ១៩៩៩ ។

ភាពទាំងនេះក៏បានចែងធានាផងដែរ នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា[៨៥] ដែលដក់ជាប់នៅក្នុងបេះដូងរបស់សង្គមពលរដ្ឋដ៏សកម្មនិងលទ្ធិប្រជាធិបតេយ្យដែលកំពុងដំណើរការ ។[៨៦] នៅក្នុងឆ្នាំ២០០៣លោកភីធើរលយប្រេកតឺបានគូសបញ្ជាក់ពីសារៈសំខាន់នៃការយល់ដឹង និងការគោរពថែមទៀតនៃសេចក្ដីថ្លែងការណ៍នេះ ដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជាអាចចូលរួមដ៏មានអត្ថន័យបំផុតនៅក្នុងមុខងារសាធារណៈ និង នៅក្នុងជួររដ្ឋាភិបាលនៃប្រទេសរបស់ខ្លួន ហើយបានស្នើសុំឱ្យទីភ្នាក់ងារអន្តរជាតិ និងប្រទេសអ្នកផ្ដល់ជំនួយនានា នៅក្នុងប្រទេសកម្ពុជាអោយយកបញ្ញត្តិនៃសេចក្ដីថ្លែងការណ៍នេះទៅធ្វើការពិចារណាទាំងស្រុងនៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីលើកស្ទួយដល់កិច្ចដំណើរការចូលរួម និងពិគ្រោះយោបល់នានា ។ លោកមានប្រសាសន៍ថាគោលគំនិតទាំងឡាយ ដូចជាការពិគ្រោះយោបល់ ការចូលរួម និងភាពជាម្ចាស់ប្រទេសជាតិអាចបាត់បង់បាត់ន័យខ្លឹមសាររបស់ខ្លួន ឬធ្វើឱ្យប្រជាពលរដ្ឋរងគ្រោះ ប្រសិនបើគេមិនគោរព អនុវត្តតាមបទបញ្ញត្តិ នៃសេចក្ដីថ្លែងការណ៍នេះទេ ។

### *អង្គការនានា ដែលធ្វើការដើម្បីសិទ្ធិមនុស្ស*

ក្នុងឆ្នាំ១៩៩៤ លោក ឃើបឺ បានស្វាគមន៍អង្គការសិទ្ធិមនុស្សផ្សេងៗ ដ៏ច្រើនលើសលុប ដែលសកម្មក្នុងវិស័យមួយចំនួន រួមមានការអប់រំសិទ្ធិមនុស្ស ការផ្ដល់ប្រឹក្សាយោបល់ និងការការពារតាមផ្លូវច្បាប់បញ្ហាពន្ធនាគារ ការលើកស្ទួយសិទ្ធិមនុស្សនៃក្រុមជនដែលងាយរងគ្រោះ ដូចជាស្ត្រី កុមារ ចាស់ជរា ជនភាគតិច និងជនពិការ ។ លោកបានចាប់អារម្មណ៍ជាខ្លាំងចំពោះតួនាទីដ៏សំខាន់របស់អង្គការទាំងនេះ ។[៨៧]

ទោះបីជាដំបូងឡើយ អង្គការសិទ្ធិមនុស្សទាំងនេះ បានផ្ដោតការយកចិត្តទុកដាក់លើកកំពស់ការយល់ដឹងពីសិទ្ធិមនុស្សក៏ដោយ លុះក្រោយមកមិនយូរប៉ុន្មាន ក៏ពួកគេបានបញ្ចូលសកម្មភាពមួយចំនួនទៀតដូចជាការឃ្លាំមើលរដ្ឋាភិបាលក្នុងការគោរពបទដ្ឋានសិទ្ធិមនុស្សនិងការស៊ើបអង្កេតរាល់បណ្ដឹងពីការរំលោភ

[៨៥] ជំពូកទី៣ នៃរដ្ឋធម្មនុញ្ញអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ។

[៨៦] របាយការណ៍ឆ្នាំ២០០៤ របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស ដាក់ជូនមហាសន្និបាត ដែលផ្ដោតការយកចិត្តទុកដាក់ជាពិសេសចំពោះសេរីភាពក្នុងការបង្កើតសមាគម សិទ្ធិបុគ្គលគ្រប់រូបក្នុងការប្រស្រ័យទាក់ទងនិងក្នុងការរៀបចំក្នុងចំណោមជាពួក ដើម្បីសំដែងមតិជាសមូហភាព លើកស្ទួយ រក្សា និងការពារផលប្រយោជន៍រួម ពីព្រោះវាជាកិច្ចការស្នូលជាពហុមធ្យោបាយ ដែលត្រូវបានគេរិតត្បិត ហើយនិងបានជួបប្រទះនូវឧបសគ្គជាច្រើនក្នុងការអនុវត្តន៍សិទ្ធិទាំងនេះ ។ របាយការណ៍លេខ A/59/401

[៨៧] សម័យប្រជុំលើកទី៤៩ : របាយការណ៍លេខ A/49/635 ឆ្នាំ១៩៩៤ របស់លោកតំណាងពិសេស ។

សិទ្ធិមនុស្សផ្សេងៗ ។ នៅក្នុងសភាពការណ៍មួយ ដែលនិទណ្ឌភាពបានក្លាយជាបញ្ហាធម្មតាទៅហើយនោះ ទើបការងារនេះមានសារៈសំខាន់ជាពិសេស ។ ប៉ុន្តែការងារនេះ នាំឱ្យពួកគេលំបាកធ្វើការជាមួយអាជ្ញាធរនានា ហើយបានកើតមានឧប្បត្តិហេតុនៃការរំលោភ ការគំរាមកំហែង និងការបំពានដល់រាងកាយរបស់សកម្មជនមួយចំនួន ហើយត្រូវបានចងក្រងជាឯកសារជាប្រចាំ នៅក្នុងអំឡុងពេលជាងមួយទសវត្សកន្លងមក ដែលបញ្ហាទាំងនេះគេកម្រឃើញមានការចាត់វិធានការកែតម្រូវណាស់ ។ បញ្ហាទាំងនេះរួមមានករណីបង្ករបួសស្នាមជាច្រើនករណី ឃាតកម្មមួយករណី ត្រូវបានការិយាល័យប្រចាំកម្ពុជាកត់ត្រាទុក ។[៨៨] ការឃុំខ្លួនតាមទំនើងចិត្តជាច្រើនករណី ករណីធ្ងន់ធ្ងរជាច្រើនទាក់ទងនឹងការបំភិតបំភ័យ និងការគំរាមកំហែង ។[៨៩] ការវាយប្រហារភាគច្រើនមានទិសដៅទៅរកអង្គការនានា ដែលបានថ្លែងដោយចំហ ជាពិសេសអំពីការរំលោភសិទ្ធិមនុស្ស មិនតែប៉ុណ្ណោះ អ្នកដឹកនាំសហគមន៍មូលដ្ឋាន និងសកម្មជននានា ជួបប្រទះការលំបាកកាន់តែខ្លាំងថែមទៀត ក្នុងការតស៊ូមតិរបស់ខ្លួនទាក់ទងនឹងបញ្ហាដីធ្លី ធនធានធម្មជាតិ និង បរិស្ថាន ។[៩០]

សេចក្តីថ្លែងការណ៍របស់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ដែលបានបង្ខូចកិត្យានុភាព និង ធ្វើការទិទៀនដល់ការងាររបស់អង្គការសិទ្ធិមនុស្សនានា គឺមិនមានប្រយោជន៍នោះទេ ហើយវាថែមទាំងធ្វើឱ្យគ្រោះថ្នាក់ដល់សុវត្ថិភាពអង្គការ និងបុគ្គលិកនានានៃអង្គការទាំងនេះទៀតផង ។ ផ្ទុយទៅវិញបើពួកគេធ្វើសេចក្តីថ្លែងការណ៍គាំទ្រ នោះវានឹងបង្ហាញពីសញ្ញាណវិជ្ជមានមួយ ហើយអាចលើកកំពស់ការយល់ដឹងពីការងារ និងតួនាទីរបស់ខ្លួន កាន់តែប្រសើរឡើងថែមទៀត ។

---

[៨៨] លោក ភួង តុង ត្រូវបានគេបាញ់សំលាប់ កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៨ បន្ទាប់ពីលោកបានចូលបំរើការជាសកម្មជនសិទ្ធិមនុស្សនៃអង្គការសិទ្ធិមនុស្សមួយ ឈ្មោះថា អង្គការអាដហុក ។ ករណីឃាតកម្មនោះ ពាក់ព័ន្ធនឹងជំលោះដីធ្លី ដែលក្នុងនោះជនរងគ្រោះបានធ្វើជាតំណាងឱ្យក្រុមអ្នកស្រុក ដែលត្រូវគេបណ្តេញដោយបង្ខំចេញពីដីរបស់ខ្លួន ។

[៨៩] ការិយាល័យប្រចាំកម្ពុជាបានធ្វើការចងក្រងករណីដូចនេះជាច្រើន ។ អង្គការសិទ្ធិមនុស្ស លីដាដូ បានធ្វើសេចក្តីថ្លែងការណ៍ និងរបាយការណ៍ជាទៀងទាត់ អំពីសភាពការណ៍របស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ចាប់ពីឆ្នាំ២០០១ មក ។

[៩០] ឧទាហរណ៍ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៤ អ្នកស្រុកប្រាំបីនាក់បានធ្វើការតវ៉ានៅខាងមុខសាលាខេត្តពោធិសាត់អំពីការចាប់ផ្តើមធ្វើសកម្មភាពជាថ្មី របស់ក្រុមហ៊ុនភាពីម៉ិច ។ អ្នកស្រុកទាំងនេះ ត្រូវរងរបួសដោយគ្រាប់បែកដៃមួយគ្រាប់ ដែលត្រូវគេគប់ចូលទៅក្នុងវិហារមួយក្នុងភូមិនៅពេលដែលពួកគេកំពុងគេងលង់លក់ ។ លោកតំណាងពិសេសមានសេចក្តីសោកស្តាយជាខ្លាំងចំពោះការវាយប្រហារនេះ ហើយលោកបានធ្វើការអំពាវនាវសុំឱ្យមានការស៊ើបអង្កេតទាំងស្រុងមួយ ហើយនាំខ្លួនជនដែលទទួលខុសត្រូវទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ ។

*ប្រព័ន្ធផ្សព្វផ្សាយ*

នៅក្នុងទសវត្សឆ្នាំ១៩៨០ ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ។[៩១] នៅពេលដែលអ៊ុនតាក់ចូលមកដល់ មិនទាន់មានកាសែតប្រឆាំង កាសែតឯកជន ឬកាសែតប្រចាំថ្ងៃនៅទីក្រុងភ្នំពេញនៅឡើយទេ[៩២]។ អត្ថប្រយោជន៍នៃប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិនៅប្រទេសកម្ពុជា ដែលអមដំណើរដោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ការស្នងបន្តនៃអង្គភាពផ្សព្វផ្សាយរបស់អ៊ុនតាក់ វិទ្យុអ៊ុនតាក់ ហើយការការពារដែលអ៊ុនតាក់បានផ្តល់អោយ គឺជាចលករ ជួយជំរុញបន្ថែម ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក។ មកទល់ឆ្នាំ១៩៩៣ គេបានបង្កើតឱ្យមានប្រព័ន្ធផ្សព្វផ្សាយបន្តផ្ទាល់អាល់បែត (albeit) គឺជាប្រព័ន្ធមួយដែលខ្វះការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈ។ សារព័ត៌មានភាគច្រើន ដែលមាននៅក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ ១៩៩៣ គឺស្ថិតក្រោមការគ្រប់គ្រងពីគណៈបក្សនយោបាយ ឬបុគ្គលអ្នកនយោបាយដោយផ្ទាល់។ បញ្ហានេះ នៅតែបន្តមានរហូតមកទល់ពេលបច្ចុប្បន្ននេះ សារព័ត៌មានជាភាសារខ្មែរមួយចំនួនតូចបានទទួលកំរៃពីការចុះផ្សាយនេះ។

នៅក្នុងឆ្នាំ១៩៩៤ លោក ឃឺប៊ី បានរាយការណ៍ថា តាមមធ្យោបាយជាច្រើន ដែលប្រទេសកម្ពុជាទទួលបាននូវសេរីភាពក្នុងការសំដែងមតិច្រើនជាងប្រទេសដទៃទៀតនៅក្នុងតំបន់។ "បើតាមការប្រៀបធៀប និងប្រវត្តិសាស្ត្រថ្មីៗនៃប្រទេសកម្ពុជា នៅពេលដែលប្រទេសនេះបានឆ្លងកាត់របបគ្រប់គ្រងផ្សេងៗ ដែលនៅក្នុងរដ្ឋាភិបាលមានតែគណៈបក្សមួយគត់ដែលគ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយ និងមានការរឹតតឹងរឹងចំពោះសេរីភាពនៃការសំដែងមតិ សេរីភាពដែលប្រទេសកម្ពុជាទទួលបាននាពេលបច្ចុប្បន្ននេះ គឺមានតែមួយ គ្មានពីរនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។[៩៣]

---

[៩១] អត្ថបទព័ត៌មានដែលបានបោះពុម្ពផ្សាយ រួមមាន ការបោះពុម្ពផ្សាយព័ត៌មានរៀងរាល់ពីរសប្តាហ៍ម្តងរបស់គណៈបក្សកាន់អំណាច *កាសែតប្រជាជាជន* (ប្រជាជន)។ កាសែតប្រចាំសប្តាហ៍របស់គណបក្ស *កាសែតកម្ពុជា*, កាសែតប្រចាំសប្តាហ៍ *កាសែតភ្នំពេញ ដែលជាកាសែតរបស់សាលាក្រុងភ្នំពេញ និងកាសែតប្រចាំសប្តាហ៍របស់កងកំលាំងប្រដាប់អាវុធ កាសែតកងទ័ពបដិវត្តន៍ (កងទ័ពបដិវត្តន៍)*។ ក្រៅពីនេះ មានស្ថានីយវិទ្យុមួយ ស្ថានីយទូរទស្សន៍មួយ និងទីភ្នាក់ងារព័ត៌មានមួយកន្លែងទៀត។

[៩២] ហ៊្វុនស៊ីនប៉ិចបានបោះពុម្ពព្រឹត្តិប័ត្រព័ត៌មានមួយពីព្រំប្រទល់ប្រទេសថៃ ហើយហ៊្វុនស៊ីនប៉ិច និង ខ្មែរក្រហម ព្រមទាំងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ បានចាក់ផ្សាយកម្មវិធីវិទ្យុរបស់ខ្លួនពីស្ថានីយ៍នៅក្នុងប្រទេសថៃ ឬនៅក្បែរព្រំដែនថៃ។

[៩៣] អនុសាសន៍របស់លោកតំណាងពិសេស លេខ A/49/635/ ភាគទីIX ផ្នែក H.93។

ច្បាប់សារព័ត៌មានថ្មីមួយត្រូវបានរដ្ឋសភាអនុម័តក្នុងខែកក្កដាឆ្នាំ១៩៩៥។ ច្បាប់នេះមានបញ្ញត្តិជាច្រើនដែលត្រូវបានទទួលការស្វាគមន៍។ ច្បាប់នេះហាមឃាត់ការត្រួតពិនិត្យពីសំណាក់អាជ្ញាធរនៅមុនពេលបោះពុម្ពផ្សាយ[៩៤] ហើយអនុញ្ញាតឱ្យសារព័ត៌មាន មានសិទ្ធិរក្សាការសំងាត់ស្តីពីប្រភពព័ត៌មានរបស់ខ្លួន។[៩៥] ទន្ទឹមនឹងនេះដែរ ច្បាប់នេះបានបញ្ចូលបញ្ញត្តិសមស្របមួយចំនួន អំពីការផាកពិន័យ និងការប្តឹងអ្នកកាសែត អ្នកនិពន្ធ ម្ចាស់កាសែត។ ផ្ទុយទៅនឹងស្មារតីនៃរដ្ឋធម្មនុញ្ញ និងបទដ្ឋានអន្តរជាតិដែលហាមឃាត់ ជាឧទាហរណ៍ "ការជេរប្រមាថដល់ស្ថាប័នជាតិ"។ ច្បាប់បានអនុញ្ញាតឱ្យព្យួរការបោះពុម្ពផ្សាយ និងការដាក់ពន្ធនាគារអ្នកកាសែតណាដែលបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែល "បណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ" ប៉ុន្តែច្បាប់នេះមិនបានផ្តល់និយមន័យណាមួយដល់ពាក្យពេចន៍ដែលមានន័យទូលាយទាំងនេះទេ។[៩៦]

ប្រព័ន្ធផ្សព្វផ្សាយមួយដែលខ្លាំង មានលក្ខណៈជាអាជីព និងឯករាជ្យ អាចដើរតួនាទីជាអ្នកឃ្លាំមើលស្ថាប័ននានា ហើយស្ថាប័នវិជ្ជាជីវៈមួយដែលរឹងមាំអាចឱ្យប្រព័ន្ធផ្សព្វផ្សាយធ្វើនិយតកម្មដោយខ្លួនឯងបាន និងដំណើរការបានដោយសេរី ដោយគ្មានការជ្រៀតជ្រែកមិនសមហេតុផលពីមជ្ឈដ្ឋានខាងក្រៅ មិនទាន់ត្រូវបានបង្កើតនៅឡើយទេ។ ការអភិវឌ្ឍន៍ខាងប្រព័ន្ធផ្សព្វផ្សាយបានទទួលរងនូវឥទ្ធិពលជាអវិជ្ជមានដោយសារការគំរាមកំហែងទៅលើអ្នកនិពន្ធ ការព្យួរការបោះពុម្ពផ្សាយនៃកាសែតប្រឆាំង ការវាយប្រហារដោយគ្រាប់បែកដៃ ការបង្ករបួសស្នាម និងការចូលរុះរើកកាយក្នុងការិយាល័យកាសែតនានា។[៩៧] យ៉ាងហោចណាស់ក៏មានតំណាងប្រព័ន្ធផ្សព្វផ្សាយចំនួនប្រាំបីនាក់ដែរ ត្រូវបានគេសំលាប់ ចាប់តាំងពីឆ្នាំ១៩៩៤មក ហើយម្នាក់ទៀតបានបាត់បង់ជីវិត ស្ថិតក្នុងការមន្ទិលសង្ស័យ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរ។[៩៨] បើតាមលោកតំណាងពិសេសដឹង ករណីនេះមិនមានអ្នកណាម្នាក់ ត្រូវបានចាប់ឱ្យទទួលខុសត្រូវចំពោះអំពើឃាតកម្ម និងការវាយប្រហារដទៃទៀតទៅលើតំណាង ឬការិយាល័យប្រព័ន្ធផ្សព្វផ្សាយនានាទេ។

---

[៩៤] មាត្រា៣ នៃច្បាប់ស្តីពីរបបសារព័ត៌មាន។

[៩៥] មាត្រា២ នៃច្បាប់ស្តីពីរបបសារព័ត៌មាន។

[៩៦] មាត្រា១៣ និងមាត្រា១២ នៃច្បាប់ស្តីពីរបបសារព័ត៌មាន។

[៩៧] សូមមេត្តាមើលឧបសម្ព័ន្ធ "ខ" ករណីរឿងមួយចំនួន ទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ។

[៩៨] នៅក្នុងសៀវភៅដដែល។

ការទុកបទចោទប្រកាន់ខាងព្រហ្មទណ្ឌរង់ចាំបន្តដើម្បីចាត់ការ ជារឿយៗមានរយៈពេលច្រើនឆ្នាំ ដែលនេះគឺជាការអនុវត្តន៍ធម្មតាទៅហើយ ក្នុងការព្យាយាមគ្រប់គ្រងអ្នកកាសែត និងសំលេងទិទៀនផ្សេងទៀត ដោយការប្រើប្រាស់តុលាការធ្វើជាឧបករណ៍ ដើម្បីចោទប្រកាន់អ្នកកាសែត និងអ្នកដទៃទៀតពីបទបរិហារកេរ្តិ៍ គឺជាការអនុវត្តន៍មួយ ដែលត្រូវបានធ្វើការកត់ត្រា ចាប់ពីឆ្នាំ១៩៩៤ រហូតមក។ យ៉ាងហោចណាស់ក៏មានបណ្តឹងបរិហារកេរ្តិ៍ចំនួនប្រាំបីដែរ ដែលរដ្ឋាភិបាលឬមន្ត្រីរដ្ឋាភិបាលបានប្តឹងតំណាងប្រព័ន្ធផ្សព្វផ្សាយ នៅក្នុងអំឡុងឆ្នាំ២០០៤ រហូតមកដល់ពាក់កណ្តាលឆ្នាំ២០០៥។ មាត្រា៦៣ កថាខ័ណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌអ៊ុនតាក់ឆ្នាំ១៩៩២ ចែងថា ការបរិហារកេរ្តិ៍ និងការជេរប្រមាថ "ត្រូវផ្តន្ទាទោសដាក់គុកពីប្រាំបីថ្ងៃ ទៅមួយឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពីមួយលាន ទៅដប់លានរៀល ឬត្រូវផ្តន្ទាតែទោសណាមួយ នៃទោសទាំងពីរនេះក៏បាន"។ ករណីថ្មីៗបំផុត មានករណីលោក ម៉ម សូណង់ដូ ជាម្ចាស់និងជានាយកស្ថានីយ៍វិទ្យុឯករាជ្យមួយ ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៥ ដោយសារលោកបានធ្វើបទសំភាសន៍មួយ ដែលបានទិទៀនលោកនាយករដ្ឋមន្ត្រី អំពីចំណាត់ការពាក់ព័ន្ធនឹងបញ្ហាព្រំដែន[៩៩] និងលោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ដែលត្រូវបានចាប់ខ្លួន នៅថ្ងៃទី១៥ ខែតុលា ដោយសារលោកបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍មួយ ដែលបានធ្វើការទិទៀនពីបញ្ហាស្រដៀងគ្នានេះ។

## *សហជីពកម្មករ*

ចំពោះវិស័យផ្សេងទៀត ការបង្កើតឱ្យមានសហជីពកម្មករ គឺជាជំហានមួយទៀតឆ្ពោះទៅមុខ។ រហូតមកទល់ចុងឆ្នាំ២០០៤ មានសហជីពកម្មកររោងចក្រ ដែលបានចុះបញ្ជីហើយមានចំនួន៦៧៥ សហព័ន្ធកម្មករថ្នាក់ជាតិមានចំនួន១៨ និងសម្ព័ន្ធសហព័ន្ធចំនួនមួយ។[១០០] បើតាមរបាយការណ៍សិទ្ធិមនុស្សឆ្នាំ២០០៤ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកបានឱ្យដឹងថា មានសហព័ន្ធកម្មករចំនួនដប់មួយដែលមានចំណង

---

[៩៩] លោកម៉ម សូណង់ដូ ម្ចាស់ស្ថានីយវិទ្យុ*សំបុកឃ្មុំ*និងលោក អ៊ិន ចាន់ស៊ីវត្ថា អ្នកបោះពុម្ពផ្សាយនៃ*កាសែតរស្មីអង្គរ* ត្រូវបានចាប់ខ្លួននៅថ្ងៃទី៣០ និង៣១ ខែមករា ឆ្នាំ២០០៣ ពីបទញុះញង់ឱ្យមានកុប្បកម្ម។

[១០០] ក្រសួងការបរទេសសហរដ្ឋអាមេរិក *ប្រទេសកម្ពុជា: របាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តន៍សិទ្ធិមនុស្ស ឆ្នាំ២០០៥* ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥។

ផង្សារភ្ជាប់ជាមួយរដ្ឋាភិបាលឬជាមួយមន្ត្រីរាជការដែលមាននិន្នាការទៅរកគណៈបក្សប្រជាជនកម្ពុជា(CPP) ចំណែកឯសហព័ន្ធធំៗពីរ និងសហជីពកម្មកររោងចក្រជាច្រើនទៀត គឺមានលក្ខណៈឯករាជ្យ ។

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញានៃអង្គការពលកម្មអន្តរជាតិសំខាន់ៗជាច្រើន ។ ច្បាប់ការងាររបស់កម្ពុជា ត្រូវបានរដ្ឋសភាអនុម័តក្នុងឆ្នាំ១៩៩៧ ដែលមានវិសាលភាពគ្របដណ្តប់លើផ្នែកការងារផ្លូវការ ប៉ុន្តែច្បាប់នេះមិនគ្របដណ្តប់លើមន្ត្រីរាជការស៊ីវិល ចៅក្រម យោធា ឬអ្នកបំរើក្នុងផ្ទះឡើយ ។ ច្បាប់តម្រូវឱ្យសហជីពទាំងអស់ ចុះបញ្ជីនៅក្រសួងទទួលបន្ទុកវិស័យការងារ មុនពេលនឹងទទួលបានសិទ្ធិ និងអត្ថប្រយោជន៍ពីច្បាប់នេះ ។[១០១] សហជីពខ្លះ ជួបប្រទះនូវការលំបាកជាច្រើនក្នុងការចុះបញ្ជី ។ នេះមានន័យថា ពួកគេត្រូវបានហាមឃាត់ ជាឧទាហរណ៍ មិនឱ្យបង្កើតការិយាល័យនៅតាមបណ្តាខេត្តនានា និងមិនឱ្យមាន "ការចរចាជាសមូហភាព" ។

ច្បាប់ស្តីបាតុកម្មនៃប្រទេសកម្ពុជា ត្រូវបានរដ្ឋសភាអនុម័ត ក្នុងឆ្នាំ១៩៩១ ដែលមានខ្លឹមសារផ្ទុយទៅនឹងសិទ្ធិសេរីភាពនៃការប្រជុំដោយសន្តិវិធី ហើយត្រូវបានគេអះអាងថា អធម្មនុញ្ញភាព ។ មាត្រា៣៧ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញ ធានាការពារសិទ្ធិធ្វើកូដកម្ម សិទ្ធិធ្វើបាតុកម្ម និងសេរីភាពនៃការប្រជុំដោយសន្តិវិធី ។ សិទ្ធិទាំងនេះ គឺជាមូលដ្ឋាននៃ "លិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស" ។[១០២] ដូច្នេះការរិតត្បិតណាមួយត្រូវតែធ្វើឡើងដោយយកចិត្តទុកដាក់ និងដោយមានការពិនិត្យពិច័យខ្ពស់ ។ មាត្រា១នៃច្បាប់នេះបានធ្វើការហាមឃាត់ការធ្វើបាតុកម្ម តាមប្រភេទមួយចំនួនដែល "អាចបង្កឱ្យខូចភាពសុខសាន្ត" ក៏ដូចជា ខូចសណ្តាប់ធ្នាប់ ឬសន្តិសុខសាធារណៈ ។ ការបដិសេធជាប្រចាំនាបច្ចុប្បន្ននេះ ចំពោះការស្នើសុំធ្វើបាតុកម្ម ការប្រជុំជាសាធារណៈ បង្ហាញឱ្យឃើញថា ច្បាប់ត្រូវបានប្រើប្រាស់តាមបែបដៃធ្ងន់ និងតាមទំនើងចិត្ត ។ ច្បាប់ក៏បានផ្តល់អំណាចឆន្ទានុសិទ្ធិយ៉ាងច្រើនលើសលុបទៅក្នុងដៃអាជ្ញាធរនានា ដែលមានអំណាចបដិសេធការស្នើសុំធ្វើបាតុកម្ម ។[១០៣] ទោះបីជាមានបញ្ហាទាំងនេះក៏ដោយ ក៏ក្រុមប្រឹក្សាធម្មនុញ្ញបានសំរេច កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២00៤ ថាច្បាប់នេះស្របតាមរដ្ឋធម្មនុញ្ញ ។

---

[១០១] មាត្រា ២៦៨ នៃច្បាប់ការងារ

[១០២] មាត្រា៥0 និងមាត្រា៥១ នៃរដ្ឋធម្មនុញ្ញ ។

[១០៣] មាត្រា២ (២)បានផ្តល់ឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ និងតាមទំនើងចិត្ត ដល់អ្នកធ្វើសេចក្តីសំរេច ។ មាត្រា៤ បានផ្តល់ឆន្ទានុសិទ្ធិមិនសមាមាត្រដល់នគរបាលដែលអាច "ចាត់វិធានការហាមឃាត់ " ដល់បាតុករដែលគ្មានការអនុញ្ញាតិនិង "បំបែកហ្វូងបាតុករនានា" ។

សហជីពខ្លះបានជួបប្រទះនូវការលំបាកជាច្រើនក្នុងការអនុវត្តន៍សិទ្ធិសេរីភាពរបស់ខ្លួនក្នុងការប្រជុំ និងការសំដែងមតិ ។ ចាប់តាំងពីមានកុប្បកម្មប្រឆាំងថៃ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣មក ពាក្យសុំធ្វើបាតុកម្មស្ទើរតែទាំងអស់ ត្រូវបានបដិសេធ ។ វាក្លាយជាបញ្ហាធម្មតាទៅហើយ សំរាប់នគរបាល ក៏ដូចជាកងកំលាំងសន្តិសុខបំរើការជាអ្នកយាមរោងចក្រ បំបែកក្បួនដង្ហែរ ព្យុះហយាត្រា និង បាតុកម្មផ្សេងៗ ដោយសំអាងលើហេតុផលសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ ។ នៅក្នុងឱកាសជាច្រើន មានការប្រើប្រាស់កំលាំងហួសកំរិត ដើម្បីមូលហេតុសុវត្ថិភាពសាធារណៈ គេតម្រូវឱ្យសុំការយល់ព្រមជាមុន ដើម្បីរៀបចំការប្រជុំធម្មតា ប៉ុន្តែជារឿយៗការស្នើសុំរបស់ពួកគេមិនទទួលបានការឆ្លើយតបឬបានទទួលចំលើយដែលយឺតពេលខ្លាំង សំរាប់ការរៀបចំប្រជុំ ដោយកាលបរិច្ឆេទដែលបានស្នើសុំមិនអាចធ្វើទៅបាន ។

ទោះបីជាឧស្សាហកម្មមួយចំនួន បានបង្កើតប្រព័ន្ធសហជីពកម្មករកំរិតខ្ពស់ក៏ដោយ ក៏ប្រធានសហជីពឯករាជ្យខ្លះបានទទួលការគំរាមកំហែងជាប្រចាំ ហើយសមាជិករបស់ខ្លួនមួយចំនួនត្រូវបានគេបណ្តេញចេញ ឬព្យួរការងារតាមទំនើងចិត្ត ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាបានក្លាយជាចំណុចដៅជាពិសេស ។ ករណីឃាតកម្មមួយចំនួន ដែលមិនទាន់បានដោះស្រាយកើតមានក្នុងឆ្នាំ២០០៤ លើរូបលោកជា វិជ្ជា និងលោក រស់ សុវណ្ណារ៉េត ដែលបច្ចុប្បន្នករណីទាំងនេះ ស្ថិតនៅចំពោះមុខគណៈកម្មាធិការទទួលបន្ទុកសេរីភាពខាងសមាគម នៃអង្គការពលកម្មអន្តរជាតិ ។ ករណីឃាតកម្មនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងជាពិសេស ដល់សកម្មភាពការងារសហជីព ។

## *ផ្នែកទី VIII : សេចក្តីសន្និដ្ឋាន និងអនុសាសន៍*

ភាពស្ថិតនៅយូរនៃបញ្ហានិទណ្ឌភាព នៅពេញមួយទសវត្សរកន្លងមកនេះ នៅក្នុងប្រទេសកម្ពុជា ដែលរបាយការណ៍នេះ បានព្យាយាមធ្វើការពន្យល់ បង្ហាញឱ្យឃើញថា ចំណាត់ការនានាផ្នែកច្បាប់ និង នយោបាយ ចាំបាច់ដើម្បីបង្កើតវប្បធម៌នៃការគោរពសិទ្ធិមនុស្ស និងដើម្បីធានាការពារសិទ្ធិគ្រប់យ៉ាងតាម រយៈនីតិរដ្ឋ ដែលជាស្នូលនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅមិនទាន់បានធ្វើនៅឡើយទេ។

ដូចបានកត់សំគាល់នៅក្នុងសេចក្តីផ្តើម លោកតំណាងពិសេសទាំងបីរូប បានសំដែងនូវកង្វល់យ៉ាង ខ្លាំងអំពីបញ្ហានិទណ្ឌភាពថាជាឧបសគ្គដ៏ធំចំពោះការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅក្នុងប្រទេស កម្ពុជា។ នៅក្នុងរបាយការណ៍ឆ្នាំ២០០៥ របស់លោកដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស លោក ភីធីរ លយប្រែកតឺ បានអះអាងថា "ជាការជាក់ស្តែងណាស់" បញ្ហានិទណ្ឌភាពកើតមានមិនត្រឹមតែដោយសារ សមត្ថភាពមានកំរិតទាបនៅក្នុងស្ថាប័នអនុវត្តច្បាប់ និងតុលាការមិនរឹងមាំប៉ុណ្ណោះទេ ប៉ុន្តែក៏ព្រោះតែ ប្រទេសកម្ពុជា នៅមិនទាន់បានបង្កើតស្ថាប័នរដ្ឋអព្យាក្រឹត្យ ដែលមានភារកិច្ចត្រួតពិនិត្យលើអំណាចនីតិ ប្រតិបត្តិ និងលើមធ្យោបាយពង្រឹងសិទ្ធិ ដែលបានធានាការពារនៅក្នុងច្បាប់ និងរដ្ឋធម្មនុញ្ញនៅឡើយ។ តុលាការនៅ តែស្ថិតនៅក្រោមការជ្រៀតជ្រែកពីសំណាក់អង្គការនីតិប្រតិបត្តិ និងការបណ្តោយឱ្យមាន អំពើពុករលួយ។ "កិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើកំណែទំរង់ប្រព័ន្ធយុត្តិធម៌នៅក្នុងអំឡុងពេលជាងមួយ ទសវត្សរកន្លងមកនេះ មិនមានការរីកចំរើនជាដុំកំភួននៅក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ឡើយ"។ យោធិន នគរបាល កងរាជអាវុធហត្ថ និងកំលាំងប្រដាប់អាវុធដទៃទៀត ដែលទទួលខុសត្រូវចំពោះការប្រព្រឹត្ត អំពើរំលោភធ្ងន់ធ្ងរមិនទាន់ត្រូវបានចាប់ខ្លួន ឬចោទប្រកាន់នៅឡើយទេ។[១០៤]

ទោះបីជាមានការខកខានក្នុងការនាំខ្លួនជនទាំងឡាយ ដែលទទួលខុសត្រូវទៅតុលាការ ដើម្បីធ្វើ ការផ្តន្ទាទោសតាមច្បាប់ ជារឿយៗបានបង្ហាញពីការខ្វះធនធាន និងសមត្ថភាពរបស់មន្ត្រីនានា ស្ថាប័ន អនុវត្តច្បាប់នៅទន់ខ្សោយ ហើយកិច្ចដំណើរការមិនល្អរបស់ប្រព័ន្ធតុលាការ ការខកខានរបស់ស្ថាប័នទាំង

---

[១០៤] សូមមើលរបាយការណ៍លេខ E/CN.4/2005/116 កថាខ័ណ្ឌទី១៤។

នេះ ក្នុងការលើកស្ទួយដល់ការគោរពច្បាប់ ក៏អាចបង្ហាញផងដែរអំពីទំលាប់ទទួលយកបញ្ហានិទណ្ឌភាព និងការឃុបឃិតពីសំណាក់នគរបាល យោធា និងទីភ្នាក់ងារសន្តិសុខនានា ។

ស្ថាប័នសន្និសញ្ញានានា បានគូសបញ្ជាក់ពីគំរូស្រដៀងគ្នានេះ ។ ស្ថាប័នទាំងនេះបានទទួលស្គាល់ថា ការបំពេញកាតព្វកិច្ចអន្តរជាតិ គឺពិតជាមានការលំបាកនៅក្នុងប្រទេសមួយ ដែលត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទាំដោយសង្គ្រាម ដែលជួបប្រទះអស្ថេរភាពនយោបាយ ហើយបន្តទទួលរងនូវឧបសគ្គធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ច ។[១០៥] ទោះជាយ៉ាងណាក៏ដោយ គេបានកត់សំគាល់ផងដែរថា ការលំបាកតែប៉ុណ្ណឹង មិនអាចជាហេតុនាំឱ្យប្រទេសកម្ពុជា ខកខានក្នុងការបំពេញកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនឡើយ ។ ជាពិសេស គណៈកម្មការនីមួយៗ បានផ្តល់អនុសាសន៍អំពីសេចក្តីត្រូវការឱ្យមានការដោះស្រាយបញ្ហានិទណ្ឌភាព ដើម្បីបោះជំហានទៅមុខ ។[១០៦] កង្វល់អំពីបញ្ហានិទណ្ឌភាព គឺមានការទាក់ទង ទោះជាបញ្ហាដែលត្រូវពិនិត្យពិច័យ គឺជាការរើសអើងពូជសាសន៍ សិទ្ធិកុមារ ការលុបបំបាត់ការធ្វើទារុណកម្ម ឬសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយជាទូទៅក្តី ។

ប្រទេសអ្នកផ្តល់ជំនួយនានាបានទទួលស្គាល់ថា កម្ពុជាកំពុងស្ថិតនៅត្រង់ចំណុច"ផ្លូវបំបែក" ហើយប្រសិនបើមិនធ្វើកំណែទម្រង់អភិបាលកិច្ចទេនោះ សមិទ្ធិផលអភិវឌ្ឍន៍ដែល "ទទួលបានដោយលំបាក" នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ នឹងជួបប្រទះឧបសគ្គជាពុំខាន ។ សេចក្តីត្រូវការដើម្បីពង្រឹង "ក្នុងករណីខ្លះត្រូវកសាងពីបាតដៃទទេ" ប្រព័ន្ធទទួលខុសត្រូវរបស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋកម្ពុជា ។ កំណែទម្រង់ក្នុងវិស័យសំខាន់ចាំបាច់មួយចំនួននឹងជួបប្រទះឧបសគ្គ "ពីព្រោះកំណែទម្រង់ទាំងនេះនឹងអាចប៉ះពាល់ដល់ផលប្រយោជន៍បុគ្គលមួយចំនួនដែលមានអំណាច ។ ជាងនេះទៅទៀត ដើម្បីសំរេចគោលដៅកំណែទម្រង់

---

[១០៥] សូមមើលឧទាហរណ៍ ក្នុងរបាយការណ៍លេខ CAT/C/CR/31/7 (2004), ផ្នែក " គ ", របាយការណ៍លេខ CCPR/C/79/Add.108 (1999) ផ្នែក " គ ", របាយការណ៍លេខ CRC/C/15/Add.128 (2000), ផ្នែក " គ ", របាយការណ៍លេខ CERD/C/304/Add.54 (1998) ផ្នែក " ខ " ។

[១០៦] ឧទាហរណ៍ គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ បានគូសបញ្ជាក់ក្នុងឆ្នាំ១៩៩៨ថា "មានកង្វល់ជាច្រើនអំពីកង្វះឯករាជ្យភាពនៃតុលាការ ការដែលគ្មានក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញក៏ដូចជាបញ្ហានិទណ្ឌភាពរបស់ជនដៃដល់ក្នុងអំពើរំលោភសិទ្ធិមនុស្ស ហើយការរំលោភសិទ្ធិមនុស្សក្នុងករណីខ្លះ ដូចជា ការសំលាប់ក្រៅច្បាប់ និងការធ្វើទារុណកម្ម ។ បញ្ហាទាំងនេះរួមចំណែកធ្វើឱ្យអន្តរាយយ៉ាងធ្ងន់ធ្ងរដល់កិច្ចខិតខំប្រឹងប្រែងបង្កើតនីតិរដ្ឋនៅកម្ពុជា បើគ្មាននីតិរដ្ឋទេ អនុសញ្ញានេះនឹងមិនអាចអនុវត្តបានពេញលេញឡើយ ។ សូមមើលសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ CERD/C/៣០៤/Add.៥៤ (១៩៩៨) ផ្នែក "គ" ចំណុច ៦ ។

ទាំងនេះ រដ្ឋាភិបាលត្រូវពឹងផ្អែកលើលិទ្ធិប្រជាធិបតេយ្យមួយដែលទន់ខ្សោយ មន្ត្រីរាជការមានប្រាក់បៀវត្សទាបជាដដែល និងស្ថាប័ននានាដែលមិនរឹងមាំ និងងាយពុករលួយដែលជាកម្មវត្ថុនៃការធ្វើកំណែទម្រង់នោះ ។[១០៨]

ទោះបីជាមានសេចក្តីព្រាងច្បាប់ជាច្រើន ក្នុងវិស័យផ្សេងៗត្រូវបានរៀបចំ តាំងពីការអនុម័តរដ្ឋធម្មនុញ្ញក្នុងឆ្នាំ១៩៩៣ គេឃើញមានការរីកចំរើនតិចតួចខាងវិស័យនីតិកម្មពិតប្រាកដ ក្នុងការកសាងក្របខ័ណ្ឌច្បាប់មួយ ដែលការពារសិទ្ធិមនុស្សដ៏មានប្រសិទ្ធភាព និងដ៏គត់ហ្មត់ ។ ច្បាប់ថ្មីៗ ទាមទារឱ្យមានមិនត្រឹមតែជំនួយផ្នែកបច្ចេកទេសសំរាប់ការព្រៀងច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែសំខាន់បំផុតនោះគឺការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល និងគណបក្សនយោបាយធំៗថា គេគួរតែអនុម័ត និងអនុវត្តច្បាប់ទាំងនោះ ។ ការដែលគ្មានការប្តេជ្ញាចិត្តនេះ នាំឱ្យការខ្វះខាតច្បាប់បន្តមានតទៅទៀត ហើយស្ថាប័ននានា មិនមានការគ្រប់គ្រងលើការការពារសិទ្ធិ ហើយអាចបណ្តាលឱ្យកើតមានបរិយាកាសនៃការរំលោភសិទ្ធិផ្សេងៗបាន ។

បុគ្គល និងក្រុមមួយចំនួន ដែលបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ ដោយរួមទាំងការរំលោភសិទ្ធិមនុស្ស ហើយជាពិសេស យោធិន នគរបាល កងរាជអាវុធហត្ថជាតិ និងកងកំលាំងប្រដាប់អាវុធដទៃទៀតមិនទាន់បានធ្វើការចាប់ខ្លួន ឬចោទប្រកាន់ ឬផ្តន្ទាទោសនៅឡើយ ។ សភាពការណ៍នេះ បាននាំទៅរកការបាត់បង់ជំនឿទុកចិត្តលើប្រព័ន្ធយុត្តិធមិ បានធ្វើឱ្យខូចដល់កិត្យានុភាពរបស់តុលាការ និងរដ្ឋាភិបាល ហើយបានផ្តល់លទ្ធភាពឱ្យជនដែលទទួលខុសត្រូវចំពោះអំពើល្មើសទាំងនេះ អាចបន្តប្រព្រឹត្តល្មើសច្បាប់តទៅទៀតដែលមិនអាចគ្រប់គ្រងបាន ។ នេះមានន័យថា ប្រជាពលរដ្ឋកម្ពុជា មិនបានទទួលការការពារពីច្បាប់ទេ ដោយហេតុថា ជនទាំងឡាយដែលបានប្រព្រឹត្តល្មើសច្បាប់ ត្រូវបានគេបណ្តោយឱ្យដើរហើរដោយសេរី ។ វាក៏អាចបង្កើតឱ្យមានកាលៈទេសៈនៃអំពើហឹង្សាជាទូទៅផងដែរ ដោយសារតែប្រជាពលរដ្ឋយល់ថា ពួកគេអាចកាន់ច្បាប់ក្នុងដៃរបស់គេដោយផ្ទាល់បាន ។

ការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលប្រទេសកម្ពុជាជាអ្នករៀបចំឡើង ដោយមានការជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ ទំនងជានឹងនាំឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើន ។ កិច្ចខិតខំប្រឹងប្រែងគួរធ្វើឡើងដើម្បីធានាសំរេចឱ្យបាននូវលទ្ធភាពនេះ ហើយការជំនុំជំរះទៀតសោធត្រូវ "សំរេចលទ្ធផលមួយដែល

---

[១០៨] សន្ទរកថាបើកដោយនាយកប្រចាំប្រទេសនៃធនាគារពិភពលោក ក្រុមពិគ្រោះយោបល់សំរាប់កិច្ចប្រជុំកម្ពុជា (CG) ខែធ្នូ ឆ្នាំ២០០៤ ។

មានគោលដៅធំ៧បី" គឺការលើកកំពស់បទដ្ឋាននៃនីតិវិធីត្រឹមត្រូវជាទូទៅ និងជំរុញឱ្យមានការវាយតំលៃខ្ពស់ថែមទៀតនៃនីតិរដ្ឋ និងសេចក្តីត្រូវការឱ្យមានការទទួលខុសត្រូវជាផ្លូវការ ក្នុងចំណោមមេដឹកនាំនានា និងប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ។ ជាពិសេស ការជំនុំជំរះនេះ ផ្តល់នូវឱកាសមួយដ៏សំខាន់ក្នុងការលើកកំពស់ឯករាជ្យភាព និងអធិបតេយ្យភាពរបស់តុលាការ ។ លើសពីនេះទៅទៀត បទពិសោធន៍ទាំងឡាយដែលបានមកពីការជំនុំជំរះនេះ មិនគួរកំណត់ចំពោះតែអ្នកដែលបានចូលរួមដោយផ្ទាល់នោះឡើយ ។ ទោះជាចៅក្រម និងព្រះរាជអាជ្ញាគ្រប់រូប ត្រូវធ្វើជាគំរូនៅក្នុងវិជ្ជាជីវៈច្បាប់ទាំងមូលក្តី ការជំនុំជំរះអាចមានប្រសិទ្ធិភាពដោយប្រយោល ដល់ការកសាងសមត្ថភាពនៅក្នុងសហគមន៍អ្នកច្បាប់ និងនគរបាលទូទៅ ដែលអាចទទួលការបណ្តុះបណ្តាលឱ្យចូលបំរើការងារ នៅក្នុងព្រំដែនដែលបានកំណត់ដោយច្បាប់អន្តរជាតិ ។ អវត្តមានជាទូទៅនៃនីតិវិធីត្រឹមត្រូវ ដូចបានរៀបរាប់នៅក្នុងរបាយការណ៍នេះ ត្រូវបានគេឃើញថាជាការដែលមិនអាចទទួលយកបានឡើយ ។[១០៩]

វាជាការសំខាន់ណាស់ដែលការជំនុំជំរះក្តីនេះ - ដែលបើតាម *អង្គច្បាប់* ត្រូវស្ថិតនៅចំពោះមុខ "អង្គជំនុំជំរះវិសាមញ្ញ " ក្នុងតុលាការកម្ពុជា[១១០] - ហើយ*តាមការអនុវត្តន៍ជាក់ស្តែង* គឺមិនធ្វើដាច់ដោយឡែកពីប្រព័ន្ធតុលាការកម្ពុជាឡើយ ។ ដូច្នេះហើយ វិធាននៃភស្តុតាង និងនីតិវិធីដែលអនុម័តដោយអង្គជំនុំជំរះវិសាមញ្ញ នឹងអាចជាវិធានរួមសំរាប់តុលាការកម្ពុជា*ទាំងអស់* ។[១១១]

---

[១០៩] សូមមេត្តាមើល ភាគទី៦ ។

[១១០] មាត្រា២ នៃ" *ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* " ចែងថា អង្គជំនុំជំរះវិសាមញ្ញ ត្រូវបានបង្កើតឡើង នៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ពោលគឺ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ...។

[១១១] សូមមេត្តាមើលកិច្ចព្រមព្រៀងទូទៅរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា លេខយោង#២ ខាងលើ ។ ដូច្នេះ មាត្រា១២ តម្រូវថា នីតិវិធីរបស់អង្គជំនុំជំរះវិសាមញ្ញ ត្រូវតែស្របជាមួយច្បាប់កម្ពុជា ប៉ុន្តែប្រសិនបើច្បាប់កម្ពុជាមិនស្របទៅនឹងបទដ្ឋានអន្តរជាតិទេនោះ "អាចស្វែងរកការណែនាំពីវិធាននានា ដែលបានកំណត់នៅកំរិតអន្តរជាតិ " ។ មាត្រា១៣ តម្រូវថា សិទ្ធិរបស់ជនជាប់ចោទ " ដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ត្រូវបានគោរពនៅទូទាំងកិច្ចដំណើរការជំនុំជំរះក្តីទាំងមូល ។ ជាពិសេស សិទ្ធិទាំងនេះត្រូវរួមទាំងសិទ្ធិៈ ចូលរួមក្នុងសវនាការត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានសន្មត់ជាមុនថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់... ហើយដើម្បីពិនិត្យ ឬបានពិនិត្យលើសាក្សីនានាដែលដាក់បន្ទុកលើខ្លួន" ។

ការអនុវត្តនីកំរងអនុសាសន៍ដ៏ទូលំទូលាយ ដែលបានធ្វើឡើងដោយលោកតំណាងពិសេសជាបន្តបន្ទាប់  មហាសន្និបាត  គណៈកម្មការសិទ្ធិមនុស្ស និងស្ថាប័ននានាទទួលបន្ទុកខាងសន្ធិសញ្ញា ចាប់តាំងពីឆ្នាំ ១៩៩៤ មក គឺមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហានិទណ្ឌភាព និងកត្តានានាដែលនាំឱ្យបញ្ហាទាំងនេះកើតមានឡើង។ ការព្រួយបារម្ភជាពិសេសនោះគឺ ការការពារសិទ្ធិទាំងឡាយ ដែលមិនអាចជាកម្មវត្ថុនៃការដកហូតសិទ្ធិគ្រប់ពេលវេលាដូចមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សិទ្ធិទាំងនោះរួមមានសិទ្ធិរស់រានមានជីវិត ការហាមឃាត់ការធ្វើទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងទទួលស្គាល់ថា ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។ នៅក្នុងសេចក្តីផ្តល់មតិទូទៅរបស់ខ្លួនលេខ២៩ គណៈកម្មាធិការសិទ្ធិមនុស្សក៏បានកត់សំគាល់ពី "ធាតុផ្សំដទៃទៀត"នៅក្នុងកតិកាសញ្ញាដែលបើតាមយោបល់របស់ខ្លួន មិនអាចជាកម្មវត្ថុនៃការដកហូតសិទ្ធិបានឡើយ ដោយរួមទាំងការប្រព្រឹត្តដោយមនុស្សធម៌ និងដោយគោរពសេចក្តីថ្លៃថ្នូរជាមនុស្សដែលមានមកពីកំណើត ចំពោះជនគ្រប់រូប ដែលត្រូវបានគេដកហូតសេរីភាពរបស់ខ្លួន។

អនុសាសន៍ជាគន្លឹះមួយចំនួនរួមមាន :

- ស្នើឱ្យមានការស៊ើបអង្កេតជាបន្ទាន់ និងធ្វើការចោទប្រកាន់ស្របទៅតាមនីតិវិធីត្រឹមត្រូវនៃច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនូវរាល់បណ្តឹងទាំងអស់ ដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស។
- ស្នើឱ្យពិនិត្យឡើងវិញ និងស៊ើបអង្កេតករណីរឿងដែលនៅសេសសល់ ទាក់ទងនឹងអំពើឃាតកម្ម និង ការសំលាប់ភ្លាមៗគួរឱ្យតក់ស្លុត និងអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដទៃទៀត ហើយនាំខ្លួនជនទាំងឡាយដែលទទួលខុសត្រូវទៅតុលាការ ដើម្បីធ្វើការផ្តន្ទាទោសទៅតាមច្បាប់។
- ស្នើឱ្យការពារជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្ស។ ជនរងគ្រោះនិងក្រុមគ្រួសាររបស់ពួកគេមានសិទ្ធិទទួលនូវសំណងជម្ងឺចិត្ត និងជួសជុលរាល់ការខូចខាតផ្សេងៗ។
- ស្នើបង្កើតគណៈកម្មការស៊ើបអង្កេតឯករាជ្យមួយ ដើម្បីពិនិត្យរាល់សកម្មភាពនៃអំពើហឹង្សាដោយហ្វូងមនុស្ស ពីមូលហេតុដែលនាំឱ្យកើតមានការវាយប្រហារ និងពីវិធីក្នុងការទប់ស្កាត់កុំឱ្យហេតុការណ៍ទាំងនេះកើតមានតទៅទៀត។
- ដើម្បីបញ្ចប់ការធ្វើទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចៅក្រម និងព្រះរាជអាជ្ញាគួរធ្វើការសាកសួរពីកាលៈទេសៈផ្សេងៗជុំវិញចំ

លើយសារភាពទាំងអស់ ដែលគេប្រើប្រាស់ជាភស្តុតាងក្នុងការជំនុំជំរះរឿងក្តីព្រហ្មទណ្ឌ មិនគួរអនុញ្ញាតឱ្យទទួលយកចំលើយសារភាពដោយបង្ខំ ធ្វើជាភស្តុតាងនៅក្នុងសវនាការឡើយហើយគួរតែផ្តន្ទាទោសចំពោះជនទាំងឡាយណា ដែលពាក់ព័ន្ធក្នុងការប្រើប្រាស់កំលាំងលើរូបកាយ ដើម្បីទទួលបានចំលើយសារភាព ។ គួរអនុវត្ត និងធ្វើវិសោធនកម្មដោយដាក់បញ្ចូលសេចក្តីតម្រូវផ្សេងៗក្រោមអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មទៅក្នុងច្បាប់ជាតិ ។[១១២] គួរបង្កើតឱ្យមានប្រព័ន្ធមួយដែលអនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាល ចូលពិនិត្យយ៉ាងទៀងទាត់នៅក្នុងបន្ទប់ឃុំឃាំងរបស់នគរបាល និង មន្ទីរឃុំឃាំងផ្សេងៗទៀត ។

- ជំរុញការអនុម័តឱ្យបានឆាប់រហ័សនូវច្បាប់និងក្រមនានាដែលជាផ្នែកមួយដ៏សំខាន់នៃគោលការណ៍ច្បាប់ជាមូលដ្ឋាន ។ ច្បាប់និងក្រមទាំងនោះត្រូវតែស្របជាមួយសន្ធិសញ្ញានានាដែលប្រទេសកម្ពុជាជាប់កាតព្វកិច្ចត្រូវអនុវត្តតាម ។
- កំណែទំរង់ប្រព័ន្ធយុត្តិធមិជាមូលដ្ឋាន គឺជាការសំខាន់ខ្លាំងណាស់ ក្នុងការបញ្ចប់បញ្ហានិទណ្ឌភាព ។ ប្រទេសកម្ពុជាត្រូវការប្រព័ន្ធតុលាការមួយដែលឯករាជ្យ មិនលំអៀង និងមានប្រសិទ្ធិភាព ។ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និង ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ គឺជាច្បាប់ដែលទាមទារការអនុម័តឱ្យបានឆាប់រហ័សបំផុត ។ ការរៀបចំរចនាសម្ព័ន្ធជាថ្មីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឱ្យមានភាពទូលំទូលាយ និង ស៊ីជំរៅ គឺសំខាន់ជាសារវ័ន្ត ។
- ប្រទេសកម្ពុជាត្រូវការឱ្យមានគណៈមេធាវីមួយដែលខ្លាំង ហើយឯករាជ្យ ។ បទបញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែផ្តល់ន័យត្រង់ច្បាស់លាស់ ចំពោះការចូលជាសមាជិកនៃគណៈមេធាវី តាមលក្ខណៈត្រឹមត្រូវ និងមិនលំអៀង ឱ្យតែអ្នកច្បាប់នោះបំពេញតាមលក្ខខណ្ឌទាំងឡាយដែលបានតម្រូវ ។ រដ្ឋាភិបាលមិនត្រូវធ្វើការជ្រៀតជ្រែកទៅក្នុងការងាររបស់គណៈមេធាវីឡើយ ។
- ប្រទេសកម្ពុជាក៏ត្រូវមានកម្មវិធីជំនួយផ្នែកច្បាប់ផងដែរ ដើម្បីជួយដល់ជនក្រីក្រដែលអាចប្រើប្រាស់ប្រព័ន្ធយុត្តិធមិ ដោយផ្អែកលើបទដ្ឋានមួយដែលរឹងមាំ ។

---

[១១២] វាមានសារសំខាន់បំផុត ចំពោះក្រមព្រហ្មទណ្ឌ និង ក្រមនីតិវិធីព្រហ្មទណ្ឌ

- ត្រូវលើកស្ទួយដល់សិទ្ធិជនជាប់ចោទ ក្នុងការចូលរួមក្នុងការជំនុំជំរះក្តីប្រកបដោយភាពត្រឹមត្រូវ សិទ្ធិនេះបានទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ ដោយការជំនុំជំរះក្តី ដែលរំលោភលើនីតិវិធីត្រឹមត្រូវ ។
- ត្រូវការឱ្យមានការបង្ហាញ និងធានាថា យោធា និងនគរបាលមិនស្ថិតនៅពីលើច្បាប់ឡើយ ហើយត្រូវបញ្ជាក់ឡើងវិញពីគោលការណ៍នៃ "ភាពស្មើគ្នាចំពោះមុខច្បាប់" ។ ស្នើសុំឱ្យបង្កើតគណៈកម្មាធិការជាន់ខ្ពស់មួយ ដើម្បីស៊ើបអង្កេតរាល់បណ្តឹងនានា ពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់យោធិន ឬនគរបាល ។
- ពង្រឹងលក្ខខណ្ឌនៃការឃុំខ្លួន ដោយរួមទាំងការពិនិត្យលើគោលនយោបាយក្នុងការកាត់ទោស និងការបង្កើតឱ្យមានជំរើសផ្សេងៗនៃការដាក់ឱ្យនៅក្រៅឃុំ ជំនួសឱ្យការដាក់ពន្ធនាគារ ការផ្តល់ម្ហូបអាហារសមរម្យ និងការថែទាំសុខភាពដល់អ្នកទោស និងពិរុទ្ធជន បំពេញសេចក្តីត្រូវការពិសេសរបស់ស្ត្រី និងកុមារ និងអនុញ្ញាតឱ្យមេធាវី សមាជិកគ្រួសារ និងអង្គការសិទ្ធិមនុស្សនានាចូលក្នុងពន្ធនាគារ ដើម្បីជួបសួរសុខទុក្ខអ្នកទោស ដោយអនុវត្តស្របតាមបទបញ្ជាពាក់ព័ន្ធជាធរមាន ។
- អនុវត្តតាមសេចក្តីថ្លែងការណ៍របស់អ.ស.ប ស្តីពីអ្នកការពារសិទ្ធិមនុស្ស ។ ប្រទេសកម្ពុជាមានសង្គមស៊ីវិលមួយដែលសកម្ម ហើយខ្លាំង ដែលដើរតួនាទីមួយយ៉ាងសំខាន់ក្នុងការពង្រឹងដល់ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋនៅក្នុងប្រទេស ។ ត្រូវធានាអោយលទ្ធភាពរបស់គេក្នុងការបំពេញការងារដ៏សំខាន់នេះ បានដោយពេញលេញនិងដោយសេរី ។

អនុសាសន៍ទាំងនេះ គួរតែអាន ពិចារណា និងអនុវត្ត ស្របជាមួយរបាយការណ៍ និងអនុសាសន៍នានា ដែលបានបង្ហាញដោយលោកតំណាងពិសេស តាំងពីឆ្នាំ ១៩៩៤មក ។ អនុសាសន៍ទាំងនេះ តំណាងឱ្យធាតុអប្បបរមា នៃយុទ្ធសាស្ត្រមានប្រសិទ្ធិភាព ដើម្បីបញ្ចប់និទណ្ឌភាពនៅកម្ពុជា ។

## ឧបសម្ព័ន្ធ ក : កំណត់សំគាល់អំពីប្រភពផ្សេងៗ :

របាយការណ៍នេះ ត្រូវបានសរសេរចងក្រងឡើង ដោយផ្អែកលើឯកសារបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ ។ របាយការណ៍នេះធ្វើការដកស្រង់ចេញពីរបាយការណ៍នានា របស់លោកតំណាងពិសេសទាំងឡាយនៃអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដាក់ជូនមហាសន្និបាត និងគណៈកម្មការសិទ្ធិមនុស្ស និងរបាយការណ៍ដទៃទៀត តាមវិស័យនីមួយៗ ។ របាយការណ៍នេះ ក៏បានធ្វើការដកស្រង់ចេញពីរបាយការណ៍នានា នៃរដ្ឋាភិបាលកម្ពុជា ដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស និងគណៈកម្មការប្រឆាំងការធ្វើទារុណកម្ម ហើយក៏បានដកស្រង់ផងដែរចេញពីសេចក្តីសន្និដ្ឋាន និងអនុសាសន៍មួយចំនួន ដែលគណៈកម្មការទាំងពីរនេះបានធ្វើឡើង ។ ឯកសារទាំងនេះ អាចរកឃើញផងដែរនៅក្នុងគេហទំព័រ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ។

### គណៈកម្មការសិទ្ធិមនុស្ស

- សេចក្តីសំរេចចិត្តរបស់គណៈកម្មការសិទ្ធិមនុស្ស : របាយការណ៍លេខ E/CN.4/RES/1993/6
- សេវាប្រឹក្សាយោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា: E/CN.4/2005/116
- សេវាប្រឹក្សាយោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា: E/CN.4/2004/105
- សេវាប្រឹក្សាយោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា: E/CN.4/2003/114
- សេវាប្រឹក្សាយោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា: E/CN.4/2002/118
- សេវាប្រឹក្សាយោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា: E/CN.4/2001/103

- សេវាប្រឹក្សាយោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា: E/CN.4/2000/109
- សេវាប្រឹក្សាយោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា: E/CN.4/1999/101
- សេវាប្រឹក្សាយោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា: E/CN.4/1998/95
- សេវាប្រឹក្សាយោបល់ក្នុងវិស័យសិទ្ធិមនុស្ស តួនាទីរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស : របាយការណ៍លេខ E/CN.4/1998/94
- សេវាប្រឹក្សាយោបល់ក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា : របាយការណ៍លេខ E/CN.4/1997/85
- សេវាប្រឹក្សាយោបល់ក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា : របាយការណ៍លេខ E/CN.4/1996/93
- សេវាប្រឹក្សាយោបល់ក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា : របាយការណ៍លេខ E/CN.4/1995/87
- សេវាប្រឹក្សាយោបល់ក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា : របាយការណ៍បន្ថែមលេខ E/CN.4/1995/87/Add.1
- សេវាប្រឹក្សាយោបល់ក្នុងវិស័យសិទ្ធិមនុស្ស ។ របាយការណ៍របស់លោកតំណាងពិសេសអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា : របាយការណ៍បន្ថែមលេខ E/CN.4/1994/73/Add.1
- របាយការណ៍របស់Diane Orientlicher អ្នកជំនាញការឯករាជ្យ ក្នុងការធ្វើបច្ចុប្បន្នភាពកម្រងគោលការណ៍នានា ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហានិទណ្ឌភាព កម្រងគោលការណ៍ទាំងឡាយដែលបានធ្វើបច្ចុប្បន្នភាពរួចហើយ សំរាប់ការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស តាមរយៈសកម្មភាពប្រយុទ្ធប្រឆាំងនឹងបញ្ហានិទណ្ឌភាព:របាយការណ៍លេខ E/CN.4/2005/102/Add.1

## មហាសន្និបាត

- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា សេចក្តីសំរេចចិត្តរបស់មហាសន្និបាត អ.ស.ប.: A/RES/58/191
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/58/317
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/57/230
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/56/209
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/55/291
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/54/353
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/53/400
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/52/489
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/51/453
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/50/681
- ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៏របស់លោកតំណាងពិសេស ដែលត្រូវបានលោកអគ្គលេខាធិការដាក់ជូនមហាសន្និបាត អ.ស.ប.: របាយការណ៏លេខ A/49/635

## ស្ថាប័នទទួលបន្ទុកខាងសន្ធិសញ្ញា

- របាយការណ៏ដំបូងរបស់កម្ពុជាដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស: CCPR/C/81Add.12
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម: CAT/C/CR/31/7

- សេចក្តីសង្កេតសន្និដ្ឋាន នៃគណៈកម្មការសិទ្ធិមនុស្ស: របាយការណ៍លេខ CCPR/C/79/Add.108
- សេចក្តីសង្កេតសន្និដ្ឋាននៃគណៈកម្មាធិការលុបបំបាត់រាល់ការរើសអើងប្រកាន់ពូជសាសន៍: CERD/C/304/Add.54
- សេចក្តីសង្កេតសន្និដ្ឋាន នៃគណៈកម្មការសិទ្ធិកុមារ: របាយការណ៍លេខ CRC/C/15/Add.128

## របាយការណ៍ និងអនុស្សារណៈផ្សេងៗ

- របាយការណ៍ចុងក្រោយរបស់ផ្នែកសិទ្ធិមនុស្សអ៊ុនតាក់ ចុះខែកញ្ញា ឆ្នាំ១៩៩៣
- របាយការណ៍របស់ក្រុមអ្នកជំនាញការ: ការវាយប្រហារដោយគ្រាប់បែកដៃនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ ហើយនិងការសំលាប់ក្រៅច្បាប់ កាលពីថ្ងៃទី២-៧ ខែកក្កដា ឆ្នាំ ១៩៩៧ : ការវាយតំលៃលើការស៊ើបអង្កេត ខែឧសភា ឆ្នាំ១៩៩៨។
- របាយការណ៍របស់ក្រុមអ្នកជំនាញការសំរាប់កម្ពុជា: A/53/850 ខែកុម្ភៈ ឆ្នាំ១៩៩៩។
- របាយការណ៍បេសកកម្មរបស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីធ្វើការវាយតំលៃពីសភាពការណ៍បច្ចុប្បន្ន នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា : ថ្ងៃទី១០-២២ ខែកក្កដា ឆ្នាំ១៩៩៩។
- អនុសាសន៍របស់លោកតំណាងពិសេស: ភស្តុតាងនៃការប្រហារជីវិតភ្លាមៗគួរឱ្យតក់ស្លុត ការធ្វើទារុណកម្ម និងការបាត់ខ្លួនមនុស្ស ចាប់ពីថ្ងៃទី២-៧ ខែកក្កដា ឆ្នាំ១៩៩៧។
- អនុសាសន៍របស់លោកតំណាងពិសេស ចំពោះរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨។
- ការឃ្លាំមើលរបស់តំណាងពិសេស អំពីអំពើហិង្សា និងការបំភិតបំភ័យខាងនយោបាយ ឆ្នាំ១៩៩៨។
- របាយការណ៍របស់លោកតំណាងពិសេស នៃលោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្ស ស្តីពីសិទ្ធិខាងសារព័ត៌មាន ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៨។
- របាយការណ៍របស់លោកតំណាងពិសេស: គំនុំសងសឹកនៅលើដងផ្លូវ ក្នុងប្រទេសកម្ពុជា ខែមិថុនា ឆ្នាំ២០០២។
- របាយការណ៍របស់លោកតំណាងពិសេស: ស្ថានភាពពន្ធនាគារនៅកម្ពុជា ឆ្នាំ១៩៩៤ ឆ្ពោះទៅកាន់គោលនយោបាយពន្ធនាគារប្រកបដោយមនុស្សធម៌ នៅប្រទេសកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០០២។
- របាយការណ៍របស់លោកតំណាងពិសេស : ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ ចុះខែធ្នូ ឆ្នាំ២០០៣។
- របាយការណ៍របស់លោកតំណាងពិសេស: ដីសម្បទានគោលដៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា

## ឧបសម្ព័ន្ធ ខ : ករណីដោយឡែកផ្សេងៗចំពោះបុគ្គលៈ

១. ករណីសម្រាំងចាប់ពីខែធ្នូ ឆ្នាំ១៩៩២ ដល់ខែតុលា ឆ្នាំ២០០៣ ដែលបានលើកឡើងជាថ្មីម្តងទៀតជាមួយរាជរដ្ឋាភិបាលកម្ពុជា

ចាប់ពីឆ្នាំ១៩៩២រហូតមក អ៊ុនតាក់ និងលោកតំណាងពិសេសនានានៃអគ្គលេខាធិការអ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានលើកឡើងនូវករណីរំលោភសិទ្ធិមនុស្សជាក់លាក់ជាច្រើនជាមួយអាជ្ញាធរកម្ពុជា ។ ដូចបានកត់ត្រាទុកនៅក្នុងរបាយការណ៍នេះ បញ្ជីមួយដែលមានចំនួន ១៧៨ករណី ត្រូវបានដាក់បញ្ចូលក្នុងលិខិតមួយចុះខែកុម្ភៈ ឆ្នាំ២០០៤ ហើយបានផ្ញើជូនរាជរដ្ឋាភិបាលកម្ពុជារួចហើយ ។ ក្នុងខែវិច្ឆិកា ឆ្នាំ ២០០៤ ក្រសួងមហាផ្ទៃក៏បានផ្តល់ចម្លើយមួយជូនលោកតំណាងពិសេស ។ ករណីទាំងឡាយដែលបានលើកឡើងក្នុងរបាយការណ៍នេះ ក៏ដូចជាករណីជាបន្តបន្ទាប់ បង្ហាញយ៉ាងច្បាស់ពីកន្សោមនៃការរំលោភសិទ្ធិមនុស្ស ដែលបានកើតឡើង និងបន្តកើតឡើង ។ ករណីទាំងនោះក៏បានបង្ហាញឱ្យឃើញផងដែរនូវបែបផែនជាការស៊ីសង្វាក់គ្នាមួយនៃភាពយឺតយ៉ាវ និងភាពគ្មានឆន្ទៈក្នុងការស៊ើបអង្កេត ការចោទប្រកាន់តាមផ្លូវតុលាការ និងការជំនុំជំរះនានា ចំពោះជនទាំងឡាយនោះដែលទទួលខុសត្រូវ ។ ខាងក្រោមនេះ គឺជាករណីទាំងឡាយបន្ថែមលើករណីដែលបានលើកឡើងរួចហើយក្នុងរបាយការណ៍ទាំងស្រុង ហើយគួរតែយល់ឃើញថា វាស្របទៅនឹងរបាយការណ៍នោះ ។

### ករណីទាំងឡាយដែលកំពុងតែស៊ើបអង្កេត

ករណីចំនួន ៦៤ ក្នុងចំណោមករណីចំនួន ១៧៨ ដែលបានដាក់ជូនរាជរដ្ឋាភិបាល ហើយមូលហេតុដែលបាន ផ្តល់ជូនគឺថា គេមិនទាន់បានធ្វើការចាប់ខ្លួនទេ ពីព្រោះការស៊ើបអង្កេតកំពុងតែបន្ត ។ ករណីទាំងនេះរួមមាន :

*ករណីគណៈបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា :*

កាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥ ការវាយប្រហារដោយគ្រាប់បែកជាច្រើនលើក ត្រូវបានធ្វើឡើងទៅលើបរិវេណគណៈបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ដែលដឹកនាំដោយលោកតាសឹន សាន និងទៅលើវត្តមួយដែលអ្នកគាំទ្រគណៈបក្សនេះស្នាក់នៅ ។

*ករណីឈ្មោះ សុខ វ៉ាន់ថន និង ស៊ូ សាល :*

កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៩៧ ទាហានជាច្រើននៃកងវរៈសេនាធំលេខ៣៧ ដែលមានទីតាំងនៅក្នុងឃុំអូរ ខេត្តកំពង់ស្ពឺ បានចាប់ខ្លួនកសិករម្នាក់ឈ្មោះ សុខ វ៉ាន់ថន និង មនុស្សចំនួន ៣នាក់ទៀត - ២នាក់ជាបងប្អូន ប្រុសនឹងគ្នាមានឈ្មោះ ស៊ូ ស៊ី និង ស៊ូ សាល ដែលអ្នកទាំងពីរនេះជាអតីតទាហានខ្មែរក្រហម និងអ្នកភូមិទី៣ ម្នាក់ទៀតឈ្មោះ ហៀម បែក ។ នៅថ្ងៃទី១៤ ខែសីហា អ្នកភូមិជាច្រើនបានប្រទះឃើញសាកសព សុខ វ៉ាន់ ថន និង ស៊ូ សាល ។ ដៃ និង កជើងរបស់ពួកគេត្រូវបានចងជាប់ និង បាក់ក ។ ភ្នែកពួកគេត្រូវបានខ្វេះចេញ ។ ក្បាល ទ្រូង និងពោះរបស់ពួកគេត្រូវបានគេវះ ។ ថ្លើម និង ប្រម៉ាត់ ត្រូវបានកាត់យក ។ តាមសេចក្តីរាយ ការណ៍ មនុស្ស ២នាក់ផ្សេងទៀតបានរត់គេចខ្លួនរួច ។

*ករណីវាយប្រហារទៅលើតុលាការក្រុងភ្នំពេញ :*

កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៨ កងរាជអាវុធហត្ថប្រហែល ៥0នាក់ ប្រដាប់ដោយអាវុធធុនធ្ងន់ មកពីខ័ណ្ឌដូនពេញក្នុងទីក្រុងភ្នំពេញ បានឡោមព័ទ្ធតុលាការក្រុងភ្នំពេញ ក្រោយពីតុលាការសម្រេចដោះលែងជន សង្ស័យ ២នាក់ ក្នុងករណីឃាតកម្មមួយ ។ ពួកគេបានបង្ខំឱ្យតុលាការប្រគល់ជនទាំង២នាក់នោះ ហើយត្រូវ បានវាយដំយ៉ាងធ្ងន់ធ្ងរ និង ក្រោយមកត្រូវបានបញ្ជូនទៅពន្ធនាគារ T-3 ។

*ករណីឈ្មោះ ថុង សយ :*

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៨ ឈ្មោះថុង សយ ដែលជាតំណាងគណៈបក្សរាស្ត្រនិយម ប្រចាំនៅស្រុក សន្ទុក ខេត្តកំពង់ធំ ត្រូវបានបាញ់សម្លាប់ នៅពេលលោកកំពុងធ្វើដំណើរមកភូមិវិញពីការមើលថែទាំស្រែ ។

*ករណីឈ្មោះ សៅ សាវ៉ន :*

កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២00២ ឈ្មោះសៅ សាវ៉ន ដែលជាអ្នកសង្កេតការណ៍អង្គការនិកហ្វិក (NICFEC) បានត្រូវសម្លាប់នៅភូមិតាល្បៀង ឃុំរមាំងថ្កោល ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

**ករណីដែលមិនមានចំណាត់ការ**

ករណីចំនួន ២៥ ក្នុងចំណោមករណីចំនួន ១៧៨ មូលហេតុដែលបានផ្តល់ជូនថាមិនត្រូវបានចាត់ការ ពីព្រោះសកម្មភាពទាំងនេះទាក់ទងនឹងការប្រយុទ្ធគ្នា ដែលកើតឡើងពីខែកក្កដាឆ្នាំ១៩៩៧ ។

*ករណីលោកវេជ្ជបណ្ឌិត សេង គឹមលី :*

កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៧ វេជ្ជបណ្ឌិតសេង គឹមលី ដែលជាគ្រូពេទ្យយោធាត្រូវបាន ប្រទះឃើញស្លាប់នៅក្នុងនិវេសនដ្ឋានរបស់លោកនៅទីក្រុងភ្នំពេញ។ លោកត្រូវបានគេបាញ់ចំនួន ៣គ្រាប់ ត្រង់ក្បាល និងទ្រូង។

*ករណីអង្គរក្សរបស់លោកឧត្តមសេនីយ៍ ញឹក ប៊ុនឆៃ :*

កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៧ អង្គរក្សចំនួន៤នាក់ របស់លោកឧត្តមសេនីយ៍ញឹក ប៊ុនឆៃ ត្រូវបានសម្លាប់ភ្លាម១តែម្តង ក្រោយពីទាហានដែលស្មោះនឹងគណៈបក្សប្រជាជនកម្ពុជា វាយដណ្តើមបានផ្ទះ សំរាប់ធ្វើជាការិយាល័យរបស់លោកឧត្តមសេនីយ៍ នៅសំណង់ ១២។

*ករណីលោកឧត្តមសេនីយ៍ ចៅ សម្បត្តិ និង ក្រូច យឿម*

កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៧ លោកឧត្តមសេនីយ៍ចៅ សម្បត្តិ ដែលជានាយករងនៃនាយកដ្ឋាន ស៊ើបការ និងចារកម្ម និងលោកឧត្តមសេនីយ៍ក្រូច យឿម ដែលជាអនុរដ្ឋលេខាធិការក្រសួងការពារជាតិត្រូវ បានសម្លាប់ភ្លាម១តែម្តង។ មុនហេតុការណ៍នោះ សាក្សីបានឃើញទាហានជាច្រើននៃវរៈសេនាធំកងទ័ពឆ័ត្រ យោងលេខ ៩១១ កំពុងតែចាប់ខ្លួនពួកគេនៅជិតស្ថានីយ៍រថភ្លើងដំណាក់ស្មាច់នៅខាងកើតស្រុកឧត្តុង្គ ខេត្ត កំពង់ស្ពឺ។

*ករណីឈ្មោះ ឈុន ម៉ា*

កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧ មានទាហានចំនួន ១២នាក់ មកពីស្រុកវ៉ារិន ដែលអះអាង ថាស្ថិតក្រោមការបញ្ជារបស់មន្ត្រីយោធាម្នាក់ឈ្មោះមាស ម៉ម បានឡោមព័ទ្ធផ្ទះឈ្មោះឈុន ម៉ា នៅភូមិ ប្រាសាទ ឃុំប្រាសាទ ស្រុកវ៉ារិន ខេត្តសៀមរាប។ លោក ឈុន ម៉ា បានគេចខ្លួនរួច។ ទាហានទាំងនោះ ក៏បានបាញ់រះ កាំភ្លើងចូលទៅក្នុងផ្ទះ ហើយបណ្តាលឱ្យត្រូវកូនប្រុសអាយុ១០ឆ្នាំ របស់លោកស្លាប់។ ក្រោយមក ទាហានទាំងនោះបានឆែកឆេរនៅក្នុងផ្ទះ ហើយបានវាយប្រពន្ធរបស់លោកទៀតផង ។

*ករណីឈ្មោះ ភាព :*

កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៧ លោក ភាព ដែលជាអង្គរក្សរបស់ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលជានាយករដ្ឋមន្ត្រីទី១ ត្រូវបានសម្លាប់ដោយអង្គរក្សរបស់លោកហ៊ូរ សារ៉េត ដែលពេលនោះត្រូវបានតែងតាំងថ្មីៗ ជាមេបញ្ជាការអង្គភាពកងរក្សាព្រះអង្គប្រចាំនៅតាំងក្រសាំង ។ ជាច្រើនថ្ងៃក្រោយមកសាកសពលោក ភាព ត្រូវបានគាស់ចេញពីក្នុងដី ។ សាកសពមានស្នាមរឹតកជាច្រើន និងបាក់កផង ។

ហេតុផលដែលផ្តល់ជូនថាមិនមានចំណាត់ការក្នុងករណីទាំង៤នេះ គឺដោយសារតែខ្មែរក្រហមត្រួតត្រាតំបន់នោះ ។ ករណីទាំងនោះរាប់បញ្ចូលទាំង :

*ករណីនៅភូមិ ពាម សូ :*

កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៩៤ ដោយរាប់បញ្ចូលទាំងកូនក្មេងផង មានមនុស្សចំនួន ១៣នាក់ ត្រូវបានសម្លាប់នៅក្នុងការវាយប្រហារមួយទៅលើសហគមន៍ជនជាតិវៀតណាម នៅក្នុងភូមិពាមសូ ស្រុកស្អាងខេត្តកណ្តាល ។ មនុស្សចំនួន២៥នាក់ផ្សេងទៀត ដែលភាគច្រើនជាកុមារ បានរងរបួសផងដែរ ។ ការវាយប្រហារនោះ ត្រូវបានធ្វើឡើងក្នុងនាមកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ (NADK) ។ ជនសង្ស័យទាំង៧នាក់ ត្រូវបានដោះលែងដោយសារតែគ្មានភស្តុតាង ។

*ករណីអង្គការពិគ្រោះយោបល់មីន (MAG):*

កាលពីក្នុងខែមីនា ឆ្នាំ១៩៩៦ ទាហានខ្មែរក្រហមបានចាប់ខ្លួនអ្នកដោះមីន របស់អង្គការ MAG ចំនួន៣០នាក់ នៅស្រុកអង្គរជុំ ខេត្តសៀមរាប ។ ដំបូង ជនចាប់ជំរិតបានទាមទារប្រាក់រំលោះ ហើយបានដោះលែងពួកគេវិញ តែទុកមនុស្ស ២នាក់ ដែលមានឈ្មោះ គ្រីសស្តុហ្វហ៊ឺ ហូវស៏ (Christopher Howes) ជាគ្រូបង្វឹកជនជាតិអង់គ្លេស និង ឈ្មោះ ហួន ហួត ជនជាតិខ្មែរជាជំនួយការរបស់គាត់ ។ គេជឿជាក់ថាមន្ត្រីខ្មែរក្រហមពិតជាបានសម្លាប់ពួកគេនៅអន្លង់វែង ។

**ករណីទាំងឡាយដែលមិនត្រូវបានចាត់ការ - ហេតុផលផ្សេងៗ**

ហេតុផលជាច្រើនផ្សេងៗទៀត ត្រូវបានគេផ្តល់ជូន ដោយសារតែការខនខានមិនបានស៊ើបអង្កេត និងចោទប្រកាន់តាមផ្លូវតុលាការ ។

*ករណីលោក ថុង សុផារ៉ា ៖*

កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៦ លោកថុង សុផារ៉ា ត្រូវបានវាយដំរហូតដល់ស្លាប់នៅពេលលោកស្ថិតក្នុងការឃុំឃាំងនៅខេត្តសៀមរាប ។ ក្រសួងមហាផ្ទៃបានជម្រាបថា នគរបាលខេត្តមិនបានស៊ើបអង្កេត ឬចាត់ការលើឯកសារករណីនេះទេ ដោយសារតែគ្មានដីកាពីព្រះរាជអាជ្ញាបញ្ជាឱ្យនគរបាលស៊ើបអង្កេត ។

*ករណីលោក ដាញ់ ទាវ*

កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ លោកដាញ់ ទាវ ដែលជាមន្ត្រីនគរបាលម្នាក់ផ្នែកប្រឆាំងអំពើភាវរកម្មនៃក្រសួងមហាផ្ទៃ ត្រូវបានចាប់ខ្លួន ឃុំខ្លួននិងសួរចម្លើយនៅក្នុងការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់របស់នគរបាលក្រុងភ្នំពេញ ។ គាត់ត្រូវបានវាយដំរហូតដល់សន្លប់ ហើយក្រោយមកឱ្យផ្តិតមេដៃលើចម្លើយសារភាព ។ នៅថ្ងៃទី២១ ខែកក្កដា គាត់ត្រូវបានគេនាំយកទៅតុលាការក្រុងជាមួយមនុស្ស៥នាក់ផ្សេងទៀត ដែលត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងករណីតែមួយ ។ ពួកគេមានស្លាកស្នាមវាយដំនៅលើមុខ ខ្នង និងទ្រូង ។ ក្រសួងមហាផ្ទៃបានជម្រាបថា ដាញ់ ទាវ ត្រូវបានចាប់ខ្លួនជាមួយជនល្មើស៣នាក់ផ្សេងទៀត ហើយត្រូវបានគេបញ្ជូនទៅតុលាការក្រុងភ្នំពេញ ។ ពួកគេត្រូវបានឃុំខ្លួននៅពន្ធនាគារ PJ តាមដីកាចាប់ខ្លួន ដែលតុលាការចេញកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩៨ ។ ចម្លើយរបស់ក្រសួងមិនបានលើកឡើងពីការស៊ើបអង្កេតណាមួយទៅលើអំពើទារុណកម្មដែលសង្ស័យថាត្រូវបានធ្វើឡើងទៅលើ ដាញ់ ទាវ នៅពេលដែលគាត់ស្ថិតក្នុងការឃុំខ្លួនរបស់នគរបាលឡើយ ។

*ករណីលោក ជា ប៊ុនថន ៖*

កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៩ លោក ជា ប៊ុនថន បានស្លាប់ដោយសារតែការធ្វើទារុណកម្មក្រោយពីនគរបាលស្រុកកៀនស្វាយ ខេត្តកណ្តាល បានចាប់ខ្លួន និងឃុំខ្លួនគាត់ដោយគ្មានដីកា ។ ក្រសួងមហាផ្ទៃបានជម្រាបជូនថា នគរបាលបានឃុំខ្លួនលោក ជា ប៊ុនថន រយៈពេល៤៨ម៉ោង ដើម្បីកសាងសំនុំរឿងបញ្ជូនទៅតុលាការ ។ នៅចន្លោះម៉ោង ១០ និង ម៉ោង ១១យប់ លោកជា ប៊ុនថន ក៏បានធ្វើអត្តឃាតដោយចងកខ្លួនឯង ។ ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រ និងអាជ្ញាធរមូលដ្ឋាន ក៏បានធ្វើកោសល្យវិច័យ ។ ផ្អែកតាមការស៊ើបអង្កេតដែលធ្វើឡើងដោយក្រុមអង្គការសិទ្ធិមនុស្ស បានឱ្យដឹងថាតាមសេចក្តីរាយការណ៍

ដៃទាំងពីររបស់លោកជា ប៊ុនថន មានជាប់ខ្នោះនៅពេលគេឃើញគាត់នៅក្នុងបន្ទប់ឃុំឃាំង ។ កោសល្យវិច័យពេទ្យមិនបានដាក់បញ្ចូលទៅក្នុងរបាយការណ៍របស់នគរបាលស្តីពីករណីនេះឡើយ ។ នគរបាលបានបញ្ជាឱ្យប្រពន្ធ លោក ជា ប៊ុនថន បូជាសពជាបន្ទាន់ ។ សមាជិកក្រុមគ្រួសារ និងអ្នកដែលធ្វើបុណ្យសពបាននិយាយថា សាកសពមានស្នាមជាំក្រហមខ្មៅ នៅជុំវិញក ដើមភ្លៅ កជើង និងក្រចកដៃ ។

**ករណីដែលមានវិធានការដាក់វិន័យ**

ករណីចំនួន៣ ក្នុងចំណោម១៧៨ករណី ក្រសួងមហាផ្ទៃបានកត់សំគាល់ថា មានវិធានការដាក់វិន័យត្រូវបានធ្វើឡើងជំនួសការកាត់ទោសដោយតុលាការ ហើយករណីទាំងនោះមាន :

*ករណីឈ្មោះ ស្រី តូច :*

កាលពីខែកក្កដា ឬ ខែសីហា ឆ្នាំ១៩៩៦ នាយកពន្ធនាគារបានរំលោភសេពសន្ថវៈពិរុទ្ធជនស្ត្រីម្នាក់ឈ្មោះ ស្រី តូច នៅពន្ធនាគារខេត្តកោះកុង ។ ក្រសួងមហាផ្ទៃបានជម្រាបថា នាយកពន្ធនាគាររូបនេះត្រូវបានដកចេញពីតួនាទីនៅក្នុងឆ្នាំ១៩៩៧ ក្រោយពីគេរកឃើញថាមានការរំលោភបែបនោះមែន ។ តាមសេចក្តីរាយការណ៍ជាបន្តបន្ទាប់បានឱ្យដឹងថា លោកនាយកពន្ធនាគាររូបនេះ ត្រូវបានផ្តល់តួនាទីជាមន្ត្រីនគរបាលជាន់ខ្ពស់មួយនៅក្នុងខេត្តទៅវិញទេ ។

*ករណីជួញដូរមនុស្ស :*

កាលពីខែធ្នូ ឆ្នាំ១៩៩៧ បណ្តាញជាច្រើនដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស បានត្រូវរកឃើញថាកំពុងតែរកស៊ីជួញដូរមនុស្សពីស្រុកដងទង់ និងស្រុកបាក់ខ្លង ក្នុងខេត្តកោះកុង ។ បណ្តាញទាំងនេះមានការពាក់ព័ន្ធក្នុងអំពើលក់ដូរមនុស្សក្មេងៗ ដោយមានល័ក្ខខ័ណ្ឌដ៏អាក្រក់បំផុត ដើម្បីទៅធ្វើការងារនៅប្រទេសថៃ ។ លោកស្នងការនគរបាលខេត្តកោះកុង បានទទួលស្គាល់ថា មាននគរបាលមួយចំនួនពាក់ព័ន្ធក្នុងអំពើជួញដូរមនុស្ស ហើយថាបានបញ្ជូនឈ្មោះមេខ្លោងចំនួន៤នាក់ ទៅក្រសួងមហាផ្ទៃរួចហើយ ។ ក្រសួងមហាផ្ទៃបានជម្រាបថា អ្នកទាំងនោះត្រូវបានបញ្ជូនមកក្រសួងមហាផ្ទៃ ដើម្បីដាក់វិន័យហើយ ប៉ុន្តែក្រសួងមិនបញ្ជាក់ឱ្យបានច្បាស់ថាតើវិធានការដាក់វិន័យ ដែលធ្វើឡើងទៅលើពួកគេតាមប្រភេទណានោះទេ ។

**ករណីដែលបានបញ្ជូនទៅតុលាការ**

ក្រសួងមហាផ្ទៃបានជម្រាបថា ករណីចំនួន៦១ត្រូវបានគេបញ្ជូនទៅតុលាការនានា។ តាមពត៌មានដែលការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានទទួលជាបន្តបន្ទាប់ពីតុលាការនានា បានឱ្យដឹងថា នៅក្នុងករណីចំនួន១៧ ចៅក្រមស៊ើបអង្កេតបានលើកលែងការចោទប្រកាន់ ឬបានសម្រេចឱ្យជនសង្ស័យរួចខ្លួន។ ក្នុងករណីចំនួន៩ទៀត ជនល្មើសបានគេចខ្លួនមុនពេលចាប់ខ្លួន។ ប្រហែល១៦ករណីក្នុងចំណោម១៧៨ករណី មានការផ្តន្ទាទោស។ ទោះបីជាយ៉ាងណាក៏ដោយក្នុងករណីមួយចំនួន ការផ្តន្ទាទោសត្រូវបានធ្វើឡើងជាលក្ខណៈកំបាំងមុខ និងក្នុងករណីផ្សេងៗទៀត បទល្មើសដែលផ្តន្ទាទោសនោះគឺមិនសមហេតុផលទៅនឹងអង្គហេតុ ហើយនៅក្នុងករណីមួយចំនួនទៀត គឺមិនសមហេតុផលទាំងស្រុងតែម្តង។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា នឹងតាមដានជាមួយតុលាការលើករណីផ្សេងៗតទៅទៀត។

*ករណីលោកវរៈសេនីយ៍ទោ សាធ សឿន :*

កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ តាមពត៌មានថា លោកវរៈសេនីយ៍ទោ សាធ សឿន បានសម្លាប់យុវជនម្នាក់ ឈ្មោះពៅ អាយុ១៦ឆ្នាំ នៅចំពោះមុខមន្ត្រីនគរបាល និងកងរាជអាវុធហត្ថជាច្រើន។ ពៅ ត្រូវបានសង្ស័យថាបានលបចូលលួចនៅក្នុងផ្ទះមួយនៅក្នុងខេត្តកំពង់ចាម។ ក្រសួងមហាផ្ទៃបានជម្រាបថា ករណីនេះត្រូវបានបញ្ជូនទៅតុលាការខេត្ត ហើយតុលាការបានបើកសវនាការក៏រួចហើយដែរ ប៉ុន្តែ តុលាការមិនបានសម្រេចឃុំខ្លួនសាធ សឿន ទេ។ តាមសេចក្តីរាយការណ៍ សាធ សឿន និងក្រុមគ្រួសារជនរងគ្រោះបានសម្រួលគ្នាក្រៅប្រព័ន្ធតុលាការ ហើយមិនមានចំណាត់ការខាងផ្លូវច្បាប់ឡើយ។

*ករណី ជឹម ឈួន :*

កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ លោក ជឹម ឈួន ដែលជាសកម្មជនគណៈបក្សសមរង្ស៊ី និងអនាគតជា បេក្ខជនឈរឈ្មោះក្រុមប្រឹក្សាឃុំ ត្រូវបានគេធ្វើឃាតនៅភូមិទួលបី ឃុំរាយពាយ ស្រុកកងមាស ខេត្ត កំពង់ចាម។ ក្រសួងមហាផ្ទៃបានជម្រាបថា នគរបាលចាប់ និងបញ្ជូនខ្លួនឈ្មោះ ស៊ុយ ទៀនទៅតុលាការ។ ស៊ុយ ទៀន ត្រូវបានកាត់ទោស ហើយសម្រេចឱ្យរួចខ្លួនកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០០០។ កាលពីថ្ងៃ ទី០៥ ខែធ្នូ ឆ្នាំ២០០១ តុលាករកំពូលក៏បានសម្រេចតំកល់សេចក្តីសម្រេចឱ្យរួចទោសនេះផងដែរ។

*ករណីឈ្មោះ ស៊ឹម ម៉ូវ :*

កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០០ ឈ្មោះ ស៊ឹម ម៉ូវ ដែលជាសកម្មជនគណៈបក្សសមរង្ស៊ីបាន ត្រូវសម្លាប់នៅភូមិអណ្តូងដី ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ។ ក្រសួងមហាផ្ទៃជម្រាបថា នគរបាលបាន បញ្ជូនសំណុំរឿងជាមួយនឹងជនសង្ស័យ៣នាក់ទៅតុលាការ ។ ពួកគេត្រូវបានឃុំខ្លួនកាល ពីថ្ងៃទី២៥ តុលា ឆ្នាំ២០០៣ និងត្រូវចោទប្រកាន់ពីបទឃាតកម្ម ។ កំឡុងពេលស៊ើបអង្កេត ចៅក្រម ស៊ើបអង្កេតបានលើកលែងការចោទប្រកាន់ និង ដោះលែងជនទាំងបីនាក់នោះ ។

*ករណីឈ្មោះ លី សេង :*

កាលពីថ្ងៃទី២២ មីនា ឆ្នាំ១៩៩៣ លោកអនុសេនីយ៍ឯក លី សេង ត្រូវបានធ្វើឃាតនៅភូមិព្រែក មហាទេពក្នុងខេត្តបាត់ដំបង ។ នៅថ្ងៃទី០៧ ខែកក្កដា អយ្យការពិសេសរបស់អ៊ុនតាក់ បានចេញដីកាចាប់ ខ្លួនឧត្តមសេ នីយ៍ ផន សាលីន ដែលជាមេបញ្ជាការរងយោធភូមិភាគ៥ ។ អយ្យការយោធាជំនាន់រដ្ឋកម្ពុជា និងតុលាការខេត្តបាត់ដំបងក៏បានចេញដីកាចាប់ខ្លួនផងដែរ ។ ក្រសួងមហាផ្ទៃបានជម្រាបថា តុលាការខេត្ត បានកំពុងតែតាមរកចាប់ខ្លួនជនល្មើស ។ ផន សាលីន បច្ចុប្បន្នត្រូវបានដាក់ឱ្យឈរជើងនៅខេត្តពោធិ៍សាត់ ហើយមានតួនាទីជានាយសេនាធិការរងយោធភូមិភាគ៥ ទទួលខុសត្រូវតំបន់ប្រតិបត្តិការសឹករងខេត្ត ពោធិ៍សាត់ ។

*ករណីនៅភូមិត្រយឹង :*

កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៧ មនុស្ស៥នាក់ត្រូវបានសម្លាប់ និង៥នាក់ទៀតត្រូវបាន រងរបួស នៅក្នុងការវាយប្រហារដោយគ្រាប់បែកមួយនៅភូមិត្រយឹង ឃុំរានអណ្តើក ស្រុកគីរីវង្ស ខេត្ត តាកែវ ។ តុលាការខេត្តបានចេញដីកាចាប់ខ្លួនមេបញ្ជាការសេនាជនឃុំ ឈ្មោះ លៀន តេង និងសមាជិក យោធាឃុំ ម្នាក់ឈ្មោះ ឃុំ ជៀន ។ ក្រសួងបានជម្រាបថា ជនល្មើសបានគេចខ្លួនបាត់អស់ហើយ ។

*ករណី ឈ្មោះ សរិប ផល្លី :*

កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៨ ទាហានម្នាក់បានបាញ់សម្លាប់ សរិប ផល្លី នគរបាលម្នាក់ និងកូនប្រុស របស់តំណាងគណៈបក្សហ៊្វុនស៊ិនប៉ិចប្រចាំស្រុកម្នាក់នៅភូមិពណិ ឃុំកណ្តោលជ្រុំ ស្រុក ពញាក្រែក ។ ទាហាន នោះ គឺជាសមាជិកម្នាក់នៃកងពលធំលេខ៤ ដែលមានទីតាំងនៅក្នុងស្រុកត្បូងឃ្មុំ ។ មានមនុស្សជាច្រើន បានឃើញឃាតកម្មនេះ ។ ក្រសួងមហាផ្ទៃបានជម្រាបថា ការស៊ើបអង្កេតបានបញ្ចប់

រួចហើយ និងថាករណីនេះត្រូវបានបញ្ជូនទៅតុលាការហើយ ដោយមានជនសង្ស័យឈ្មោះ ចាន់ ផល បានគេចខ្លួន ។ នគរបាលកំពុងតែតាមរកចាប់ខ្លួនជនសង្ស័យនោះ ។

*ករណីឈ្មោះ ភួង តុង :*

កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៨ ភួង តុង ត្រូវបានបាញ់សម្លាប់ ក្រោយពីបានចូលបំរើការងារថ្មីៗ ជាសកម្មជនឱ្យអង្គការអាដហុក ។ ឃាតកម្មនេះ ទាក់ទងនឹងជម្លោះដីធ្លីមួយ ជាមួយក្រុមហ៊ុនថ្មនៅក្នុងតំបន់ដែលជនរងគ្រោះបានធ្វើជាតំណាងឱ្យខាងក្រុមអ្នកភូមិ ដែលត្រូវប្រឈមមុខនឹងការបណ្តេញចេញ ។ ការស៊ើបអង្កេតបានបង្ហាញថា មានទាហានម្នាក់ និងនគរបាលម្នាក់គឺជាអ្នកទទួលខុសត្រូវ ។ ពួកគេ និងជនទី៣ម្នាក់ទៀតដែលជាកសិករ ត្រូវបានចាប់ខ្លួននៅក្នុងខែតុលា ឆ្នាំ១៩៩៩ ។ កសិករ និងនគរបាល ត្រូវបានចោទពីបទឃាតកម្ម រីឯទាហានត្រូវបានចោទពីបទមនុស្សឃាតដោយចេតនា ។ ដោយសារតែគ្មានភស្តុតាងកំឡុងពេលស៊ើបអង្កេត ចៅក្រមស៊ើបអង្កេត បានលើកលែងការចោទប្រកាន់ទាំងអស់លើជនទាំងបីនាក់នោះ ។ ព្រះរាជអាជ្ញាក៏ប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនេះ ។ សាលាឧទ្ធរណ៍បានចេញសាលដីកាតំកល់សេចក្តីសម្រេចលើកលែងការចោទនេះទៀត ។ នៅពេលដែលប្តឹងសារទុក្ខទៅតុលាការកំពូល តុលាការកំពូលបានបដិសេធផ្នែកមួយចំនួននៃសេចក្តីសម្រេចនេះ ដោយសម្រេចតំកល់បទចោទប្រកាន់ទាំងឡាយទៅលើទាហាននិងនគរបាលដដែល ។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៥ តុលាការខេត្តកណ្តាលក៏បានធ្វើការជំនុំជំរះ ។ នគរបាលត្រូវបានគេរកឃើញថាមានពិរុទ្ធភាពពីបទមនុស្សឃាតដោយអចេតនា ហើយត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចំនួន៨ឆ្នាំ ។ រីឯទាហានត្រូវបានគេសម្រេចឱ្យរួចខ្លួនដោយសារ តែគ្មានភស្តុតាង ។

*ករណីនៅភូមិរំដេញ :*

កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៨ គ្រាប់បែកមួយគ្រាប់ត្រូវបានគប់ទៅលើក្រុមគ្រួសារមួយ ដែលនៅជុំគ្នានៅយ៉ខាងមុខផ្ទះ នៅភូមិរំដេញ ឃុំសោម ស្រុកគិរីវង្ស ខេត្តតាកែវ ដោយបានសម្លាប់មនុស្ស២នាក់ និងធ្វើឱ្យ៤នាក់រងរបួស ដែលក្នុងនោះម្នាក់ ជាសកម្មជនគណៈបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា (ឬហៅកាត់ថា គណៈបក្សលោកតាសឺន សាន) ។ ឈ្មោះ ណាំ កាយ និងឈ្មោះ ណាំ នួន បានស្លាប់មួយរំពេច ។ ឈ្មោះ ខៀវ ទូច អេប សឿង សឿន អ៊ឹម និង សូត្រ ព្រីង បានរងរបួស ។

ឈ្មោះ ខៀវ ទូច គឺជាតំណាងប្រចាំស្រុករបស់គណៈបក្សលោកតា សឺន សាន ។ ក្រសួងបានជម្រាបថា ឈ្មោះ ឃុន ផន អាយុ ៣៨ឆ្នាំ ត្រូវបានចាប់ និងបញ្ជូនខ្លួនទៅតុលាការរួចហើយ ។ គាត់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារចំនួន ១៧ឆ្នាំ ។ គាត់សារភាពថា បានគប់គ្រាប់បែកមែន និងបាននិយាយថា មូលហេតុដែលគាត់ធ្វើដូច្នេះ ដោយសារតែជនរងគ្រោះទាំងឡាយនោះបានគំរាមរកសម្លាប់គាត់កាលពីពេលមុន ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ជនរងគ្រោះ និងក្រុមអង្គការសិទ្ធិមនុស្សបានសង្ស័យថា មានពាក់ព័ន្ធនឹងរឿងនយោបាយដែរ ។ រហូតមកដល់ខែមេសា ឆ្នាំ២០០៥ ឃុន ផន កំពុងតែបំរើទោសរបស់ខ្លួននៅក្នុងពន្ធនាគារនៅឡើយទេ ។

*ករណីឈ្មោះ ឆាយ ថន :*

កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០០១ ឈ្មោះ ឆាយ ថន អនាគតបេក្ខជនឈរឈ្មោះក្រុមប្រឹក្សាឃុំរបស់គណៈបក្សហ៊្វុនស៊ិនប៉ិច ត្រូវបានសម្លាប់នៅភូមិទួលវិហារ ឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ក្រសួងបានជម្រាបថា នគរបាលបានរកឃើញថាឈ្មោះ មុំ ឡញ ជាជនសង្ស័យ ប៉ុន្តែថាជននេះបានគេចខ្លួនមុនការចាប់ខ្លួន ។ តុលាការបានចោទប្រកាន់គាត់ពីបទប្រើប្រាស់អាវុធខុសច្បាប់ ប៉ុន្តែមិនបានចោទប្រកាន់គាត់ពីបទឃាតកម្មទេ ។ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ មុំ ឡញ ក៏ត្រូវបានគេកាត់ទោសកំបាំងមុខ និងត្រូវបានផ្តន្ទាទោសរយៈពេលមួយឆ្នាំ តែទោសនេះត្រូវព្យួរ ពីបទប្រើប្រាស់អាវុធខុសច្បាប់ ។

*ករណីឈ្មោះ ទី សុវណ្ណ :*

កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២ សកម្មជនគណៈបក្សសមរង្ស៊ីម្នាក់ឈ្មោះ ទី សុវណ្ណ ត្រូវបានសម្លាប់ក្នុងតំបន់សំណង់អាណាធិបតេយ្យនៅបូរីកីឡា សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ក្រសួងបានជម្រាបថា ជនល្មើសឈ្មោះ សោម សូភី អាយុ៣៩ឆ្នាំ ភេទប្រុស ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែ( ម១) កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២ ។ ករណីនេះត្រូវបានបញ្ជូនទៅតុលាការរួចរាល់ហើយ ។ ឈ្មោះ សោម សូភីនេះ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ ពីបទមនុស្សឃាតដោយអចេតនា ។ តាមការស៊ើបអង្កេតដោយនគរបាល ចៅក្រមស៊ើបអង្កេតហម ម៉េងសែ និងក្រុមអង្គការសិទ្ធិមនុស្សបានបង្ហាញឱ្យឃើញថា គាត់បានបាញ់ចំទី សុវណ្ណដោយអចេតនាកំឡុងពេលកម្មវិធីផឹកស៊ីមួយ ។

*ករណីពាក់ព័ន្ធនឹងការវាយប្រហារលើសារព័ត៌មាន*

ករណីភាគច្រើនក្នុងចំណោមករណីទាំងនេះ ក្រសួងមហាផ្ទៃបានអះអាងថា ការស៊ើបអង្កេតកំពុងតែបន្ត ។

*ករណីឈ្មោះ ធូ ចាន់មង្គល :*

កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៤ បីខែក្រោយពីគ្រាប់បែកមួយគ្រាប់ ត្រូវបានគប់ចូលការិយាល័យកាសែតដែលបណ្ដាលឱ្យមនុស្ស៥នាក់រងរបួសនោះ លោក ធូ ចាន់មង្គល ចាងហ្វាងកាសែតអន្តរាគមន៍ ត្រូវបានប្រទះឃើញស្លាប់នៅលើផ្លូវមួយនៅទីក្រុងភ្នំពេញ ។ ការស្លាប់នេះអាចបណ្ដាលមកពីគ្រោះថ្នាក់ចរាចរ ។

*ករណីលោក នួន ចាន់ :*

កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៤ មនុស្ស២នាក់ បានជិះម៉ូតូបាញ់សម្លាប់ លោក នួន ចាន់ ចាងហ្វាងកាសែតសំលេងយុវជនខ្មែរ នៅទីក្រុងភ្នំពេញ ។

*ករណីកាសែតកោះសន្តិភាព :*

កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៤ អ្នកយកព័ត៌មានកាសែតកោះសន្តិភាពឈ្មោះសៅ ចាន់តារា ត្រូវបានបាញ់សម្លាប់នៅក្នុងខេត្តកំពង់ចាម ។ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៧ គ្រាប់បែកមួយគ្រាប់ត្រូវបានគប់ចូលការិយាល័យកាសែត ហើយក្រោយមក លោកចាងហ្វាងក៏ត្រូវបានគេបាញ់ប្រហារ ។ ឈ្មោះសាធ សឿត ត្រូវបានកាត់ទោសពីបទធ្វើឃាតលើលោក សៅ ចាន់តារា ប៉ុន្តែត្រូវបានសម្រេចឱ្យរួចខ្លួនពីបទចោទប្រកាន់នេះ ។ សាលាឧទ្ធរណ៍ក៏បានសម្រេចតំកល់សេចក្ដីសម្រេចឱ្យរួចខ្លួននេះ ហើយបណ្ដឹងសារទុក្ខមិនត្រូវបានធ្វើទៅតុលាការកំពូលឡើយ ។

*ករណីលោក ឯក មង្គល :*

កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៥ លោកឯក មង្គល ដែលជាអ្នកផ្សាយវិទ្យុFM90 បានទទួលរងនូវការបាញ់ដោយអាវុធ ។

*ករណីលោក ធន់ ប៊ុនលី :*

កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៦ មានជន ២នាក់ជិះម៉ូតូបានបាញ់សម្លាប់ លោក ធន់ ប៊ុនលី ចាងហ្វាង កាសែតឧត្តមគតិខ្មែរ នៅទីក្រុងភ្នំពេញ ។ កន្លះម៉ោងមុនស្លាប់ លោកបានប្រាប់មិត្តភក្តិរបស់លោកម្នាក់ថា លោកភ័យខ្លាចចំពោះសុវត្ថិភាពរបស់លោក ។ នៅក្នុងឆ្នាំ១៩៩៥ លោកត្រូវបានគេចោទប្រកាន់ និងផ្តន្ទាទោសចំនួនពីរដង ពីបទចុះផ្សាយអត្ថបទជាច្រើន ដែលរិះគន់ដល់រាជរដ្ឋាភិបាល ។

*ករណី លោក ឡេង សំអាង :*

កាលពីថ្ងៃទី២ ខែមករា ឆ្នាំ១៩៩៧ នគរបាលបានធ្វើការវាយដំ និង បានបាញ់ទៅលើលោក ឡេង សំអាងចាងហ្វាងកាសែតគំនិតកូនខ្មែរ ។

*ករណីលោក មីឆែល សិនន្យ៉ែរ (Michael Senior):*

កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៧ ទាហានម្នាក់បានបាញ់សម្លាប់ លោកមីឆែល សិនន្យ៉ែរ ជាអ្នកថតរូបសេរី មានដើមកំណើតជាខ្មែរ នៅពេលដែលលោកមានបំណងថតរូបទាហានជាច្រើន ដែលកំពុងលួចទំនិញ នៅក្នុងផ្សារមួយនៅទីក្រុងភ្នំពេញ ។

*ករណី លោក ជួរ ជេតថារិទ្ធី*

នៅក្នុងរបាយការណ៍ មានព័ត៌មានលំអិតស្តីពីឃាតកម្មលើលោក ជួរ ជេតថារិទ្ធី កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៣ ។ ក្រសួងបានជម្រាបជូនថា ករណីនេះកំពុងតែស្ថិតក្រោមការស៊ើបអង្កេតបន្ថែម ។

## ២. ការ "ស៊ីឈ្នួល"សម្លាប់ ចាប់ពីខែកុម្ភៈ ឆ្នាំ២០០៣ ដល់ខែឧសភា ឆ្នាំ២០០៤

ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ទាំងមូលរួចមកហើយ ករណីឃាតកម្មធំៗជាច្រើន បានកើតឡើងនៅក្នុងទីក្រុងភ្នំពេញ នៅកំឡុងពេលដំណើរឆ្ពោះទៅរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកសភា នៅខែកក្កដា ឆ្នាំ២០០៣ ហើយនិងនៅកំឡុងពេលការជាប់គាំងផ្នែកនយោបាយ ។ ករណីទាំងនេះ មិនត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីករណីទាំង ១៧៨ ដែលបានដាក់ជូនក្រសួងមហាផ្ទៃនោះទេ ។ គ្មានករណីណាមួយត្រូវបានដោះស្រាយគួរឱ្យកត់សំគាល់នោះឡើយ ។ ខាងក្រោមនេះ គឺជាសេចក្តីបន្ថែមលើករណីដែលមាន ដូចជាករណី ចៅក្រមសុខ សេដ្ឋាមុន្នី អ្នកផ្សាយវិទ្យុលោកជួរ ជេថារិទ្ធី លោកប្រធានសហជីព ជា វិជ្ជា ដែលករណីទាំងនេះមានយ៉ាងលំអិតក្នុងរបាយការណ៍ ។

*ករណីព្រះសង្ឃ សំ ប៊ុនធឿន :*

ព្រះសង្ឃ សំ ប៊ុនធឿន គឺជានាយកមជ្ឈមណ្ឌលសមាធិវិប្បសនា ជាព្រះសង្ឃ និង ជាគ្រូបង្រៀន។ នៅថ្ងៃ ទី៦ ខែកុម្ភៈ ឆ្នាំ២០០៣ មានជន២នាក់បានបាញ់ព្រះអង្គនៅខាងមុខកុដិព្រះអង្គនៅវត្តលង្កការ។ ក្រោយពី បាញ់រួច ឃាតករក៏បានជិះម៉ូតូគេចខ្លួនបាត់។ នៅថ្ងៃទី៨ ខែកុម្ភៈ ព្រះអង្គក៏បានសុគត់នៅមន្ទីរពេទ្យ។ ស្នងការនគរបាលក្រុងភ្នំពេញក៏បានសុំឱ្យនាយកដ្ឋានយុត្តិធមិកណ្តាលក្រសួងមហាផ្ទៃស៊ើបអង្កេតលើករណីនេះ។ មកដល់ពេលនេះ មិនទាន់មានការចាប់ខ្លួនជនណាម្នាក់ពីបទប្រព្រឹត្តបទល្មើសនេះឡើយ។

*ករណីលោក ឱម រ័ត្នសាឌី :*

លោកឱម រ័ត្នសាឌី ដែលជាទីប្រឹក្សារបស់ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ គឺជាមន្ត្រីជាន់ខ្ពស់ដែលមានឈ្មោះបោះសំលេងរបស់គណៈបក្សហ៊្វុនស៊ិនប៉ិច។ លោកត្រូវបានគេបាញ់មួយគ្រាប់ចំត្រង់ខ្នង ពេលកណ្តាលថ្ងៃត្រង់ នៅកណ្តាលទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៣។ ឃាតករ២នាក់ដែលពាក់ព័ន្ធបានជិះម៉ូតូគេចខ្លួនបាត់ពីកន្លែងកើតហេតុ។ ក្រោយមកនៅថ្ងៃនោះ លោក ឱម រ័ត្នសាឌី ក៏បានស្លាប់នៅមន្ទីរពេទ្យ។

លោកស្នងការនគរបាលក្រុងភ្នំពេញបានបង្កើតគណៈកម្មការពិសេសមួយ ដើម្បីធ្វើការស៊ើបអង្កេតរឿងនេះ។ ទាហានឆ័ត្រយោងម្នាក់ ឈ្មោះម៉ម សុផាន ត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែមីនា និងឈ្មោះ អៀវ ឈូករ័ត្ន ដែលជាបងប្រុសរបស់គាត់ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣។ នគរបាលបានដកហូតបានអាវុធខ្លីចំនួនមួយដើម និងម៉ូតូមួយគ្រឿង។ លោកមេធាវីដែលត្រូវបានចាត់តាំងឱ្យការពារជនជាប់ចោទបាននិយាយថា ម៉ម សុផាន បានសារភាពថា ខ្លួនបានប្លន់ទូរស័ព្ទដៃរបស់លោក ឱម រ័ត្នសាឌី ហើយថាការបាញ់នោះគឺកើតឡើងដោយអចេតនាទេ និងបានឆ្លើយថា ជនម្នាក់ទៀត ឈ្មោះ រស់ សុផាត ដែលជាទាហានឆ័ត្រយោងដែលទើបជ្រើសរើសថ្មីៗ បានជួយ បើកម៉ូតូឱ្យខ្លួន។ នៅថ្ងៃទី១៥ ខែមីនា រស់ សុផាត ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ភ្លាមៗតែម្តង។ ឈ្មោះ អៀវ ឈូករ័ត្ន ត្រូវបានដោះលែងនៅថ្ងៃ ទី១៤ ខែមីនា។

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ តុលាការក្រុងភ្នំពេញបានរកឃើញជនជាប់ចោទមានពិរុទ្ធភាព ហើយបានកាត់ទោសពួកគេឱ្យជាប់ពន្ធនាគាររយៈពេល ២០ឆ្នាំ ពីបទប្រើប្រាស់អាវុធខុសច្បាប់ ( មាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់) ពីបទប្លន់ ( មាត្រា៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ) និង ពីបទមនុស្សឃាតដោយចេតនា ( មាត្រា៤នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ) ។ ក្រឡាបញ្ជីបាន អានតែកំណត់ហេតុសាកសួរសាក្សីតែប៉ុណ្ណោះ ។ គ្មានសាក្សីណាម្នាក់បានមកឆ្លើយបំភ្លឺនៅចំពោះមុខ តុលាការឡើយ ។

មានសំនួរជាច្រើនត្រូវបានចោទសួរឡើងពាក់ព័ន្ធនឹងគុណភាពនៃការស៊ើបអង្កេត និង ការជំនុំជំរះ ថាតើជនសង្ស័យធ្វើឡើងដោយខ្លួនឯងដូចដែលអាជ្ញាធរបានអះអាងមែនដែរឬទេ និងថាតើហេតុផលនៃ អំពើឃាតកម្មនេះ ពោលគឺអំពើប្លន់យកទូរស័ព្ទដៃមួយគ្រឿង គួរឱ្យជឿបានដែរឬទេ ពីព្រោះវាផ្ទុយទៅនឹង អង្គហេតុទាំងឡាយដែលសាក្សីបានឃើញផ្ទាល់ភ្នែក ។

*ករណី កញ្ញា ទូច ស្រីនិច និង អ្នកស្រី គីម ស៊ីនួន :*

កាលពីព្រឹកថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៣ ប្រហែលជាម៉ោង១១ និង៤៥នាទី កញ្ញា ទូច ស្រីនិច អាយុ២៤ ឆ្នាំ ដែលជាតារាចំរៀងដ៏ល្បី ត្រូវបានគេបាញ់យ៉ាងកៀកបំផុត ត្រូវចំនួនបីគ្រាប់ ដែលក្នុងនោះ ២គ្រាប់ ត្រូវចំក្បាល និងមួយគ្រាប់ទៀតត្រូវចំក ។ ម្តាយរបស់នាង គឺអ្នកស្រី គីម ស៊ីនួន អាយុ៥៩ឆ្នាំ នៅពេលអ្នកស្រីព្យាយាមបាំងការពារកូនស្រី អ្នកស្រីត្រូវបានបាញ់ចំមួយគ្រាប់ត្រង់ខ្នងហើយក្រោយមក ក៏បានស្លាប់នៅមន្ទីរពេទ្យ ។ សាក្សីបានឱ្យដឹងថា មានជន៤នាក់បានជិះម៉ូតូពីរគ្រឿងឈប់ខាងមុខហាង លក់ផ្កាដែលកញ្ញា ទូច ស្រីនិច និងម្តាយរបស់នាងបានកំពុងតែដើរចេញ ហើយបានបាញ់ប្រហែល៦ ទៅ ៧គ្រាប់សំដៅពួកគេ ។ តាមសេចក្តីរាយការណ៍ ជន ២នាក់ ស្លៀកពាក់ជាយោធា ។ កញ្ញា ទូច ស្រីនិច ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យទីក្រុងបាងកក ។ នាងមិនស្លាប់ទេ ប៉ុន្តែនៅតែមិនអាចកំរើកបាន ពីកចុះក្រោម ។ ទោះជានាងមិនមែនជាសមាជិកគណៈបក្សហ៊្វុនស៊ិនប៉ិចក៏ដោយ ក៏នាងត្រូវបានយល់ ឃើញជាសាធារណៈថា នាងគឺជាសមាជិករបស់គណៈបក្សនេះដែរ ហើយបានច្រៀងចំរៀងជាច្រើនបទឱ្យ គណៈបក្សនេះ នាពេលឃោសនាកាលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅក្នុងខែកក្កដា ឆ្នាំ២០០៣ ។ ក្រោយពីព្រឹត្តិការណ៍ភ្លាម អ្នកនាំពាក្យរាជរដ្ឋាភិបាលបាននិយាយថា អំពើបាញ់ប្រហារនេះបានបង្ហាញឱ្យ ឃើញពីយុទ្ធនាការជាប្រព័ន្ធនៃអំពើភាវរកម្ម ដែលត្រូវបានរៀបចំឡើងចុងក្រោយដើម្បីធ្វើឱ្យខូចកិត្តិយស

លោកនាយករដ្ឋមន្ត្រី ។ លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ផងដែរថា កំលាំងនោះបានប្រព្រឹត្តអំពើនេះ ដើម្បីបង្ខូចកេរ្តិ៍ឈ្មោះគណៈបក្សប្រជាជនកម្ពុជា ហើយលោកក៏បានបញ្ជានគរបាល និងយោធាទាំងអស់ឱ្យ ពង្រឹងសន្តិសុខ និងឱ្យបង្កើតក្រុមពិសេស មួយដើម្បីស្វែងរកជនល្មើសទាំងនេះ ។ មកទល់ពេលនេះ មិនទាន់មានការចាប់ខ្លួនជនណាម្នាក់នៅឡើយទេ ហើយនគរបាល ក៏មិនទាន់បានកំណត់អត្តសញ្ញាណជន សង្ស័យណាមួយដែរ ។ ពួកគេបាននិយាយថា ការស៊ើបអង្កេតកំពុងតែបន្ត ហើយត្អូញត្អែរថា ជនរងគ្រោះ និងសមាជិកក្រុមគ្រួសារទាំងឡាយបានបដិសេធមិនព្រមសហការ ។ កាលពីខែមករា ឆ្នាំ ២០០៥ កញ្ញា ទូច ស្រីនិច និង សមាជិកក្រុមគ្រួសារបានទៅរស់នៅសហរដ្ឋអាមេរិក ។

*ករណីលោក រស់ សុវណ្ណារ៉េត :*

កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៤ ជន ២នាក់ បានជិះម៉ូតូមួយគ្រឿងបាញ់សម្លាប់លោករស់ សុវណ្ណារ៉េត សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃសហជីពសេរីកម្មករព្រះរាជាណាចក្រកម្ពុជា និង ជាតំណាងសហជីព ប្រចាំនៅរោងចក្រកាត់ដេរទ្រីណុងហ្គាលកុមារា (Tinunggal Komara) នៅ ខ័ណ្ឌឬស្សីកែវ ក្នុងក្រុងភ្នំពេញ នៅពេលដែលលោកកំពុងតែធ្វើដំណើរដោយជិះម៉ូតូពីរោងចក្រមកផ្ទះ ។ នៅពេលដែលលោកដួលទៅលើដី ជនទាំងពីរនាក់នោះ មុនពេលជិះម៉ូតូគេច បានជិះម៉ូតូមកក្បែរគាត់ ហើយបាញ់២គ្រាប់ថែមទៀត ។ ក្រោយពីឧប្បត្តិហេតុកើតឡើងភ្លាម នគរបាលបាននិយាយថា ហេតុផល នៃការបាញ់សម្លាប់នេះ គឺអាចបណ្តាលមកពីការប្រកួតប្រជែងគ្នាជាមួយសហជីពផ្សេងៗក្នុងរោងចក្រ ។

កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ តុលាការក្រុងភ្នំពេញបានកាត់ទោស និងផ្តន្ទាទោសឈ្មោះ ថាច់ សារ៉េត អាយុ ២២ឆ្នាំ ដែលជាទាហានឆ័ត្រយោង ឱ្យជាប់ពន្ធនាគាររយៈពេល១៥ឆ្នាំ ពីបទឃាតកម្ម គិតទុកជាមុន តាមមាត្រា៣នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ជនជាប់ចោទ បានបដិសេធ ចំពោះការចោទប្រកាន់នោះ ហើយបាននិយាយយ៉ាងទទូចថា ខ្លួនបាននៅខេត្តសៀមរាបទេ នៅពេលដែល មានការសម្លាប់ ។ សវនាការបានបង្ហាញឱ្យឃើញថា មានការរំលោភលើនីតិវិធីច្បាប់ និងមិនស្របតាម និយាមការជាមូលដ្ឋានបំផុតនៃសវនាការប្រកបដោយភាពយុត្តិធម៌ ។ ចៅក្រមជំនុំជំរះ បានដាក់បន្ទុកទៅ លើជនជាប់ចោទឱ្យបង្ហាញភស្តុតាងដែលថា ខ្លួនមិននៅភ្នំពេញទេនៅពេលដែលឧប្បត្តិហេតុនេះកើតឡើង ហើយបានបដិសេធចម្លើយសាក្សី ៣នាក់ដែលគាំទ្រការអះអាងរបស់ជនជាប់ចោទ ។ ជនជាប់ចោទបាន

ត្រូវកាត់ទោសដោយផ្អែកលើចម្លើយរបស់មន្ត្រីនគរបាលម្នាក់ ដែលទទួលខុសត្រូវលើការស៊ើបអង្កេត និងផ្អែកលើកំណត់ហេតុសាកសួរសាក្សី ២នាក់តែប៉ុណ្ណោះ ដែលមិនដែលបានបង្ហាញខ្លួននៅតុលាការសោះ ។ ចៅក្រមបានបដិសេធមិនផ្តល់សេចក្តីពន្យល់ថា តើហេតុអ្វីបានជាសាក្សីដែលរស់នៅក្រុងភ្នំពេញមិនអាចមកឆ្លើយបំភ្លឺជាសាធារណៈបាន ហើយបានស្តីបន្ទោសលោកមេធាវីដោយចំហរ នៅពេលលោកដាក់សំណើចុងក្រោយដើម្បីសុំពន្យាសវនាការនេះ ។ សវនាការនេះប្រព្រឹត្តទៅរយៈពេលប្រហែលតែមួយម៉ោងប៉ុណ្ណោះ ។ ចុងចម្លើយត្រូវបានបញ្ជាឱ្យសងសំណងចំនួន ២000ដុល្លាអាមេរិក ទៅប្រពន្ធជនរងគ្រោះ ។ ករណីនេះត្រូវបានប្តឹងទៅសាលាឧទ្ធរណ៍ ។

## ៣. <u>ករណីធ្វើទារុណកម្ម និងអំពើប្រព្រឹត្ត ឬទណ្ឌកម្មបែបឃោរឃៅ អមនុស្សធម៌ និង បន្ថោកបន្ទាប</u>

*ករណីលោក តែម សេង :*

កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៩៣ អយ្យការពិសេសរបស់អ៊ុនតាក់បានចេញដីកាចាប់ខ្លួនលោក តែម សេង ដែលជានាយករងពន្ធនាគារខេត្តបាត់ដំបង ពីបទប៉ុនប៉ងធ្វើឃាតកម្ម បង្ករបួសស្នាម បង្ខាំងមនុស្សខុសច្បាប់ និងរំលោភលើសិទ្ធិបុគ្គលទៅលើឈ្មោះ ញ៉ៅ ហួម កាលពីខែកុម្ភៈ ឆ្នាំ១៩៩២ និងទៅលើឈ្មោះអៀង សាម៉ុង និង ទូន ជ្រី កាលពីខែមីនា ឆ្នាំ១៩៩៣[១] ។ នគរបាលអ៊ុនតាក់ បាន ព្យាយាមអនុវត្តដីកាចាប់ខ្លួននេះ ប៉ុន្តែលោកបានគេចខ្លួនបាត់ ។ គាត់បានបន្តធ្វើការនៅពន្ធនាគារ រហូតដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៣ ទើបអ៊ុនតាក់ ចាប់ខ្លួនគាត់បាន ។ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ តុលាការក្រុងភ្នំពេញបានចោទប្រកាន់គាត់ពីបទរំលោភសិទ្ធិបុគ្គលទាក់ទងនឹងឧប្បត្តិហេតុ ដែលកើតឡើងកាលពីខែកុម្ភៈ ឆ្នាំ១៩៩២[២] ។ គាត់ត្រូវបានចាប់ខ្លួន និងកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល១ឆ្នាំ និងត្រូវបានបញ្ជាឱ្យសងសំណងទៅគ្រួសារជនរងគ្រោះផងដែរ ។ ក្រោយពីបំរើទោសរួចហើយ គាត់ត្រូវបានអនុញ្ញាតឱ្យចូលកាន់តួនាទីជានាយករងពន្ធនាគារខេត្តបាត់ដំបងវិញដដែល ។ នៅក្នុងរបាយការណ៍ឆ្នាំ១៩៩៩ ដែលបានដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលបានលើកឡើងពីករណីលោក តែម សេងនេះថាជាភស្តុតាងនៃចំណាត់ការទាំងឡាយ របស់ខ្លួន ដែលធ្វើឡើងទៅលើមន្ត្រីនានា ដែលពាក់ព័ន្ធនឹងអំពើធ្វើទុក្ខទោសដល់អ្នកទោស ។ លោកតែម សេង បានចូលនិវត្តន៍នៅឆ្នាំ២00៣ ក្រោយពីគណៈ

[១] ដីកាចាប់ខ្លួន និងឃុំខ្លួន ចេញដោយអ៊ុនតាក់ លេខ៩ ឆ្នាំ១៩៩៣

[២] តុលាការក្រុងភ្នំពេញ ចេញដីកាឃុំខ្លួនលេខ៣២៧៥/ព្រ.ទ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

កម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មព្រមទាំងលោកតំណាងពិសេស បានចោទសួរអំពីការបន្តតួនាទីគាត់ជាមន្ត្រីពន្ធនាគារនោះ[៣] ។

*ករណីឈ្មោះ អៀត អឿន :*

ឈ្មោះអៀត អឿន ដែលជាកសិករនៅខេត្តព្រៃវែង ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ ដោយសង្ស័យថាគាត់បានលួចក្របីជាច្រើន ហើយគាត់បានស្លាប់ ក្រោយពីការឃុំខ្លួនអស់រយៈពេលបីថ្ងៃ នៅតាមស្ថានីយ៍នគរបាលចំនួនបីកន្លែងផ្សេងៗគ្នានោះ ។ មុនពេលស្លាប់ ជនរងគ្រោះបានប្រាប់ប្រពន្ធរបស់ខ្លួនថានគរបាលបីនាក់ ដែលគាត់ស្គាល់អត្តសញ្ញាណ បានវាយដំគាត់ ។ ប្រពន្ធនិងកូនស្រីរបស់គាត់បានឃើញគាត់មានស្នាំជាំជាច្រើននៅលើរាងកាយ និងនៅត្រង់មុខ បាក់ធ្មេញពីរ និងក្អួតចេញឈាម ។ មុនពេល បូជា ការវះតាក់ពិនិត្យសាកសពមិនត្រូវបានធ្វើឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយក្រុមគ្រួសារមានរូបថត ដែលបង្ហាញឱ្យឃើញពីស្នាមជាំនៅលើផ្ទៃមុខ ដើមទ្រូង ពោះ ខ្នង គូទ ភ្លៅ និងជើង ។ នៅក្នុងខែតុលា និង ខែវិច្ឆិកា ឆ្នាំ២០០១ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបញ្ជូនព័ត៌មានយ៉ាងលំអិតអំពីករណីនេះ ជូនអគ្គនាយកនគរបាលជាតិដើម្បីស្នើឱ្យលោកស៊ើបអង្កេត ។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានទទួលការទាក់ទងចំនួនពីរលើកពីក្រសួងមហាផ្ទៃ: របាយការណ៍មួយដែលមិនមានខ្លឹមសារច្បាស់លាស់ពីស្នងការនគរបាលខេត្តព្រៃវែង និងរបាយការណ៍មួយទៀតដែលធ្វើឡើងដោយអគ្គនាយកនគរបាលជាតិ កាលពីខែធ្នូ ឆ្នាំ២០០២ ដែលក្នុងរបាយការណ៍នោះបានសរសេរថា លោកអគ្គនាយកនគរបាលជាតិបានចាត់តាំងនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ឱ្យស៊ើបអង្កេតលើករណីនេះហើយ ។ ការស៊ើបអង្កេត បានសន្និដ្ឋានថា ឈ្មោះអៀត អឿន បានស្លាប់ដោយសារជំងឺចុកពោះធ្ងន់ធ្ងរ ក្អួត និងកោសខ្យល់ហួសប្រមាណ ។ ក្រុមគ្រួសារជនរងគ្រោះមិនត្រូវបានសាកសួរឡើយ កំឡុងពេលស៊ើបអង្កេត ។ តាមសំណើររបស់អង្គការមិនមែនរដ្ឋាភិបាលលីកាដូ អ្នកជំនាញការម្នាក់នៅប្រទេសហ្វីលីពីន បានធ្វើកោសល្យវិច័យដោយផ្អែកលើរូបថត ។ ទោះបីជាអ្នកជំនាញការនោះមិនអាចធ្វើការសន្និដ្ឋានចុងក្រោយមួយទៅលើមូលហេតុនៃការស្លាប់ដោយសារមិនមានសាកសពវះមកពិនិត្យមើលក៏ដោយ ក៏អ្នកជំនាញការនោះយល់ឃើញថា "វាគួរអោយជឿបំផុតថា

---

[៣] អង្គការសហប្រជាជាតិ សេចក្តីប្រកាសសារព័ត៌មាន គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម ពិនិត្យឡើងវិញរបាយការណ៍ដំបូងរបស់ប្រទេសកម្ពុជានៅសម័យប្រជុំលើកទី៣០ របស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្មកាលពីថ្ងៃទី២៩ ខែមេសាឆ្នាំ២០០៣ ។

ជនរងគ្រោះបានទទួលរងរបួសជាច្រើនដោយការប៉ះទង្គិចយ៉ាងខ្លាំងនៅត្រង់ក្បាល ដងខ្លួន និងដៃជើង ។ ផ្អែកតាមព័ត៌មានដែលអាចយកជាការបានស្តីពីព្រឹត្តិហេតុ នៃការស្លាប់នេះ របួសលើលលាដ៍ក្បាលជាច្រើនកន្លែង ត្រូវបានយល់ឃើញយ៉ាងខ្លាំងថាជាដើមហេតុផ្ទាល់ ដែលបណ្តាលឱ្យស្លាប់ ហើយលក្ខណៈនៃការស្លាប់នេះត្រូវបានគេចាត់ទុកថាជាអំពើមនុស្សឃាត ។"

នៅក្នុងការវិវត្តន៍ដែលគួរអោយកត់សំគាល់មួយ កាលពីខែកុម្ភៈ ឆ្នាំ២០០២ តុលាការខេត្តព្រៃវែងបានចោទប្រកាន់នគរបាល ២នាក់ ពីបទមនុស្សឃាតដោយចេតនា ។ កាលពីខែកក្កដា ឆ្នាំ២០០២ នគរបាលម្នាក់ទៀតក៏ត្រូវបានចោទប្រកាន់ផងដែរ ។ ករណីនេះមិនទាន់បានជំនុំជំរះនៅឡើយទេ ។ ប្រធានតុលាការខេត្តព្រៃវែងដែលជាចៅក្រមជំនុំជំរះបាននិយាយថា សវនាការអាចនឹងត្រូវធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ២០០៥ ប៉ុន្តែត្រូវបានផ្អាកទៅវិញ ហើយមកទល់ពេលសរសេររបាយការណ៍នេះ កាលបរិច្ឆេទថ្មីមិនទាន់ត្រូវបានកំណត់នៅឡើយទេ ។

*ករណីឈ្មោះ នី សុខរ៉ន :*

កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៤ លោកនី សុខរ៉ន អាយុ៣៥ឆ្នាំ ជាទាហានវរៈសេនាតូចលេខ ២០៤ នៅខេត្តក្រចេះ បានស្លាប់ ក្រោយពីទាហានបីនាក់ដែលធ្វើការនៅវរៈជាមួយគ្នា បានដឹកគាត់ចេញពីផ្ទះកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ហើយត្រូវបានឃុំខ្លួននៅបន្ទាយយោធានៅស្រុកស្នួលនោះ ។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៤ វេលាម៉ោង ៤រសៀល ទាហាន៤នាក់ បានជិះម៉ូតូនាំលោកនី សុខរ៉ន ទៅវាលស្រែមួយ ហើយក៏ទុកគាត់ចោលនៅទីនោះ ។ ពួកគេបានប្រាប់អ្នកភូមិជាច្រើនថា គាត់គ្រុនក្តៅយ៉ាងខ្លាំង ។ អ្នកភូមិក៏បាននាំគាត់ទៅផ្ទះ ។ ប្រពន្ធគាត់ និងអ្នកផ្សេងទៀតបាននិយាយថា ពួកគាត់បានឃើញស្នាមជាំជាច្រើនកន្លែងនៅលើខ្លួនរបស់គាត់ៈ ហើមថ្គាមនិងភ្លៅ ស្នាមរលាកនៅលើពោះ និងមានរបួសជាច្រើនកន្លែងនៅត្រង់កជើងស្តាំ ។ ប្រពន្ធរបស់គាត់បានប្រាប់ថា នៅពេលនោះគាត់កំពុងតែសន្លប់បាត់ស្មារតី មិនអាចដើរបាន និងហូបអ្វីក្រៅពីផឹកទឹកឡើយ ។ គាត់ប្រាប់ប្រពន្ធគាត់ថា គាត់ត្រូវបានគេដាក់ច្រវ៉ាក់ជើង និងថាមានទាហានជាច្រើននាក់បានព័ទ្ធគាត់ ហើយវាយដំគាត់ ។ ប្រពន្ធគាត់មិនអាចយកគាត់ទៅមន្ទីរពេទ្យដើម្បីព្យាបាលបានទេ ពីព្រោះពួកគាត់ក្រីក្រពេក ។

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៤ វេលាម៉ោង៤រសៀល លោកនី សុខរ៉ែនក៏បានស្លាប់។ ក្រុមគ្រួសារបានប្ដឹង ក្រុមប្រឹក្សាឃុំ និងនគរបាលប៉ុស្តិ៍ និង អង្គការសិទ្ធិមនុស្សអាដហុកអំពីករណីនេះ។ ការស៊ើបអង្កេតរបស់នគរបាល និងរបាយការណ៍ពេទ្យបានបញ្ជាក់ថា លោកនី សុខរ៉ែន បានទទួលរងរបួសជាច្រើនកន្លែងនៅលើរាងកាយ។ របាយការណ៍ពេទ្យក៏បានអះអាងថា មានស្នាំជាំជាច្រើនកន្លែងនៅផ្នែកក្បាលខាងក្រោយ ត្រង់សៀតផ្កា ក ទ្រូងខាងស្ដាំ ខ្នង និងនៅលើជើងខាងស្ដាំ និងខាងឆ្វេង។ មានស្នាមរបួសនៅលើពោះនិងចង្កា។ ប៉ុន្តែរបាយការណ៍នេះមិនបានលើកឡើងអំពីមូលហេតុ ដែលបណ្ដាលឱ្យមានរបួសទាំងនោះឡើយ។

លោកព្រះរាជអាជ្ញាបានទទួលការបំភ្លឺមួយពីលោកមេបញ្ជាការឈ្មោះ ស៊ុន ហេង ថា អ្នកដែលស្លាប់នោះ នៅពេលស្រវឹងបានធ្លាក់បោកក្បាលពីលើស្ពានចូលក្នុងប្រឡាយទឹកមួយ ហើយនៅពេលនោះយោធិនក៏បាន ជួយព្យាបាលដោយ "ជប់" និង "កោសខ្យល់" ឱ្យគាត់។ លោកមេបញ្ជាការនិយាយថា អ្នកដែលស្លាប់នោះបានប្រកាច់ និងពីមុនក៏ធ្លាប់មានជម្ងឺខ្មោចចូល និងអាចប្រព្រឹត្តសកម្មភាពកាចសាហាវ និងអាចរត់ចូលព្រៃផងដែរ ហើយថាស្នាមជាំ និងស្លាកស្នាមដទៃទៀតនោះ អាចកើតមានលើរាងកាយគាត់នៅពេលដែលខ្មោចចូលគាត់។ នគរបាលមិនបានធ្វើការស៊ើបអង្កេតអោយហ្មត់ចត់នោះទេ ហើយហាក់បីដូចជាយល់ស្រប ជាមួយនឹងការបកស្រាយរបស់យោធា។

នៅក្នុងការវិវត្តន៍មួយដែលគួរអោយកត់សំគាល់នោះ កាលពីថ្ងៃទី៣០ ខែធ្នូ ជនសង្ស័យ ២នាក់មានឈ្មោះ ស៊ុន ហេង និង គង់ គួយ ត្រូវបានចាប់ខ្លួនពីបទឃាតកម្មគិតទុកជាមុន តាមមាត្រា៣នៃច្បាប់ស្ដីពីស្ពានទម្ងន់ទោសនៃបទឧក្រិដ្ឋ ក្រោយមក តុលាការខេត្តក្រចេះក៏បានធ្វើការចោទប្រកាន់ពួកគេ ។ ប៉ុន្តែ នៅថ្ងៃ ទី១៨ ខែមករា ឆ្នាំ២០០៥ តុលាការបានធ្វើការលើកលែងចោទប្រកាន់ ដោយអះអាងថាគ្មានភស្តុតាង។ នគរបាលនិងតុលាការ បានសន្និដ្ឋានថា របួសទាំងឡាយនោះបានកើតមានឡើងនៅពេលដែលធ្លាក់ចុះពីលើស្ពានចូលក្នុងប្រឡាយ នៅពេលដែលគាត់ស្រវឹងស្រា ហើយស្នាកស្នាម និងស្នាមជាំនៅលើរាងកាយសាកសពជាច្រើនទៀតនោះ គឺបណ្ដាលមកពី "ការកោសខ្យល់" ។ យោងតាមរបាយការណ៍ដែលបានទទួលពីក្រុមគ្រួសារសាកសពត្រូវបានគេបង្ខំឱ្យទទួលយកសំណង និងមិនឱ្យប្ដឹងឧទ្ធរណ៍ឡើយ។

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៥ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានសរសេរលិខិតមួយច្បាប់ដាក់ជូនលោកអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ពាក់ព័ន្ធនឹងលទ្ធភាពនៃបណ្តឹងឧទ្ធរណ៍ ។ គ្មានបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើយ ។

## ឧបសម្ព័ន្ធ គ : សម័យប្រជុំលើកទីផ្ទាំបី (២០០៤) ការផ្តល់យោបល់ទូទៅលេខ៣១ : ចរិតនៃកាតព្វកិច្ចទូទៅខាងផ្លូវច្បាប់ ដែលបានដាក់អោយរដ្ឋភាគីនានាអនុវត្ត តាមកតិកាសញ្ញា*

១- ការផ្តល់យោបល់ទូទៅនេះ បានដាក់ជំនួសការផ្តល់យោបល់លេខ៣ ដែលឆ្លុះបញ្ចាំង និងពង្រីកនូវគោលការណ៍របស់ខ្លួន។ បទបញ្ញត្តិទូទៅស្តីពីការមិនរើសអើងនៃមាត្រា២ កថាខ័ណ្ឌ១ ដែលបានលើកឡើងនៅក្នុងការផ្តល់យោបល់ទូទៅលេខ១៨ និងការផ្តល់យោបល់ទូទៅលេខ២៨ ហើយការផ្តល់យោបល់ទូទៅនេះ គួរតែអានជាមួយគ្នានឹងការផ្តល់យោបល់ទូទៅទាំងនេះ។

២-កាលបើមាត្រា២ បានគូសបញ្ជាក់ពីកាតព្វកិច្ចរបស់រដ្ឋជាភាគី ចំពោះបុគ្គលគ្រប់រូបថា ជាម្ចាស់សិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញានោះ ដូច្នេះរដ្ឋភាគីនីមួយៗមានផលប្រយោជន៍ស្របច្បាប់ ក្នុងការអនុវត្តន៍កាតព្វកិច្ចរបស់ខ្លួន ដូចជារដ្ឋសមាជិកដទៃទៀតដែរ។ នេះកើតចេញពីហេតុដែលថា " វិធានទាំងឡាយដែលទាក់ទងនឹងសិទ្ធិជាមូលដ្ឋានរបស់មនុស្ស " គឺជាកាតព្វកិច្ច *erga omnes* និង ដូចដែលបានគូសបញ្ជាក់នៅក្នុងកថាខ័ណ្ឌទីបួននៃអារម្ភកថា នៃកតិកាសញ្ញា កាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ ក្នុងការលើកស្ទួយការគោរពសិទ្ធិជាសាកល និងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ ក្រៅពីនេះ វិសាលភាពកិច្ចសន្យានៃសន្ធិសញ្ញា ដែលពាក់ព័ន្ធនឹងរដ្ឋភាគី ចំពោះសន្ធិសញ្ញាដែលចាំបាច់ត្រូវអនុវត្តចំពោះរដ្ឋភាគីដទៃទៀត ដើម្បីគោរពតាមកិច្ចការរបស់ខ្លួន ស្របតាមសន្ធិសញ្ញា។ ពាក់ព័ន្ធនឹងបញ្ហានេះ គណៈកម្មាធិការសូមធ្វើការរំលឹកដល់រដ្ឋភាគីនានា ដែលមានបំណងអោយមានការយកចិត្តទុកដាក់លើមាត្រា៤១ នៃប្រកាសនេះ។ គណៈកម្មាធិការក៏បានរំលឹកថែមទៀតថា រដ្ឋភាគីទាំងនោះបានធ្វើអោយសេចក្តីប្រកាសមានតំលៃជាសក្តានុពល ដោយការបង្កើតអោយមាននីតិវិធីតាមរយៈមាត្រានេះ។ ប៉ុន្តែហេតុការណ៍តែមួយគត់ ដែលយន្តការអន្តររដ្ឋផ្លូវការមួយ សំរាប់ការដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការសិទ្ធិមនុស្សមានចំពោះរដ្ឋភាគី ដែលបានធ្វើសេចក្តីប្រកាសស្របតាមមាត្រា៤១ មិនមានន័យថា នីតិវិធីនេះ ជាវិធីតែមួយ ដែលតាមរយៈនេះ រដ្ឋភាគីអាចបញ្ជាក់ពីផលប្រយោជន៍របស់ខ្លួន ក្នុងការអនុវត្តន៍ភារកិច្ចជាមួយរដ្ឋភាគីដទៃទៀតនោះទេ។ ផ្ទុយទៅវិញ និតិវិធីនៃមាត្រា៤១ គួរត្រូវបានគេចាត់

* បានអនុម័តកាលពីថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០០៤ នាសម័យប្រជុំរបស់ខ្លួនលើទី ២១៨៧

ទុកថាជាការបន្ថែម (មិនមែនជាការកាត់បន្ថយ) ផលប្រយោជន៍របស់រដ្ឋភាគី ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកនោះឡើយ ។ អាស្រ័យហេតុនេះ គណៈកម្មាធិការសូមស្នើអោយរដ្ឋភាគីនានា ពិនិត្យលើការរំលោភសិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញា ដោយរដ្ឋភាគីណាមួយ ។ ដើម្បីទាញការចាប់អារម្មណ៍ចំពោះការរំលោភដែលអាចកើតមាន ទៅលើកាតព្វកិច្ចក្នុងកតិកាសញ្ញា ដោយរដ្ឋភាគីដទៃទៀត និងដើម្បីធ្វើការអំពាវនាវដល់រដ្ឋភាគីទាំងនោះ សូមអោយគោរពកាតព្វកិច្ចទាំងឡាយនៃអនុសញ្ញា ដោយមិនចាត់ថាជាសកម្មភាពអមិត្ត ហើយគួរតែចាត់ថាជាការឆ្លុះបញ្ចាំងអំពីផលប្រយោជន៍ស្របច្បាប់របស់សហគមន៍ទៅវិញ ។

៣- មាត្រា២ កំណត់ពីវិសាលភាពយ៉ាងច្បាស់ពីកាតព្វកិច្ចខាងផ្លូវច្បាប់ ដែលរដ្ឋភាគីត្រូវអនុវត្តតាម កតិកាសញ្ញានេះ ។ កាតព្វកិច្ចទូទៅមួយ កំណត់អោយរដ្ឋភាគីទាំងអស់ គោរពសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញា និងដើម្បីធានាសិទ្ធិទាំងនោះ ដល់បុគ្គលគ្រប់រូប នៅក្នុងទឹកដី និងស្ថិតក្រោមយុត្តាធិការរបស់ខ្លួន (សូមមើលកថាខ័ណ្ឌទី ៩ និងទី១០ ខាងក្រោម ) ។ អនុលោមតាមគោលការណ៍ ដែលមានចែងនៅក្នុងមាត្រា២៦ នៃអនុសញ្ញា ក្រុង វីយែនស្តីពីច្បាប់សន្ធិសញ្ញា តម្រូវអោយរដ្ឋភាគីទាំងអស់អនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលមានចែងនៅក្នុងកតិកាសញ្ញានេះដោយសុទ្ធចិត្ត ។

៤- កាតព្វកិច្ចនៃអនុសញ្ញាជាទូទៅ និងមាត្រា២ ជាពិសេស ចងភ្ជាប់កាតព្វិកច្ចដល់រដ្ឋភាគីនីមួយៗ ទាំងស្រុង ។ គ្រប់ស្ថាប័នរបស់រដ្ឋាភិបាល (នីតិប្រតិបត្តិ នីតិបញ្ញត្តិ និងស្ថាប័នតុលាការ ) និងអាជ្ញាធរសាធារណៈ ឬអាជ្ញាធររដ្ឋាភិបាលដទៃទៀត នៅគ្រប់ជាន់ថ្នាក់ ថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន ) មានភារកិច្ច ចូលរួមទទួលខុសត្រូវជាមួយរដ្ឋភាគី ។ ស្ថាប័ននីតិប្រតិបត្តិ ដែលជាធម្មតា ធ្វើជាតំណាងអោយរដ្ឋភាគី នៅលើឆាកអន្តរជាតិ ដោយរួមទាំង នៅចំពោះមុខគណៈកម្មាធិការ មិនអាចអោយមានសកម្មភាពណាមួយ វិសមិតភាពជាមួយបទបញ្ញត្តិនៃកតិកាសញ្ញា ដែលបានអនុវត្តដោយស្ថាប័នមួយផ្សេងទៀតរបស់រដ្ឋាភិបាល ធ្វើជាមធ្យោបាយដើម្បីអោយរួចផុតការទទួលខុសត្រូវចំពោះសកម្មភាព និងវិសមិតភាពជាយថាហេតុបានឡើយ ។ ការយល់ដឹងនេះ កើតចេញដោយផ្ទាល់ពីគោលការណ៍ ដែលមានចែងក្នុងមាត្រា២៧នៃអនុសញ្ញាក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ដែលក្នុងនោះ រដ្ឋភាគីនីមួយៗ " មិនអាចសំអាងលើបទបញ្ញត្តិនៃច្បាប់ជាតិរបស់ខ្លួនធ្វើជាលេស ចំពោះការខកខានរបស់ខ្លួន ក្នុងការអនុវត្តសន្ធិសញ្ញាណាមួយឡើយ" ។ ទោះបីជា មាត្រា២

កថាខ័ណ្ឌទី២ អនុញ្ញាតអោយរដ្ឋភាគីអនុវត្តសិទ្ធិទាំងឡាយ ដែលមានចែងក្នុងកតិកាសញ្ញានេះ ស្របទៅតាមកិច្ចដំណើរការរដ្ឋធម្មនុញ្ញចំពោះច្បាប់ជាតិ  គេប្រើប្រាស់គោលការណ៍ដូចគ្នានេះ ដើម្បីរារាំងរដ្ឋភាគីនានាកុំអោយបង្កើតបទបញ្ញត្តិ នៃច្បាប់រដ្ឋធម្មនុញ្ញ ឬទិដ្ឋភាពផ្សេងទៀតនៃច្បាប់ជាតិ ដើម្បីធ្វើជាលេស ចំពោះការខកខានមិនបានបំពេញ ឬអនុវត្តកាតព្វកិច្ចទាំងឡាយ ដែលមានចែងនៅក្នុងសន្ធិសញ្ញា ។  អាស្រ័យហេតុនេះ គណៈកម្មាធិការសូមរំលឹកដល់រដ្ឋភាគីទាំងអស់ អំពីរចនាសម្ព័ន្ធសហព័ន្ធនៃលក្ខខ័ណ្ឌក្នុង មាត្រា៥០ ដែលក្នុងនោះ បទបញ្ញត្តិនៃកតិកាសញ្ញានេះចែងថា "  ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋ សហព័ន្ធ ដោយគ្មានការកម្រិត ឬលើកលែងឡើយ ។

៥- មាត្រា២ កថាខ័ណ្ឌទី១ កាតព្វកិច្ចក្នុងការគោរព និងធានាសិទ្ធិដែលទទួលស្គាល់ដោយអនុសញ្ញា មានប្រសិទ្ធភាពអនុវត្តភ្លាម សំរាប់រដ្ឋភាគីទាំងអស់ ។ មាត្រា២ កថាខ័ណ្ឌទី២ ចែងពីក្របខណ្ឌទូលំទូលាយមួយដែលក្នុងនោះ មានការលើកស្ទួយ និងការការពារសិទ្ធិ ដែលមានចែងនៅក្នុងកតិកាសញ្ញា ។ គណៈកម្មាធិការ បានគូសបញ្ជាក់ជាយថាហេតុកន្លងមកហើយ នៅក្នុងការផ្តល់យោបល់ទូទៅលេខ២៤ ដែលជាការបំរុងទុក សំរាប់មាត្រា២ អាចមានវិសមិតភាពជាមួយនឹងកតិកាសញ្ញា កាលបើគេធ្វើការពិចារណាអំពីគោលដៅ និងគោលបំណងរបស់វា ។

៦- កាតព្វកិច្ចតាមផ្លូវច្បាប់ ក្នុងមាត្រា២ កថាខណ្ឌទី១ មានទាំងចរិតវិជ្ជមានផង និងចរិតអវិជ្ជមានផង ។ រដ្ឋភាគីត្រូវជៀសវាងការប្រព្រឹត្តរំលោភបំពានលើសិទ្ធិទាំងឡាយ ដែលបានទទួលស្គាល់ដោយកតិកាសញ្ញា ហើយការរិតត្បិតទៅលើសិទ្ធិណាមួយនោះ អាចធ្វើទៅបានលុះត្រាតែស្របតាមបទបញ្ញត្តិពាក់ព័ន្ធ នៃអនុសញ្ញានេះ ។ ប្រសិនបើមានការរិតត្បិត រដ្ឋភាគីត្រូវបង្ហាញពីភាពចាំបាច់របស់ខ្លួន ហើយការចាត់វិធានការនានាត្រូវតែសមាមាត្រទៅនឹងគោលដៅស្របច្បាប់ ដើម្បីធានាការការពារសិទ្ធិ ដែលមានចែងក្នុងកតិកាសញ្ញាប្រកបដោយនិរន្តរភាព និងប្រសិទ្ធិភាព ។ ទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ការរិតត្បិតមិនអាចប្រើប្រាស់ ឬធ្វើឡើងក្នុងលក្ខណៈដែលធ្វើអោយខូចដល់សារៈសំខាន់នៃសិទ្ធិណាមួយដែលមានចែងក្នុងកតិកាសញ្ញានេះឡើយ ។

៧- មាត្រា២ តម្រូវអោយរដ្ឋភាគីទាំងអស់អនុម័តវិធានការផ្នែកច្បាប់ តុលាការ រដ្ឋបាល អប់រំ និងវិធានការដទៃទៀត ដើម្បីអនុវត្តអោយបានពេញលេញនូវកាតព្វកិច្ចខាងផ្លូវច្បាប់របស់ខ្លួន។ គណៈកម្មាធិការជឿជាក់ថា សំខាន់ត្រូវលើកកំពស់ការយល់ដឹង អំពីកតិកាសញ្ញា មិនត្រឹមតែនៅក្នុងចំណោមមន្ត្រីសាធារណៈ និងភ្នាក់ងាររដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវលើកកំពស់ការយល់ដឹងនេះនៅក្នុងចំណោមប្រជាពលរដ្ឋទាំងមូលផង។

៨- មាត្រា២ កថាខ័ណ្ឌទី១ ចងភ្ជាប់កាតព្វកិច្ចទាំងនេះចំពោះរដ្ឋភាគីទាំងអស់ ហើយក្នុងន័យនេះ វាមិនមានឥទ្ធិពលខ្សែទទឹងដោយផ្ទាល់ទៅលើច្បាប់អន្តរជាតិឡើយ។ គេមិនអាចគិតថា កតិកាសញ្ញានេះ ជំនួសច្បាប់ជាតិ ទោះច្បាប់ព្រហ្មទ័ណ្ឌ ឬច្បាប់រដ្ឋប្បវេណីក៏ដោយ។ ទោះជាយ៉ាងណាក្តី កាតព្វកិច្ចវិជ្ជមានចំពោះរដ្ឋភាគី ក្នុងការធានាអំពីសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញា នឹងអាចអនុវត្តបានពេញលេញ លុះត្រាណាតែរដ្ឋការពារ បុគ្គលទាំងអស់ ដោយមិនត្រូវការពារត្រឹមតែមន្ត្រីរបស់ខ្លួនចំពោះការរំលោភសិទ្ធិក្នុងកតិកាសញ្ញាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវការពារបុគ្គលឯកជន ឬស្ថាប័នឯកជន ដែលបានប្រព្រឹត្តនូវអំពើឆ្គាំឆ្គងផ្សេងៗទៀតផង ហើយដែលទង្វើបែបនេះអាចធ្វើអោយខូចដល់ការទទួលបានសិទ្ធិក្នុងកតិកាសញ្ញានេះ ដើម្បីឱ្យគេអាចអនុវត្តបានចំពោះបុគ្គលឯកជន ឬស្ថាប័នឯកជន។ វាអាចមានកាលៈទេសៈខ្លះដែលក្នុងនោះ ការខកខានមិនបានធានាសិទ្ធិក្នុងកតិកាសញ្ញា ដូចក្នុងមាត្រា២បានតម្រូវស្រាប់ ហើយវាអាចនាំអោយកើតមានការរំលោភសិទ្ធិដោយរដ្ឋភាគីនានា។ នេះគឺដោយសារតែរដ្ឋភាគីបណ្តែតបណ្តោយ ឬខកខានមិនបានចាត់វិធានការផ្សេងៗ ឬមិនយកចិត្តទុកដាក់ទាន់ពេលវេលា ដើម្បីធ្វើការទប់ស្កាត់ ការផ្តន្ទាទោស ការស៊ើបអង្កេត ឬការកែខៃ នូវគ្រោះថ្នាក់ដែលបង្ករឡើងដោយទង្វើរបស់បុគ្គលឯកជន ឬស្ថាប័នឯកជន។ គណៈកម្មាធិការសូមរំលឹកដល់រដ្ឋភាគីទាំងអស់ អំពីទំនាក់ទំនងគ្នារវាងកាតព្វកិច្ចវិជ្ជមាន ដែលបានកំណត់នៅក្នុងមាត្រា២ និងសេចក្តីត្រូវការអោយមានការដោះស្រាយប្រកបដោយប្រសិទ្ធិភាព ក្នុងករណីមានការរំលោភលើមាត្រា២ កថាខ័ណ្ឌទី៣ នៃកតិកាសញ្ញានេះ។ កតិកាសញ្ញាខ្លួនវាផ្ទាល់ គ្រោងទុកជាមុនក្នុងមាត្រាខ្លះ និងក្នុងផ្នែកមួយចំនួន ដែលរដ្ឋភាគីទាំងអស់មានកាតព្វកិច្ចជាវិជ្ជមានក្នុងការលើកឡើងនូវសកម្មភាពនានា របស់បុគ្គលឯកជន ឬស្ថាប័នឯកជន។ ឧទាហរណ៍ ការធានាការពារសិទ្ធិឯកជននៃមាត្រា១៧ ត្រូវតែការពារដោយច្បាប់។ ក្រៅពីនេះក៏មានបញ្ជាក់ន័យផងដែរ នៅក្នុងមាត្រា៧ថា រដ្ឋភាគីទាំងអស់ ត្រូវតែចាត់វិធានការវិជ្ជមាន ដើម្បីធានាថា បុគ្គលឯកជន ឬស្ថាប័ន

ឯកជនមិនធ្វើទារុណកម្ម និងដាក់ទណ្ឌកម្ម ឬប្រព្រឹត្តអំពើឃោឃៅ អមនុស្សធម៌ ឬធ្វើអោយបាត់តំលៃជាមនុស្សទៅលើអ្នកដទៃ នៅក្នុងអំណាចរបស់ខ្លួន ។ នៅក្នុងវិស័យទាំងឡាយ ដែលប៉ះពាល់ដល់ទិដ្ឋាភាពជាមូលដ្ឋាន នៃជីវិតរស់នៅធម្មតា ដូចជាការងារ ឬគេហកិច្ចបុគ្គលគ្រប់រូប ត្រូវបានការពារមិនអោយមានការរើសអើង ស្ថិតក្នុងអត្ថន័យនៃ មាត្រា២៦ របស់ កតិកាសញ្ញានេះ ។

៩- ជនគ្រប់រូប គឺជាអ្នកដែលទទួលបាននូវសិទ្ធិនានា ដូចកតិកាសញ្ញានេះបានទទួលស្គាល់ស្រាប់ ។ ទោះជាមានការលើកលែងពីមាត្រា១ ក្តី ក៏កតិកាសញ្ញានេះមិនបានរៀបរាប់អំពីសិទ្ធិរបស់នីតិបុគ្គល ឬ រូបវន្តបុគ្គល ឬសមូហភាពប្រហាក់ប្រហែលនេះឡើយ ។ កតិកាសញ្ញានេះ ទទួលស្គាល់នូវសិទ្ធិជាច្រើន ដូចជា   សេរីភាពក្នុងការកាន់សាសនា ឬជំនឿរបស់ខ្លួន (មាត្រា១៨) សិទ្ធិចូលរួមជាសមាគម  (មាត្រា២២) ឬសិទ្ធិរបស់សមាជិកជនភាគតិច  (មាត្រា២៧) ដែលអាចប្រើប្រាសជាមួយសិទ្ធិដទៃទៀត ។  ការដែលគណៈកម្មាធិការមានសម្ថកិច្ច ទទួលនិងពិនិត្យបណ្តឹង ត្រូវបានហាមឃាត់ចំពោះបណ្តឹងទាំងឡាយណាដែលដាក់ស្នើឡើងដោយបុគ្គល ឬក្នុងនាមបុគ្គល (មាត្រា១ នៃពិធីសារបន្ថែម (លើកទីមួយ) មិនបានរារាំងបុគ្គល ប្តឹងតវ៉ាថាទង្វើរ ឬការខកខាន របស់នីតិបុគ្គលពាក់ព័ន្ធ និងស្ថាប័នប្រហាក់ប្រហែល នាំអោយមានការរំលោភលើសិទ្ធិរបស់ខ្លួន ។

១០- មាត្រា២ កថាខណ្ឌទី១ តម្រូវអោយរដ្ឋភាគីគោរព និងធានាការពារសិទ្ធិទាំងឡាយ ដែលមានចែងក្នុងកតិកាសញ្ញា ចំពោះបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដីរបស់ខ្លួន និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។ នេះមានន័យថា រដ្ឋភាគីមួយត្រូវតែគោរព និងធានាការពារសិទ្ធិ ដែលមានចែងនៅក្នុងកតិកាសញ្ញា ចំពោះជនណាម្នាក់ដែលស្ថិតក្នុងអំណាច ឬក្រោមការត្រួតត្រាផ្ទាល់របស់រដ្ឋភាគីនោះ ទោះបីជាបុគ្គលនោះមិនរស់នៅក្នុងទឹកដីនៃរដ្ឋភាគីក៏ដោយ ។ ដូចបានគូសបញ្ជាក់នៅក្នុងការផ្តល់យោបល់ទូទៅលេខ ១៥ ដែលបានអនុម័ត នៅក្នុងសម័យប្រជុំលើកទីម្ភៃប្រាំពីរ (១៩៨៦) ការប្រើប្រាស់សិទ្ធិដែលមានចែងក្នុងកតិកាសញ្ញា មិនមានកំណត់ចំពោះតែប្រជាពលរដ្ឋ នៃរដ្ឋភាគីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំរាប់បុគ្គលគ្រប់រូប ដោយមិនគិតពីជាតិសាសន៍ ភាពគ្មានរដ្ឋ ដូចជាអ្នកស្វែងរកសិទ្ធិជ្រកកោន ជនភៀសខ្លួន កម្មករអន្តោប្រវេសន៍ និងបុគ្គលដទៃទៀត ដែលយល់ថាខ្លួនស្ថិតនៅក្នុងទឹកដី ឬស្ថិតក្រោមយុត្តាធិការរបស់រដ្ឋភាគី នោះ ។ គោលការណ៍នេះក៏អនុវត្តផងដែរ ចំពោះបុគ្គលទាំងឡាយដែលមានអំណាច ឬការគ្រប់គ្រងផ្ទាល់ លើកំលាំង

ប្រដាប់អាវុធរបស់រដ្ឋមួយ ហើយកំពុងបំពេញភារកិច្ច នៅក្រៅទឹកដីរបស់ខ្លួន ដោយមិនគិតពីកាលៈទេសៈ ដែលអំណាច ឬការគ្រប់គ្រងនេះទទួលបានតាមវិធីណាមួយឡើយ ដូចជាកំលាំង ដែលបង្កើតបានជាកងទ័ព ជាតិរបស់រដ្ឋមួយ ដែលត្រូវបានបញ្ជូលទៅធ្វើការជាមួយនឹងប្រតិបត្តិការរក្សាសន្តិភាព ឬប្រតិបត្តិការពង្រឹង សន្តិភាពអន្តរជាតិ ។

១១- ដូចបានគូសបញ្ជាក់នៅក្នុងការផ្តល់យោបល់ទូទៅលេខ២៩១ កតិកាសញ្ញានេះក៏អនុវត្តផងដែរ នៅ ក្នុងស្ថានភាពដែលមានជំលោះប្រដាប់អាវុធ ដែលក្នុងនោះ វិធាននៃច្បាប់មនុស្សធម៌អន្តរជាតិត្រូវគេយក មកអនុវត្ត ។ ពាក់ព័ន្ធនឹងសិទ្ធិកតិកាសញ្ញា មានវិធានជាក់លាក់មួយចំនួននៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលទាក់ទងជាពិសេស ចំពោះគោលបំណងនៃការបកស្រាយសិទ្ធិកតិកាសញ្ញា វិស័យច្បាប់ទាំងពីរគឺ សំរាប់បំពេញបន្ថែម មិនមែននៅដាច់ដោយឡែកពីគ្នានោះទេ ។

១២- ម្យ៉ាងទៀត កាតព្វកិច្ចក្នុងមាត្រា២ តម្រូវអោយរដ្ឋភាគីគោរព និងធានាការពារសិទ្ធិកតិកាសញ្ញា របស់ជនគ្រប់រូបនៅក្នុងទឹកដី និងក្រោមការត្រួតត្រារបស់ខ្លួន មានកាតព្វកិច្ចមិនធ្វើបត្យាប័ន នីរទេស បញ្ជូន បណ្តេញ ឬនាំជនណាម្នាក់ចេញពីទឹកដីរបស់ខ្លួន ។ កាលបើមានមូលហេតុច្រើនដែលអាចជឿថា នឹង នាំអោយមានហានិភ័យពិតប្រាកដ ដែលមិនអាចកែខៃបាន ដូចបានសង្កេតឃើញនៅក្នុងមាត្រា៦ និង មាត្រា៧ នៃកតិកាសញ្ញានេះ មិនថានៅក្នុងប្រទេសដែលបញ្ជូនជននោះចេញ ឬក្នុងប្រទេសដែលទទួល ជននោះទេ ។ អាជ្ញាធររដ្ឋបាល និងអាជ្ញាធរតុលាការពាក់ព័ន្ធ ត្រូវដឹងពីសេចក្តីត្រូវការ ដើម្បីធានាការ អនុវត្តន៍កាតព្វកិច្ច កតិកាសញ្ញា នៅក្នុងបញ្ហាទាំងនេះ ។

១៣- មាត្រា២ កថាខ័ណ្ឌទី២ តម្រូវឱ្យរដ្ឋភាគីចាត់វិធានការចាំបាច់ ដើម្បីអនុវត្តសិទ្ធិកតិកាសញ្ញា តាម របៀបរបបក្នុងស្រុក ។ ចំណុចនេះមានន័យថា ប្រសិនបើច្បាប់និងការអនុវត្តក្នុងស្រុករបស់ខ្លួនមិនទាន់បាន ការពារសិទ្ធិកតិកាសញ្ញាទេនោះ រដ្ឋភាគីត្រូវផ្តល់សច្ចាប័ន ដើម្បីធ្វើការកែប្រែច្បាប់ ឬការអនុវត្តន៍ក្នុង ស្រុក តាមការចាំបាច់ ដើម្បីធានាឱ្យច្បាប់ ឬការអនុវត្តន៍ទាំងនោះ ស្របទៅនឹងកតិកាសញ្ញានេះ ។ ក្នុង ករណីមិនមានភាពស្របគ្នា រវាងច្បាប់ជាតិ និងកតិកាសញ្ញាទេ មាត្រា២ តម្រូវឱ្យធ្វើកាកែប្រែច្បាប់ ឬកែប្រែការអនុវត្តន៍ក្នុងស្រុក ដើម្បីឱ្យស្របទៅនឹងនិយាម ដែលបានធានាដោយកតិកាសញ្ញា ។ មាត្រា២

អនុញ្ញាត ឱ្យរដ្ឋភាគីបន្តអនុវត្តកាតព្វកិច្ចនេះ ស្របតាមរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញក្នុងស្រុករបស់ខ្លួន។ អាស្រ័យហេតុនេះ គឺមិនចាំបាច់យកកតិកាសញ្ញានេះ ទៅអនុវត្តដោយផ្ទាល់នៅក្នុងតុលាការទេ ដោយគ្រាន់តែបញ្ចូលកតិកាសញ្ញានេះទៅក្នុងច្បាប់ជាតិនោះគឺជាការស្រេច។ គណៈកម្មាធិការប្រកាន់យកទស្សនៈនេះ ប៉ុន្តែទោះជាដូច្នេះក្តី ការធានារបស់កតិកាសញ្ញាអាចទទួលបាននូវការការពារប្រសើរឡើងថែមទៀត នៅក្នុងរដ្ឋភាគីទាំងនេះ ប្រសិនបើយកកតិតាសញ្ញានេះទៅអនុវត្តដោយស្វ័យប្រវត្តិ ឬតាមរយៈការបញ្ចូលទៅក្នុងផ្នែកណាមួយនៃច្បាប់ជាតិ។ គណៈកម្មាធិការសូមអញ្ជើញរដ្ឋភាគីទាំងឡាយណា ដែលមិនទាន់បានបញ្ចូលកតិកាសញ្ញានេះទៅក្នុងផ្នែកណាមួយនៃច្បាប់ជាតិទេនោះ សុំឱ្យគិតគូពិចារណា បញ្ចូលកតិកាសញ្ញានេះ ជាផ្នែកមួយនៃច្បាប់ជាតិ ដើម្បីសំរួលដល់ការទទួលបានយ៉ាងពេញលេញ នូវសិទ្ធិកតិកាសញ្ញា ដូចបានតម្រូវដោយមាត្រា២។

១៤- សេចក្តីតម្រូវនៅក្នុងមាត្រា២ កថាខ័ណ្ឌទី២ ឱ្យចាត់វិធានការអនុវត្តសិទ្ធិកតិកាសញ្ញាជាបន្ទាន់ និងជាស្ថាពរ។ ការខកខានមិនបានគោរពកាតព្វកិច្ចនេះ មិនអាចយកមកធ្វើលេស ដោយយោងលើបញ្ហានយោបាយ សង្គម វប្បធម៌ ឬ សេដ្ឋកិច្ច ក្នុងប្រទេសបានឡើយ។

១៥- មាត្រា២ កថាខ័ណ្ឌទី៣ តម្រូវថា ក្រៅពីការការពារសិទ្ធិកតិកាសញ្ញាប្រកបដោយប្រសិទ្ធិភាព រដ្ឋភាគីត្រូវធានាឱ្យបុគ្គលគ្រប់រូបមានសិទ្ធិ និងទទួលបានការដោះស្រាយដ៏មានប្រសិទ្ធិភាព ដើម្បីការពារសិទ្ធិទាំងនោះ។ ការដោះស្រាយនេះ គួតែធ្វើឱ្យបានសមស្រប ដោយត្រូវគិតគូ ពីភាពងាយរងគ្រោះពិសេសនៃក្រុមមនុស្សមួយចំនួន ជាពិសេសគឺកុមារ។ គណៈកម្មាធិការបង្ហាញពីសារៈសំខាន់របស់រដ្ឋភាគីក្នុងការបង្កើតយន្តការរដ្ឋបាល និងតុលាការមានសមត្ថកិច្ច ដើម្បីដោះស្រាយបណ្តឹងអំពីការរំលោភសិទ្ធិនៅក្នុងច្បាប់ជាតិ។ គណៈកម្មាធិការកត់សំគាល់ថា ការប្រើប្រាស់សិទ្ធិ ដែលកតិកាសញ្ញាបានទទួលស្គាល់អាចត្រូវបានធានាការពារយ៉ាងមានប្រសិទ្ធិភាពដោយតុលាការ តាមវិធីផ្សេងៗជាច្រើន ក្នុងនោះរួមមាន ការអនុវត្តន៏កតិកាសញ្ញាដោយផ្ទាល់ ការអនុវត្តន៏ច្បាប់ធម្មនុញ្ញប្រៀបធៀប ឬបទបញ្ញត្តិច្បាប់ដទៃទៀត ឬការបកស្រាយកតិកាសញ្ញា ក្នុងការអនុវត្តន៏ច្បាប់ជាតិ។ យន្តការរដ្ឋបាល តម្រូវជាពិសេសឱ្យអនុវត្តកាតព្វកិច្ចទូទៅ ក្នុងការស៊ើបអង្កេតលើបទចោទប្រកាន់ពីការរំលោភភ្លាមៗទាំងស្រុង និងប្រកបដោយប្រសិទ្ធិភាព តាមរយៈស្ថាប័នទាំងឡាយ ដែលឯករាជ្យនិងមិនលំអៀង។ ត្រូវផ្តល់អំណាចសម

ស្របឱ្យស្ថាប័នសិទ្ធិមនុស្សជាតិ ដើម្បីឱ្យស្ថាប័ននេះអាចសំរេចគោលដៅនេះបាន។ ការខកខានដោយរដ្ឋភាគីណាមួយក្នុងការអង្កេតលើបទចោទប្រកាន់ពីការរំលោភសិទ្ធិ អាចនិងដោយខ្លួនឯងផ្ទាល់ដែលនាំឱ្យមានការរំលោភដាច់ដោយឡែកមួយទៅ លើកតិកសញ្ញា។ ការបញ្ចប់អំពើរំលោភតទៅទៀត គឺជាកត្តាមួយដ៏សំខាន់នៃសិទ្ធិទទួលបានការដោះស្រាយ ប្រកបដោយប្រសិទ្ធភាព។

១៦- មាត្រា២ កថាខ័ណ្ឌទី៣ តម្រូវឱ្យរដ្ឋភាគីជួសជុលការខូចខាត ដល់ជនទាំងឡាយ ដែលគេរំលោភសិទ្ធិខ្លួនក្នុងកតិកាសញ្ញា។ ការមិនបានជួសជុលការខូចខាតដល់ជនដែលត្រូវគេរំលោភសិទ្ធិខ្លួនក្នុងកតិកាសញ្ញាកាតព្វកិច្ចក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធិភាព ដែលសំខាន់ចំពោះប្រសិទ្ធិភាពនៃមាត្រា២កថាខ័ណ្ឌ ទី៣ មិនត្រូវបានគេអនុវត្ត។ ក្រៅពីការជូសជុលជាក់ស្តែង ដែលមាត្រា៩ កថាខ័ណ្ឌទី៥ និងមាត្រា១៤ កថាខ័ណ្ឌទី៦ បានតម្រូវគណៈកម្មាធិការយល់ថា ជាទូទៅកតិកាសញ្ញាតម្រូវឱ្យផ្តល់សំណងឱ្យបានសមស្រប។ គណៈកម្មាធិការកត់សំគាល់ថា ប្រសិនជាអាចធ្វើទៅបាន ការជួសជុលអាចជាការធ្វើឱ្យដូចដើមឡើងវិញ ការស្តារសម្បទា និងការថ្លឹងថ្លែងពីភាពពេញចិត្ត ដូចជាការសុំខមាលទោសជាសាធារណៈ វិធីរំឭកជាសាធារណៈ ការសន្យាថានឹងមិនប្រព្រឹត្តតទៅទៀត និងការកែប្រែនៅក្នុងច្បាប់ និងការអនុវត្តដែលពាក់ព័ន្ធ ក៏ដូចជាការនាំខ្លួនចារីនៃអំពើរំលោភសិទ្ធិមនុស្ស ទៅតុលាការដើម្បីធ្វើការជំនុំជំរះ។

១៧- ជាទូទៅ គោលបំណងនៃកតិកាសញ្ញា នឹងត្រូវបរាជ័យ ប្រសិនជាគ្មានកាតព្វកិច្ចជាមូលដ្ឋាន ចំពោះមាត្រា២ ក្នុងការចាត់វិធានការនានា ដើម្បីទប់ស្កាត់មិនឱ្យកើតមានការរំលោភកតិកាសញ្ញា។ អាស្រ័យហេតុនេះ គណៈកម្មាធិការបានអនុវត្តជារឿយៗ ក្នុងករណីជាច្រើន ក្រោមពិធីសារបន្ថែម ដើម្បីបញ្ចូលទៅក្នុងទស្សនៈរបស់វា នូវសេចក្តីត្រូវការសំរាប់វិធានការនានា លើសពីការដោះស្រាយជាក់លាក់ណាមួយចំពោះជនរងគ្រោះ ដែលត្រូវចាត់ឡើង ដើម្បីជៀសវាងការកើតមានអំពើរំលោភ។ វិធានការទាំងនេះតម្រូវឱ្យមានការកែប្រែច្បាប់ ឬការអនុវត្តន៏នៅក្នុងរដ្ឋភាគី។

១៨- ប្រសិនបើការស៊ើបអង្កេត ដូចបានរៀបរាប់នៅក្នុងកថាខ័ណ្ឌទី១៥ បង្ហាញឱ្យឃើញពីអំពើរំលោភសិទ្ធិមួយចំនួនក្នុងកតិកាសញ្ញា រដ្ឋភាគីត្រូវធានាថា ជនទាំងឡាយដែលទទួលខុសត្រូវ ត្រូវបាននាំខ្លួនទៅ

តុលាការ ដើម្បីវិនិច្ឆ័យទោសតាមច្បាប់ ។ ចំពោះការខកខាន ក្នុងការស៊ើបអង្កេត ការខកខានមិនបាននាំខ្លួនចារីនៃអំពើរំលោភនេះ អាចនិងដោយខ្លួនឯងផ្ទាល់នាំឱ្យមានការរំលោភដាច់ដោយឡែកមួយទៅលើកតិកាសញ្ញា ។ កាតព្វកិច្ចទាំងនេះ កើតមានជាពិសេស ចំពោះអំពើរំលោភទាំងឡាយ ដែលគេចាត់ជាបទព្រហ្មទណ្ឌ ដែលស្ថិតនៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ដូចជាការ ធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅអមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តំលៃជាមនុស្ស (មាត្រា៧) ការសំលាប់មនុស្សក្រៅច្បាប់ និងតាមទំនើងចិត្ត (មាត្រា៦) និងការបាត់ខ្លួនដោយបង្ខំ (មាត្រា៧ និងមាត្រា៩ ហើយភាគច្រើនក្នុងមាត្រា៦) ។ ជាការពិតណាស់ បញ្ហានិទណ្ឌភាពចំពោះអំពើរំលោភទាំងនេះ គឺជាបញ្ហាមួយដែលគណៈកម្មាធិការនៅតែមានការព្រួយបារម្ភ វាអាចជាកត្តាមួយដ៏សំខាន់ រួមចំណែកដល់ការកើតមានអំពើរំលោភ ។ កាលបើវាជាផ្នែកមួយនៃការរីករាលដាល ឬការវាយប្រហារឥតមានរើសមុខ លើជនស៊ីវិល  ការរំលោភលើកតិកាសញ្ញានេះ គឺជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ (សូមមើលលក្ខន្តិកៈក្រុងរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ  មាត្រា៧) ។

ដូច្នោះហើយ ប្រសិនបើមន្ត្រីសាធារណៈ ឬភ្នាក់ងាររដ្ឋប្រព្រឹត្តរំលោភលើសិទ្ធិកតិកាសញ្ញា ដូចបានរៀបរាប់នៅក្នុងកថាខ័ណ្ឌនេះ រដ្ឋភាគីពាក់ព័ន្ធមិនអាចសំរាលឱ្យជនល្មើសរួចផុតពីការទទួលខុសត្រូវផ្ទាល់ខ្លួនបានឡើយ ដូចជាការលើកលែងទោសមួយចំនួន (សូមមើលការផ្តល់យោបល់ទូទៅលេខ២០  (៤៤)) និងអភ័យឯកសិទ្ធិ និងសំណងខាងផ្លូវច្បាប់ជាមុន ។ ម្យ៉ាងទៀត គេមិនអាចលើកសំអាងពីឋានៈផ្លូវការរបស់ជន ដែលត្រូវបានចោទប្រកាន់ពីការទទួលខុសត្រូវចំពោះអំពើរំលោភ ថាមានអភ័យឯកសិទ្ធិរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់បានឡើយ ។ ឧបសគ្គដទៃទៀត ចំពោះការបង្កើតការទទួលខុសត្រូវតាមផ្លូវច្បាប់គួរតែដកចេញ  ដូចជាការការពារដោយសារការគោរពបញ្ជារបស់ចៅហ្វាយនាយ ឬអាជ្ញាយុកាលរយៈពេលខ្លីពេក ក្នុងករណីដែលអាជ្ញាយុកាលនេះអាចអនុវត្តបាន ។ រដ្ឋភាគីទាំងអស់ គួរជួយគ្នាទៅវិញទៅមក ក្នុងការនាំខ្លួនជនសង្ស័យដែលបានប្រព្រឹត្តអំពើរំលោភលើកតិកាសញ្ញានេះ ទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ។

១៩- គណៈកម្មាធិការពិនិត្យឃើញថា សិទ្ធិក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធិភាព ក្នុងកាលៈទេសៈណាមួយ គេអាចតម្រូវឱ្យរដ្ឋភាគីថែង និងអនុវត្តវិធានការបណ្តោះអាសន្ន ឬក្នុងចន្លោះណាមួយ

ដើម្បីបញ្ចៀស កុំឱ្យមានការរំលោភនេះតទៅទៀត និងព្យាយាមកែខែសភាពការណ៍តាមដែលអាចធ្វើទៅបាន នៅមុនពេលឱកាសគ្រោះថ្នាក់ ដោយអំពើរំលោភនេះអាចកើតមាន។

២០- ទោះជាប្រព័ន្ធច្បាប់របស់រដ្ឋភាគី បាននិងកំពុងព្យាយាមដោះស្រាយឱ្យបានសមស្របក្តី ក៏ការរំលោភសិទ្ធិកតិកាសញ្ញានៅតែកើតមាននៅឡើយ។ នេះបង្ហាញឱ្យឃើញពីភាពបរាជ័យនៃការដោះស្រាយ ចំពោះប្រសិទ្ធភាពក្នុងការអនុវត្តជាក់ស្តែង។ ដោយហេតុនេះ គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគីទាំងអស់ផ្តល់ព័តិមានអំពីឧបសគ្គដែលកើតមានចំពោះប្រសិទ្ធិភាពនៃការដោះស្រាយកន្លងមក នៅក្នុងរបាយការណ៍តាមកាលកំណត់របស់ខ្លួន។